# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងអប់រំ យុវជន និងកីឡា

## សៀវភៅសិក្សា

# កិច្ចតែងការបង្រៀនបញ្ជ្រាប

# ការអប់រំភាពជាពលរដ្ឋសកល

## GCED INTEGRATED LESSON PLANS

មជ្ឈមណ្ឌលសហប្រតិបត្តិការការអប់រំភាពជាពលរដ្ឋសកល

GCC-CAMBODIA 2023

ការបោះពុម្ពលើកទី១

## មាតិការ ទំព័រ


**មុខវិជ្ជាប្រវត្តវិទ្យា**

| | | |
|---|---|---|
| ១ | ការខូចខាតដោយសារសង្គ្រាមស៊ីវិលនៅកម្ពុជា និងផលវិបាក | ១ |
| ២ | ផលវិបាកនៃសង្គ្រាមលោកលើកទី២ | ៨ |
| ៣ | ព្រឹត្តិការណ៍សំខាន់ៗនៅតំបន់មជ្ឈឹមបូព៌ា | ១៤ |
| | **មុខវិជ្ជាសិល្បៈ** | |
| ៤ | របាំនេសាទ | ២០ |
| ៥ | រចនាខ្លែង (បេតិកភណ្ឌវប្បធម៌អរូបីយ៍) | ២៦ |
| | **មុខវិជ្ជាអក្សរសាស្ត្រខ្មែរ** | |
| ៦ | រឿង ទុំទាវ (នំមិនធំជាងនាឡិ) | ២៩ |
| | **មុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា** | |
| ៧ | តម្លៃ និងសីលវិជ្ជា | ៣៤ |
| ៨ | រដ្ឋាភិបាល | ៣៩ |
| ៩ | បញ្ញា | ៤៥ |
| | **មុខវិជ្ជាចិត្តវិទ្យាអប់រំ** | |
| ១០ | ការគិតស៊ីជម្រៅ II | ៦០ |
| | **មុខវិជ្ជាគរុកោសល្យ** | |
| ១១ | គោលការណ៍នៃការបង្រៀន | ៧៤ |
| | **មុខវិជ្ជាភូមិវិទ្យា** | |
| ១២ | ផលអាក្រក់នៃការរំខានដោយសំឡេងនិងកិច្ចការពារ | ៨១ |
| | **មុខវិជ្ជាផែនដី និងបរិស្ថានវិទ្យា** | |
| ១៣ | ការធ្វើចំណាត់សិលាកម្ទេចកំណ | ៨៨ |
| | **មុខវិជ្ជាសេដ្ឋកិច្ច** | |
| ១៤ | ការត្រួតពិនិត្យលើការងារ និងអតិផរណា | ៩៥ |
| | **មុខវិជ្ជាគេហវិទ្យា** | |
| ១៥ | វិធីធ្វើបង្អែមបបរត្នោត | ៩៩ |
| | **មុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍** | |
| ១៦ | ព័ត៌មាន ទំនាក់ទំនង និងបច្ចេកវិទ្យា(ផ្អែកទី១១) | ១០៦ |
| ១៧ | ការប្រើប្រាស់អ៊ីនធឺណិត និងបង្កើតអ៊ីម៉ែល | ១១០ |
| | **មុខវិជ្ជាក្សេត្រសាស្ត្រ** | |
| ១៨ | រូបសាស្ត្រនៃដី | ១១៦ |

**មុខវិជ្ជាអេឡិចត្រូនិក**
១៩ ភាពជាពលរដ្ឋសកលក្នុងវិស័យអេឡិចត្រូនិក ១២៣
**មុខវិជ្ជាជីវវិទ្យា**
២០ ទិវាទឹកស្អាតពិភពលោក ១៣១
**មុខវិជ្ជាភាសាអង់គ្លេស**
២១ Funerals ១៤៣
**មុខវិជ្ជាភាសាបារាំង**
២២ Au restaurant en mettant GCED ១៥០
**មុខវិជ្ជាមេកានិក**
២៣ សុវត្ថិភាពការងារផ្សារអគ្គិសនី ១៥៦
**មុខវិជ្ជាគណិតវិទ្យា**
២៤ សំណុំ ១៦៧
២៥ ការប្រើអនុគមន៍ដើម្បីដោះស្រាយបញ្ហា ១៧១
**មុខវិជ្ជាគីមីវិទ្យា**
២៦ កត្តាជះឥទ្ធិពលលើល្បឿនប្រតិកម្ម (ស៊ីនេទិចគីមី) ១៧៨
២៧ ថ្មពិលអេឡិចត្រូគីមី ១៩០
**មុខវិជ្ជាកែច្នៃអាហារ**
២៨ ការថែរក្សាអាហារដោយប្រើប្រាស់ Nitrite និង Nitrate ២០០
**មុខវិជ្ជាស្រាវជ្រាវអប់រំ**
២៩ ការជ្រើសរើសប្រធានបទ និង ការដាក់សំណើស្រាវជ្រាវ ២០៦
**មុខវិជ្ជារូបវិទ្យា**
៣០ កំលាំងកកិត ២១២
**ឧបសម្ព័ន្ធ**
លិខិតឧទ្ទេសនាមលេខ ៦៦១៨ អយក.ឧទន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ ២២៦

**គណៈកម្មការបច្ចេកទេស**

| | | |
|---|---|---|
| ១. ឯកឧត្តម | ពុត សាមិត្ត | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ២.ឯកឧត្តម | អ៊ុង ជិនណា | អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ |
| ៣.ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | នាយកវិទ្យាស្ថានជាតិអប់រំ |

**គណៈកម្មការនិពន្ធ**

| | | |
|---|---|---|
| ១. លោក | ឌី បុណ្ណា | នាយករងវិទ្យាស្ថានជាតិអប់រំ |
| ២. លោកបណ្ឌិត | នូវ វីរ៉ា | នាយករងវិទ្យាស្ថានជាតិអប់រំ |
| ៣. លោកស្រី | ប៊ុន សុផានី | នាយិការងវិទ្យាស្ថានជាតិអប់រំ |
| ៤. លោក | ថៃ ហោង | នាយករងវិទ្យាស្ថានជាតិអប់រំ |
| ៥. លោកបណ្ឌិត | ម៉ម ចាន់សៀន | អនុប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ |

...............

..............

សិក្ខាកាម+គ្រូឧទ្ទេសដែលបានរៀបចំកិច្ចតែងការបង្រៀន (លិខិតឧទ្ទេសនាមលេខ ៦៦១៨ អយក.ឧទន ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០២៣។

# ប្រធានបទ៖ ការខូចខាតដោយសារសង្គ្រាមស៊ីវិលនៅកម្ពុជា និងផលវិបាក

ជា កល្យាណ ទី សុផល ចាប រតនា ហង់ ស្រីម៉ាច
វិទ្យាស្ថានជាតិអប់រំ

- កាលបរិច្ឆេទ ៖ ថ្ងៃទី................ខែ..............ឆ្នាំជូត ទោស័កព.ស ២៥៦...
  ត្រូវនឹងថ្ងៃទី..........ខែ..............ឆ្នាំ២០២...
- មុខវិជ្ជា ៖ ប្រវត្តិវិទ្យា ថ្នាក់ទី១២
- ជំពូកទី២ ៖ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា
- មេរៀនទី៣ ៖ សម័យសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥)
- ប្រធានបទ ៖ ការខូចខាតដោយសារសង្គ្រាមស៊ីវិលនៅកម្ពុជា និងផលវិបាក
- រយៈពេល ៖ ១ម៉ោង (៥០នាទី)

## I- វត្ថុបំណង

ក្រោយពីរៀនចំណុចនេះចប់សិស្សមានសមត្ថភាព៖

- **វិជ្ជាសម្បទា :** ពណ៌នាពីផលវិបាកនៃសង្គ្រាមនៅកម្ពុជា អំឡុងឆ្នាំ១៩៧០-១៩៧៥ បានត្រឹមត្រូវ តាមរយៈការសង្កេតរូបភាព។
- **បំណិនសម្បទា :** វិភាគពីផលប៉ះពាល់នៃសង្គ្រាមលើវិស័យនយោបាយ សង្គម សេដ្ឋកិច្ច ក្នុងរបបសាធារណរដ្ឋខ្មែរ បានច្បាស់លាស់ តាមរយៈការ**អនុវត្តសកម្មភាព** Museum Walks។
- **ចរិយាសម្បទា :** បណ្តុះស្មារតី ក្នុងការធ្វើការងារ ឬ ការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព ការទទួលខុសត្រូវ នៅថ្នាក់មូលដ្ឋាន ជាតិ និងពិភពលោក ដែលប្រកបដោយសន្តិភាព និងនិរន្តរភាព។ (GCED)

## II- ខ្លឹមសារមេរៀន

- ប្រវត្តិសាស្ត្រខ្មែរ
- របបសាធារណរដ្ឋខ្មែរ
- ប្រធានបទ/សិក្សាបញ្ញត្តិ: ការខូចខាតដោយសារសង្គ្រាមស៊ីវិលនៅកម្ពុជា និងផលវិបាក

## II- សម្ភារៈបង្រៀន

- ឯកសារ ឬ សៀវភៅក្រៅពីសៀវភៅសិក្សាគោល
- សៀវភៅសិក្សាគោល : បោះពុម្ពឆ្នាំ២០១៥ ទំព័រ១៩៤០ ដល់១៤១

- ទី សុផល(២០១៩), ប្រវត្តិសាស្ត្រខ្មែរ(ប្រើប្រាស់ផ្ទៃក្នុងវិទ្យាស្ថានជាតិអប់រំ)
- ក្រដាសA4 ហ្វីត ស្កុត ក្រដាសកាតុង
- រូបភាព(សង្គ្រាមត្រជាក់......)។

## IV- **វិធីសាស្ត្របង្រៀន**

- វិធីសាស្ត្របង្រៀនបែបចម្រុះ ដោយបញ្ជ្រាប5Es
- ការបញ្ជ្រាបGCED : បញ្ជ្រាបតាមរយៈការកំណត់នូវ វត្ថុបំណងមេរៀន, ការពិភាក្សាក្រុម ដោយ សិស្សចេះធ្វើការងារជាក្រុម ដើម្បីរកដំណោះស្រាយរួមគ្នា និងប្រើប្រាស់សំណួរពង្រីកគំនិត ដោយបញ្ចូលនូវទស្សនៈនៃការអប់រំភាពជាពលរដ្ឋសកល។

## IV. **ដំណើរការមេរៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| | ជំហានទី១៖ រដ្ឋបាលថ្នាក់(៣នាទី) | |
| - ពិនិត្យអវត្តមាន<br>- អនាម័យ<br>- សណ្ដាប់ធ្នាប់ក្នុងថ្នាក់រៀន | ប្រមូលអារម្មណ៍សិស្សដើម្បីរៀន<br>បញ្ជ្រាប GCED | - សម្អាតថ្នាក់រៀន<br>-ប្រធានថ្នាក់រាយការណ៍អវត្តមាន<br>-ត្រៀមខ្លួនសម្រាប់រៀនមេរៀនថ្ងៃនេះ |
| | ជំហានទី២៖ រំលឹកមេរៀនចាស់ (៧នាទី) | |
| | ទាញចំណាប់អារម្មណ៍ | |
| **បង្កើតសកម្មភាព**<br>-គ្រូបង្កើតការចាប់អារម្មណ៍<br>-តើរូបភាពនេះឆ្លុះបញ្ចាំងពីទស្សនៈអ្វីខ្លះ?<br>(ដោយបង្ហាញជារូបភាព ឬ ដាក់បង្ហាញក្នុង Slide PPT) |  | -សិស្សឆ្លើយ<br>-មនោគមន៍វិជ្ជាសេរី និងកុម្មុនីស្ត ក្នុងបរិបទសង្គ្រាមត្រជាក់ (១៩៤៧-១៩៩១)<br>-សង្គ្រាម... |
| | ជំហានទី៣៖ ខ្លឹមសារមេរៀនថ្មី (៣០នាទី)<br>**មេរៀនទី៣ សម័យសាធារណរដ្ឋខ្មែរ** | |
| | Explore(រុករក) | |

| | | |
|---|---|---|
| -គ្រូកត់ត្រាចំណងជើងរង និងពន្យល់ពាក្យដាក់លើក្តារខៀន ឬបង្ហាញក្នុង Slide PPT | ការខូចខាតដោយសារសង្គ្រាមស៊ីវិលនៅកម្ពុជា និងផលវិបាក<br><br>សំណួរបំផុស<br>បញ្ជ្រាប GCED | -សិស្សកត់ត្រា |
| -គ្រូបង្ហាញរូបភាពឱ្យសិស្សសង្កេត | រូបភាពតំណាងក្នុងកិច្ចតែងការ | -សិស្សសង្កេត គិត និងឆ្លើយ |
| -តើរូបនេះបង្ហាញពីព្រឹត្តិការណ៍អ្វីខ្លះ ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាសម័យសាធារណរដ្ឋខ្មែរ? |  | --សង្គ្រាមស៊ីវិលនៅកម្ពុជា (១៩៧០-១៩៧៥)<br><br>-ផលវិបាកនៃសង្គ្រាម |
| • សរសេរសំណួរគន្លឹះនៅលើក្តារខៀន និងឱ្យសិស្សកត់ត្រាចូលក្នុងសន្លឹកកិច្ចការ។ | សំណួរគន្លឹះ: | • សិស្សកត់ត្រាសំណួរគន្លឹះចូល ក្នុងសន្លឹកកិច្ចការ។ |
| **សំណួរគន្លឹះ:**<br>**«តើសង្គ្រាមស៊ីវិលឆាបឆេះអស់រយៈពេល៥ឆ្នាំ (១៩៧០-១៩៧៥) នៅកម្ពុជា បានបង្កនូវការខូចខាត និងផលវិបាកដូចម្ដេចខ្លះចំពោះសង្គមជាតិ? »** | | |
| -បែងចែកសិស្សជា៣ក្រុម | **ខ្លឹមសារពិភាក្សាក្រុម (២០នាទី)**<br>-ក្រុមទី១ ៖ផ្តោតទៅលើនយោបាយ<br>-ក្រុមទី២៖ ផ្តោតទៅលើសង្គម<br>-ក្រុមទី៣៖ ផ្តោតទៅលើសេដ្ឋកិច្ច | -សិស្សពិភាក្សារកចម្លើយដោយមានមានឯកសារយោងបន្ថែមច្បាស់លាស់។ |
| Explain (ពន្យល់) | | |
| • បែងចែកសិស្សជា៣ក្រុមតូចៗ | បញ្ជ្រាប GCED | • សិស្សចូលតាមក្រុម |
| • **គ្រូឱ្យសិស្សអនុវត្តសកម្មភាព** Museum Walks | សង្គ្រាមស៊ីវិលឆាបឆេះអស់រយៈពេល៥ឆ្នាំ(១៩៧០-១៩៧៥) ដែលបង្កនូវការខូចខាត និងផលវិបាកដូចតទៅ៖ | • តំណាងសិស្សឡើងពន្យល់តាមក្រុម និងសន្និដ្ឋាន (ដោយមានភស្តុតាង និង |

| | | |
|---|---|---|
| | | អំណះអំណាង ត្រឹមត្រូវដោយឈរលើឯកសារយោងច្បាស់លាស់។ |
| • ក្រុមទី១៖ ផ្តោតលើផ្នែកនយោបាយ | **នយោបាយ:** ឱកាសឱ្យខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៥។ | • **នយោបាយ**<br>អស្ថិរភាពនយោបាយដោយសង្គ្រាមស៊ីវិល បានបង្កវិនាសកម្មលើគ្រប់វិស័យដែលជាឱកាសឱ្យខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៥។ |
| • ក្រុមទី២៖ ផ្តោតទៅលើសង្គម | **សង្គម:** សង្គមអស្ថិរភាព មិនមានការអភិវឌ្ឍ។ | • **សង្គម**<br>-សង្គ្រាមបានសម្លាប់ប្រជាជនកម្ពុជាជាងមួយលាននាក់<br>-ប្រជាជនភៀសខ្លួនពីជនបទចូលទីក្រុង រស់ដោយខ្វះស្បៀង ជួបភាពអនាធិបតេយ្យ អំពើហិង្សា ចោរកម្ម...<br>-អំពើសូកប៉ាន់រីកដុះដាលដល់វិស័យសិក្សាធិការ<br>-បំផ្លាញធនធានមនុស្ស គ្រឹះស្ថានសិក្សា វត្តអារាម...។ |
| • ក្រុមទី៣៖ ផ្តោតទៅលើសេដ្ឋកិច្ច | **សេដ្ឋកិច្ច:** អតិផរណាប្រាក់រៀល។ | • **សេដ្ឋកិច្ច**<br>-ដីស្រែចម្ការត្រូវបោះបង់ចោលព្រមទាំងក្លាយទៅជាចម្ការមីននិងរណ្តៅគ្រាប់៥២<br>-រោងចក្រឧស្សាហកម្ម៧៥ភាគរយ ត្រូវបំផ្លិចបំផ្លាញ<br>-ចម្ការកៅស៊ូត្រូវបាត់បង់<br>-ផ្លូវថ្នល់ និងស្ពានពី៧០ភាគរយ ទៅ៨០ភាគរយត្រូវអន្តរាយ។<br>-ចម្លើយត្រឹមត្រូវផ្សេងទៀត |

| | | |
|---|---|---|
| • គ្រូសម្របសម្រួលចម្លើយក្រុមនីមួយៗលើក្ដារខៀន។ចម្លើយទាំងអស់របស់ក្រុមនីមួយៗគឺត្រឹមត្រូវទាំងអស់។ | | • សិស្សស្ដាប់ និងកត់ត្រាចម្លើយចូលសៀវភៅ។ |
| • ចូរប្អូនសន្និដ្ឋានពីផលវិបាកសង្គ្រាមស៊ីវិលដែលឆាបឆេះអស់រយៈពេល៥ឆ្នាំ (១៩៧០-១៩៧៥)។ | **សន្និដ្ឋាន**<br>សង្គ្រាមស៊ីវិលដែលឆាបឆេះអស់រយៈពេល៥ឆ្នាំ(១៩៧០-១៩៧៥) បានផ្ដល់ផលវិបាកជាច្រើនដល់សង្គម សេដ្ឋកិច្ច បញ្ហានយោបាយ។ | • សិស្សសន្និដ្ឋាន |
| • ឱ្យសិស្សកត់ត្រាចម្លើយដែលត្រឹមត្រូវចូលក្នុងសៀវភៅរៀងខ្លួនៗ។ | | • កត់ត្រាចម្លើយដែលត្រឹមត្រូវចូលក្នុងសៀវភៅ។ |
| Elaborate (ពង្រីកគំនិត) | | |
| **គ្រូចោទជាសំណួរដោយបញ្ជ្រាបGCED**<br>• ប្រវត្តិសាស្ត្រគឺជាគ្រូដ៏ល្អម្នាក់។ តើយើងត្រូវធ្វើដូចម្ដេចដើម្បីទប់ស្កាត់កុំឱ្យមានសង្គ្រាមស៊ីវិលកើតឡើងនៅកម្ពុជា? | បញ្ជ្រាបGCED | **ដើម្បីទប់ស្កាត់កុំឱ្យមានសង្គ្រាមស៊ីវិលៈ**<br>-ទប់ស្កាត់កុំឱ្យមានអំពើហិង្សា និងការប្រើប្រាស់អាវុធ<br>-ទប់ស្កាត់សង្គ្រាមនៅលើទឹកដីកម្ពុជា<br>-ទប់ស្កាត់ការបែកបាក់សាមគ្គី ឬ ជម្លោះផ្ទៃក្នុង និងជាមួយបរទេស<br>-ទប់ស្កាត់មនោគមវិជ្ជាព្រៃផ្សៃ និងមិនជាប្រយោជន៍ជាតិ<br>-ទប់ស្កាត់ការទម្លាក់រដ្ឋាភិបាលស្របច្បាប់ដោយប្រដាប់អាវុធ ឬសកម្មភាពខុសច្បាប់<br>-ទប់ស្កាត់ភាពអយុត្តិធម៌សង្គម<br>-ទប់ស្កាត់អំពើពុករលួយ |

| | | |
|---|---|---|
| | | -ទប់ស្កាត់សកម្មភាពជ្រុលនិយម<br>-ទប់ស្កាត់និទណ្ឌភាព<br>-ទប់ស្កាត់ការបង្កើតតំបន់អប្បគមន៍<br>-ការពារវប្បធម៌សន្តិភាព<br>-ការពារសន្តិភាព និងស្ថិរភាពសង្គម<br>-ការពារលទ្ធិប្រជាធិបតេយ្យ និងគោរពច្បាប់រដ្ឋ<br>-ដោះស្រាយបញ្ហាដោយសន្តិវិធី<br>-គោរពសិទ្ធិមនុស្ស ជំនឿពិពិធភាពក្នុងសង្គម<br>-រក្សាភាពយុត្តិធម៌ និងតម្លាភាព<br>-លើកស្ទួយវិស័យអប់រំ និងអ្នកចេះដឹង<br>-អប់រំភាពជាពលរដ្ឋដែលមានការយោគយល់គ្នាទៅវិញទៅមក<br>-បញ្ចូលការអប់រំស្តីពីផលវិបាកនៃសង្គ្រាម ក្នុងកម្មវិធីសិក្សា<br>-សិក្សាប្រវត្តិសាស្ត្រ និងតាមដានស្ថានភាពក្នុងប្រទេស និងជុំវិញពិភពលោក<br>-បំពេញភារកិច្ចប្រកបដោយការទទួលខុសត្រូវខ្ពស់អភិវឌ្ឍវិស័យសេដ្ឋកិច្ច វិស័យវប្បធម៌ |

| | | |
|---|---|---|
| | | វិស័យអប់រំ វិស័យទំនាក់ទំនង ...។ |
| **ជំហានទី៤៖ ពង្រឹងពុទ្ធិ (៧នាទី)** | | |
| Evaluate (វាយតម្លៃ) | | |
| - ឱ្យសិស្សម្នាក់ៗ ធ្វើ Mind map ពីអ្វីដែលពួកគាត់បានរៀន។ | ការបញ្ជ្រាបGCED | -អនុវត្តតាមការណែនាំរបស់គ្រូ |
| **ជំហានទី៥៖ កិច្ចការផ្ទះ និង បណ្តាំផ្ញើ (៣នាទី)** | | |
| • គ្រូដាក់កិច្ចការឱ្យសិស្សធ្វើ នៅផ្ទះ | **កិច្ចការផ្ទះ**<br>ការបញ្ជ្រាបGCED | • សិស្សកត់ត្រាកិច្ចការផ្ទះ |
| -ចូរប្អូនសង្ខេបពីចំណុចសំខាន់នៃមេរៀន ដោយឈរលើ៤ចំណុច៖<br>១-ផលប៉ះពាល់ខ្លាំងចំពោះការអភិវឌ្ឍប្រទេសជាតិ<br>២-ផលប៉ះពាល់ខ្លាំងចំពោះការអប់រំនៅកម្ពុជា<br>៣-ផលប៉ះពាល់ខ្លាំងចំពោះសុខមាលភាពប្រជាជន<br>៤-សរសេរសេចក្តីសន្និដ្ឋានខ្លីមួយអំពី សន្តិភាពនាំឱ្យមានការអភិវឌ្ឍ។ | | |
| -ប្អូនៗត្រូវស្វ័យសិក្សាជាប្រចាំ។ | **បណ្តាំផ្ញើ** | -សិស្សស្តាប់ និងអនុវត្តនៅផ្ទះ។ |

# ប្រធានបទៈ ផលវិបាកនៃសង្គ្រាមលោកលើកទី២

ជា កល្យាណ ទី សុផល ចាប រតនា ហង់ ស្រីម៉ាច
វិទ្យាស្ថានជាតិអប់រំ

- កាលបរិច្ឆេទ ៖ ថ្ងៃទី.................ខែ..............ឆ្នាំជូតទោស័កព.ស ២៥៦...
  ត្រូវនឹងថ្ងៃទី..........ខែ..............ឆ្នាំ២០២...
- មុខវិជ្ជា ៖ ប្រវត្តិវិទ្យា ថ្នាក់ទី១១
- ជំពូកទី១ ៖ ប្រវត្តិសាស្ត្រពិភពលោក
- មេរៀនទី១៦ ៖ សង្គ្រាមលោកលើកទី២ (១៩៣៩ ដល់ ១៩៤៥)
- ប្រធានបទ ៖ ផលវិបាកនៃសង្គ្រាមលោកលើកទី២
- រយៈពេល ៖ ១ម៉ោង (៥០នាទី)

## I. **វត្ថុបំណងនៃមេរៀន**

**-វិជ្ជាសម្បទា** ៖ ព័ណនាពីស្ថានភាពរបស់ប្រជាជននៅក្នុងសង្គ្រាមលោកលើកទី២បានត្រឹមត្រូវតាមរយៈគុក្កតាគំនិត និងសំណួរបំផុសរបស់គ្រូ។

**-បំណិនសម្បទា**៖ វិភាគពីផលវិបាកនៃសង្គ្រាមលោកលើកទី២បានត្រឹមត្រូវនៅក្នុងប្រអប់គុក្កតាគំនិត។

**-ចរិយាសម្បទា** ៖ ថែរក្សា ការពារ សាមគ្គីភាព និងមានទំនាក់ទំនងល្អរវាងប្រទេសមួយទៅប្រទេសមួយផ្សេងទៀតប្រកបដោយសន្តិភាព។

## II. **សម្ភារៈឧបទេស**

-ក្រដាសA៤ ហ្វឺត ស្កុត ក្រដាសកាតុង

-រូបគំនូរគុក្កតាគំនិតអំពីសង្គ្រាមលោកលើកទី២

## II. **វិធីសាស្ត្របង្រៀនៈ** -វិធីសាស្ត្របង្រៀនបែបរិះរក (IBL) តាមរយៈយុទ្ធវិធីគុកក្កតាគំនិត

-បញ្ជ្រាប GCED តាមរយៈវិធីសាស្ត្របង្រៀន និងខ្លឹមសារមេរៀន

## IV. **ដំណើរនាំមេរៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| **ជំហានទី១៖ រដ្ឋបាលថ្នាក់(៣នាទី)** | | |
| • ត្រួតពិនិត្យអវត្តមាន<br>• ពិនិត្យអនាម័យ និងសណ្ដាប់ធ្នាប់ថ្នាក់រៀន<br>• សំណេះសំណាល | ប្រមូលអារម្មណ៍សិស្សដើម្បីរៀន<br>បញ្ជ្រាប GCED | • ប្រធានថ្នាក់រាយការណ៍<br>• សិស្សស្ងៀមស្ងាត់<br>• សិស្សត្រៀមខ្លួនរួចរាល់សម្រាប់មេរៀនថ្ងៃនេះ |
| **ជំហានទី២៖ រំលឹកមេរៀនចាស់ (៧នាទី)** | | |

| | | |
|---|---|---|
| • គ្រូសួរសំណួរលើខ្លឹមសារមេរៀន ដែលរៀនរួចហើយ | សង្គ្រាមលោកលើកទី២ | •សិស្សស្តាប់ គិត និងឆ្លើយសំណួរគ្រូ |
| -តើសង្គ្រាមលោកលើកទី២ចាប់ផ្តើមដោយប្រទេសណាខ្លះ? | | -អ៊ីតាលី អាឡឺម៉ង់ ជប៉ុន ។ |
| -តើមូលហេតុអ្វីដែលធ្វើឱ្យសង្គ្រាមលោកលើកទី២ត្រូវបានបញ្ចប់? | | -ដោយសារសហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បរិមាណូពីរគ្រាប់ទៅលើកោះរបស់ជប៉ុន គឺ ហ៊ីរ៉ូស៊ីម៉ានិងណាកាសាគី ដែលធ្វើឱ្យជប៉ុនចុះចាញ់សង្គ្រាមលោកលើកទី២។ |
| **ជំហានទី៣៖ ខ្លឹមសារមេរៀនថ្មី (៣០នាទី)**<br>ផលវិបាកនៃសង្គ្រាមលោកលើកទី២ | | |
| • ណែនាំសិស្សឱ្យសង្កេតរូបភាព រួចសួរសំណួរបំផុស | សំណួរបំផុស<br>បញ្ជ្រាប GCED | • សិស្សសង្កេត គិត និងឆ្លើយសំណួររបស់គ្រូ |
| -តើរូបភាពនេះបង្ហាញពីអ្វី? |  | -ការធ្វើសង្គ្រាម |
| • សរសេរសំណួរគន្លឹះនៅលើក្តារខៀន និងឱ្យសិស្សកត់ត្រាចូលក្នុងសន្លឹកកិច្ចការ។ | សំណួរគន្លឹះ | • សិស្សកត់ត្រាសំណួរគន្លឹះចូល ក្នុងសន្លឹកកិច្ចការ។ |
| **សំណួរគន្លឹះ**<br>ក្រោយសង្គ្រាមលោកលើកទី២ត្រូវបានបញ្ចប់ តើសង្គ្រាមនេះបានផ្តល់ផលវិបាកអ្វីខ្លះ? | | |

| | | |
|---|---|---|
| • ឱ្យសិស្សសង្កេតគំនូរតុក្កតា គំនិត និងសរសេរខ្លឹមសារ នៅក្នុងប្រអប់ពពុះលើក្តារខៀន | | • សិស្សសង្កេត គិត និងឆ្លើយសំណួររបស់គ្រូ |
| • បែងចែកសិស្សជា៤ក្រុមតូចៗដែលមានសមាជិក៤នាក់។ | បញ្ញាប GCED | • សិស្សចូលតាមក្រុម |

## ផលវិបាកនៃសង្គ្រាមលើកទី២




| | | |
|---|---|---|
| • សរសេរសំណួពិភាក្សានៅលើក្តារខៀន រួចឱ្យសិស្សពិភាក្សាតាមក្រុម | | • សិស្សពិភាក្សាក្រុម និងកត់សំណួរចូលសន្លឹកកិច្ចការ |
| - តើសង្គ្រាមលោកលើកទី២ផ្តល់ផលវិបាកអ្វីខ្លះ ? | **រូបពពុះA៖** ផលវិបាកដល់មនុស្ស | • ក្រុមA៖ ផលវិបាកដល់មនុស្ស |

| | | |
|---|---|---|
| | <br> | -ស្លាប់ របួស ពិការ បែកបាក់ គ្រួសារ ក្មេងកំព្រា |
| • ឱ្យក្រុមនីមួយៗសរសេរចម្លើយនៅក្នុងរូបពពុះនៅលើក្រដាសកាតុងរួចពន្យល់នៅលើក្ដាខៀនដោយតំណាងក្រុមម្នាក់។ | **រូបពពុះB៖** ផលវិបាកដល់សង្គម<br><br> | ក្រុមB៖ ផលវិបាកដល់សង្គម<br>-ខូចខាតហេដ្ឋារចនាសម្ព័ន្ធ<br>-ខូចផ្លូវគមនាគមន៍ |
| | **រូបពពុះC៖** ផលវិបាកដល់សេដ្ឋកិច្ច<br> | ក្រុមC៖ ផលវិបាកដល់សេដ្ឋកិច្ច<br>-ធ្វើឱ្យសេដ្ឋកិច្ចធ្លាក់ចុះ<br>-បាត់បង់ដៃគូរពាណិជ្ជកម្ម |

| | | |
|---|---|---|
| |  | |
| | **រូបពុះD៖ផលវិបាកដល់នយោបាយ**  | ក្រុមទីD៖ផលវិបាកនយោបាយ<br>-អស្ថេរភាពនយោបាយ<br>-បាត់បង់ទំនាក់ទំនងអន្តរជាតិ<br>-ធ្វើឱ្យពិភពលោកប្រឈមមុខសង្គ្រាមថ្មី |
| • គ្រូសម្របសម្រួលចម្លើយក្រុមនីមួយៗលើក្តារខៀន។ចម្លើយទាំងអស់របស់ក្រុមនីមួយៗគឺត្រឹមត្រូវទាំងអស់។ | | • សិស្សស្តាប់ និងកត់ត្រាចម្លើយចូលសៀវភៅ។ |
| • ចូរប្អូនសន្និដ្ឋានពីផលវិបាកក្រោយសង្គ្រាមលោកលើកទី២។ | **សន្និដ្ឋាន**<br>សង្គ្រាមលោកលើកទី២បានផ្តល់ផលវិបាកជាច្រើនដល់សង្គម សេដ្ឋកិច្ច មនុស្សស្លាប់ និងបញ្ហានយោបាយលើពិភពលោក។ | • សិស្សសន្និដ្ឋាន |
| • ឱ្យសិស្សកត់ត្រាចម្លើយដែលត្រឹមត្រូវចូលក្នុងសៀវភៅរៀងខ្លួនៗ។ | | • កត់ត្រាចម្លើយដែលត្រឹមត្រូវចូលក្នុងសៀវភៅ។ |
| | **ជំហានទី៤៖ ពង្រឹងពុទ្ធិ (៧នាទី)** | |
| | ការបញ្ជ្រាបGCED | |

| | | |
|---|---|---|
| -ក្រៅពីប៉ះពាល់សង្គម សេដ្ឋកិច្ច នយោបាយនិងមនុស្សតើសង្គ្រាមមានផលប៉ះពាល់ដល់បរិស្ថានដែរឬទេ ?ព្រោះអ្វី ? | | -មានផលប៉ះពាល់ដល់បរិស្ថានព្រោះវាធ្វើឱ្យខូចខាតប្រព័ន្ធជាវាសាស្ត្រ គុណភាពដី ព្រៃឈើសត្វ និងបាត់បង់ធនធានធម្មជាតិជាដើម។ |
| **ជំហានទី៥៖ កិច្ចការផ្ទះ និង បណ្តាំផ្ញើ ( ៣នាទី )** | | |
| • គ្រូដាក់កិច្ចការឱ្យសិស្សធ្វើនៅផ្ទះ<br>-ដើម្បីការពារកុំឱ្យមានសង្គ្រាមកើតឡើងតើប្អូនៗមានទស្សនៈដូចម្តេច ? | **កិច្ចការផ្ទះ**<br>ការបញ្ជ្រាបGCED | • សិស្សកត់ត្រាកិច្ចការផ្ទះ |
| • សូមប្អូនៗអានមេរៀនឡើងវិញពេលត្រឡប់ទៅផ្ទះ និងសាកល្បងធ្វើការស្រាវជ្រាវមេរៀនបន្ត។ | **បណ្តាំផ្ញើ** | • សិស្សស្តាប់ និងអនុវត្តនៅផ្ទះ។ |

# ប្រធានបទ៖ ព្រឹត្តិការណ៍សំខាន់ៗនៅតំបន់មជ្ឈឹមបូព៌ា

ជា កល្យាណ ប៉ូ សុខា ទី សុផល ចាប រតនា ហង់ ស្រីម៉ាច
**វិទ្យាស្ថានជាតិអប់រំ**

- កាលបរិច្ឆេទ ៖ ថ្ងៃទី.................ខែ..............ឆ្នាំជូតទោស័កព.ស ២៥៦...
  ត្រូវនឹងថ្ងៃទី..........ខែ..............ឆ្នាំ២០២...
- មុខវិជ្ជា ៖ ប្រវត្តិវិទ្យា ថ្នាក់ទី១២
- ជំពូកទី៣ ៖ ប្រវត្តិសាស្ត្រតំបន់ ក្នុងសង្គ្រាមត្រជាក់
- មេរៀនទី៤ ៖ បណ្ដាប្រទេសនៅតំបន់មជ្ឈឹមបូព៌ា
- ប្រធានបទ ៖ ព្រឹត្តិការណ៍សំខាន់ៗ នៅតំបន់មជ្ឈឹមបូព៌ា
- រយៈពេល ៖ ៥០នាទី (ម៉ោងទី១)

## I. **វត្ថុបំណងនៃមេរៀន**

-**វិជ្ជាសម្បទា** ៖ រៀបរាប់ពីព្រឹត្តិការណ៍ធំៗ កើតមាននៅក្នុងតំបន់មជ្ឈឹមបូព៌ាបានច្បាស់លាស់ តាមរយៈការសង្កេតរូបភាព និងសំណួរបំផុសរបស់គ្រូ។

-**បំណិនសម្បទា**៖ កំណត់ព្រឹត្តិការណ៍សំខាន់ៗ ដែលកើតមាននៅតំបន់មជ្ឈឹមបូព៌ាបានត្រឹមត្រូវ តាមរយៈការពិភាក្សាក្រុម។

-**ចរិយាសម្បទា** ៖ ចូលរួមគោរពសិទ្ធិគ្នាទៅវិញទៅមក ដោយរក្សាសន្តិភាព និងទំនាក់ទំនងល្អជាមួយប្រទេសជិតខាង។

## II. **សម្ភារៈឧបទេស**

-ក្រដាសA៤ ហ្វឺត ស្កុត ក្រដាសកាតុង

-រូបភាពទាក់ទងនឹងខ្លឹមសារមេរៀនដូចជា៖ ផែនទីមជ្ឈឹមបូព៌ា រូបសាសនិក រូបស្ថានភាពប្រជាជន និងរូបភាពផ្សេងៗទៀត។

## II. **វិធីសាស្ត្របង្រៀន**: -វិធីសាស្ត្របង្រៀនបែបរិះរក (IBL)

-បញ្ជ្រាប GCED តាមរយៈវិធីសាស្ត្របង្រៀន និងខ្លឹមសារមេរៀន

## IV. **ដំណើរការនាំមេរៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| **ជំហានទី១៖ រដ្ឋបាលថ្នាក់(៣នាទី)** | | |
| • ត្រួតពិនិត្យអវត្តមាន<br>• ពិនិត្យអនាម័យ និង | ប្រមូលអារម្មណ៍សិស្សដើម្បីរៀន<br>បញ្ជ្រាប GCED | • ប្រធានថ្នាក់រាយការណ៍<br>• សិស្សស្ងៀមស្ងាត់ |

| | | |
|---|---|---|
| សណ្ដាប់ធ្នាប់ថ្នាក់រៀន<br>• សំណេះសំណាល | | • សិស្សត្រៀមខ្លួនរួចរាល់សម្រាប់មេរៀនថ្ងៃនេះ |
| **ជំហានទី២៖ រំលឹកមេរៀនចាស់ ( ៧នាទី )**<br>**«ប្រទេសថៃ»** | | |
| • គ្រូសួរសំណួរលើខ្លឹមសារមេរៀន ដែលរៀនរួចហើយអំពីប្រទេសថៃ។ | | • សិស្សស្ដាប់ គិត និងឆ្លើយសំណួរគ្រូ |
| - តើប្រទេសថៃបានផ្ទុះរឿងបដិវត្តន៍នៅឆ្នាំណា ? | | -ប្រទេសថៃផ្ទុះរឿងបដិវត្តន៍នៅឆ្នាំ១៩៣២។ |
| -តើស្ដេចរាមាទី៩ របស់ថៃមានព្រះនាមអ្វី ? | | -ស្ដេចរាមាទី៩របស់ថៃ មានព្រះនាមថា ភូមិពលអាឌុលយ៉ាតេជ |
| - តើក្រោយសង្គ្រាមលោកលើកទី២ ប្រទេសថៃបានជួបវិបត្តិរដ្ឋប្រហារអ្វីខ្លះ ? | | -ក្រោយសង្គ្រាមលោកលើកទី២ ប្រទេសថៃបានជួបវិបត្តិរដ្ឋប្រហារជាច្រើនលើកច្រើនសារ ដូចជារដ្ឋប្រហារសភារដ្ឋធម្មនុញ្ញ និងរដ្ឋប្រហារយោធា។ |
| **ជំហានទី៣៖ ខ្លឹមសារមេរៀនថ្មី ( ៣០នាទី )**<br>**«បណ្ដាប្រទេស នៅតំបន់មជ្ឈិមបូព៌ា»** | | |
| - សួរសំណួរបំផុសទៅសិស្ស<br>-តើអ្នកទាំងអស់គ្នាធ្លាប់ស្គាល់តំបន់មជ្ឈិមបូព៌ាដែរឬទេ ? | សំណួរបំផុស<br>បញ្ច្រាប GCED | -សិស្សគិត និងឆ្លើយសំណួរ<br>- ធ្លាប់/ មិនធ្លាប់ |
| •ណែនាំសិស្សឱ្យសង្កេតរូបភាព រួចសួរសំណួរបំផុស<br>-តើប្រទេសណាខ្លះ ស្ថិតនៅតំបន់មជ្ឈិមបូព៌ា ? | **ព្រឹត្តិការណ៍សំខាន់ៗនៅតំបន់មជ្ឈិមបូព៌ា**<br><br><br> | •សិស្សសង្កេត គិត និងឆ្លើយសំណួររបស់គ្រូ<br>-មានប្រទេសដូចជា៖ តួកគី- ស៊ីរី- អ៊ីរ៉ង់- អ៊ីរ៉ាក់- លីបង់- ហ្សកដានី- អ៊ីស្រាអែល- អារ៉ាប៊ីសាអូឌីត- ស៊ូដង់-យេម៉ែន -អេហ្ស៊ីប និង លីប៊ី។ |

| | | |
|---|---|---|
| -តើប្រទេសណាដែលធំជាងគេនៅក្នុងឧបទ្វីបអារ៉ាប់? | | -ប្រទេសធំជាងគេ នៅក្នុងឧបទ្វីបអារ៉ាប់ ប្រទេសអារ៉ាប៊ីសាអូឌីត។ |
| -តើប្រទេសណាមួយដែលមានចំណាត់ថ្នាក់ ជាប្រទេសក្របំផុតនៅក្នុងតំបន់? | | -ប្រទេសដែលក្របំផុតនោះគឺប្រទេសយេម៉ែន។ |
| • សរសេរសំណួរគន្លឹះនៅលើក្តារខៀន និងឱ្យសិស្សកត់ត្រាចូលក្នុងសន្លឹកកិច្ចការ។ | សំណួរគន្លឹះ | • សិស្សកត់ត្រាសំណួរគន្លឹះចូលក្នុងសន្លឹកកិច្ចការ។ |
| សំណួរគន្លឹះ<br>តើមានព្រឹត្តិការណ៍សំខាន់ៗអ្វីខ្លះ កើតឡើងនៅក្នុងតំបន់មជ្ឈឹមបូព៌ា? | | |
| • បែងចែកសិស្សជា៤ក្រុមពិភាក្សាលើសំណួរ។ | បញ្ជ្រាប GCED<br>**ពិភាក្សាក្រុម** | • សិស្សចូលតាមក្រុម |
| • សរសេរសំណួពិភាក្សានៅលើក្តាខៀន រួចឱ្យសិស្សពិភាក្សាតាមក្រុម | | • សិស្សពិភាក្សាក្រុម និងកត់សំណួរចូលសន្លឹកកិច្ចការ |
| - **ក្រុមទី១៖** ចូរបង្ហាញពីតួនាទីសាសនានៅក្នុងប្រទេសស៊ីរី។ | **ក្រុមទី១**<br><br>Religions in Syria | **ក្រុមទី១**៖បង្ហាញពីតួនាទីសាសនា នៅក្នុងប្រទេសស៊ីរី៖<br>-ប្រជាជនស៊ីរីភាគច្រើន កាន់សាសនាអ៊ីស្លាម-ស៊ូនីត។<br>-ប្រជាជនភាគតិចដែលប្រកាន់សាសនាអ៊ីស្លាម-អាឡាវីត មានតួនាទីសំខាន់ក្នុងវិស័យយោធា។<br>-តំណាងរបស់អ្នកកាន់សាសនាអ៊ីស្លាម និកាយឌ្រូស៊ី មានតួនាទីសំខាន់ក្នុងកិច្ចការនយោបាយស៊ីរីចំណែកនៅក្នុងទីក្រុងអាឡេប៉ូវិញមានអ្នកកាន់សាសនាគ្រិស្តមានចំនួនច្រើនឡើង។ |

| | | |
|---|---|---|
| **-ក្រុមទី២៖** ចូរប្អូនពណ៌នាការរស់នៅចម្រុះជាតិសាសន៍ នៅក្នុងប្រទេសអ៊ីរ៉ាក់។ | **ក្រុមទី២**   | **ក្រុមទី២៖** ការរស់នៅចម្រុះជាតិសាសន៍នៅអ៊ីរ៉ាក់៖ -ប្រជាជនភាគច្រើននៅអ៊ីរ៉ាក់ ជាពួកអ៊ីស្លាមស៊ីអ៊ីត និង១/៤ ជាពួកស៊ូនីត។ -នៅភាគខាងជើងប្រទេសអ៊ីរ៉ាក់មានពួកឃឺដរស់នៅច្រើន -ហើយតំបន់ម៉ូស៊ូលនៃប្រទេសអ៊ីរ៉ាក់ មានពួកអាស៊ីរស់នៅគោរពសាសនាគ្រិស្ត និងមានពួកជ្វីបរស់នៅខ្លះដែរ ក្នុងទីក្រុងបាកដាដនាឆ្នាំ១៩៥០-១៩៥១។ |
| **-ក្រុមទី៣៖** តើមានបញ្ហាអ្វីបានកើតឡើង នៅប្រទេសលីបង់ ក្នុងឆ្នាំ១៩៧៥? | **ក្រុមទី៣**  ប្រទេសលីបង់ឆ្នាំ១៩៧៥ | **ក្រុមទី៣៖** បញ្ហាដែលកើតឡើងនៅប្រទេសលីបង់ក្នុងឆ្នាំ១៩៧៤ -នៅឆ្នាំ១៩៧៥ បានផ្ទុះឡើងនូវការលុបបំបាត់កិច្ចព្រមព្រៀង ស្តីអំពីការបែងចែករវាងអ៊ីស្លាម និងគ្រិស្តសាសនិក។ -នៅក្នុងទំនាស់នោះ មានជំនួយពីកម្លាំងទ័ពរបស់អង្គការរំដោះជាតិប៉ាលេស្ទីនផង បានធ្វើឱ្យលីបង់ធ្លាក់ចូលទៅក្នុងភ្នក់ភ្លើងសង្គ្រាមស៊ីវិលយ៉ាងកាចសាហាវ |
| **-ក្រុមទី៤៖** ហេតុអ្វីបានជាពួកអ៊ីស្រាអែល ត្រូវបានគេបណ្តេញ ចេញពីតំបន់ភាគខាងលិចនៃទន្លេហ្ស៊កដង់ នៅឆ្នាំ១៩៤៩? ហើយឆ្នាំណាទើបអ៊ីស្រាអែល ត្រឡប់មកកាន់កាប់តំបន់នេះវិញ? | **ក្រុមទី៤**  | **ក្រុមទី៤៖**មូលហេតុដែលអ៊ីស្រាអែល ត្រូវបានគេបណ្តេញចេញ៖ -នៅឆ្នាំ១៩៤៩ ក្រោយសង្គ្រាមអារ៉ាប់-អ៊ីស្រាអែលមក ពួកគេក៏បានបណ្តេញពួកអ៊ីស្រាអែលចេញពីតំបន់ភាគខាងលិចនៃទន្លេហ្ស៊កដង់ ហើយបានពង្រីកទីនោះ ដោយសារតែប្រជាជន |

ទន្លេហ្ស៊កដង់ និងពួកអ៊ីស្រាអែល

| | | |
|---|---|---|
| | | ហ្សកជានីរស់នៅលើសពី៨០០ ពាន់នាក់ និងជាកន្លែងដែលពួកប៉ាលេស្ទីន ធ្លាប់រស់នៅ។<br>-អ៊ីស្រាអែល ត្រឡប់មកកាន់កាប់តំបន់នេះវិញនៅឆ្នាំ១៩៦៧ |
| • គ្រូឱ្យសិស្សតាមក្រុមនីមួយៗឡើងធ្វើបទបង្ហាញពីហេតុផលដែលពួកគេបានរកឃើញតាមរយៈការពិភាក្សា។<br>• គ្រូសម្របសម្រួលចម្លើយក្រុមនីមួយៗលើក្តារខៀន។ | | • តំណាងក្រុមឡើងបង្ហាញលទ្ធផលរបស់ខ្លួនដល់ក្រុមដទៃ។<br><br>• សិស្សស្តាប់ និងកត់ត្រាចម្លើយចូលសៀវភៅ។ |
| • ចូរប្អូនសន្និដ្ឋានពីមានព្រឹត្តិការណ៍សំខាន់ៗដែលកើតឡើងនៅក្នុងតំបន់មជ្ឈិមបូព៌ា។ | **សន្និដ្ឋាន**<br>ព្រឹត្តិការណ៍សំខាន់ៗមាន៖<br>-ការប្រកាន់សាសនារវាងសាសនាគ្រិស្ត និងអ៊ីស្លាម។<br>-សាសនាអ៊ីស្លាមបែងចែកជាច្រើននិកាយដូចជា ស៊ីអ៊ីត ស៊ូនីត អាឡាវីត និងឌ្រូស៊ី។<br>-ការរស់នៅចម្រុះជាតិសាសន៍<br>-បញ្ហាព្រំដែន៖ ដណ្តើមទឹកដីគ្នារស់នៅ។ | • សិស្សសន្និដ្ឋាន |
| • ឱ្យសិស្សកត់ត្រាចម្លើយដែលត្រឹមត្រូវចូលក្នុងសៀវភៅរៀងខ្លួនៗ។ | | • កត់ត្រាចម្លើយដែលត្រឹមត្រូវចូលក្នុងសៀវភៅ។ |
| **ជំហានទី៤៖ ពង្រឹងពុទ្ធិ (៧នាទី)** | | |
| -តើមានជនជាតិណាខ្លះ រស់នៅក្នុងប្រទេសអ៊ីរ៉ាក់? | ការបញ្ជ្រាបGCED | -មានពួកអ៊ីស្លាមស៊ីអ៊ីត ពួកស៊ូនីត ពួកឃើដ ពួកអាស៊ី និងពួកជ្វីប ។ |
| - តើប្រជាជននៅតំបន់មជ្ឈិមបូព៌ា កាន់សាសនាធំៗអ្វីខ្លះ? | | -ពួកគេកាន់សាសនាគ្រិស្ត និងសាសនា អ៊ីស្លាម។ សាសនា |

| | | |
|---|---|---|
| តើសាសនាណាមួយ ដែលប្រជាជនគោរពច្រើនជាងគេ? | | ដែលមានប្រជាជនគោរពច្រើនជាងគេគឺ សាសនាអ៊ីស្លាម។ |
| **ជំហានទី៥៖ កិច្ចការផ្ទះ និង បណ្តាំផ្ញើ (៣នាទី)** | | |
| • ដាក់កិច្ចការផ្ទះឱ្យសិស្សធ្វើ<br>-តើបញ្ហាប្រកាន់សាសនា នៅតំបន់មជ្ឈឹមបូព៌ា បានផ្តល់ផលវិបាកអ្វីខ្លះដល់ការរស់នៅរបស់ប្រជាជន និងសង្គមជាតិ? | **កិច្ចការផ្ទះ**<br>ការបញ្ជ្រាបGCED | • សិស្សកត់ត្រាកិច្ចការផ្ទះ |
| • សូមប្អូនៗអានមេរៀនឡើងវិញពេលត្រឡប់ទៅផ្ទះ និងសាកល្បងធ្វើការស្រាវជ្រាវមេរៀនបន្ត។ | **បណ្តាំផ្ញើ** | • សិស្សស្តាប់ និងអនុវត្តនៅផ្ទះ។ |

# ប្រធានបទ៖ របាំនេសាទ

អ៊ុំ សុចិន្តា វ៉ា ចំណាន ណម ណារតន៍
វិទ្យាស្ថានជាតិអប់រំ

- **កាលបរិច្ឆេទ** ៖ ថ្ងៃ........ខែ.........ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
  ត្រូវនឹងថ្ងៃទី............ ខែ........ឆ្នាំ២០២៣
- **មុខវិជ្ជា** ៖ សិល្បៈ
- **ជំពូកទី១** ៖ ទស្សនីយភាពសិល្បៈនាដសាស្ត្រ
- **មេរៀនទី៣** ៖ របាំនេសាទ (ទ្រឹស្តី)
- **រយៈពេល** ៖ ១ម៉ោង សម្រាប់ថ្នាក់...
- **គោលវិធី** ៖ សិស្សមជ្ឈមណ្ឌល

## I. វត្ថុបំណង ៖ ក្រោយពីបានសិក្សាមេរៀននេះចប់ គរុនិស្សិតនឹងទទួលបាន៖

**- វិជ្ជាសម្បទា ៖**

សារតារបាំនេសាទដែលបង្ហាញពីសម្បត្តិធម្មជាតិនៃមាតុភូមិកម្ពុជា មានបឹងទន្លេសាបជាជម្រកត្រីដ៏ធំប្រើចលនាក្បាច់ ក្រឡា សញ្ញេតនាទៅតាមបែបធម្មជាតិ និងចរិកលក្ខណៈរបស់អ្នកសុក្រស្រែចំការ។

**- បំណិនសម្បទា ៖**

អនុវត្តន៍ចលនាក្បាច់ ក្រឡា និងដាក់សញ្ញេតនាបានត្រឹមត្រូវតាមក្បួតនៃរបាំខ្មែរ បែងចែកចលនាក្បាច់ ក្រឡា តួប្រុសស្រីបានទៅតាមកាយសម្បទា និងទីតាំងសម្តែង។

**-ចរិយាសម្បទា ៖**

បណ្តុះស្មារតីសិស្សចូលរួមស្វ័យសិក្សារបាំនេសាទដែលជាអត្តសញ្ញាណជាតិខ្មែរ បន្តផ្សព្វផ្សាយរបៀបនេសាទត្រីជាលក្ខណៈគ្រួសារដោយប្រើឧបករណ៍នេសាទបែបបុរាណ ដើម្បីជួយកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន សេដ្ឋកិច្ច និងសង្គម។(GCED)

## II.សម្ភារៈឧបទេសៈ

- រូបភាពទាក់ទងពីរបាំនេសាទ
- វីដេអូ
- ឧបករណ៍បំពងសម្លេង
- ឯកសារមេរៀន

## III.វិធីសាស្ត្របង្រៀន ៖

- ពន្យល់ និងសួរឆ្លើយ ដោយបញ្ជ្រាបGCED

## IV.ដំណើរការបង្រៀន៖

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| **ជំហានទី១ ៖ លំនឹងថ្នាក់ (២នាទី)** | | |
| -គ្រូសួរសុខទុក្ខសិស្ស និងព័ត៌មានដែលសិស្សបានជួបនាពេលធ្វើដំណើរមកសាលារៀន<br>-ពិនិត្យអវត្តមាន និងវិន័យ និត្យអនាម័យ សណ្ដាប់ធ្នាប់ និងឯកសណ្ឋានគរុសិស្ស | **(រដ្ឋបាលថ្នាក់)**<br>(GCED) | -សិស្សរៀបរាប់ព័ត៌មានដែលបានជួប<br>-ប្រធានក្រុម ឬអនុប្រធានថ្នាក់ រាយការណ៍ អវត្តមានកូនក្រុម<br>-សិស្សឈរគ្រូពិនិត្យឯកសណ្ឋាន |
| **ជំហានទី២ ៖ រំលឹកមេរៀនចាស់ (៣នាទី)** | | |
| -តើសិល្បៈរបាំខ្មែរមានប៉ុន្មានប្រភេទ ?អ្វីខ្លះ ? | - សិល្បៈរបាំខ្មែរមាន៣ប្រភេទ គឺរបាំព្រះរាជទ្រព្យ របាំប្រពៃណី របាំប្រជាប្រិយ ។ | - សិស្សគិតរកចម្លើយដែលគ្រូបានសួរ<br>- សិស្សឡើងឆ្លើយនូវចម្លើយដែលគាត់បានគិតឃើញ |
| **ជំហានទី៣៖ខ្លឹមសារមេរៀនថ្មី(៤០នាទី)** | | |

| | | |
|---|---|---|
| | **មេរៀនទី៣ របាំខ្មែរ (ត)**<br>៣.១.២ របាំប្រពៃណី | |
| -ដូចម្ដេចដែលហៅថាប្រភេទរបាំប្រពៃណី ហើយប្រភេទរបាំនេះមានរបាំអ្វីខ្លះ? | - ប្រភេទរបាំប្រពៃណី គឺរបាំប្រពៃណី គឺសម្គាល់របាំទាំងឡាយដែលស្ថិតជាប់នឹងពិធីប្រពៃណី ឬ ពិធីតំណត្រកូលដ៏យូរលង់មក ហើយរបស់ជនជាតិខ្មែរ ឬជនជាតិដទៃទៀត ទាំងអស់ដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាក្នុងតំបន់ខុសៗគ្នាទាំងមានការនិយមដូចគ្នាក្ដី ឬការនិយមខុសគ្នាក្ដី នៅតំបន់ភ្នំ តំបន់ខ្ពង់រាប តំបន់ វាលទំនាបទន្លេមេគង្គ និងតំបន់មាត់សមុទ្រ ។ មានដូចជា របាំក្ងោកប៉ៃលិន របាំគោះត្រឡោក របាំកណ្ដូបសេះ គោះអង្រែ របាំនេសាទ របាំត្រុដិ......។ | - សិស្សគិតរកចម្លើយដែលគ្រូបានសួរ និងឆ្លើយសំណួរគ្រូ |
| | ២.៣ របាំនេសាទ (GCED) | |
| -តើរបាំនេសាទមានលក្ខណៈយ៉ាងដូចម្ដេចខ្លះ? | - របាំនេសាទបានបង្ហាញពីសម្បត្តិធម្មជាតិនៃមាតុភូមិយើងមានលក្ខណៈអំណោយផលល្អណាស់សម្រាប់ជីវិតប្រជាជន កម្ពុជាយើងនេះ ។ បឹងទន្លេសាបជាជង្រុកត្រីដ៏ធំហើយមាន ត្រីច្រើនសំបូរបែប ជាបឹងមួយដែលមានឈ្មោះល្បីផងនៅ ក្នុងពិភពលោកនេះ។ ក្រៅពីនេះយើងនៅមានមាត់សមុទ្រ ទន្លេ ស្ទឹង ត្រពាំង បឹងជាច្រើនទៀតដែលសុទ្ធតែជាជម្រក បន្តពូជត្រី ដើម្បីចិញ្ចឹមផ្គត់ផ្គង់ជីវភាពប្រជារាស្ត្រខ្មែរឱ្យរស់ នៅបានដោយសុខស្រួល។ មិនតែប៉ុណ្ណោះទេ វាលស្រែដ៏ធំ ល្វឹងល្វើយនៅឆ្ងាយពីស្ទឹងទន្លេ ដែលគេមើលទៅឃើញ តែ ថ្ងៃបណ្ដើរកូនព្រិចៗនៅខែចែត្រក្នុងរដូវប្រាំងនោះ... លុះ ដល់ពេលមានភ្លៀងធ្លាក់ ហើយមានទឹកដក់បន្តិចបន្តួច តាម | - សិស្សគិតរកចម្លើយដែលគ្រូបានសួរ និងឆ្លើយសំណួរគ្រូ |

| | | |
|---|---|---|
| -តើរបាំនេសាទ និងរូបភាពរបាំនេសាទបាន បង្ហាញពីអត្តចរិកប្រជាជនខ្មែរបែបណាខ្លះ? | វាលស្រែក៏បែរជាមានមាត់ត្រីរអ៊ិចនៅតាមវាលស្រែនោះ។<br>( GCED )<br><br> | - សិស្សគិតរកចម្លើយដែលគ្រូបានសួរ និងឆ្លើយសំណួរគ្រូ |
| -តើរបាំនេសាទបម្រើដោយវង់ភ្លេងអ្វី?ហើយសម្តែងក្នុងកម្មវិធីអ្វីខ្លះ?ចូរបង្ហាញឱ្យបានច្បាស់លាស់។ | -របាំនេសាទ និងរូបភាពរបាំនេសាទបាន បង្ហាញពីអត្តចរិកប្រជាជនខ្មែរដូចជាៈចលនាក្បាច់ទាំងស្រីទាំងប្រុសទន់ភ្លន់រហ័សរហួនស្វាហាប់ រីឯអត្តចរិកស្លូតបូតសុភាពរាបសាអធ្យាស្រ័យគ្នាទៅវិញទៅមក ប្រកបដោយការសាមគ្គីភាពក្នុងសហគមន៍រស់នៅជុំវិញខ្លួន និងភាពទទួលខុសត្រូវតាមបែបប្រពៃណី សង្គម វប្បធម៌ជាតិខ្មែរ។ | |

<table>
<tr>
<td></td>
<td>
<br>របាំនេសាទបម្រើដោយវង់ភ្លេងខ្មែរមួយប្រភេទគឺវង់ភ្លេងមហោរី ហើយសម្ដែងជូនក្នុងកម្មវិធីដូចជា៖<br>ទទួលគណៈប្រតិភូជាតិ អន្តរជាតិក្នុងពិធីលៀងស័យភោជៈ ជូនអង្គទូតបណ្ដាប្រទេសនានា ពិធីបុណ្យអុំទូក ពិធីរៀបអាពាហ៍ពិពាហ៍ ឡើងគេហដ្ឋានថ្មី បញ្ចុះសីម៉ា.........។ល។<br></td>
<td>- សិស្សគិតរកចម្លើយដែលគ្រូបានសួរ និងឆ្លើយសំណួរគ្រូ</td>
</tr>
<tr>
<td colspan="3">ជំហានទី៤៖ ពង្រឹងពុទ្ធិ (៣នាទី)</td>
</tr>
<tr>
<td>-តើការសិក្សារបាំនេសាទផ្ដល់អត្ថប្រយោជន៍ដែលឬទេដល់អ្នកសិក្សា ?អ្វីខ្លះ ?ចូរបង្ហាញឱ្យបានច្បាស់លាស់។</td>
<td>( GCED )<br>-ការសិក្សារបាំនេសាទបានផ្ដល់អត្ថប្រយោជន៍យ៉ាងសំបូរបែបដល់អ្នកសិក្សាមានដូចជា៖ ទទួលបាននូវកាយសម្បទាសម្រស់សម្រ ក្បួនក្បាច់ចលនារបាំ ចេះបញ្ចូលសញ្ចេតនាក្នុងការសម្ដែង ចេះធ្វើការរួមគ្នាប្រកបដោយបរិយាកាសរីករាយ ស្គាល់ឧបករណ៍នេសាទមួយបែបរបស់</td>
<td>-សិស្សព្យាយាមឆ្លើយរៀងៗខ្លួនតាមរយៈចំណេះដឹងពីមេរៀននិងការស្រាវជ្រាវ ដែលពួកគេបានសិក្សារួច។</td>
</tr>
</table>

| | | |
|---|---|---|
| | ខ្មែរ ដែលបានប្រើតាំងពីបុរាណ បានចូលរួមថែរក្សារបាំប្រពៃណី ក៏ដូចជាបានចូលរួមផ្សព្វផ្សាយដល់ការប្រើប្រាស់ឧបករណ៍នេសាទដែលខុសច្បាប់នាំឲ្យបំផ្លាញពូជត្រី និងបរិស្ថានផងដែល។<br><br><br> | |
| **ជំហានទី៥៖បណ្តាំផ្ញើ(២នាទី)** | | |

| | | |
|---|---|---|
| -ឲ្យសិស្សមើលមេរៀនដែលទើបនឹងបានរៀនឡើងវិញ ហើយ និងរៀនពត់ដៃជើងនៅផ្ទះដើម្បីត្រៀមការអនុវត្តរបាំនេសាទ។ |   | -សិស្សស្តាប់គ្រូណែនាំ |

**ប្រធានបទ៖ រចនាខ្លែង (បេតិកភណ្ឌវប្បធម៌អរូបីយ៍)**

**សោភណ្ឌ សុភ័ក្ត្រ ស្រី សុកសាផាត គង់ វលក្ខណ៍**
**វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**

កាលបរិច្ឆេទ៖ ថ្ងៃ ...............................ខែ........................ឆ្នាំ...................ព.ស.២៥៦...
ត្រូវនឹងថ្ងៃទី................ខែ..............ឆ្នាំ២០.........

មុខវិជ្ជា ៖ អប់រំសិល្បៈ
ជំពូក២ ៖ ហត្ថកម្ម
មេរៀន ៖ រចនាខ្លែង
ថ្នាក់ទី៧

## ១. វត្ថុបំណង ៖ បន្ទាប់ពីបានសិក្សាមេរៀនខ្លែង

. **វិជ្ជាសម្បទា** រៀបរាប់អំពីការរចនាខ្លែង**ដែលជាវប្បធម៌ចំរុះ**ជាមូលដ្ឋានដើម្បីឆ្ពោះទៅការបង្កើតគំនិតច្នៃប្រតិដ្ឋថ្មី ដែលមានលក្ខណៈវិទ្យាសាស្ត្រ វប្បធម៌ និងសង្គមតាមរយៈឯកសារសកលរបស់យូណេស្កូ ។

. **បំណិនសម្បទា** ប្រើប្រាស់បច្ចេកទេសនិងសម្ភារៈបានត្រឹមត្រូវក្នុងការរចនាផលិតខ្លែងតាមលំនាំ**ខ្លែងខ្មែរនិងខ្លែងផ្សេងៗ** ដែលអាចបង្ហោះលេងជាមួយគ្នា និងចែករំលែកការយល់ឃើញអំពីខ្លែងតាមរយៈរូបគំរូ ។

. **ចរិយាសម្បទា** មានស្មារតី**ចេះជួយគ្នាទៅវិញទៅមក ដើម្បីលើកស្ទួយ និងចូលរួមក្នុងការផ្សព្វផ្សាយ លើកកម្ពស់ស្នាដៃសិល្បៈ ជាសកល** បានត្រឹមត្រូវ ដោយយកគំរូតាម ស្នាដៃសិល្បៈដូនតា ។

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| | **ជំហានទី ១ (៣ នាទី)** | |
| . សូមរក្សាសណ្ដាប់ធ្នាប់នៅកន្លែងអង្គុយ<br>. តើមានអ្នកអវត្តមានឬទេ?<br>**. តើប្អូនៗធ្លាប់បានទៅទស្សនាសារមន្ទីរសិល្បៈដែរទេ?និងបានឃើញអ្វីខ្លះនៅទីនោះ?** (GCED) | ពិនិត្យសណ្ដាប់ធ្នាប់ក្នុងថ្នាក់រៀន និង**ចែករំលែកបទពិសោធន៍** | . ចូលរួមសម្អាតថ្នាក់បានស្អាតល្អ<br>. ប្រាប់ពីការចូលរួមក្នុងថ្នាក់រៀន |

| | | |
|---|---|---|
| | | . នៅសារមន្ទីមានការតាំងស្នាដៃសិល្បៈជាច្រើន **ទាំងបុរាណនិងទំនើប លក្ខណៈជាតិនិងអន្តរជាតិ។** |
| **ជំហានទី ២ (៥ នាទី)** | | |
| . ចូរប្អូនធ្វើការបង្ហាញពីបច្ចេកទេសធ្វើស្នាដៃចម្លាក់អំពីសម្ភារៈដែលអាចប្រើប្រាស់ឡើងវិញនេះ។  | រំលឹកពីបទពិសោធន៍ដែលបានរៀនកន្លងមក | . បកស្រាយតាមស្ថានភាពរូបដែលបានធ្វើនៅក្នុងថ្នាក់។ |
| **ជំហានទី ៣ (៣០ នាទី)** | | |
| **. ចូរប្អូនៗទស្សនារូបភាពខ្លែងឯកខ្មែរ និងខ្លែងតាមបណ្តាប្រទេសមួយចំនួនទៀត ព្រមទាំងវីដេអូ និយាយអំពីខ្លែងឯកខ្មែរ។** (GCED)     . ចូរប្អូនសង្កេតលើសម្ភារៈទាំងអស់នេះ។ (មានសម្ភារៈបង្ហាញផ្ទាល់)   | មេរៀន រចនាខ្លែង<br>. បទបង្ហាញប្រវត្តិខ្លីៗអំពីខ្លែងខ្មែរ និងខ្លែង<br>(តាមរយៈឯកសារអត្ថបទ រូបភាព វីដេអូ)<br>. ណែនាំពីការប្រើប្រាស់សម្ភារៈ<br>. បង្ហាញពីបច្ចេកទេសធ្វើខ្លែងឯកខ្មែរតាមជំហានៗ (ដោយផ្ទាល់ឬតាមរយៈវីដេអូ) | . ទស្សនាដោយយកចិត្តទុកដាក់ និងកត់ចំណាំ។<br>. កត់ចំណាំរាល់សម្ភារៈទាំងអស់ដែលបានបង្ហាញ។<br>. សាកល្បងធ្វើតាមការណែនាំ<br>. ដើរទស្សនាស្នាដៃមិត្តភក្តិ។ |

| | | |
|---|---|---|
| . ចូរប្អូនសាកល្បងធ្វើតាមបច្ចេកទេសនេះជាមួយគ្រូ។<br><br>. សម្របសម្រួលសកម្មភាពពេលធ្វើស្នាដៃសាកល្បង។ | | |
| **ជំហានទី ៤ (១០ នាទី)** | | |
| . ចូរប្អូនបង្ហាញពីបច្ចេកទេសនិងសម្ភារៈក្នុងការរចនាខ្លែងរបស់ប្អូន។<br>**. ចូរប្អូនបង្ហាញចំណាប់អារម្មណ៍អំពីខ្លែងតាមបណ្ដាប្រទេសផ្សេងៗដែលទើបតែបានរៀនរួចហើយ។ (GCED)**<br>. ចូររៀបចំសម្អាតសម្ភារៈឱ្យបានស្អាតឡើងវិញ។ | ពង្រឹងចំណេះដឹងក្នុងសកម្មភាពមេរៀននេះ | . បានបង្ហាញតាមលទ្ធភាពដែលចងចាំ។<br>**. បង្ហាញចំណាប់អារម្មណ៍ អំពីខ្លែងនៃបណ្ដាប្រទេសផ្សេងៗ។ (GCED)**<br>. កិច្ចការរៀបចំសម្ភារៈទៅតាមកន្លែងឡើងវិញ។ |
| **ជំហានទី ៥ (៣ នាទី)** | | |
| **. ចូរប្អូនៗសាកល្បងធ្វើកិច្ចការនេះដោយគូរព្រាងរូបរាងខ្លែងផ្សេងៗនិងខ្លែងឯកដែលប្អូនស្រឡាញ់ជាមួយពុកម៉ែនិងបងប្អូនមិត្តភក្ដិនៅផ្ទះដើម្បីទទួលបានចំណេះដឹងបន្ថែមនិងជួយផ្សព្វផ្សាយវប្បធម៌ផងដែរ។ (GCED)** | បណ្ដាំផ្ញើផ្សេងៗទាក់ទងនឹងមេរៀននេះ។ | . យកចិត្តទុកដាក់និងរៀបចំសម្រាក |

# ប្រធានបទ៖ រឿង ទុំទាវ( នំមិនធំជាងនាឡិ )

គួយ សុគាន
វិទ្យាស្ថានជាតិអប់រំ

កាលបរិច្ឆេទ ៖ថ្ងៃ………ខែ…………ឆ្នាំ....................... ព.ស.២៥៦....
ត្រូវនឹងថ្ងៃទី……………ខែ…………………ឆ្នាំ២០២....
មុខវិជ្ជា ៖ អក្សរសាស្ត្រខ្មែរ
ថ្នាក់ ៖ ទី១១
មេរៀន ៖ សមត្ថភាពអំណាន
រយៈពេល ៖ ១ម៉ោង

**១-វត្ថុបំណង ៖ ក្រោយពីបានសិក្សាមេរៀននេះចប់ សិស្សានុសិស្សនឹងទទួលបាន៖**

**ក-វិជ្ជាសម្បទា៖**

- ប្រាប់ពីផ្នត់គំនិតទុកដាក់កូនចៅ(ទស្សនៈនំមិនធំជាងនាឡិ) និងការតស៊ូទាមទារសេរីភាពរបស់កូនស្រីក្នុងសម័យលង្វែកបានច្បាស់លាស់តាមរយៈការអានអត្ថបទកំណាព្យ

**ខ-បំណិនសម្បទា៖**

- វិភាគពិចារណាផ្នត់គំនិតទុកដាក់កូនចៅ(ទស្សនៈនំមិនធំជាងនាឡិ) និងការតស៊ូសេរីភាពតាមរយៈការពិភាក្សាក្រុម

**គ-ចរិយាសម្បទា៖**

- ចូលរួមកែលម្អពីផ្នត់គំនិតទុកដាក់កូនចៅ(ទស្សនៈនំមិនធំជាងនាឡិ) ក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ន។

**២-សម្ភារឧបទេស**

- សៀវភៅសិក្សាគោលទំព័រ២៨-៣២ ដកស្រង់អត្ថបទរឿងទុំទាវរបស់ព្រះភិក្ខុសោមឆ្នាំ១៩១៥
- ក្ដារខៀន ហ្វឺត សៀវភៅសិស្ស សៀវភៅគ្រូ
- វីដេអូទាក់ទងនឹងរឿងទុំទាវ
- រូបភាពមួយចំនួនទាក់ទងនឹងទស្សនៈនំមិនធំជាងនាឡិ

**៣-វិធីសាស្ត្របង្រៀន៖ វិធីបង្រៀនតាមបែបរិះរក**( IBL )

**៤-លំនាំនៃការបង្រៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យឯកសណ្ឋាន វិន័យ សណ្ដាប់ធ្នាប់ថ្នាក់រៀន | **ជំហានទី១( ២នាទី )**<br>(រដ្ឋបាលថ្នាក់) | - សិស្សស្ងៀមស្ងាត់ |

| | | |
|---|---|---|
| -តើសប្តាហ៍មុនលោក លោកស្រីបានសិក្សាមេរៀនអ្វី? | **ជំហានទី២( ៥នាទី )**<br>(រំឭកមេរៀនចាស់) | - សិស្សឆ្លើយ |
| -ដូចម្តេចហៅថាទំនៀមទម្លាប់?<br><br><br>-តើទំនៀមទម្លាប់ខ្មែរមានអ្វីខ្លះ?<br><br>-ទំនៀមទម្លាប់ពេលរៀបអាពាហ៍ពិពាហ៍របស់ខ្មែរប្រព្រឹត្តទៅដូចម្តេច? | **មេរៀន៖ ទំនៀមទម្លាប់ខ្មែរ**<br>-ទំនៀមទម្លាប់គឺអ្វីដែលធ្លាប់ធ្វើតៗតាមគ្នាអាចជាទម្លាប់ល្អ កើតបានជាសុខដុមនីយកម្មក្នុងគ្រួសារ និងសង្គម។<br>-ទំនៀមទម្លាប់ខ្មែរសំខាន់ៗមានគឺ ពេលកើត ពេលការ និងពេលកប់(ស្លាប់)<br>-មុនពេលរៀបការ(ស្ដីដណ្ដឹង) ពេលរៀបការ និងក្រោយពេលរៀបការ។ | -សិស្សឆ្លើយ<br><br><br>-សិស្សឆ្លើយ<br><br>-សិស្សឆ្លើយ |
| | **ជំហានទី៣( ៤៥នាទី )**<br>( …………………. ) | |
|  |  |  |
| | **ការបំផុសគំនិត**<br>https://www.facebook.com/www.education.nic.com.KH/ | |
| -ក្រោយពីទស្សនាវីដេអូរួច។<br>-តើលោកអ្នកអាចកំណត់បាននូវចំណងជើង និងប្រភពអត្ថបទបានយ៉ាងដូចម្តេចដែរ? | -ចំណងជើងនេះ (នំមិនធំជាងនាឡិ)ជាអត្ថបទដកស្រង់ចេញពីរឿងទុំទាវរបស់ព្រះភិក្ខុសោមឆ្នាំ ១៩១៥។<br>-ដូច្នេះ ថ្ងៃនេះ គឺសិក្សា «នំមិនធំជាងនាឡិ»។ | -សិស្សឆ្លើយ |
| -តើអ្នកយល់យ៉ាងដូចម្តេចចំពោះន័យនៃចំណងជើងអត្ថបទនេះ? | -ន័យចំៈ នាឡិ គឺជារង្វាស់បុរាណរបស់ខ្មែរឬពុម្ពសម្រាប់ធ្វើនំ ឬចាក់នំគឺសំដៅយកពែងកែវ ឬកន្ទោងសម្រាប់ចាក់នំអាកោ ចាហួយ។ល។ ហេតុនេះហើយបានលោកពោលថា នំទាំងអស់មិនអាចធំជាងរង្វាល់របស់វាឡើយ។<br>-ន័យធៀបវិញៈនាឡិសំដៅដល់ផ្នត់គំនិតរបស់ឳពុកម្ដាយតាំងពីបុរាណជាពិសេសសម័យសង្វែកក្នុងការ | -សិស្សឆ្លើយ |

| | | |
|---|---|---|
| | ទុកដាក់កូនចៅឱ្យមានគូស្រករ គឺមាតាបិតា ឬអាណាព្យាបាលមានសិទ្ធិសម្រេចទាំងស្រុងលើវាសនាកូនស្រី។ ទោះបីជាកូនស្រីមិនពេញចិត្តនឹងកូនកម្លោះក្តី ក៏មិនហ៊ានប្រកែកដែរដោយខ្លាចអំណាចម្តាយ។ | |
| -គ្រូជំរុញសិស្សឱ្យបង្កើតសំណួរ? | **សំណួរ**<br>-តើទស្សនៈនំមិនធំជាងនាឡិនេះបានឆ្លុះបញ្ចាំងពីផ្នត់គំនិតខ្មែរសំខាន់អ្វីខ្លះក្នុងសម័យលង្វែក? | -សិស្សបង្កើតសំណួរ |
| -គ្រូឱ្យសិស្សរិះរកចម្លើយប៉ាន់ស្មាន | **ចម្លើយ**<br>អត្ថបទកំណាព្យនេះបានឆ្លុះបញ្ចាំងដូចជា៖<br>១-ពិធីស្តីដណ្តឹងលេចឡើងតាមរយៈគ្រួសារអរជូនស្តីដណ្តឹងនាងទាវ<br>២-ទស្សនៈនំមិនធំជាងនាឡិលេចឡើងតាមរយៈម្តាយទាវបង្ខំនាងឱ្យមានគូស្រករ និងផលវិបាក<br>៣-ការតស៊ូមតិរបស់នាងទាវ | -សិស្សឆ្លើយ |
| ក្រុមទី១៖ពិធីស្តីដណ្តឹង<br>GCED | **ការពិភាក្សាក្រុម**<br>១-ពិធីស្តីដណ្តឹងនៃគ្រួសារអរជូនចំពោះនាងទាវ | -សិស្សពិភាក្សាក្រុម |
|  | | |
| -ក្រុមទី២៖នំមិនធំជាងនាឡិ<br>GCE | ២-នំមិនធំជាងនាឡិលេចឡើងតាមរយៈម្តាយទាវបង្ខំនាងមានគូស្រករ និងផលវិបាក | - សិស្សពិភាក្សាក្រុម |



| | | |
|---|---|---|
| | <br>-ចិត្តលោភលន់ហួសហេតុ និងអំណាចផ្តាច់ការនាំឱ្យបាត់បង់កូនស្រីជាទីស្រឡាញ់<br>-ការមិនយល់ចិត្តកូនស្រីនាំឱ្យមានការសោកស្តាយថ្ងៃក្រោយ។<br>-ម្តាយទាវក្លាយជាអ្នកងារ និងត្រូវកប់ទាំងរស់(ទោស) | |
| ក្រុមទី៣៖ ការតស៊ូមតិរបស់នាងទាវ<br>GCED | ៣-ការតស៊ូមតិរបស់នាងទាវ<br> | -សិស្សពិភាក្សាក្រុម |
| -គ្រូឱ្យសិស្សសន្និដ្ឋាន<br>GCED | **សន្និដ្ឋាន៖**<br>ដូច្នេះ អត្ថបទកំណាព្យនេះពិតជាមានរូបារម្មណ៍យ៉ាងវិសេសវិសាលក្នុងការទាក់ទាញអ្នកអាន និងមានខ្លឹមសារឆ្លុះបញ្ចាំងពីផ្នត់គំនិត ដែលជាទំនៀមទម្លាប់ខ្មែរ ហើយក៏បានបង្ហាញពីចិត្តលោភលន់ស្រឡាញ់បុណ្យសក្តិ និងការបង្ខិតបង្ខំកូនស្រីឱ្យរៀបការទាំងនាងមិនពេញចិត្ត ហើយនាំឱ្យនាងបាត់បង់ជីវិតទៅតាមប្តីរបស់នាង។ ផ្នត់គំនិតនេះពុំមែនកើតតែក្នុងស្រុកខ្មែរទេ សូម្បីតែក្នុងប្រទេសអង់គ្លេសក៏មានរឿងប្រហាក់ប្រហែលគ្នានេះបានកើតឡើងដែរតាមរយៈរឿងរ៉ូមេអូ និងស្សូរីយ៉ែត។ ដូចនេះ ឥទ្ធិពលនៃផ្នត់គំនិតនំមិនធំជាងនាឡិបានប្រែក្លាយជាការតស៊ូទាមទារសេរីភាពមួយសម្រាប់ | -សិស្សសន្និដ្ឋាន |

| | | |
|---|---|---|
| | យុវជនខ្មែរនាពេលបច្ចុប្បន្នក្នុងការសម្រេចចិត្តរើសគូស្រករ ដើម្បីរៀបចំសុភមង្គល។ | |
| -តើទស្សនៈនំមិនធំជាងនាឡិបានផ្តល់នូវគុណវិបត្តិអ្វីខ្លះដល់គ្រួសារនាងទាវ | **ជំហានទី៥(៥នាទី)**<br>(ពង្រឹងពុទ្ធិ)<br>-ស្លាប់នាងទាវជាកូនស្រីតែមួយគត់<br>-ម្តាយបាត់បង់កូនជាទីស្រឡាញ់<br>-មហិច្ឆតាទាំងឡាយត្រូវរលាយអស់<br>-ម្តាយនានាជំនាន់ក្រោយមិនយកគំរូតាម | - សិស្សឆ្លើយ |
| -ចូរប្អូនៗសាកល្បងសិក្សាពីផ្នត់គំនិតរបស់មាតា បិតាក្នុងការទុកដាក់កូនចៅឱ្យមានគូស្រករក្នុងសហគមន៍ប្អូនកំពុងរស់នៅ។ | **ជំហានទី៥(៣នាទី)**<br>(បណ្តាំផ្ញើ)<br>កិច្ចការផ្ទះ | -សិស្សកត់ត្រា |

# ប្រធានបទ៖ តម្លៃ និងសីលវិជ្ជា

ឡុច ចាន់ថន ប៉ូ ប៊ុន្ថន
វិទ្យាស្ថានជាតិអប់រំ

**កាលបរិច្ឆេទ** ៖ ថ្ងៃ.................... ខែ.......... ឆ្នាំ...........ព.ស. ២៥៦......
ត្រូវនឹងថ្ងៃ................ខែ.......... ឆ្នាំ២០២.......
**មុខវិជ្ជា** ៖ សីលធម៌ពលរដ្ឋវិជ្ជា
**ប្រធានបទ** ៖ តម្លៃ និងសីលវិជ្ជា រយៈពេល២ម៉ោង
**រយៈពេល** ៖ ១ម៉ោង (ម៉ោងទី២)

## I. វត្ថុបំណងមេរៀន

ក្រោយពីបញ្ចប់ការសិក្សាមេរៀននេះ អាចបញ្ជ្រាបខ្លឹមសារពលរដ្ឋសកលដល់អ្នកសិក្សាអំពី៖

- **វិជ្ជាសម្បទា/ពុទ្ធិ៖** សីលវិជ្ជាឬទស្សនវិជ្ជាសីលវិជ្ជា ហេតុដែលនាំឱ្យយើងសិក្សាទស្សនវិជ្ជាសីលធម៌ កត្តាសំខាន់ៗក្នុងការវាយតម្លៃសីលអំពើ និងហេតុផលបណ្តាលឲ្យមានសីលធម៌
- **បំណិនសម្បទា/ចិត្ត-សង្គម៖** វាយតម្លៃសីលវិជ្ជា ហេតុផលនៃទស្សនវិជ្ជាសីលធម៌ កត្តាសំខាន់ៗក្នុងការវាយតម្លៃសីលអំពើ និងហេតុផលបណ្តាលឲ្យមានសីលធម៌
- **ចរិយាសម្បទា/ឥរិយាបថ៖** បណ្តុះស្មារតី ចូលរួម ឱ្យតម្លៃ និងប្រតិបត្តិ សីលវិជ្ជា និងអំពើផ្សេងៗដោយមានទំនួលខុសត្រូវខ្ពស់ក្នុងនាមជាពលរដ្ឋសង្គម

## II. សម្ភារៈឧបទ្ទេស៖

ប្រធានបទ ស្តីពី **តម្លៃ និងសីលវិជ្ជា ដែល**រៀបចំដោយក្រុមការងារ GCED នៃវិទ្យាស្ថានជាតិអប់រំ និងឯកសារយោងដែល ពាក់ព័ន្ធជាមួយកម្មវិធីបណ្តុះបណ្តាលមធ្យមសិក្សា..

## III. វិធីសាស្ត្របង្រៀន៖ សិស្សមជ្ឈមណ្ឌល បែបពិភាក្សា និងការងារក្រុម៖

## IV. ដំណើរការមេរៀន

| **សកម្មភាពគ្រូ** | **ខ្លឹមសារ** | **សកម្មភាពសិស្ស** |
|---|---|---|
| រដ្ឋបាលថ្នាក់រៀន<br><br>ពិនិត្យវត្តមាន<br><br>អនាម័យ | **ជំហានទី១**<br><br>**ពង្រឹងថ្នាក់**<br><br>*(៣ នាទី)* | ក្រោកឈរ ស្ងៀមស្ងាត់<br><br>ប្រធានថ្នាក់រាយការណ៍<br><br>**កិច្ចស្វាគមន៍**(GCED)៖<br><br>ការសួរ សុខទុក្ខសិស្ស ឆ្លុះបញ្ចាំងនូវការអប់រំពលរដ្ឋសកល..ការស្រលាញ់ យកចិត្តទុក្ខដាក់ ព្រួយបារម្មណ៍ (GCED) |

| | | |
|---|---|---|
| ❖ សំណួរអំពីមេរៀនចាស់<br>តើតម្លៃអត្តនោម័ត និងសត្យានុម័តជាអ្វី?<br>តើគេចែកតម្លៃប៉ុន្មានកម្រិតអ្វីខ្លះ?<br><br>**គ្រូបំផុសសំណួរទាក់ទង (GCED)៖**<br>**តើតម្លៃនោះមានពាក់ព័ន្ធជាមួយការអប់រំភាពជាពលរដ្ឋសកល?** | **ជំហានទី២**<br>**រម្លឹកមេរៀនចាស់៖**<br>**មេរៀន តម្លៃ និងសីលវិជ្ជា**<br>*(៧ នាទី)* | **សិស្សឆ្លើយជាលក្ខណៈបុគ្គល**<br>- តម្លៃអត្តនោម័ត និងសត្យានុម័ត<br>- ការបែងចែកតម្លៃមាន៖ តម្លៃកម្រិតទាប និងតម្លៃកម្រិតខ្ពស់<br>**ការជ្រើសរើសតម្លៃអាចជា(GCED)៖**<br>- ជាសេរីភាព<br>- ជាសិទ្ធិ និងការរស់រានមានជីវិត<br>- កាតព្វកិច្ច ករណីកិច្ច<br>- ជាផលប្រយោជន៍<br>- ជាឧត្តមគតិ គតិបណ្ឌិត<br>- ជាសញ្ចេតនា និងការទទួលខុសត្រូវ ជាអំណាច ទ្រព្យសម្បត្តិ |
| គ្រូបែងចែកសិស្សជាក្រុម | **ជំហានទី៣៖ មេរៀនថ្មី**<br>*(៣៥ នាទី)*<br>**តម្លៃ និងសីលវិជ្ជា(ត)** | **សិស្សរៀបចំក្រុមតាមការណែនាំរបស់គ្រូ** |
| **ក្រុម១៖ សិក្សាពីនិយមន័យសីលវិជ្ជា**<br><br>❖ **ហេតុអ្វីមនុស្សគ្រប់រូបត្រូវមានសីលធម៌(GCED)?** | - សិក្សាពីអ្វីមួយដែលត្រូវ ឬខុសនៅក្នុងទង្វើរបស់មនុស្ស និងការស្វែងរកជីវិតប្រកបដោយកុសល។<br>- ជាការសិក្សាផ្តោតទៅលើគោលការណ៍សីលធម៌ ច្បាប់នៃការប្រព្រឹត្ត ឬប្រព័ន្ធផ្សេងៗដែលគេគួរតែប្រព្រឹត្តតាមយ៉ាងម៉ត់ចត់<br>- សីលវិជ្ជាកំណត់នូវអ្វីដែលជាការប្រព្រឹត្តល្អ និងជាអ្វីដែលជាការប្រព្រឹត្តមិនល្អ។<br>- សីលវិជ្ជាបង្ហាញនូវអំពើរបស់មនុស្សដែលគួរទទួល | **គ្រូឱ្យសិស្សផ្តល់និយមន័យ៖**<br>- សីលវិជ្ជាជាអ្វី?<br>❖ **ហេតុអ្វីមនុស្សគ្រប់រូបត្រូវមានសីលធម៌(GCED)?**<br>- បង្ហាញមនុស្សនូវតម្លៃពិតសម្រាប់ជីវិត បង្កើនន័យសម្រាប់ជីវិត សម្រាប់គ្រួសារ សម្រាប់សង្គម និងពិភពលោក |

| | | |
|---|---|---|
| | យក និងផ្តល់ឲ្យនូវគំរូមួយដោយផ្អែកលើមូលដ្ឋានអាកប្បកិរិយាប្រកបដោយសីលធម៌ ត្រឹមត្រូវ គុណធម៌..។ | |
| **ក្រុម២៖ សិក្សាពីមូលហេតុអ្វីដែលនាំឱ្យយើងត្រូវសិក្សាទស្សនវិជ្ជាសីលធម៌**<br>❖ ហេតុអ្វីមនុស្សគ្រប់រូបត្រូវមានសីលធម៌(GCED)? | - លោក ធីចឹស ថា៖ ហេតុអ្វីបានជាអំពើមួយល្អប្រសើរជាងអំពើមួយទៀត<br>- ទស្សនវិជ្ជាសីលធម៌ព្យាយាមបង្ហាញមនុស្សនូវតម្លៃពិតនៃជីវិត និងបង្កើនន័យឱ្យជីវិត<br>- សីលធម៌ជារបកគំហើញនៃតម្លៃពិតនៃជីវិត និងញ៉ាំងឲ្យមនុស្សប្រួមគ្នាស្វែងរកតម្លៃទាំងនោះ។ | **ហេតុអ្វីបានជាអ្នកត្រូវរស់នៅដោយមានសីលធម៌?**<br>❖ **ហេតុអ្វីមនុស្សគ្រប់រូបត្រូវមានសីលធម៌(GCED)?**<br>- ជីវិតដែលមានតម្លៃគឺជាជិវិតដែលរស់នៅប្រកបដោយសីលធម៌ មានគុណភាពជីវិត និង<br>- ភាពជាពលរដ្ឋសកល |
| **ក្រុម៣៖ សិស្សាពីកត្តាសំខាន់ៗក្នុងការវាយតម្លៃសីលអំពើ**<br>**ក.ហេតុផលជំរុញ៖**<br>**ខ.មធ្យោបាយ៖**<br>❖ គ្រូលើកជាសំណួរបំផុសគំនិតទាក់ទង GCED | - មិនអាចមើលឃើញដោយងាយទេ។ អ្នកដែលអាចដឹងហេតុផលជំរុញនេះច្បាស់គឺមានតែអ្នកធ្វើអំពើដោយផ្ទាល់តែប៉ុណ្ណោះ។<br>- គេអាចវិនិច្ឆ័យខាងសីលធម៌យ៉ាងងាយដោយឈរលើមូលដ្ឋាននៃមធ្យោបាយដែលអ្នកណាម្នាក់យកទៅប្រើប្រាស់។ ឧ.មានវិធីសាស្ត្រជាច្រើនក្នុងការរកប្រាក់ចំណូល ដូចជា រកដោយសុចរិត ខុសច្បាប់ អំពើពុករលួយ កេងប្រវ័ញ្ចអ្នកដទៃ លួច ប្លន់..ជាដើម។ | **តើវង្វាយតម្លៃសីលអំពើរបស់មនុស្សម្នាក់ផ្អែកលើកត្តាអ្វីខ្លះ?**<br>**ចូររៀបរាប់...**<br>ក.ហេតុផលជម្រុញ<br>ខ. មធ្យោបាយ<br>ឧ. គ្មានអាហារបរិភោគ<br>ក.អ្នកប្រព្រឹត្តជាអ្នកដឹងនូវអ្វីដែលខ្លួនត្រូវធ្វើ<br>ខ. សុំទានគេ លួចគេ ប្រព្រឹត្តិអំពើពុករលួច ធក់ប្លន់.... |

| | | |
|---|---|---|
| | | ❖ **គ្រូលើកជាសំណួរបំផុសគំនិតទាក់ទង GCED**<br>- នៅពេលមនុស្សម្នាក់ប្រព្រឹត្តិអ្វីមួយមិនត្រឹមត្រូវដូចជា លួច ឆក់ប្លន់ ប្រព្រឹត្តិអំពើពុករលួយ....<br>- តើមានផលប៉ះពាល់អ្វីខ្លះដល់ភាពជាពលរដ្ឋរបស់អ្នក និងសង្គមរបស់អ្នក? |
| **ក្រុម៤៖ សិក្សាពីមូលហេតុផលដែលបណ្ដាលឲ្យមនុស្សមានសីលធម៌**<br><br>ក.ផលប្រយោជន៍ផ្ទាល់ខ្លួន៖<br><br>ខ.បញ្ញារបស់ព្រះ ឬអាទិទេព៖<br><br>គ.ផលប្រយោជន៍រួម៖<br><br>❖ **ដើម្បីឱ្យបុគ្គល សហគមន៍ សង្គម និងពិភពលោកមាន សន្តិភាព ចៀសផុតពីសង្គ្រាម និងការកាប់សម្លាប់គ្នា(GCED)៖** | លោក ចន ហ្វស្ដើរ្យ បានពេលថា ហេតុផលដែលមនុស្សត្រូវតែប្រកបដោយសីលធម៌ព្រោះ៖<br>- ជាទង្វើល្អ ទោះជាវាមិនទទួលបានភ្លាមៗ ក៏អាចទទួលបាននៅពេលបន្ទាប់ ឬអនាគតដែរ<br>- មនុស្សធ្វើអំពើល្អ ព្រោះតែព្រះរបស់គេចង់ឲ្យគេធ្វើអំពើនោះដើម្បីទទួលរង្វាន់<br>- អ្នកដែលគោរពច្បាប់សីលធម៌ជាក់លាក់មួយនឹងជួយគេឲ្យឈានដល់សង្គមមួយដែលមានលក្ខណៈល្អប្រសើរ។ | **គ្រូឱ្យសិស្សបង្ហាញហេតុផលសីលធម៌ក្នុងជីវិតរស់នៅប្រចាំថ្ងៃ៖**<br>- សីលធម៌នាំមកនូវការគោរព<br>- សីលធម៌នាំមកនូវការចុះសម្រុងគ្នាក្នុងការរស់នៅ<br>- សីលធម៌នាំមកនូវសន្តិភាពពិភពលោក<br>- សីលធម៌លុបបំបាត់សង្គ្រាម<br><br>❖ **ដើម្បីឱ្យបុគ្គល សហគមន៍ សង្គម និងពិភពលោកមាន សន្តិភាព ចៀសផុតពីសង្គ្រាម និងការកាប់សម្លាប់គ្នា(GCED)៖**<br>- មនុស្សម្នាក់ៗត្រូវយល់ដឹងអំពីតម្លៃអត្តនោម័ត សត្យានុម័យ និងទំនាក់ទំនងរបស់វា<br>- មនុស្សត្រូវមានសីលធម៌ក្នុងការរស់នៅមនុស្សត្រូវគោរពច្បាប់រដ្ឋ សាសនា វប្បធម៌ |

| | | |
|---|---|---|
| | | - និងចូលរួមថែរក្សាពិភពលោកឱ្យមាននិរន្តភាពសម្រាប់អ្នកជំនាន់ក្រោយ |
| ❖ **គ្រូសួរសិស្សអំពីសារៈសំខាន់នៃការរស់នៅនិងប្រតិបត្តិសីលធម៌**<br>អ្វីជាសីលវិជ្ជា?<br>តើការរស់នៅដោយមានសីលធម៌ ផ្តល់អត្ថប្រយោជន៍អ្វីដល់អ្នក? សង្គម? | **ជំហានទី៤៖**<br>ការពង្រឹងពុទ្ធិ<br>(៧នាទី) | **សិស្សឆ្លើយសំណួរ ជាលក្ខណៈបុគ្គល**<br>❖ **ដើម្បីឱ្យបុគ្គល សហគមន៍ សង្គម និងពិភពលោកមាន សន្តិភាព ចៀសផុតពីសង្គ្រាម និងការកាប់សម្លាប់គ្នា(GCED)៖**<br>- សិស្សអាចបង្ហាញពីការយល់ដឹងរបស់ពួកគេ តាមរយៈខ្លឹមសារមេរៀន«តម្លៃនិងសីលវិជ្ជា»ជាមួយភាពជាពលរដ្ឋសកល នៅក្នុងបរិបទនៃការរស់នៅរបស់ខ្លួន<br>- គ្រូសម្របសម្រួលខ្លឹមសារមេរៀនជាមួយបរិបទសង្គម និងពិភពលោក |
| **កិច្ចការផ្ទះ៖**<br>ចូរប្អូនៗសម្ភាសចាស់ព្រឹទ្ធចារក្នុងភូមិឱ្យបាន៥នាក់ ពីសារៈប្រយោជន៍នៃការរស់នៅដោយសីលធម៌ | **ជំហានទី៥៖**<br>បណ្តាំផ្ញើរ<br>(៣នាទី) | **បណ្តាំផ្ញើរ**<br>សូមប្អូនៗប្រគល់កិច្ចការនៅថ្ងៃស្អែក<br>និងធ្វើបទបង្ហាញ៣នាទីម្នាក់នៅថ្ងៃស្អែក |

# ប្រធានបទ៖ រដ្ឋាភិបាល

ប្រាក់ ពៅ ផ្លុង តូន

វិទ្យាស្ថានជាតិអប់រំ

**កាលបរិច្ឆេទ** ៖ថ្ងៃ................ខែ.............ឆ្នាំ..................ព.ស. ២៥៦........
ត្រូវនឹងថ្ងៃ ទី............ ខែ............. ឆ្នាំ ២០២.........

**មុខវិជ្ជា** ៖សីលធម៌ពលរដ្ឋវិជ្ជា

**ប្រធានបទ** ៖រដ្ឋាភិបាល (GCED មាននៅក្នុងគោលបំណងទី១៖ប្រព័ន្ធ និងរចនាសម្ព័ន្ធតំបន់ ជាតិ និងអន្តរជាតិ )

**រយៈពេល** ៖១ម៉ោង

## I.វត្ថុបំណង

- **វិជ្ជាសម្បទា/ពុទ្ធិ៖** បង្ហាញពីគោលបំណង តួនាទីរដ្ឋាភិបាលគុណសម្បត្តិ និងគុណវិបត្តិរដ្ឋបាលកណ្តាល មូលហេតុ និងគោលដៅនៃការធ្វើកំណែទម្រង់ បានច្បាស់លាស់ដោយផ្តើមចេញពីខ្លឹមសារមេរៀន។
- **បំណិនសម្បទា/ចិត្ត-សង្គម៖** ពិភាក្សាអំពីទំនួលខុសត្រូវរបស់រដ្ឋបាលកណ្តាល មូលហេតុ និងគោលដៅនៃកំណែទម្រង់ គោលបំណង និងតួនាទីរដ្ឋាភិបាលបានស៊ីជម្រៅតាមរយៈសំណួរពិភាក្សា។
- **ចរិយាសម្បទា/ឥរិយាបថ៖** មានស្មារតីសាមគ្គីភាពក្នុងការចូលរួមអភិវឌ្ឍន៍សង្គម រវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋប្រកបដោយសុខដុមនីយកម្មជាប្រចាំដោយអនុវត្តតាមការអនុវត្តផ្ទាល់។

## II. សម្ភារៈឧបទេ្ទស៖ ក្រដាស់ ស្ទីត សៀវភៅគោល វីដេអូ

## III. វិធីសាស្រ្តបង្រៀន៖ ៖ វិធីសាស្រ្តបង្រៀនបែបគម្រោង ( Project Based Learning )

## IV. ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| រដ្ឋបាលថ្នាក់រៀន<br>ពិនិត្យវត្តមាន<br>អនាម័យសួរសុខទុក្ខសិស្ស | **ជំហានទី១**<br>ពង្រឹងថ្នាក់<br>*(៣ នាទី)* | ក្រោកឈរ ស្ងៀមស្ងាត់<br>ប្រធានថ្នាក់រាយការណ៍<br>**ការសួរ សុខទុក្ខសិស្ស** |

| | | |
|---|---|---|
| សួរសំណួរអំពីមេរៀនចាស់<br>បង្ហាញរូបភាព ថ្នាក់ដឹកនាំ<br>បង្ហាញវីដេអូស្ដីពីការប្រជុំគណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | **ជំហានទី២**<br>រម្លឹកមេរៀនចាស់<br>*(៧ នាទី)* | សិស្សឆ្លើយជាលក្ខណៈបុគ្គល<br>តាមរយៈការមើលវីដេអូ ពីម្សិលមិញ (ការប្រជុំគណៈរដ្ឋមន្ត្រី)<br>**ហេតុអ្វីបានជាមានការប្រជុំគណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា?** |
| គ្រូចាក់វីដេអូ បន្ទាប់មកពន្យល់<br>(ការប្រជុំគណរដ្ឋមន្ត្រី)<br>គ្រូបែងចែកសិស្សជា៤ក្រុម<br>ពិភាក្សារយៈពេល១៥នាទី និងធ្វើបទបង្ហាញ១ក្រុម០៣នាទី | **ជំហានទី៣៖ មេរៀនថ្មី**<br>*(៣០ នាទី)*<br>រដ្ឋាភិបាល | **សិស្សមើលវីដេអូ បន្ទាប់មកស្ដាប់គ្រូពន្យល់។**<br>ការប្រជុំរបស់គណៈរដ្ឋមន្ត្រីគឺជាការប្រជុំពេញអង្គ ដើម្បីសម្រេចដោះស្រាយរាល់កិច្ចការទូទៅរបស់រដ្ឋាភិបាល។ |

| | | |
|---|---|---|
| **ក្រុមទី១.** រដ្ឋបាលកណ្តាលមានគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះ? <br><br> (គ្រូណែនាំសិស្សគ្រប់ក្រុមឱ្យពិនិត្យទៅសំណួរច្បាស់លាស់ ដើម្បីយល់ច្បាស់ពីបញ្ហា បន្ទាប់មកណែនាសិស្សឱ្យបង្កើតផែនការ ដើម្បីដោះស្រាយបញ្ហា ជាចុងក្រោមគ្រូណែនាំសិស្សក្នុងការវាយតម្លៃលើដំណោះស្រាយក្រុមរបស់ខ្លួន និងតំណាងក្រុមធ្វើបទបង្ហាញ) | **- គុណសម្បត្តិរដ្ឋបាលកណ្តាល៖** <br><br> - មានភាពខ្លាំងធ្វើឱ្យមានការឯកភាពគ្នាក្នុងការអនុវត្តការងារដូចគ្នា ដោយគ្មានករណីពិសេស ឬដោយឡែកសម្រាប់មូលដ្ឋានណាមួយឡើយ។ <br><br> - ផ្តល់ជូនប្រជាពលរដ្ឋនូវសិទ្ធិស្មើគ្នាក្នុងការរួមវិភាគទាន អនុវត្តការងារដែលតម្រូវឱ្យធ្វើ ។ <br><br> **+ គុណវិបត្តិរដ្ឋបាលកណ្តាល៖** <br><br> - ការប្រមូលផ្តុំអំណាចរដ្ឋបាលឱ្យនៅតែមួយកន្លែង និងធ្វើឱ្យដំណើរការរដ្ឋបាលកណ្តាលមានបន្ទុកធ្ងន់ធ្ងរ។ <br> - ប្រធានស្ថាប័នរដ្ឋបាលកណ្តាលមិនអាចអោបក្រសោមការងារទាំងអស់បានទេ។ | **- គុណសម្បត្តិរដ្ឋបាលកណ្តាល៖** <br><br> - មានភាពខ្លាំងធ្វើឱ្យមានការឯកភាពគ្នាក្នុងការអនុវត្តការងារដូចគ្នា ដោយគ្មានករណីពិសេស ឬដោយឡែកសម្រាប់មូលដ្ឋានណាមួយឡើយ។ <br><br> - ផ្តល់ជូនប្រជាពលរដ្ឋនូវសិទ្ធិស្មើគ្នាក្នុងការរួមវិភាគទាន អនុវត្តការងារដែលតម្រូវឱ្យធ្វើ ។ <br><br> **+ គុណវិបត្តិរដ្ឋបាលកណ្តាល៖** <br><br> - ការប្រមូលផ្តុំអំណាចរដ្ឋបាលឱ្យនៅតែមួយកន្លែង និងធ្វើឱ្យដំណើរការរដ្ឋបាលកណ្តាលមានបន្ទុកធ្ងន់ធ្ងរ។ <br><br> - ប្រធានស្ថាប័នរដ្ឋបាលកណ្តាលមិនអាចអោបក្រសោមការងារទាំងអស់បានទេ។ |

| | | |
|---|---|---|
| **ក្រុមទី២៖** មូលហេតុអ្វីបានជាមានការធ្វើកំណែទម្រង់ ហើយកំណែទម្រង់មានគោលដៅដូចម្តេច? | **+ ការធ្វើកំណែទម្រង់ដើម្បី៖**<br>- ប្រសិទ្ធភាពសេវាសាធារណៈជូនប្រជាពលរដ្ឋ ដូចជា៖<br>- ប្រជាពលរដ្ឋមានលទ្ធភាពចូលរួមយ៉ាងសកម្មនៅមូលដ្ឋាន។<br>- ផ្តល់សេវាសាធារណៈរបស់ក្រសួងស្ថាប័ននៅថ្នាក់ជាតិកាន់តែរហ័ស និងមានប្រសិទ្ធិភាព។<br>- បង្កើននូវលទ្ធភាពនៃការរកប្រភពធនធាននៅមូលដ្ឋានសម្រាប់ផ្តល់សេវា និងការអភិវឌ្ឍ។<br>**+ ទិសដៅកំណែទម្រង់រដ្ឋបាល**<br>- ដើម្បីលើកកម្ពស់ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យ។<br>- កាត់បន្ថយភាពក្រីក្រតាមរយៈការបង្កលក្ខណៈឱ្យប្រជាពលរដ្ឋធ្វើសេចក្តីសំរេច ទាក់ទងនឹងតម្រូវការចាំបាច់នានានៅមូលដ្ឋាន។ | **+ ការធ្វើកំណែទម្រង់ដើម្បី៖**<br>- ប្រសិទ្ធិភាពសេវាសាធារណៈជូនប្រជាពលរដ្ឋ ដូចជា៖<br>- ប្រជាពលរដ្ឋមានលទ្ធភាពចូលរួមយ៉ាងសកម្មនៅមូលដ្ឋាន<br>- ផ្តល់សេវាសាធារណៈរបស់ក្រសួងស្ថាប័ននៅថ្នាក់ជាតិកាន់តែរហ័ស និងមានប្រសិទ្ធិភាព។<br>- បង្កើននូវលទ្ធភាពនៃការរកប្រភពធនធាននៅមូលដ្ឋានសម្រាប់ផ្តល់សេវា និងការអភិវឌ្ឍ។<br>**+ ទិសដៅកំណែទម្រង់រដ្ឋបាល**<br>- ដើម្បីលើកកម្ពស់ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យ។<br>- កាត់បន្ថយភាពក្រីក្រតាមរយៈការបង្កលក្ខណៈឱ្យប្រជាពលរដ្ឋធ្វើសេចក្តីសំរេច ទាក់ទងនឹងតម្រូវការចាំបាច់នានានៅមូលដ្ឋាន។ |

| | | |
|---|---|---|
| **ក្រុមទី៣.** ចូរគូសដ្យាក្រាមរចនាសម្ព័ន្ធ និងរដ្ឋបាលឯកភាព និងតួនាទីស្ថាប័ននីមួយៗ ។ | **+ រដ្ឋបាលឯកភាព**<br><br>- ជាការរៀបចំឱ្យមានក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអាចម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធាន រាប់ទាំងហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិក្នុងមូលដ្ឋាន ហើយក្រុមប្រឹក្សានីមួយៗ មានលទ្ធភាពសម្របសម្រួលប្រកបដោយប្រសិទ្ធភាព ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋតាមមូលដ្ឋាន។ | **+ សិស្សគូសដ្យាក្រាមបង្ហាញអំពីរដ្ឋបាលឯកភាព**<br><br>- ជាការរៀបចំឱ្យមានក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអាចម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធាន រាប់ទាំងហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិក្នុងមូលដ្ឋាន ហើយក្រុមប្រឹក្សានីមួយៗ មានលទ្ធភាពសម្របសម្រួលប្រកបដោយប្រសិទ្ធភាព ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋតាមមូលដ្ឋាន។ |
| **ក្រុមទី៤.** តើភារកិច្ចរបស់រដ្ឋាភិបាលមានអ្វីខ្លះ? តើរដ្ឋាភិបាលកន្លងមកបានបំពេញតួនាទីរបស់ខ្លួនប៉ុន្មានភាគរយ? | **+ គោលបំណងរបស់រដ្ឋាភិបាល៖**<br>- ការពារផលប្រយោជន៍ប្រជាជន<br>- ពង្រឹងច្បាប់ឱ្យមានប្រសិទ្ធភាព<br>- ការពារ អាយុជីវិត កិត្តិយស សេចក្ដីថ្លៃថ្នូររបស់ពលរដ្ឋ។<br>- លើកស្ទួយសុខុមាលភាពរដ្ឋ។<br>- ផ្ដល់សេវាកម្មល្អជូនពលរដ្ឋ។<br>- ថែរក្សាទំនៀមទម្លាប់ប្រពៃណីវប្បធម៌ និងអត្តសញ្ញាណជាតិ។ | **+ គោលបំណងរបស់រដ្ឋាភិបាល៖**<br>- ការពារផលប្រយោជន៍ប្រជាជន<br>- ពង្រឹងច្បាប់ឱ្យមានប្រសិទ្ធភាព<br>- ការពារ អាយុជីវិត កិត្តិយស សេចក្ដីថ្លៃថ្នូររបស់ពលរដ្ឋ។<br>- លើកស្ទួយសុខុមាលភាពប្រជាជន<br>- ផ្ដល់សេវាកម្មល្អជូនពលរដ្ឋ។<br>- ថែរក្សាទំនៀមទម្លាប់ប្រពៃណីវប្បធម៌ និងអត្តសញ្ញាណជាតិ។ |

| | | |
|---|---|---|
| | - លើកស្ទួយទស្សនជាតិនិយម និងធ្វើឱ្យពលរដ្ឋស្រលាញ់ និងការពារប្រពៃណីទំនៀមទំលាប់ និងវប្បធម៌ជាតិ។<br>+ **ភារកិច្ចរបស់រដ្ឋាភិបាលត្រូវបានកកមណត់ដោយរដ្ឋធម្មនុញ្ញ**<br>- រដ្ឋាភិបាលមានភារកិច្ចការពាររដ្ឋធម្មនុញ្ញ។<br>- អនុវត្តតាមច្បាប់ផ្សេងៗដែលបានអនុម័តដោយអង្គការនីតិបញ្ញត្តិ។<br>-កំណត់និងអនុវត្តកម្មវិធីនយោបាយរបស់រដ្ឋស្របតាមរដ្ឋធម្មនុញ្ញ។<br>- ទទួលស្គាល់សិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋគ្រប់រូបនៅក្នុងសង្គម។<br>- មានសិទ្ធិអំណាចចរចាធ្វើទំនាក់ទំនងពាណិជ្ជកម្មនិងសហប្រតិបត្តិការសេដ្ឋកិច្ចវប្បធម៌ វិទ្យាសាស្ត្របច្ចេកទេសជាមួយបរទេស។<br>- ការពារនីត្យានុកូលភាពជាតិ។<br>- ធានាសណ្តាប់ធ្នាប់សន្តិសុខសាធារណៈ។<br>- យកចិត្តទុកដាក់ចំពោះ ជីវភាពប្រជាជន។<br>- ការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី | - លើកស្ទួយទស្សនជាតិនិយម និងធ្វើឱ្យប្រជាជនចេះស្រលាញ់ និងការពារប្រពៃណីទំនៀម ទំលាប់ និងវប្បធម៌ជាតិ។<br>+ **ភារកិច្ចរបស់រដ្ឋាភិបាលត្រូវបានកកមណត់ដោយរដ្ឋធម្មនុញ្ញ**<br>- រដ្ឋាភិបាលមានភារកិច្ចការពាររដ្ឋធម្មនុញ្ញ។<br>- អនុវត្តតាមច្បាប់ផ្សេងៗដែលបានអនុម័តដោយអង្គការនីតិបញ្ញត្តិ។<br>-កំណត់និងអនុវត្តកម្មវិធីនយោបាយរបស់រដ្ឋស្របតាមរដ្ឋធម្មនុញ្ញ។<br>- ទទួលស្គាល់សិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋគ្រប់រូបនៅក្នុងសង្គម។<br>- មានសិទ្ធិអំណាចចរចាធ្វើទំនាក់ទំនងពាណិជ្ជកម្មនិងសហប្រតិបត្តិការសេដ្ឋកិច្ចវប្បធម៌ វិទ្យាសាស្ត្របច្ចេកទេសជាមួយបរទេស។<br>- ការពារនីត្យានុកូលភាពជាតិ។<br>- ធានាសណ្តាប់ធ្នាប់សន្តិសុខសាធារណៈ។<br>- យកចិត្តទុកដាក់ចំពោះ ជីវភាពប្រជាជន។<br>- ការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី |

| | | |
|---|---|---|
| | - រក្សាការពារទំនៀមទំលាប់ និងប្រពៃណីល្អរបស់ជាតិ។ | - រក្សាការពារទំនៀមទំលាប់ និងប្រពៃណីល្អរបស់ជាតិ។ |
| ១.មូលហេតុអ្វីបានជាត្រូវធ្វើកំណែទម្រង់រដ្ឋបាល?<br>២.មូលហេតុអ្វីបានជាត្រូវធ្វើកំណែទម្រង់រដ្ឋបាល?<br>៣.រដ្ឋបាលឯកភាពជាអ្វី?<br>៤.តើរដ្ឋាភិបាលមានភារកិច្ចអ្វីខ្លះ? | **ជំហានទី៤៖**<br>**ពង្រឹងពុទ្ធិ**<br>**(៧នាទី)** | **សិស្សឆ្លើយសំណួរជាលក្ខណៈបុគ្គល**<br>- សិស្សអាចបង្ហាញពីការយល់ដឹងរបស់ពួកគេ តាមរយៈខ្លឹមសារមេរៀន«រដ្ឋាភិបាល»ជាមួយភាពជាពលរដ្ឋសកល នៅក្នុងបរិបទនៃការរស់នៅរបស់ខ្លួន។<br>- គ្រូសម្រួលខ្លឹមសារមេរៀន ជាមួយបរិបទកីឡា៣៤ច និងពិភពលោក។ |
| **កិច្ចការផ្ទះ:**<br>**ក្រុមនីមួយៗជ្រើសរើសយកប្រធានបទមួយដូចខាងក្រោម៖**<br>១- សិក្សាពីការយល់ដឹងអំពីតួនាទីរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ និងតួនាទីរបស់រដ្ឋបាលមូលដ្ឋាន (ភូមិឃុំ)។<br>២- សិក្សាពីការយល់ដឹង និងវាយតម្លៃរបស់ប្រជាពលរដ្ឋអំពីតួនាទី និងភារកិច្ចរបស់រដ្ឋាភិបាល (រដ្ឋបាលកណ្តាល)។<br>៣- ផ្សព្វផ្សាយអំពីតួនាទីរបស់ពលរដ្ឋក្នុងការចូលរួមអភិវឌ្ឍសហគមន៍។<br>៤- ផ្សព្វផ្សាយអំពីតួនាទី និង | **ជំហានទី៥៖**<br>បណ្តាំផ្ញើរ និងកិច្ចការស្រាវជ្រាវ<br>(៣នាទី) | **ក្រុមនីមួយៗជ្រើសរើសយកប្រធានបទមួយដូចខាងក្រោម៖**<br>១- សិក្សាពីការយល់ដឹងអំពីតួនាទីរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ និងតួនាទីរបស់រដ្ឋបាលមូលដ្ឋាន (ភូមិឃុំ)។<br>២- សិក្សាពីការយល់ដឹង និងវាយតម្លៃរបស់ប្រជាពលរដ្ឋអំពីតួនាទី និងភារកិច្ចរបស់រដ្ឋាភិបាល (រដ្ឋបាលកណ្តាល)។<br>៣- ផ្សព្វផ្សាយអំពីតួនាទីរបស់ពលរដ្ឋក្នុងការចូលរួមអភិវឌ្ឍសហគមន៍។<br>៤- ផ្សព្វផ្សាយអំពីតួនាទី និងភារកិច្ចរបស់រដ្ឋាភិបាលដល់សហគមន៍របស់ |

| | | |
|---|---|---|
| ភារកិច្ចរបស់រដ្ឋាភិបាលដល់សហគមន៍របស់ពួកគេ។ | | ពួកគេ។ |

## ប្រធានបទ ៖ បញ្ញា

ផេង ថុននី អ៊ូ ម៉ារិន ធុំ គន្ធី
វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

កាលបរិច្ឆេទ ៖ ថ្ងៃ.......... ទី .....ខែ......ឆ្នាំ.............ព.ស.២៥៦........
មុខវិជ្ជា ៖ សីលធម៌-ពលរដ្ឋវិជ្ជា
ជំពូកទី១ ៖ តម្លៃមនុស្ស
មេរៀនទី១ ៖ បញ្ញា
ដកស្រង់ ៖ សៀវភៅសិក្សាគោលសីលធម៌ -ពលេដ្ឋ ថ្នាក់ទី១២
រយៈពេល ៖ ៥០នាទី
វិធីសាស្រ្តបង្រៀន ៖ គោលវិធីសិស្សមជ្ឈមណ្ឌល ( តាមបែបសហការ )
គោលបំណង ៖ បង្ហាញពីអត្ថន័យ នៃពាក្យ បញ្ញា ប្រភេទបញ្ញា និងសភាវគតិ បានច្បាស់តាមរយៈសិក្សាស្វែងយល់ទស្សនៈ របស់ទស្សនវិទូមួយចំនួន។ និងឱ្យយល់កាន់តែច្បាស់អំពីអត្ថន័យនៃខ្លឹមសារមេរៀនអំពី« បញ្ញា » ។

### I. វត្ថុបំណង

- **វិជ្ជាសម្បទា** ៖ ប្រាប់បានពីបញ្ញត្តិនៃពាក្យ« បញ្ញា និង សភាវគតិ »បានត្រឹមត្រូវ តាមរយៈសំណួរបំផុសលើខ្លឹមសារមេរៀននិងសង្កេតរូបភាព
- **បំណិនសម្បទា** ៖ កំណត់បានពីប្រភេទបញ្ញាមនុស្ស និងបញ្ញាសត្វ បានត្រឹមត្រូវ តាមរយៈសំណួរពិភាក្សាក្រុម។
- **ចរិយាសម្បទា** ៖ បណ្តុះស្មារតី ក្នុងការប្រើប្រាស់បញ្ញាបានត្រឹមត្រូវកតាម រយៈការអនុវត្តជាប្រចាំក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ។

### II. ខ្លឹមសារមេរៀន

1/ ចំណុចណែនាំមួយចំនួន៖ សរុបអំពីខ្លឹមសារមេរៀន« បញ្ញា »

* ខ្លឹមសារមេរៀននេះផ្តោតសំខាន់ទៅលើ២ចំណុច៖

១) បញ្ញា

ក. និយមន័យ

ខ. ប្រភេទនៃបញ្ហា

២) សភាវគតិ

សម្រាប់មេរៀនបញ្ហានេះ ៖ ចង់ឱ្យគរុនិស្សិតមានការគិតនិងយល់កាន់តែច្បាស់ក្នុងការរស់នៅរបស់មនុស្សក្នុងសង្គមរមែងជួបនឹងឧបសគ្គផ្សេងៗបណ្ដាលមកពីបាតុភូតធម្មជាតិឬបណ្ដាលមកពីការប្រព្រឹត្តរបស់មនុស្សចំពោះគ្នាទៅវិញទៅមក។ រាល់ដំណោះស្រាយបញ្ហាទាំងឡាយប្រកបដោយជោគជ័យនេះបង្ហាញពីភាពប៉ិនប្រសប់ឬសតិបញ្ញាប្រកបដោយភាពឈ្លាសវៃរបស់មនុស្សគ្រប់ជំនាន់
ចំពោះសត្វវិញ បើជួបបញ្ហាគ្រោះធម្មជាតិហើយ សត្វគ្មានដំណោះស្រាយអ្វីថ្មីចំពោះមុខឡើយ...។ (GCED)

III.**សម្ភារឧបទេស**

**+សម្ភារៈសម្រាប់គ្រូ ៖**

- កិច្ចតែងការបង្រៀន ស្លាយមេរៀន កុំព្យូទ័រយួរដៃ LCD ក្រដាស់ផ្ទាំងធំ ហ្វឺត ស្កុតបិត
- ផ្ទាំងរូបភាព បណ្ណសំណួរ បណ្ណចរាចរណ៍...។
- សៀវភៅសិក្សាគោល៖ សៀវភៅសីលធម៌-ពលរដ្ឋវិជ្ជា របស់ក្រសួង អប់រំ យុវជន និងកីឡា (ទំព័រទី ០១-០៣)។

**+សម្ភារៈសម្រាប់សិស្ស ៖**

-សៀវភៅសិស្ស និងសៀវភៅសរសេរ ប៊ិច ខ្មៅដៃ បន្ទាត់ ស្កុតបិត ក្រដាសរ៉ាម

-បណ្ណសំណួរ

**IV.វិធីសាស្ត្របង្រៀន**

- វិធីសាស្ត្របង្រៀន ៖ គោលវិធីសិស្សមជ្ឈមណ្ឌល ( តាមបែបសហការ)

V.**ដំណើរការបង្រៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារ** | **សកម្មភាពសិស្ស** |
|---|---|---|
| **ជំហានទី១៖** <u>លំនឹងថ្នាក់រៀន(៣នាទី)</u> | | |
| – **សុខសប្បាយជាទេប្អូនៗ?**<br>– **បានបាញ់កាល់កុលឬនៅ?**<br>– **ចូលរៀនគ្រប់គ្នាឬនៅ?**<br>– **សិស្សល្អពេលចូលរៀនត្រូវមានឥរិយាបថដូចម្តេច?**(GCED) | – សំណេះសំណាល<br>– ពិនិត្យអនាម័យ<br>– ពិនិត្យអវត្តមាន<br>– សណ្ដាប់ធ្នាប់ | – បាទ/ចាស់សុខសប្បាយ<br>– បាទ/ចាស់រួចរាល់ហើយ<br>– ប្រធានថ្នាក់រាយការណ៍ |

| **សកម្មភាពគ្រូ** | **ខ្លឹមសារ** | **សកម្មភាពសិស្ស** |
|---|---|---|
| | | |
| **ជំហានទី២៖(៧នាទី)** | | |
| *កែកិច្ចការផ្ទះ (កែរួម)<br><br>១.តើចំណុចណាមួយនៃតម្លៃ របស់មនុស្ស ដែលប្អូនៗគិត ថាសំខាន់ជាងគេ?(GCED)<br><br>២. អ្វីទៅជាការឱ្យតម្លៃខ្លួនឯង ?(GCED)<br><br>*សួរសំណួររំឭកមេរៀនចាស់៖<br>១.តើតម្លៃជាអ្វី ? | ក/កែកិច្ចការផ្ទះ<br>មេរៀន តម្លៃ<br><br>**១/តម្លៃផ្ទាល់ខ្លួនឬ ការឱ្យតម្លៃខ្លួនឯង**<br><br>២/ការឱ្យតម្លៃខ្លួនឯង គឺ សំដៅទៅលើវិធីដែលយើងគិតអំពីខ្លួនយើង និងស្វែងយល់ពីមជ្ឈដ្ឋានខាងក្រៅផងដែរ។(GCED)<br><br>**<u>ខ/រំឭកមេរៀនចាស់</u>**<br>១-តម្លៃ គឺជាអ្វីដែលគេជ្រើសរើស ជាអ្វីដែលគេចង់បានគួរជាទីប្រាថ្នា<br>២.បានជាមនុស្សគ្រប់រូបគិតថា តម្លៃសំខាន់ចំពោះគេ ព្រោះ៖ | -សិស្ស១នាក់កែនៅក្តារខៀន<br><br>១/ចំណុចសំខាន់នៃតម្លៃ របស់មនុស្សដែលខ្ញុំគិតថាសំខាន់ជាងគេ គឺតម្លៃផ្ទាល់ខ្លួន ឬ ការឱ្យតម្លៃខ្លួនឯង។(GCED)<br>២/ការឱ្យតម្លៃខ្លួនឯង គឺ សំដៅទៅលើវិធីដែលយើងគិតអំពីខ្លួនយើងនិងស្វែងយល់ពីមជ្ឈដ្ឋានខាងក្រៅផងដែរ។(GCED)<br><br>សិស្សឆ្លើយ<br>១. សិស្ស ២ឬ៣នាក់ ឆ្លើយតាមការយល់ឃើញ និងការចងចាំមេរៀន។<br>២.តម្លៃសំខាន់ចំពោះគេ ព្រោះ៖ |

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| ២. ហេតុអ្វីបានជាមនុស្សគ្រប់រូបគិតថាតម្លៃសំខាន់ចំពោះគេ? (GCED)<br><br>*សំណួរភ្ជាប់មេរៀនថ្មី៖<br>៣. នៅពេលមនុស្សជួបបញ្ហា តើពួកគេប្រើអ្វីដើម្បីដោះស្រាយបញ្ហា? ចូរលើកឧទាហរណ៍បញ្ជាក់។(GCED) | តម្លៃបានផ្តល់នូវកិត្តិនាមកិត្តិយសនិងសេចក្តីថ្លៃថ្នូរចំពោះរូបគេ ។<br>ឧទាហរណ៍:ដូចជាអំពើល្អ កុសល ...។(GCED)<br>**គ/ <u>សំណួរភ្ជាប់មេរៀនថ្មី៖</u>**<br>៣. នៅពេលមនុស្សជួបបញ្ហាអ្វីមួយកើតឡើង ៖<br>គឺពួកគេយក"បញ្ញា"ទៅដោះស្រាយ។<br>ឧទាហរណ៍:ពេលមានរឿងនៅចំពោះមុខមនុស្សយកសមត្ថភាព ឬបញ្ញាទៅដោះស្រាយរាល់បញ្ហាមិនឱ្យប៉ះពាល់ដល់អ្នកនៅជុំវិញខ្លួន ...?(GCED) | តម្លៃបានផ្តល់នូវកិត្តិនាមកិត្តិយសនិងសេចក្តីថ្លៃថ្នូរចំពោះរូបគេ។(GCED)<br><br>សិស្សឆ្លើយ<br>៣.គរុនិស្សិត២ឬ៣នាក់ឆ្លើយសំណួរតាមការយល់ដឹងរបស់ពួកគេ។<br>- ឧទាហរណ៍: ..(GCED) |
| **ជំហានទី៣៖ <u>មេរៀនថ្មី(៣០នាទី)</u>** | | |
| *តើថ្ងៃនេះយើងនឹងរៀនមេរៀនអ្វី?<br>គ្រូសរសេរចំណងមេរៀនលើក្តារខៀន<br>ក/ឱ្យសិស្សសង្កេតរូបភាព | មេរៀនទី១ "បញ្ញា"<br><br>- (សិក្សារូបភាព) | – សិស្សអានចំណងជើងមេរៀន<br>– សិស្សសង្កេតនិងឆ្លើយសំណួរ<br>-ទូរស័ព្ទ |

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| – ក្នុងរូបភាពមានអ្វី?<br>– ហេតុអ្វីបានជាប្អូនដឹងថាជាទូរស័ព្ទ?<br>– ឆ្លើយជាបុគ្គល ឬជាដៃគូ។<br><br>ខ/ប្រើសំណួរបំផុស<br>* អ្វីជាបញ្ញា?<br><br>*អ្វីជាសភាវគតិ? | <br>សង្កេត<br>ស្តាប់<br><br>**សតិបញ្ញាន័យ**<br>" បញ្ញា"<br><br>សភាវគតិ<br><br>គ/ស្វែងយល់អត្ថបទ"បញ្ញា" | -បានឃើញនាំឱ្យដឹងថាជាទូរស័ព្ទតាមរយៈ ប្រើ សតិបញ្ញា<br><br>សភាវគតិ<br>ជាការប្រព្រឹត្តដដែលៗពីកំណើតរបស់សត្វមានជីវិតទៅតាមប្រភេទនីមួយៗ។ |

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| គ/ឱ្យសិស្សសិក្សាស្រាវជ្រាវស្វែងយល់អត្ថបទ<br>.គ្រូសរសេរពាក្យគន្លឹះលើក្តារខៀន<br>– រកអត្ថន័យនៃពាក្យគន្លឹះ សម្បទា<br><br>ឃ/ពិភាក្សាក្រុម<br>បែក៥ក្រុមពិភាក្សា(១០នាទី)<br><br>* ក្រុមទី១<br>**ទស្សនវិទូដែលល្បីៗនៅលើពោភព លោកណាខ្លះបានចូលរួមឱ្យនិយម** | សម្បទាៈ<br>- គឺជាសំណុំលទ្ធភាពចិត្តរបស់បុគ្គលដែលស៊ីចង្វាក់គ្នាក្នុងសកម្មភាពណាមួយជាក់លាក់ ។<br>ឧទាហរណ៍: ក្រុមកីឡាបាល់ទាត់មួយក្រុមដែលលេងស៊ីចង្វាក់គ្នាក្នុងរង្វង់សកម្មភាពមួយជាក់<br><br>លាក់តែងទទួលបានលទ្ធផលល្អ ។<br><br>ពិភាក្សាក្រុម<br><br>***ទស្សនវិទូល្បីៗនៅលើពិភព លោកដែលបានចូលរួមឱ្យនិយម ន័យ"បញ្ញា"មានលោក ៖ ក្លាប៉ាវែត ឌីឡាគ្រ័រ ព្រះពុទ្ធ។(GCED)** | គ/សិក្សាស្វែងយល់តាមការណែនាំ<br>-ស្តាប់ គិត កត់ត្រា<br>ឆ្លើយតាមការយល់ដឹងរបស់គេម្នាក់ៗ<br><br>-សិស្ស២ឬ៣នាក់ឆ្លើយតាមរយៈការយល់ខ្លឹមសារមេរៀន<br><br>*សិស្សចូលរួមឆ្លើយតាមក្រុម<br><br>**ក្រុមទី១<br>ទស្សនវិទូដែលល្បីៗនៅលើពោភពលោកណាខ្លះបានចូលរួមឱ្យនិយមន័យ"បញ្ញា"បានចូលរួមឱ្យនិយមន័យ"បញ្ញា"មានលោកៈក្លាប៉ាវែត ឌីឡាគ្រ័រ** |

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| ន័យ"បញ្ញា"?ចូរបង្ហាញទស្សនវិទូយ៉ាងតិចរូប។(GCED)<br><br>ក/ក្លាប៉ារ៉ែត(GCED)<br><br>ខ/លោកដឺឡាក្រ័រ(Delacroix) | លោកក្លាប៉ារ៉ែត<br><br>បានឱ្យនិយមន័យបញ្ញា៖<br>-គឺជាសម្បទាដែលអាចសម្របទៅនឹងស្ថានការណ៍ថ្មីៗ ។ ឧទាហរណ៍: មនុស្សអាចសម្របខ្លួនទៅនឹងអាកាសធាតុក្តៅ ឬត្រជាក់ ។(GCED)<br><br>លោកឌឺឡាគ្រ័រ<br><br>បានឱ្យនិយមន័យបញ្ញាថា៖<br>• ជាសិល្បៈសម្រាប់បង្កើតប្រព័ន្ធអរូបីកម្មហើយបញ្ជូនប្រព័ន្ធអរូបីកម្មទាំងនោះទៅក្នុងស្ថានភាពរូបីមួយ ។ ឧទាហរណ៍: មនុស្សអាចបង្កើតឧបករណ៍ប្រើប្រាស់តាមក្តីស្រមៃ ។(GCED) | ព្រះពុទ្ធ។(GCED)<br><br>ក/. លោកក្លាប៉ារ៉ែតបានឱ្យនិយមន័យបញ្ញា៖<br>-គឺជាសម្បទាដែលអាចសម្របទៅនឹងស្ថានការណ៍ថ្មីៗ ។ ឧទាហរណ៍: មនុស្សអាចសម្របខ្លួនទៅនឹងអាកាសធាតុក្តៅ ឬត្រជាក់ ។(GCED)<br><br>ខ/លោកដឺឡាក្រ័របានឱ្យនិយមន័យបញ្ញា៖<br>• ជាសិល្បៈសម្រាប់បង្កើតប្រព័ន្ធអរូបីកម្មហើយបញ្ជូនប្រព័ន្ធអរូបីកម្មទាំងនោះទៅក្នុងស្ថានភាពរូបីមួយ ។ ឧទាហរណ៍: មនុស្សអាចបង្កើត |

| **សកម្មភាពគ្រូ** | **ខ្លឹមសារ** | **សកម្មភាពសិស្ស** |
|---|---|---|
| គ/ ព្រះពុទ្ធ |  ព្រះពុទ្ធ<br>ព្រះពុទ្ធយល់ថា បញ្ញា៖ គឺជាប្រទីបសម្រាប់បំភ្លឺសត្វលោកទៅរកសេចក្តីសុខ ។ ឧទាហរណ៍: មនុស្សមានបញ្ញាគេអាចរំដោះខ្លួនពីសេចក្តីទុក្ខបាននិងចេះផ្លាស់ប្តូរតាមកាលៈទេសៈ ។<br>ឧទាហរណ៍ ៖ ទុក្ខកើតចេញពីអវិជ្ជា និង តណ្ហា ។(GCED)<br>__២/ មនុស្សខុសពីសត្វគឺ ៖__<br>+មនុស្ស មានប្រវត្តិ; | ឧបករណ៍ប្រើប្រាស់តាមក្តីស្រមៃ ។(GCED)<br>គ/ទ្រឹស្តីព្រះពុទ្ធសាសនា បញ្ញា៖<br>•គឺជាប្រទីបសម្រាប់បំភ្លឺសត្វលោកទៅរកសេចក្តីសុខ ។ ឧទាហរណ៍: មនុស្សមានបញ្ញាគេអាចរំដោះខ្លួនពីសេចក្តីទុក្ខបាន និងចេះផ្លាស់ប្តូរតាមកាលៈទេសៈ ។<br>•ឧទាហរណ៍៖ ទុក្ខកើតចេញពីអវិជ្ជា និង តណ្ហា ។(GCED) |

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| សំណួរទី២ (ក្រុមទី២):<br>២/តើមនុស្សខុសពីសត្វដូចម្តេចខ្លះ ?<br><br>សំណួរទី៣ (ក្រុមទី៣): | - មានអានុស្សាវរីយ៍;<br>- មានការបង្កើតថ្មី;<br>-ចំណេះដឹងគ្មានព្រំដែន ។<br>+សត្វ គ្មានប្រវត្តិ<br>-គ្មានអានុស្សាវរីយ៍<br>គ្មានការបង្កើតថ្មី<br>-ចំណេះដឹងមានព្រំដែន ។<br><br>៣.លោកហាក់ម៉ាន់បានឱ្យនិយមន័យបញ្ហាថា៖<br>-ជាអនុគមន៍សម្របមធ្យោបាយទៅនឹងគោលដៅមានន័យថារាល់អាកប្បកិរិយាប្រកបដោយបញ្ញាពុំមែនជាអាកប្បកិរិយាគ្មានគោលបំណងទេតែជាអាកប្បកិរិយាមួយមានគោលបំណងច្បាស់លាស់សម្រាប់ដោះស្រាយបញ្ហាមួយជាក់លាក់...។<br><br>ប្រភេទបញ្ហាមានពីរគឺ៖<br>- បញ្ហាប្រតិបត្តិ: ជាបញ្ហាកម្រិតទាបកើតមានឡើងចំពោះសត្វ | (ចម្លើយក្រុមទី២):<br>*មនុស្សខុសពីសត្វគឺ ៖<br>- មនុស្ស មានប្រវត្តិ<br>- មានអានុស្សាវរីយ៍<br>- មានការបង្កើតថ្មី<br>- ចំណេះដឹងគ្មានព្រំដែន ។<br>* សត្វ គ្មានប្រវត្តិ; -គ្មានអានុស្សាវរីយ៍ -គ្មានការបង្កើតថ្មី<br>-ចំណេះដឹងមានព្រំដែន ។<br><br>ចម្លើយក្រុមទី៣<br>លោកហាក់ម៉ាន់បានឱ្យនិយមន័យបញ្ហាថា៖<br>-ជាអនុគមន៍សម្របមធ្យោបាយទៅនឹងគោលដៅមានន័យថារាល់អាកប្បកិរិយាប្រកបដោយបញ្ញាពុំមែនជាអាកប្បកិរិយាគ្មានគោលបំណងទេតែជាអាកប្បកិរិយាមួយមានគោលបំណងច្បាស់លាស់សម្រាប់ |

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| តើលោកហាតម៉ាន់បានឱ្យនិយមន័យបញ្ញាដូចម្ដេច? ចូរពន្យល់ ។<br><br>សំណួរទី៤(ក្រុមទី៤) :<br>តើបញ្ញាមានប៉ុន្មានប្រភេទ? អ្វីខ្លះ? ចូរពន្យល់ ។ | ស្វានិងក្មេងក្រោមអាយុ២ឆ្នាំ។ បញ្ញាប្រភេទនេះមានលក្ខណៈប្រតិបត្តិសុទ្ធសាធនិងផ្សារភ្ជាប់នឹងអ្វីដែលជារូបី ។<br>- បញ្ញាទ្រឹស្ដី: ជាបញ្ញាដែលកើតចេញពីគំនិតអរូបីដោយប្រើប្រាស់ភាសាជំនួយ ។ បញ្ញាប្រភេទនេះជាសកម្មភាពនៃការយល់និងដឹង និងការពន្យល់ហេតុការណ៍ទាំងឡាយ ជាទូទៅកើតមានចំពោះមនុស្សចាប់ពីក្មេងចេះនិយាយបង្គួរឡើងទៅ...។<br><br>៥.សភាវគតិនិងបញ្ញាខុសគ្នាត្រង់៖<br><br>-សភាវគតិគឺជាអាកប្បកិរិយាដដែលពីកំណើតរបស់សត្វមានជីវិតទៅតាមប្រភេទនីមួយៗ ។ | ដោះស្រាយបញ្ហាមួយជាក់លាក់...។<br><br>ចម្លើយក្រុមទី៤<br>ប្រភេទបញ្ញាមានពីរគឺ៖<br>- បញ្ញាប្រតិបត្តិ: ជាបញ្ញាកម្រិតទាបកើតមានឡើងចំពោះសត្វស្វានិងក្មេងក្រោមអាយុ២ឆ្នាំ។ បញ្ញាប្រភេទនេះមានលក្ខណៈប្រតិបត្តិសុទ្ធសាធនិងផ្សារភ្ជាប់នឹងអ្វីដែលជារូបី ។<br>- បញ្ញាទ្រឹស្ដី: ជាបញ្ញាដែលកើតចេញពីគំនិតអរូបីដោយប្រើប្រាស់ភាសាជំនួយ ។ បញ្ញាប្រភេទនេះជាសកម្មភាពនៃការយល់និងដឹង និងការពន្យល់ហេតុការណ៍ទាំងឡាយ ជាទូទៅកើតមានចំពោះមនុស្សចាប់ពីក្មេងចេះនិយាយបង្គួរឡើងទៅ..។ |

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| -សំណួរទី៥(ក្រុមទី៥) :<br>៥/តើសភាវគតិនិងបញ្ញាខុសគ្នាដូចម្តេច ?<br><br> | - បញ្ញា ជាការជ្រើសរើសល្បិចក្នុងការដោះស្រាយបញ្ហាដែលមានលក្ខណៈខុសៗគ្នា។ បុគ្គលដែលមានបញ្ញាតែងតែដោះស្រាយរាល់បញ្ហាណាមួយដោយល្បិចឬឧបាយផ្សេងៗ ។<br><br>**<u>សេចក្តីសន្និដ្ឋាន</u>**<br>បញ្ញាមនុស្ស ខុសពីបញ្ញាសត្វ<br>បញ្ញាសត្វ ៖<br>-ជាបញ្ញាបែបអព្ភន្តរញ្ញាណនិងរូបី<br>-មិនអាចគ្រប់គ្រងពេលវេលាបាន<br>-មិនដឹងពីអតីតកាលឬបច្ចុប្បន្នកាលឡើយ ។<br>-មិនអាចផ្តាច់ចេញ ពីសភាវគតិនិងទម្លាប់ ធម្មជាតិ ។ | ៥. សភាវគតិនិងបញ្ញាខុសគ្នាត្រង់៖<br>-សភាវគតិ គឺជាអាកប្បកិរិយាដែលៗពីកំណើតរបស់សត្វមានជីវិតទៅតាមប្រភេទនីមួយៗ ។<br>- បញ្ញា ជាការជ្រើសរើសល្បិចក្នុងការដោះស្រាយបញ្ហាដែលមានលក្ខណៈខុសៗគ្នា។ បុគ្គលដែលមានបញ្ញាតែងតែដោះស្រាយរាល់បញ្ហាណាមួយដោយល្បិច ឬឧបាយផ្សេងៗ ។<br><br>–ឱ្យតំណាងក្រុមឡើងធ្វើបទបង្ហាញ |

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| – ឱ្យតំណាងក្រុមឡើងធ្វើបទបង្ហាញ។<br>– គ្រូសំយោគ វាយតម្លៃ និងកែលម្អនូវរាល់ចំណុចខ្វះខាត។<br><br>ឱ្យសិស្សកត់ចូលសៀវភៅ<br>២-៣នាក់អាន | -ជាសម្បទាសម្រាប់ចាប់យកទំនាក់ទំនងវត្ថុ ដែលជាប់ទាក់ទងនិងការប្រតិបត្តិប៉ុណ្ណោះ ។<br>-ជាបញ្ញាមានព្រំដែននិងគ្មាន ក្នុងការបង្កើតថ្មី ។<br>បញ្ញាមនុស្ស៖<br>ជាបញ្ញាប្រកបដោយវិចារណញាណជាបញ្ញាទ្រឹស្តី គ្មានព្រំដែន<br>ចេញពីអរូបីកម្ម ទៅរូបីកម្ម<br>អាចគ្រប់គ្រងពេលវេលា<br>មានបច្ចុប្បន្នកាលនិងអនាគត<br>មានការបង្កើតថ្មី។ | – ចូលរួមសំយោគ វាយតម្លៃនិងកែលម្អនូវរាល់ចំណុចខ្វះខាត។<br><br>-ធ្វើតាមការណែនាំរបស់គ្រូ<br>-អាន |
| **ជំហានទី៤៖** <u>ពង្រឹងចំណេះដឹង</u>( **៧នាទី** ) | | |
| សំណួរផ្ទាល់មាត់<br>១/ ដូចម្តេចហៅថាបញ្ញា ? | | សិស្សឆ្លើយ |

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| ២/តើបញ្ញាមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?<br><br>៣/.ដូចម្ដេចដែលហៅថាសភាវគតិ ? | ១. ដែលហៅថា បញ្ញាគឺជា៖ ចំណេះដឹង ឬ ពុទ្ធិការបង្កើតថ្មី...។<br>ជាការជ្រើសរើសល្បិចក្នុងការដោះស្រាយបញ្ហាដែលមាន<br>លក្ខណ:ខុសៗគ្នា។<br>ឧទាហរណ៍: អ្នកមាន បញ្ញា តែងតែដោះស្រាយបានរាល់បញ្ហា ឬធ្វើអ្វីមួយតែងមានគោលបំណង និងគោលដៅច្បាស់លាស់<br><br>២. បញ្ញាមានពីរប្រភេទគឺ៖<br>បញ្ញាប្រតិបត្តិ និងបញ្ញាទ្រឹស្តី ។ គេសង្កេតឃើញបញ្ញាប្រតិបត្តិកើតមុនបញ្ញាទ្រឹស្ដី។<br><br>៣. សភាវគតិគឺជាការប្រព្រឹត្តដដែលៗពីកំណើតរបស់សត្វមានជីវិតតាមប្រភេទនីមួយៗ ។<br>ឧទាហរណ៍: សំបុកចាបសំបុកឃ្មុំ....។ | ១. ដែលហៅថា បញ្ញាគឺជា៖<br>ចំណេះដឹង ឬ ពុទ្ធិការបង្កើតថ្មី...។<br>ជាការជ្រើសរើសល្បិចក្នុងការដោះស្រាយបញ្ហាដែលមាន<br>លក្ខណ:ខុសៗគ្នា។<br>ឧទាហរណ៍: អ្នកមាន បញ្ញា តែងតែដោះស្រាយបានរាល់បញ្ហា ឬធ្វើអ្វីមួយតែងមានគោលបំណង<br>និង គោលដៅច្បាស់លាស់។<br><br>២. បញ្ញាមានពីរប្រភេទគឺ៖<br>បញ្ញាប្រតិបត្តិ និងបញ្ញាទ្រឹស្តី ។ គេសង្កេតឃើញបញ្ញាប្រតិបត្តិកើតមុនបញ្ញាទ្រឹស្ដី។<br><br>៣.សភាវគតិគឺជាការប្រព្រឹត្ត<br>ដដែលៗពីកំណើតរបស់សត្វ<br>មានជីវិតតាមប្រភេទនីមួយៗ ។ |

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| ៤/ពេលអ្នកមានបញ្ហានៅក្នុងគ្រួសារតើអ្នកដោះស្រាយដោយវិធីណា ?(GCED)<br><br>៥/ពេលដែលមានសមាជិកគ្រួសារណាម្នាក់បានប្រព្រឹត្តិមិនគប្បីដែលនាំឱ្យប៉ះពាល់ដល់ប្រពៃណីគ្រួសារនិងសង្គមតើអ្នកមានដំណោះស្រាយដូចម្ដេចដើម្បីសេចក្ដីសុខគ្រួសារនិងសង្គម។(GCED) | ពង្រីកចំណេះដឹង<br>(ពលរដ្ឋសកល)<br>ដោះស្រាយបញ្ហាដោយប្រើសតិបញ្ញា ត្រូវគ្រប់គ្រងអារម្មណ៍ឱ្យបានល្អ រកហេតុផល រកវិធីពន្យល់ផ្សះផ្សា<br>ដោះស្រាយដោយសន្តិវិធី មិនយកអំពើហិង្សាមកដោះស្រាយឡើយ។(GCED)<br><br>៥/-ប្រើសតិបញ្ញាប្រកបភាពឆ្លៃប្រឌិត<br>-អប់រំ ពន្យល់ពីហេតុផល<br>-រកដំណោះស្រាយប្រកបដោយវិធីត្រជាក់ នាំឱ្យពួកគាត់ទទួលយកបាន<br>-មិនយកអំពើហិង្សាគ្រប់រូបភាពមកដោះស្រាយទេ…….។(GCED) | ឧទាហរណ៍: សំបុកចាបសំបុកឃ្មុំ…។<br><br>៤/ពេលមានបញ្ហានៅក្នុងគ្រួសារខ្ញុំដោះស្រាយបញ្ហាដោយប្រើសតិបញ្ញា គ្រប់គ្រងអារម្មណ៍ឱ្យបានល្អ<br>ដោះស្រាយបញ្ហាដោយសន្តិវិធី<br>មិនយកអំពើហិង្សាមកដោះស្រាយឡើយ។(GCED)<br><br>៥/-ប្រើសតិបញ្ញាប្រកបភាពឆ្លៃប្រឌិត<br>-អប់រំ ពន្យល់ពីហេតុផល<br>-រកដំណោះស្រាយប្រកបដោយវិធីត្រជាក់ នាំឱ្យពួកគាត់ទទួលយកបាន |

| **សកម្មភាពគ្រូ** | **ខ្លឹមសារ** | **សកម្មភាពសិស្ស** |
|---|---|---|
| | | -មិនយកអំពើហិង្សាគ្រប់រូបភាពមកដោះស្រាយទេ......។ (GCED) |
| **ជំហានទី៥ ៖ កិច្ចការផ្ទះ (៣នាទី)** | | |
| -ឱ្យសិស្សកត់មេរៀន និងកិច្ចការផ្ទះ<br><br>–ពេលគ្រូឡប់ទៅផ្ទះវិញខំប្រឹងរៀន ពិសេសត្រូវជួយការងារឪពុកម្ដាយបងប្អូនផងណា | ១/ចូរប្អូនសិក្សាស្រាវជ្រាវមេរៀនបន្ត<br>**២/បើអ្នកជិតខាងក្បែរផ្ទះរបស់អ្នកមានការរំខានជាញយៗចូលចិត្តនិយាយខ្លាំងៗដែលនាំឱ្យរំខប៉ះពាល់ដល់ការរស់នៅរបស់អ្នកតើអ្នកដោះស្រាយបែបណា?** (GCED)<br><br>**បណ្ដាំផ្ញើ** | -សិស្សកត់មេរៀននិងកិច្ចការផ្ទះ<br><br>– បាទ/ចាស់ |

VI. **ការវាយតម្លៃ**

- ជំហានទី១ ៖ វាយតម្លៃដោយអង្កេតគុនិស្សិតតាមរយៈការគោរពវិន័យនិងសណ្ដាប់ធ្នាប់ល្អ ។
- ជំហានទី២ ៖ វាយតម្លៃគុនិស្សិតតាមរយៈការធ្វើកិច្ចការផ្ទះ និងការឆ្លើយសំណួររំលឹកមេរៀនចាស់បានត្រឹមត្រូវ ។
- ជំហានទី៣ ៖ វាយតម្លៃគុនិស្សិតតាមរយៈសកម្មភាពចូលរួមធ្វើសំណួរពិភាក្សាក្រុមនិងការអនុវត្តជាក់ស្ដែងក្នុងខ្លឹមសារមេរៀន«**បញ្ហា**»។

- ជំហានទី៤ ៖ វាយតម្លៃចម្លើយចូលរួមរបស់គរុនិស្សិតបានតត្រឹមត្រូវតាមរយៈសំណួរពង្រឹងចំណេះដឹង។
- ជំហានទី៥ ៖ វាយតម្លៃលទ្ធផលសិក្សារបស់គរុនិស្សិតតាមរយៈសកម្មភាពបង្រៀននិងរៀនដោយយកចិត្តទុកដាក់ខ្ពស់ ។

# សន្លឹកកិច្ចការ៖

- កាលបរិច្ឆេទ៖.......................................ក្រុមទី៖.........................................................
- លេខរៀង ៖.......................................ថ្នាក់ ៖.........................................................

ឈ្មោះសមាជិកក្រុម៖ ១. ២.

៣. ៤.

៥. ៦.

សំណួរ៖

ចូររកឧទាហរណ៍អំពីទំនាក់ទំនងមិនច្បាស់លាស់នៅក្នុងបរិបទអប់រំ ឬជីវិតរស់នៅប្រចាំថ្ងៃ។

ចម្លើយ៖

..............................................................................................................................................

.......................................................................................................................................

..............................................................................................................................................

.......................................................................................................................................

សូមសំណាងល្អ!

# ប្រធានបទ៖ ការគិតស៊ីជម្រៅ II

សាំង មាសសួន សឿ វណ្ណា ជី សុភ័ណ្ឌ
វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

កាលបរិច្ឆេទ ៖ ថ្ងៃទី.........ខែ........ឆ្នាំ.............ព.ស.២៥៦...
ត្រូវនឹងថ្ងៃទី.................ខែ.............ឆ្នាំ២០២...
មុខវិជ្ជា ៖ ចិត្តវិទ្យាអប់រំ
ប្រធានបទ ៖ ការគិតស៊ីជម្រៅ II
រយៈពេល ៖ ៦០ នាទី

## I. វត្ថុបំណង

**បន្ទាប់ពីបានរៀនខ្លឹមសារមេរៀននេះចប់គរុនិស្សិតប្រុស និងគរុនិស្សិតស្រីនឹង៖**

- **វិជ្ជាសម្បទា** ៖ ពិពណ៌នាខ្លឹមសារនៃទំនាក់ទំនងមិនច្បាស់លាស់នៃការគិតតាមរយៈការបង្ហាញប័ណ្ណរូបភាព និងការបកស្រាយដោយលើកឧទាហរណ៍របស់គ្រូឧទ្ទេស។
- **បំណិនសម្បទា** ៖

  -កំណត់អំពីទំនាក់ទំនងមិនច្បាស់លាស់នៃការគិតនិង ការស្វែងរកទំនាក់ទំនងមិនច្បាស់លាស់ តាមរយៈការពិភាក្សាក្រុម ដោយលើកឧទាហរណ៍នៅក្នុងបរិបទអប់រំជាស្តែង ឬជីវិតរស់នៅប្រចាំថ្ងៃរបស់គរុនិស្សិត។

  -គរុនិស្សិតផ្លាស់ប្តូរមតិយោបល់គ្នាទៅវិញទៅមកក្នុងការរកឧទាហរណ៍ជាក់ស្តែងដែលទាក់ទងបរិបទអប់រំជាសកល។
- **ចរិយាសម្បទា** ៖

  -បណ្តុះនូវទម្លាប់ឱ្យជៀសវាងការធ្វើសេចក្តីសម្រេចចិត្តផ្ទាល់ខ្លួនណាមួយ ដោយមិនសមហេតុផល និងបណ្តុះនូវទម្លាប់ក្នុងការសិក្សាស្រាវជ្រាវទៀតផង។

  **-ក្លាយជាពលរដ្ឋអក្ខរកម្មដែលមានការគិតប្រកបដោយវិចារណញាណក្នុងការធ្វើការសម្រេចចិត្តដែលមានផលជះល្អលើបញ្ហាសង្គម នយោបាយ និងសេដ្ឋកិច្ចជាដើម។** (GCED)

## II. ចំណុចណែនាំមួយចំនួន

**សរុបខ្លឹមសារមេរៀនការគិតបែបស៊ីជម្រៅ (II) ផ្តោតសំខាន់ទៅលើ៖**

- ទំនាក់ទំនងមិនច្បាស់លាស់ គឺកើតឡើងនៅពេលមានអថេរ២មានទំនាក់ទំនងទៅនឹងស្ថិតិ ប៉ុន្តែមិនជាប់ទាក់ទងគ្នាដោយផ្ទាល់ទេ។

- អថេរទាំង២នេះហាក់ដូចជាមិនច្បាស់លាស់នៅក្នុងការទំនាក់ទំនងគ្នាជាធម្មតាកើតឡើងដោយសារកត្តា(អថេរទី៣)ដែលយើងមើលមិនឃើញ។

សម្រាប់មេរៀនការគិតបែបស៊ីជម្រៅះយើងគួរតែគិតឱ្យបានជ្រៅនូវរាល់ស្ថានភាពទាំងឡាយណាដែលតែងតែកើតមានឡើង។ជាពិសេសគួរតែគិត(ពីអ្វីដែលនៅជុំវិញខ្លួនយើង)ជាជាងការគិតតែមួយជ្រុង។

## III. សម្ភារឧបទេស

- **សម្រាប់គ្រូ** ៖ កិច្ចតែងការបង្រៀន សៀវសិក្សាគោល ក្រដាសផ្ទាំងធំ ហ្វឺត បណ្ណសំណួរ ស្កុតកុំព្យូទ័រយយួរដៃ ស្លាយមេរៀន...។
- **សម្រាប់សិស្ស** ៖ សៀវភៅសិក្សាគោល សៀវភៅសរសេរ ប៊ិក បន្ទាត់ ខ្មៅដៃ...។

## IV. វិធីសាស្ត្របង្រៀន

- **គោលវិធីសិស្សមជ្ឈមណ្ឌល**
  - វិធីបង្រៀនបែបសហការ

## V. លំនាំនៃការបង្រៀន

| សកម្មភាពគ្រូឧទ្ទេស | ខ្លឹមសារ | សកម្មភាពគរុនិស្សិត |
|---|---|---|
| ជំហានទី១៖ រដ្ឋបាលថ្នាក់ (៣នាទី) | | |
| - សម្រង់វត្តមាន( ឱ្យគរុនិស្សិតយកចង្កឹះឈ្មោះដាក់ចូលក្នុងកែវ វត្តមាន)<br>- ពិនិត្យអនាម័យ និងសណ្តាប់ធ្នាប់នៅក្នុងថ្នាក់រៀន | - សម្រង់វត្តមាន និងអវត្តមាន<br>- អនាម័យ<br>- ពង្រឹងវិន័យ និងសណ្តាប់ធ្នាប់ | -គរុនិស្សិតប្រុស និងគរុនិស្សិតស្រីយកចង្កឹះឈ្មោះដាក់ចូលក្នុងកែវវត្តមាន<br>-គរុនិស្សិតរៀបបរិស្ថាននៅក្នុងថ្នាក់រៀនបានស្អាត<br>-គរុនិស្សិតគោរពវិន័យបានល្អ |
| **ជំហានទី២៖ រំឭកមេរៀនចាស់(៥នាទី)** | | |

| សកម្មភាពគ្រូឧទ្ទេស | ខ្លឹមសារ | សកម្មភាពគរុនិស្សិត |
|---|---|---|
| **សួរសំណួររំឭកមេរៀនចាស់៖**<br>១. តើការគិតបែបស៊ីជម្រៅជាអ្វី? | ១. ការគិតបែបស៊ីជម្រៅគឺជា៖ ការគិតឱ្យបានច្បាស់លាស់ ប្រកបដោយ ភាពវៃឆ្លាត និងអាចកំណត់ វិភាគប្រកបដោយប្រសិទ្ធភាព។ អាចវាយតម្លៃលើការមិនឯកភាព ដើម្បីធ្វើឱ្យជោគជ័យទៅលើការវិនិច្ឆ័យបុគ្គល និងភាពលំអៀង ដើម្បីបង្កើតមូលហេតុសមរម្យ ក្នុងការសម្រេចចិត្តដ៏វៃឆ្លាត អំពីអ្វីដែលត្រូវធ្វើ និងអ្វីដែលជាចំណង់។ | ១.គរុនិស្សិត២ ឬ៣នាក់ឆ្លើយតាមការយល់ឃើញ និងការចងចាំមេរៀន។ |
| **សំណួរភ្ជាប់មេរៀនថ្មី៖**<br>៣. តើប្អូនៗទទួលបានចំណេះដឹងអ្វីខ្លះ ពីមេរៀនការគិតបែបស៊ីជម្រៅ? | **ទំនាក់ទំនងមេរៀនថ្មី**<br>៣.ខ្ញុំទទួលបានចំណេះដឹងពីមេរៀនការគិតបែបស៊ីជម្រៅដូចជា៖<br>- យល់ច្បាស់អំពីបញ្ហា<br>- មានភាពរឹងមាំទៅលើសមត្ថភាពនៃការគិត...។ | ៣.គរុនិស្សិត ២ឬ៣នាក់ឆ្លើយសំណួរដោយយកចិត្តទុកដាក់។<br>- យល់ច្បាស់អំពីបញ្ហា<br>- មានភាពរឹងមាំទៅលើសមត្ថភាពនៃការគិត។ |
| **ជំហានទី៣៖ ខ្លឹមសារមេរៀនថ្មី (៤៥នាទី)** | | |

| សកម្មភាពគ្រូឧទ្ទេស | ខ្លឹមសារ | សកម្មភាពគរុនិស្សិត |
|---|---|---|
| -គ្រូឧទ្ទេសសរសេរចំណងជាក់លើក្តាខៀន ឬបង្ហាញស្លាយ។<br>-ថ្ងៃនេះយើង នឹងបន្តមេរៀនការគិតបែបស៊ីជម្រៅសម្រាប់បញ្ហាការអប់រំ<br><br>**ក.**គ្រូពន្យល់អំពីទំនាក់ទំនងមិនច្បាស់លាស់(spurious correlation)រយៈពេល១៥នាទី។ | **មេរៀនទី៩៖ ការគិតបែបស៊ីជម្រៅII**<br><br>សកម្មភាពទី១ (១៥នាទី)<br><br>ក. បញ្ញត្តិទំនាក់ទំនងមិនច្បាស់លាស់៖<br>(spurious correlation)<br>○ កើតឡើងនៅពេល ដែលអថេរពីរទាក់ទង គ្នាផ្នែកស្ថិតិ ប៉ុន្តែមិនទាក់ទងគ្នាដោយផ្ទាល់ទេ។ អថេរទាំង២នេះហាក់ដូចជាមានទំនាក់ទំនងគ្នាមិនច្បាស់លាស់ ហើយជាធម្មតាដោយសារតែកត្តាទី៣ដែលមើលមិនឃើញ ។<br>○ សំដៅទៅលើទំនាក់ទំនង រវាងអថេរពីរលេចចេញជាមូលហេតុដែលទាក់ទងគ្នាទៅវិញទៅមក ប៉ុន្តែមានអថេរមួយទៀតមានទំនាក់ទំនងមិនច្បាស់លាស់។<br>**ឧទាហរណ៍ទី១៖ តារាប្រមូលទិន្នន័យ អំពីការលក់ការ៉េមគី និងម៉ាស៊ីនត្រជាក់នៅស្រុកកំណើតរបស់គាត់។ គាត់បានរកឃើញថា នៅពេលដែលការលក់ការ៉េមគីថយចុះ ការលក់** | - គរុនិស្សិតប្រុស និងស្រីស្តាប់ដោយយកចិត្តទុកដាក់ និងកត់ត្រាចំណងជើងមេរៀនថ្មីចូលក្នុងសៀវភៅដៃ។<br><br>**ក.**គរុនិស្សិតប្រុស និងសគរុនិស្សិតស្រីស្តាប់ គិត កត់ត្រាទុក និងឡើងអនុវត្តទៅលើឧទាហរណ៍ ដែលគ្រូឧទ្ទេសបានដាក់ឱ្យ។ |

| សកម្មភាពគ្រូឧទ្ទេស | ខ្លឹមសារ | សកម្មភាពគរុនិស្សិត |
|---|---|---|
| ខ.គ្រូឧទ្ទេសចែកគរុនិស្សិតប្រុស និងគរុនិស្សិតស្រីជា ៤ក្រុមតាមរយៈ ការជ្រើសរើសក្រដាសពណ៌ ដោយគ្មានការរើសអើង។ (GCED)<br>ក្រុមទី១៖ពណ៌លឿង | ម៉ាស៊ីនត្រជាក់ក៏ថយចុះដែរ ហើយនៅពេលដែលការលក់ការ៉េមកើនឡើង ការលក់ម៉ាស៊ីនត្រជាក់ក៏កើនឡើងដែរ។<br>ឧទាហរណ៍ទី២៖ នៅក្នុងរយៈពេលកន្លងមកនេះ តម្លៃនៃសំបុត្រកុនបានកើនឡើង ហើយចំនួននៃអ្នកចូលមើលកុនក៏កើនឡើងផងដែរ។ ទោះជាយ៉ាងណាក៏ដោយ វាអាចជាកំហុសដែលសន្និដ្ឋានថា ប្រសិនបើរោងកុនតម្លើងថ្លៃសំបុត្រចំនួនអ្នកមើល នឹងកើនឡើងនោះទេ។ ដូចគ្នាដែរវាអាចនឹងខុសដែលសន្មត់ថាសំបុត្រឡើងថ្លៃ បណ្ដាលឱ្យអត្រានៃអ្នកចូលមើលកុនកើនឡើង។ GECD<br>សកម្មភាពទី២ (៣០នាទី)<br>ខ. ចែកគរុនិស្សិតជា ៤ក្រុម<br>- គរុនិស្សិតពិភាក្សាជាមួយសមាជិកនៅក្រុម ដើម្បីអនុវត្តទៅលើឧទាហរណ៍២ អំពីទំនាក់ទំនងមិនច្បាស់លាស់។ GCED | ខ.គរុនិស្សិតទទួលប័ណ្ណពណ៌តាមការកំណត់របស់គ្រូ រួចចូលទៅតាមក្រុមដែលគ្រូបានរៀបចំ។ ហើយទទួលយកសន្លឹកកិច្ចការ<br>-ទទួលយកប័ណ្ណតួនាទី និង ប័ណ្ណចរាចរណ៍ រួចគិតជាមួយសមាជិកក្រុម ដើម្បី |

| សកម្មភាពគ្រូឧទ្ទេស | ខ្លឹមសារ | សកម្មភាពគរុនិស្សិត |
|---|---|---|
| ក្រុមទី២៖ពណ៌ផ្កាឈូក<br>ក្រុមទី៣៖ពណ៌ផ្ទៃមេឃ<br>ក្រុមទី៤៖ពណ៌ក្រហម<br>- គ្រូឧទ្ទេសចែកសន្លឹកកិច្ចការ<br>- គ្រូឧទ្ទេសចែកបណ្ណតួនាទីក្រុម<br>- គ្រូឧទ្ទេសចែកបណ្ណចរាចរ | | ពិភាក្សា ដើម្បីស្វែងរកឧទាហរណ៍អំពីទំនាក់ទំនងមិនច្បាស់លាស់។<br>( GCED ) |
| - គ្រូឧទ្ទេសចែកប័ណ្ណសំណួរពិភាក្សាក្រុម ៖<br>ចូរស្វែងរកឧទាហរណ៍អំពីទំនាក់ទំនងមិនច្បាស់។<br>-កង្កែបថយចុះនាំឱ្យគ្រោះថ្នាក់ចរាចរកើនឡើង។<br>-ការរ៉ែមេលក់ដាច់កាន់តែច្រើននាំឱ្យក្រពើខាំមនុស្ស។<br>-ផ្សេងៗ...។ (មានក្នុងបណ្ណកិច្ចការទី១ និងទី២) | **ឧទាហរណ៍ទី១៖ កង្កែបថយចុះនាំឱ្យគ្រោះថ្នាក់ចរាចរកើនឡើង** GCED<br>X= ចំនួនកង្កែបថយចុះ<br>Y= ចំនួនគ្រោះថ្នាក់ចរាចរណ៍<br>Z= ហេដ្ឋារចនាសម្ព័ន្ធ<br>ZX= ប្រសិនបើវាលស្រែត្រូវបានអភិវឌ្ឍទៅជាហេដ្ឋារចនាសម្ព័ន្ធ នោះចំនួនកង្កែបនឹងថយចុះ ដោយសារតែពួកវាបាត់បង់មជ្ឈដ្ឋានរស់នៅ។<br>ZY= នៅពេលផ្លូវថ្នល់ត្រូវបានគេអភិវឌ្ឍ នោះនាំឱ្យមាន គ្រោះថ្នាក់ចរាចរកើនឡើងច្រើន។<br>**ឧទាហរណ៍ទី២៖ ការរ៉ែមេលក់ដាច់កាន់តែច្រើននាំឱ្យក្រពើខាំមនុស្ស** GCED | - តំណាងក្រុមឡើងធ្វើបទបង្ហាញ ទៅតាមការបែងចែកតួនាទីក្រុមនីមួយៗ។<br>- បង្ហាញឧទាហរណ៍ ដែលបានពិភាក្សានៅក្នុងក្រុម។ |

| សកម្មភាពគ្រូឧទ្ទេស | ខ្លឹមសារ | សកម្មភាពគរុនិស្សិត |
|---|---|---|
| - ការពិភាក្សាក្រុម (មានរយៈពេល ១០នាទី )<br>-គ្រូឧទ្ទេសឱ្យតំណាងគរុនិស្សិតធ្វើបទបង្ហាញ (រយៈពេល ៥ នាទីក្នុង១ក្រុម )<br>-គ្រូឧទ្ទេសឱ្យតំណាងក្រុមឡើងធ្វើបទបង្ហាញ។<br><br>គ.បន្ទាប់ពីគរុនិស្សិតធ្វើបទបង្ហាញរួច គ្រូសំយោគ វាយតម្លៃ និងកែលម្អនូវរាល់ចំណុចខ្វះខាត។ | X= ការលក់ការ៉េម<br>Y= ក្រពើខាំ<br>Z= សីតុណ្ហភាព<br>ZX= ប្រសិនបើកំដៅឡើងខ្លាំង មនុស្សជាច្រើននឹងទិញការ៉េមញ៉ាំ។<br>ZY= ប្រសិនបើកំដៅឡើងខ្លាំង មនុស្សជាច្រើន នឹងទៅលេងទឹក ហើយក្រពើនឹងខាំពួកគេ។<br>**សំយោគខ្លឹមសារតាមក្រុម និងសង្ខេបមេរៀន**<br>គ.សរុបខ្លឹមសារអំពីមេរៀនទី៩៖**ការគិតបែបស៊ីជម្រៅ វគ្គ២** GCED (Informed & Critical Literate, the attribute of GCED learners)<br>ទំនាក់ទំនងមិនច្បាស់លាស់ គឺកើតឡើងនៅពេលអថេរ២មានទំនាក់ទំនងទៅនឹងស្ថិតិ ប៉ុន្តែមិនទាក់ទងគ្នាដោយផ្ទាល់ទេ។ អថេរទាំង២នេះហាក់ដូចជាមិនច្បាស់លាស់នៅក្នុងការទំនាក់ទំនងគ្នា ជាធម្មតាកើតឡើងដោយសារកត្តា(អថេរទី៣)ដែលយើងមើលមិនឃើញ ។<br>សង្ខេបមេរៀន<br>សម្រាប់ការគិតបែបស៊ីជម្រៅ៖យើងគួរតែគិតឱ្យបានជ្រៅនូវរាល់ស្ថានភាពទាំងឡាយណាដែលតែងតែកើតមានឡើង ។ ជាពិសេសគួរតែគិតពីអ្វីដែលនៅជុំវិញខ្លួនយើង ជាជាងការគិតតែមួយជ្រុង។ | គ.គរុនិស្សិតប្រុស និងគរុនិស្សិតស្រីទទួលយកការកែលម្អពីគ្រូ ដោយយកចិត្តទុកដាក់ និងខិតខំបំពេញនូវរាល់ចំណុចខ្វះខាតដែលគ្រូបានបន្ថែមទៅលើខ្លឹមសារឱ្យមានភាពត្រឹមត្រូវឡើងវិញ។<br>- គរុនិស្សិតប្រុស និងគរុនិស្សិតស្រីស្ដាប់ និងកត់ត្រា |

| សកម្មភាពគ្រូឧទ្ទេស | ខ្លឹមសារ | សកម្មភាពគរុនិស្សិត |
|---|---|---|
| | | - សរសេរមេរៀនសង្ខេបចូលក្នុងសៀវភៅដៃរៀងៗខ្លួន។ |
| **ជំហានទី៤៖ពង្រឹងចំណេះដឹងថ្មី ( ៥នាទី )** | | |
| - តើបញ្ញត្តិទំនាក់ទំនងមិនច្បាស់លាស់គឺជាអ្វី? ចូរបង្កើតឧទាហរណ៍ឱ្យបាន២ អំពីទំនាក់ទំនងមិនច្បាស់លាស់នៅក្នុងបរិបទអប់រំ ឬជីវិតរស់នៅប្រចាំថ្ងៃ GCED - គ្រូឧទ្ទេសឱ្យគិតជាបុគ្គល ( ៥ នាទី )។ | - បញ្ញត្តិទំនាក់ទំនងមិនច្បាស់លាស់៖ គឺកើតឡើងនៅពេល ដែលអថេរពីរទាក់ទងគ្នាផ្នែកស្ថិតិ ប៉ុន្តែមិនទាក់ទងគ្នាដោយផ្ទាល់ទេ។ អថេរទាំង២ នេះហាក់ដូចជាមានទំនាក់ទំនងគ្នាមិនច្បាស់លាស់ ហើយជាធម្មតាដោយសារតែកត្តាទី៣ ដែលមើលមិនឃើញ ។ - សំដៅទៅលើទំនាក់ទំនង រវាងអថេរពីរលេចចេញជាមូលហេតុដែលទាក់ទងគ្នាទៅវិញទៅមក ប៉ុន្តែមានអថេរមួយទៀតមានទំនាក់ទំនងមិនច្បាស់លាស់។ | - គរុនិស្សិតប្រុស និង ស្រី ឆ្លើយសំណួរ បញ្ញត្តិទំនាក់ទំនងមិនច្បាស់លាស់៖ គឺកើតឡើងនៅពេល ដែលអថេរពីរទាក់ទងគ្នាផ្នែកស្ថិតិ ប៉ុន្តែមិនទាក់ទងគ្នាដោយផ្ទាល់ទេ ...។ - សំដៅទៅលើទំនាក់ទំនងរវាងអថេរពីរលេចចេញជាមូលហេតុដែលទាក់ទងគ្នាទៅវិញទៅមក ប៉ុន្តែមានអថេរមួយទៀតមានទំនាក់ទំនងមិនច្បាស់លាស់។ |

| **សកម្មភាពគ្រូឧទ្ទេស** | **ខ្លឹមសារ** | **សកម្មភាពគរុនិស្សិត** |
|---|---|---|
| **ជំហានទី៥៖ កិច្ចការផ្ទះ និងបណ្ដាំផ្ញើ(២នាទី)** | | |
| -គ្រូឧទ្ទេសចែកបណ្ណសន្លឹកម្នាក់មួយ ឱ្យគរុនិស្សិតប្រុស និងគរុនិស្សិតស្រី ធ្វើការងារជាបុគ្គលនៅផ្ទះ។<br>-គ្រូឧទ្ទេសអរគុណ និងសម្រាប់កម្មភាពរៀនក្នុងរយៈមួយម៉ោងសិក្សា។ | **កិច្ចការផ្ទះ**<br>- សន្លឹកកិច្ចការទី៣ និងទី៤ GCED<br>ទី១៖ សំណួរ៖ចូរបង្កើតឧទាហរណ៍ឱ្យបាន២ អំពីទំនាក់ទំនងមិនច្បាស់លាស់នៅក្នុងបរិបទអប់រំ ឬជីវិតរស់នៅប្រចាំថ្ងៃ។<br>ទី២៖ចូរបកស្រាយអំពីទំនាក់ទំនងមិនច្បាស់លាស់ខាងក្រោម។<br>១. ការផឹកតែ និងមហារីកសួត<br>២.ចំនួនបណ្ណាល័យសារធារណៈ និងចំនួននៃការប្រើប្រាស់គ្រឿងញៀន | -គរុនិស្សិតប្រុស និងគរុនិស្សិតស្រីយកសន្លឹកកិច្ចការ<br>-គរុនិស្សិតប្រុស និងគរុនិស្សិតស្រីជំរាបលា។ |

## VI. ការវាយតម្លៃ

- ជំហានទី១៖ ការអង្កេតលើ ការគោរពវិន័យ សណ្ដាប់ធ្នាប់ល្អ និងបរិស្ថានក្នុងថ្នាក់ (GCED)។
- ជំហានទី២៖ វាយតម្លៃតាមរយៈចម្លើយរបស់គរុនិស្សិតលើមេរៀនចាស់ការគិតបែបស៊ីជម្រៅ។
- ជំហានទី៣៖ ក. វាយតម្លៃតាមរយៈចម្លើយ និងការអនុវត្តឧទាហរណ៍របស់គរុនិស្សិត ។
  ខ. វាយតម្លៃតាមរយៈការលើកជាឧទាហរណ៍របស់គរុនិស្សិតនៅក្នុងបរិបទអប់រំ។
  គ. វាយតម្លៃតាមរយៈការអង្កេតលើការចូលរួមរបស់គរុនិស្សិត។
- ជំហានទី៤៖ វាយតម្លៃតាមរយៈចម្លើយចូលរួមរបស់គរុនិស្សិត។
- ជំហានទី៥៖ វាយតម្លៃតាមរយៈចម្លើយរបស់គរុនិស្សិតនិងការអង្កេតការកត់ត្រានិងយកចិត្តទុកដាក់របស់គរុនិស្សិត។

# សន្លឹកកិច្ចការទី១ មេរៀនទី៩ ៖

ចូររកឧទាហរណ៍អំពីទំនាក់ទំនងមិនច្បាស់លាស់ រវាង X និង Y (រយៈពេល១០នាទី)។

កង្កែបថយចុះ → គ្រោះថ្នាក់ចរាចរកើនឡើង



# សន្លឹកកិច្ចការទី១ មេរៀនទី៩ ៖

ចូររកឧទាហរណ៍អំពីទំនាក់ទំនងមិនច្បាស់លាស់រវាង X និង Y (រយៈពេល១០នាទី)។

កង្កែបថយចុះ → គ្រោះថ្នាក់ចរាចរកើនឡើង



# សន្លឹកកិច្ចការទី២ មេរៀនទី៩ ៖

ចូររកឧទាហរណ៍អំពីទំនាក់ទំនងមិនច្បាស់លាស់រវាង X និង Y (រយៈពេល១០នាទី)។

ការរ៉េមលក់ដាច់កាន់តែច្រើន → ក្រពើខាំមនុស្ស

ឧទាហរណ៍ទី២៖

X= 

Y= 

# សន្លឹកកិច្ចការទី២ មេរៀនទី៩ ៖

ចូររកឧទាហរណ៍អំពីទំនាក់ទំនងមិនច្បាស់លាស់ រវាង X និង Y(រយៈពេល១០នាទី) ។

ការ៉េមកីលក់ដាច់កាន់តែច្រើន → ក្រពើខាំមនុស្ស

ឧទាហរណ៍ទី២៖

X= 

Y= 

Z= 

ZX=  → 

ZY=  → 

រូបភាពពី google

# សន្លឹកកិច្ចការទី៣ មេរៀនទី៩ ៖

- កាលបរិច្ឆេទ ៖.......................................ក្រុមទី៖..........................................................
- លេខរៀង ៖.........................................ថ្នាក់ ៖..........................................................

ឈ្មោះសមាជិកក្រុម៖ ១. ២.

៣. ៤.

៥. ៦.

៧. ៨.

សំណួរ៖ ចូរបង្កើត ឧទាហរណ៍ឱ្យបាន២ អំពីទំនាក់ទំនងមិនច្បាស់លាស់( spurious correlation )នៅក្នុងបរិបទអប់រំ ឬជីវិតរស់នៅប្រចាំថ្ងៃ( គិតជាបុគ្គល ) រយៈពេល៥នាទី។

**ចម្លើយ៖**

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

សូមសំណាងល្អ!

# សន្លឹកកិច្ចការទី៤ មេរៀនទី៩ ៖

- កាលបរិច្ឆេទ ៖.......................................ក្រុមទី៖.........................................................
- លេខរៀង ៖.......................................ថ្នាក់ ៖.........................................................

ឈ្មោះសមាជិកក្រុម៖ ១. ២.

៣. ៤.

៥. ៦.

៧. ៨.

សំណួរ៖ គិតជាបុគ្គល (រយៈពេល៥នាទី)

ចូរបកស្រាយអំពី ទំនាក់ទំនងមិនច្បាស់លាស់ខាងក្រោម ។

១. ការផឹកតែ និងមហារីកសួត

២. ចំនួនបណ្ណាល័យសារធារណៈ និងចំនួននៃការប្រើប្រាស់គ្រឿងញៀន

៣. ការរ៉េមលក់កាន់តែដាច់ មនុស្សលង់ទឹកកាន់តែច្រើន

**ចម្លើយ៖**

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

សូមសំណាងល្អ!

# ប្រធានបទ៖ គោលការណ៍នៃការបង្រៀន

ឡាច ប៊ុនហ៊ាន
វិទ្យាស្ថានជាតិអប់រំ

កាលបរិច្ឆេទ ៖ថ្ងៃទី........... ខែ............. ឆ្នាំ.........................
មុខវិជ្ជា ៖គរុកោសល្យ
បង្រៀនរយៈពេល ៖១ម៉ោង៣០នាទី

**១. វត្ថុបំណងមេរៀន៖** ក្រោយពីការសិក្សាមេរៀននេះចប់សិក្ខាកាមនឹងមានសមត្ថភាព៖

- វិជ្ជាសម្បទា ៖
  រៀបរាប់ពីទ្រឹស្តីនៃគោលការណ៍បង្រៀនរបស់ទស្សនៈវិទូ គរុកោសលល្យវិទូ និងចិត្តវិទូល្បីល្បាញមួយចំនួនដែលមានឥទ្ធិពល និងមានទំនាក់ទំនងគ្នាសម្រាប់ការបង្រៀន និងរៀន។
- បំណិនសម្បទា ៖
  វិភាគ និងប្រៀបធៀបទ្រឹស្តីនៃគោលការណ៍បង្រៀននីមួយៗ និងតាមរយៈខ្លឹមសារនៃមេរៀន។
- ចរិយាសម្បទា ៖
  ចូលរួមប្រើប្រាស់គោលការណ៍បង្រៀននីមួយៗស្របតាមខ្លឹមសារមេរៀន សម្រាប់ការបង្រៀន និងរៀន។

## ២. សម្ភារៈបង្រៀន ៖

- សៀវភៅគោល គរុកោសល្យ សម្រាប់ការបណ្តុះបណ្តាលគ្រូកម្រិតឧត្តមបរិញ្ញាបត្រ+២
- ឯកសារ និងសៀវភៅពិគ្រោះផ្សេង ដែលពាក់ព័ន្ធ
- រូបភាព និងខ្សែវីដេអូបង្ហាញពីទស្សនៈនៃអ្នកប្រាជ្ញ ឬអ្នកអប់រំមួយចំនួន
- កុំព្យូទ័រយួរដៃ និង LCD ឧបករណ៍បញ្ចាំងស្លាយមេរៀន
- ក្រដាស់ផ្ទាំងធំ ហ្វឺត ស្កុតបិទ កន្រ្តៃតូច

## ៣. វិធីសាស្រ្តបង្រៀន

- គោលវិធីសិស្សមជ្ឈមណ្ឌល
- វិធីបង្រៀនតាមបែបសហការ ដោយបញ្ជ្រាប GCED

## ៤. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ត្រួតពិនិត្យសណ្តាប់សិស្ស អនាម័យ<br>-ការសួរសុខទុក្ខ និងវត្តមាន (បញ្ច្រាប GECED) | **ជំហានទី ១**<br>**លំនឹង/រដ្ឋបាលថ្នាក់រៀន**<br>(**រយៈពេល ៥ នាទី**) | -សិស្សក្រោយឈរ និងអង្គុយតាមកន្លែង<br>-ប្រធានថ្នាក់រាយការណ៍ |
| -សួររំឭកមេរៀនចាស់<br>-សំណួរបំផុសដើម្បីចូលមេរៀនថ្មី។ | **ជំហានទី ២**<br>**រំឭកមេរៀនចាស់**<br>(**រយៈពេល ១០ នាទី**) | -សិស្សឆ្លើយ |
| -តើគោលការណ៍នៃការបង្រៀន មានអត្ថន័យដូចម្តេច?<br>**-ចែកសិស្សជា៤ក្រុម**<br>-ចូរលើកឡើងពីទស្សនៈលើគោលការណ៍នៃការបង្រៀនរបស់៖ | **ជំហានទី ៣**<br>**មេរៀនចាស់ថ្មី**<br>(**រយៈពេល ៦០ នាទី**)<br>**មេរៀនទី៦៖ គោលការណ៍នៃការបង្រៀន**<br>-គោលការណ៍នៃការបង្រៀន ជាទស្សនៈដែលផ្តួចផ្តើម ការដឹកនាំសកម្មភាពបង្រៀនរបស់គ្រូ និងសិស្សនៅក្នុងលំនាំនៃការបង្រៀន និងរៀន។<br>**ពិភាក្សាក្រុម**<br>-លក្ខណៈប្រវត្តិសាស្ត្រនៃគោលការណ៍បង្រៀនរបស់ទស្សនៈវិទូ គុរុកោសល្យវិទូ និងចិត្តវិទូល្បីៗ។ | -សិស្សជាដៃគូ រុករកនិយមន័យនៃពាក្យគោលការណ៍នៃការបង្រៀន រួចឆ្លើយ |

| | | |
|---|---|---|
| **ក្រុមទី១**<br>ទស្សនៈលើគោលការណ៍នៃការបង្រៀនរបស់លោក កុងកុយស៊ុស (Confucius) | **-គោលការណ៍នៃការបង្រៀនរបស់លោក កុងកុយស៊ុស(ខុងជឺ)**(Confucius)<br>-លោកជាទស្សនៈវិទូចិន (551-479<br><br>BC)<br>-យកចិត្តទុកដាក់ដល់ការពង្រឹងពង្រីកចរិតភ្ញាក់រលឹក និងចរិតសកម្មរបស់សិស្សក្នុងការសិក្សា<br>-កុង កុយស៊ុស មាន ទស្សនៈថា៖ «បើចង់ចេះ តែមិនមានឆន្ទះ នោះគឺមិនរីកបញ្ញាទេ បើចង់យល់ច្បាស់ ហើយមិនប្តេជ្ញាចិត្ត នោះក៏មិនដុះគំនិតដែរ»<br>-លោកបានទូន្មានសិស្ស ឱ្យយកចិត្តទុកដាក់ហ្វឹកហ្វឺនក្នុងការសិក្សា ដើម្បីពង្រឹងពង្រីកចំណេះដឹង<br>-លោកយល់ឃើញថា «ក្នុងពេលបង្រៀន មិនត្រឹមតែធ្វើឱ្យសិស្សសប្បាយទេ តែត្រូវធ្វើឱ្យ សិស្សចូលចិត្តទៀតផង។ | -សិស្សពិភាក្សាក្រុម |

| | | |
|---|---|---|
| **ក្រុមទី២**<br>-ទស្សនៈលើគោលការណ៍នៃការបង្រៀនលោក កូម៉ិនស្គី ( Jan Amos Kominsky ) | **-គោលការណ៍នៃការបង្រៀនរបស់ លោក កូមិនស្គី** ( Jan Amos Komnisky )<br><br>-ជាគរុកោសល្យជនជាតិ ឆេកូ<br>-គាត់ជាជនដំបូងបង្អស់ ដែលបានលើកឡើងពីទ្រឹស្តីបង្រៀនជាមូលដ្ឋាន ដែលក្នុងនោះ មានរូបភាពបង្រៀននៅក្នុងថ្នាក់<br>-ជានាបាននូវចរិតអព្ភន្តរញាណ<br>-ជានាបាននូវភាពពង្រឹងពង្រីកចរិតភ្ញាក់រលឹក និងចរិតសកម្មរបស់សិស្ស<br>-ជានាបាននូវប្រព័ន្ធកម្មនៃចំណេះដឹង<br>-ជានាបាននូវសុខភាពមាំមួនល្អគ្រប់ពេលវេលា<br>-ជានាបាននូវការយល់ជ្រួតជ្រាប ឬក្តាប់ចំណេះដឹងបាន<br>-យកចិត្តទុកដាក់ដល់ភាពដោយឡែកនៃវ័យសិក្សារបស់សិស្ស<br>-ជាគរុកោសល្យវិទូដំបូងបង្អស់ ក្នុងប្រវត្តិសាស្ត្រនៃការអប់រំ ដែលបាន | -សិស្សពិភាក្សាក្រុម |

| | | |
|---|---|---|
| | លើក ឡើងពីការផ្សារភ្ជាប់សាលារៀនទៅនឹងជីវភាពរស់នៅក្នុងសង្គម។<br>**គោលការណ៍នៃការបង្រៀនរបស់ លោក ឌីស ស្ដីវ៉ិច**<br>-លោក ឌិស ស្ដីវ៉ិច (1790-1866) ជាគរុកោសល្យវិទូជាតិ អាឡឺម៉ង់<br>-យកចិត្តទុកដាក់ដល់ការធ្វើឱ្យអភិវឌ្ឍខាងសតិអារម្មណ៍ ដែលពីមុនលោកប៉េស្តាឡូស៊ី បានសង្កត់ធ្ងន់ថា៖ «...នោះគឺ ការបង្រៀន ដែលត្រូវធ្វើឱ្យបុគ្គលិកលក្ខណៈរបស់មនុស្សអភិវឌ្ឍឡើងបាន។<br>-សាស្ត្រាចារ្យគប្បីជំរុញសតិបញ្ញារបស់សិស្សឱ្យអភិវឌ្ឍឡើងសមស្របទៅនឹងភារកិច្ចទូទៅនៅក្នុងការបង្រៀន<br>-លោកបានសង្កត់ធ្ងន់ទៅលើ គោលការណ៍ពង្រឹងពង្រីកចរិតសកម្ម និងចរិតច្នៃប្រឌិតរបស់សិស្ស។<br>**គោលការណ៍នៃការបង្រៀនរបស់ លោក អ៊ូ ជិនស្គី** | |
| **ក្រុមទី៣**<br>-ទស្សនៈលើគោលការណ៍នៃការបង្រៀនលោក ឌីស ស្ដីវ៉ិច (1790-1866) | -លោក អ៊ូ ជិនស្គី (1824-1870) គរុកោសល្យវិទូជាតិ រ៉ុស្ស៊ី<br>-លោកបានបញ្ចូលលក្ខណៈវិទ្យាសាស្ត្រទៅក្នុងលំនាំនៃការបង្រៀន ឱ្យសមស្របតាមវិទ្យាសាស្ត្រនៅក្នុងគោលការណ៍នៃការបង្រៀន<br>-គោលការណ៍នៃការបង្រៀនដោយពឹងផ្អែកលើមូលដ្ឋាននៃចិត្តវិទ្យា តក្កវិទ្យា និងជីវវិទ្យា។ -សង្កត់ធ្ងន់ចំពោះគោល | -សិស្សពិភាក្សាក្រុម |

| | | |
|---|---|---|
| | ការណ៍ដែលជានាបាននូវចរិតអព្ភន្តរញាណ ចរិតសុខភាព ចរិតសកម្មម្ចាស់ការ ចរិតយល់ជ្រួតជ្រាបច្បាស់លាស់ និងចរិតប្រព័ន្ធកម្ម<br>-ជាពិសេសលោកបានយកចិត្តទុកដាក់ដល់ចរិតស្វ័យសកម្មម្ចាស់ការរបស់សិស្ស<br>-វាយតម្លៃខ្ពស់ទៅលើអត្ថន័យនៃពលកម្ម ដោយចាត់ទុកពលកម្មថា ជាកត្តាដែលធ្វើឱ្យបុគ្គលិកលក្ខណៈ របស់មនុស្សអភិវឌ្ឍឡើង។<br><br>ការចែករំលែកទៅក្រុមផ្សេង<br>(ការបញ្ច្រាបGCED) | |
| **ក្រុមទី៤**<br>-ទស្សនៈលើគោលការណ៍នៃការបង្រៀនលោក អ៊ូ ជិនស្គី<br><br>-ចែករំលែកចម្លើយទៅក្រុមផ្សេង | | -សិស្សពិភាក្សាក្រុម<br><br>-សិស្សប្តូរក្រុម ដោយចែករំលែកចម្លើយទៅក្រុមដផ្សេងទៀត។ |

| | | |
|---|---|---|
| -គ្រូសួរសំណួរ សង្ខេប និងសន្និដ្ឋាន<br><br>- | **ជំហានទី៤**<br>**ពង្រឹងពុទ្ធិ** (**១០នាទី**)<br>គោលការណ៍ណាខ្លះដែលមានលក្ខណៈរួម?<br>(បញ្ច្រាបGCED) | -សិស្សស្ដាប់<br><br>-សិស្សឆ្លើយ |
| -ឱ្យសិស្សអានសៀវភៅគោល និងស្រាវជ្រាវឯកពាក់ព័ន្ធ ដើម្បីបន្តមេរៀនទៅសប្តាហ៍ក្រោយ។ | **ជំហានទី៥**<br>**បណ្តាំផ្ញើ**<br>(**៥នាទី**) | -សិស្សអានមេរៀនបន្ត និងស្រាវជ្រាវបន្ថែម |

# ប្រធានបទ ៖ ផលអាក្រក់នៃការរំខានដោយសំឡេងនិងកិច្ចការពារ

ពន់ ជា
វិទ្យាស្ថានជាតិអប់រំ

**កាលបរិច្ឆេទ** ៖ ថ្ងៃ............................ ខែ................. ឆ្នាំ......................... ព.ស. ២៥៦........
ត្រូវនឹងថ្ងៃទី............ ខែ................. ឆ្នាំ.........................

**មុខវិជ្ជា** ៖ ភូមិវិទ្យា

**ថ្នាក់ទី** ៖ ១១

**ជំពូកទី៤** ៖ កង្វក់និងការត្រួតពិនិត្យ

**មេរៀនទី៣** ៖ ការរំខានដោយសំឡេង

**រយៈពេល** ៖ ៥០នាទី

## ១. វត្ថុបំណង

ក្រោយពីសិក្សាចំណុចនេះចប់ សិស្សមានសមត្ថភាព៖

- **វិជ្ជាសម្បទា៖** រៀបរាប់ពីផលអាក្រក់នៃការរំខានដោយសំឡេងបានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម។

- **បំណិនសម្បទា៖**ស្វែងរកវិធានការការពារពីការរំខានដោយសំឡេងបានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម។

- **ចរិយាសម្បទា៖**សិស្សចូលរួមចំណែកទប់ស្កាត់ការរំខានដោយសំឡេងនៅក្នុងមជ្ឈដ្ឋានដែលគាត់រស់នៅប្រកបដោយភាពសុខដុមរមនា។

## ២. សម្ភារៈបង្រៀន

- សៀវភៅសិស្សថ្នាក់ទី១១ របស់ក្រសួងអប់រំ យុវជន និងកីឡា ទំព័រទី១០៤ ដល់ទំព័រទី១០៩

- សៀវភៅគ្រូថ្នាក់ទី១១ របស់ក្រសួងអប់រំ យុវជន និងកីឡា ទំព័រទី៩២ ដល់ទំព័រទី៩៥

- ឯកសារផ្សេងៗដែលទាក់ទងទៅនឹងខ្លឹមសារមេរៀន

- រូបភាពការរំខានដោយសំឡេងរួមមាន៖ សំឡេងម៉ាស៊ីនយន្តហោះ សំឡេងម៉ាស៊ីនរថយន្ត ឧគ្ឃោសនាស័ព្ទធុងបាស់ គ្រឿងចក្រ។ល។

## ៣. វិធីសាស្ត្របង្រៀន

- វិធីសាស្ត្របង្រៀនតាមបែបរិះរកតាមលំនាំ 5Es ដោយបញ្ជ្រាប GCED ។

## ៤. ដំណើរនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ជំហានទី១ លំនឹងថ្នាក់ (៣នាទី) | | |
| - គ្រូត្រួតពិនិត្យសណ្ដាប់ធ្នាប់សិស្ស<br>- គ្រូត្រួតពិនិត្យវត្តមាន<br>- គ្រូត្រួតពិនិត្យអនាម័យ ។ | ពង្រឹងរដ្ឋបាលថ្នាក់ | - សិស្សអង្គុយតាមកន្លែងដោយស្ងៀមស្ងាត់<br>- សិស្សរាយការណ៍វត្តមាន ។ |
| ជំហានទី២ រំលឹកមេរៀនចាស់ (៧នាទី) | | |
| - តើប្រភពនៃការរំខានដោយសំឡេងមានអ្វីខ្លះ? | | - ប្រភពនៃការរំខានដោយសំឡេងមានដូចជា៖<br>+ ទោចក្រយានយន្ត<br>+ រថយន្ត<br>+ គោយន្ត<br>+ ត្រាក់ទ័រ<br>+ គ្រឿងម៉ាស៊ីន<br>+ គ្រឿងចក្រ<br>+ ឧក្លោសនាស័ព្ទ<br>+ រថយន្តពន្លត់អគ្គីភ័យ<br>+ រថយន្តដឹកអ្នកជំងឺ<br>+ ការប្រគុំតន្ត្រី<br>+ គ្រឿងផ្ទុះ...។<br><br>- គេអាចវាស់បាន។<br>- គេប្រើខ្នាត ដេស៊ីបែល។ |

| | | |
|---|---|---|
| - តើគេអាចវាស់សូរសំឡេងបានដែរឬទេ? បើអាចវាស់បាន តើគេប្រើជាខ្នាតអ្វី?<br><br>ការបញ្ជ្រាប GCED<br>- នៅពេលប្អូនឮគេជជែកគ្នាខ្លាំងៗ តើប្អូនមានអារម្មណ៍បែបណា?<br><br>- បើដូច្នេះ តើវាផ្ដល់ផលល្អឬអាក្រក់សម្រាប់ប្អូននិងអ្នកដទៃ? | **សំណួរបំផុសភ្ជាប់មេរៀន** | - នៅពេលខ្ញុំឮគេជជែកគ្នាខ្លាំងៗ ខ្ញុំមានអារម្មណ៍ភ័យ បេះដូងលោតញាប់ ធុញថប់និងឈឺក្បាលជាដើម ។<br><br>- វាផ្ដល់ផលអាក្រក់សម្រាប់ខ្ញុំនិងអ្នកដទៃទៀត ។ |
| **ជំហានទី៣ មេរៀនប្រចាំថ្ងៃ (រយៈពេល៖ ៣០នាទី)** | | |
| | **ជំពូកទី៤ មេរៀនទី៣**<br>**ការរំខានដោយសំឡេង (តចប់)**<br>- ផលអាក្រក់នៃការរំខានដោយសំឡេង និងកិច្ចការពារ<br>**ទាញចំណាប់អារម្មណ៍**<br>Engagement<br> | |

| | | |
|---|---|---|
| - គ្រូបង្ហាញរូបភាព<br>- តើរូបភាពនេះបង្ហាញពីអ្វី? | | - សិស្សសង្កេតរូបភាព គិត និងឆ្លើយ។ |
| - បែងចែកក្រុមពិភាក្សាជា៤ក្រុម (ពិភាក្សាលើសំណួររួមបញ្ចូលគ្នា)<br>- តើការរំខានដោយសំឡេងមានផលអាក្រក់អ្វីខ្លះ? | **ការរំខានដោយសំឡេង**<br>**រុករក**<br>**Exploration** | - សិស្សអនុវត្ត |
| - ហៅតំណាងក្រុមនីមួយៗឱ្យឡើងរាយការណ៍ពីលទ្ធផល ។ | **ពន្យល់**<br>**Explanation**<br>- ការរំខានដោយសូរសំឡេងមានផលអាក្រក់ដូចជា អាចធ្វើឱ្យមនុស្សយើងថ្លង់ សម្ពាធឈាមឡើងខ្ពស់ សាច់ដុំទាញសន្ទឹង | - សិស្សពិភាក្សារកចម្លើយដោយមានឯកសារយោងច្បាស់លាស់ ។ |

| | | |
|---|---|---|
| - គ្រូសម្របសម្រួលដើម្បីផ្ទៀងផ្ទាត់ចម្លើយសិស្ស ។<br><br>ការបញ្ជ្រាប GCED<br>- គ្រូឱ្យសិស្សពិភាក្សាសំណួរបន្តជាក្រុម<br><br>- តើយើងត្រូវមានវិធានការណ៍អ្វីខ្លះ ដើម្បីការពារពីការរំខានដោយសំឡេង? | ហើយចង្វាក់បេះដូងលោតកាន់តែញាប់។ ម្យ៉ាងទៀត អាចបណ្ដាលឱ្យយើងឈានទៅដល់ការឈឺក្បាល ដំបៅក្រពះ ដេកមិនលក់ អារម្មណ៍មិនល្អ ធុញថប់អាប់អួនៅក្នុងសង្គម...។<br><br>ពង្រីកគំនិត<br>Elaboration<br><br>- យើងត្រូវមានវិធានការណ៍ដូចជា អប់រំប្រជាពលរដ្ឋឱ្យយល់ដឹងពីផលអាក្រក់ការរំខានដោយសំឡេង និងផ្សព្វផ្សាយតាមប្រព័ន្ធឃោសនា (វិទ្យុ ទូរទស្សន៍ ទស្សនាវដ្ដី...) និងអប់រំអំពីផលប៉ះពាល់ដោយសំឡេង។ អប់រំណែនាំម្ចាស់ផលិតកម្ម សិប្បកម្ម សហគ្រាស ហាងការហ្វេ ភោជនីយដ្ឋានឱ្យសាងសង់ដាក់ | - តំណាងក្រុមឡើងរាយការណ៍<br><br>- សិស្សស្ដាប់និងកត់ត្រា<br><br>- សិស្សស្ដាប់ គិត និងពិភាក្សាក្រុម ។ |

| | | |
|---|---|---|
| - គ្រូហៅសិស្សឡើងបញ្ចេញយោបល់ ។ | ម៉ាស៊ីនភ្លើងមានបំពង់ការពារសំឡេង។ អាជ្ញាធរពាក់ព័ន្ធត្រូវចុះតាមដានមើល បើសិនជាពុំអនុវត្តតាមការណែនាំទេ គឺត្រូវផាកពិន័យជាទឹកប្រាក់ ឬរឹបអូសជាការព្រមាន។ | - សិស្សឡើងបញ្ចេញយោបល់<br><br>- សិស្សស្តាប់ និងកែតម្រូវចម្លើយ ។ |
| **ជំហានទី៤ ពង្រឹងពុទ្ធិ ( ៧នាទី )** | | |
| **ការបញ្ជ្រាប GCED**<br><br>- ប្រសិនបើយើងមិនទប់ស្កាត់ និងការពារការរំខានដោយសំឡេងមិនបានត្រឹមត្រូវ តើវាផ្តល់ផលប៉ះពាល់អ្វីខ្លះដល់សង្គមជាតិ ? | **វាយតម្លៃ**<br><br>Evaluation | - ប្រសិនបើយើងមិនទប់ស្កាត់ និងការពារការរំខានដោយសំឡេងមិនបានត្រឹមត្រូវ វាផ្តល់ផលប៉ះពាល់ដល់សង្គមជាតិដូចជា៖<br><br>+ ធ្វើឲ្យប្រជាជនមានបញ្ហាសុខភាព<br><br>+ ធ្វើឲ្យសេដ្ឋកិច្ចជាតិធ្លាក់ចុះ |

| | | |
|---|---|---|
| | | + ធ្វើឲ្យមានទំនាស់ក្នុងសង្គម<br>+ ធ្វើឲ្យខូចបរិស្ថាន<br>+ ធ្វើឲ្យបាត់បង់ភ្ញៀវទេសចរ<br>+ ធ្វើឲ្យសង្គមជាតិមានភាពអនាធិបតេយ្យ ជាដើម ។ |
| **ជំហានទី៥ កិច្ចការផ្ទះ និងបណ្តាំផ្ញើ (៣នាទី)** | | |
| ការបញ្ជ្រាប GCED<br>- តើយើងត្រូវធ្វើដូចម្តេចដើម្បីផ្សព្វផ្សាយពីផលប៉ះពាល់នៃការរំខានដោយសំឡេង?<br><br>- ប្អូនៗត្រូវស្វ័យសិក្សាជាប្រចាំ និងកុំភ្លេចធ្វើខ្លួនឲ្យទៅជាកូនល្អ សិស្សល្អ និងមិត្តល្អ ។ | **កិច្ចការផ្ទះ**<br><br>**បណ្តាំផ្ញើ** | - សិស្សកត់ត្រាសំណួរ ។<br><br>- សិស្សកត់ត្រា និងអនុវត្តតាម ។ |

# ប្រធានបទ: ការធ្វើចំណាត់សិលាកម្ទេចកំណ

នី សុពុទ្ធី
វិទ្យាស្ថានជាតិអប់រំ

កាលបរិច្ឆេទ: ....................................... រយៈពេល: ៥០នាទី កម្រិត (ថ្នាក់): ទី១២

**មុខវិជ្ជា៖ ផែនដី និងបរិស្ថានវិទ្យា**

**ជំពូកទី១ មេរៀនទី២៖ សិលា**

**១. វត្ថុបំណង:** នៅពេលចប់មេរៀននេះ សិស្សនឹងទទួលបាន ៖

- **វិជ្ជាសម្បទា:** រៀបរាប់ពីកំណកំណើតរបស់ប្រភេទទាំង៣នៃសិលាកម្ទេចកំណបានត្រឹមត្រូវ។
- **បំណិនសម្បទា:**
  - កំណត់ឈ្មោះគម្រូសិលាកម្ទេចកំណ និងធ្វើចំណាត់ថ្នាក់គម្រូសិលាកម្ទេចកំណតាមប្រភេទបានត្រឹមត្រូវតាមរយៈការសង្កេតគម្រូសិលា និងការពិភាក្សាក្រុម។
  - វិភាគសារៈសំខាន់របស់សិលា ផលប៉ះពាល់ពីអាជីវកម្មសិលាចំពោះបរិស្ថាន សង្គម និងដំណោះស្រាយប្រកបដោយទំនួលខុសត្រូវ និងសីលធម៌តាមរយៈការពិភាក្សាក្រុម។
  - អភិវឌ្ឍបំណិនក្នុងការប្រើប្រាស់មីក្រូទស្សន៍ និងកែវពង្រីកសង្កេតក្រាម សិលា
  - អភិវឌ្ឍបំណិនក្នុងការបកស្រាយ វែកញែកពន្យល់ និងធ្វើអំណៈអំណាងតាបបែបវិទ្យាសាស្ត្រ។
- **ចរិយាសម្បទា:** ឱ្យគុណតម្លៃចំពោះសិលា ប្រើប្រាស់សិលាប្រកបដោយទំនួលខុសត្រូវ និងចូលរួមថែរក្សាសិលាឱ្យប្រើប្រាស់បានយូរអង្វែង។

**២. ខ្លឹមសារ**

-សិលាកម្ទេចកំណ

**៣. សម្ភារឧបទេស:**

- គម្រូសិលាកម្ទេចកំណ៖ ថ្មភាជន៍ ថ្មភក់ សិលាក្រែ សិលាក្តាំង ប្រេស្យា ថ្មកំបោរសរីរាង្គ ធ្យូងថ្ម ហាលីត និង កាល់ស៊ីត
- មីក្រូទស្សន៍ កែវពង្រីក ទឹកខ្មេះ ក្រដាសជូត
- សន្លឹកកិច្ចការ

**៤. លំនាំនៃការបង្រៀន៖**

**វិធីសាស្ត្របង្រៀនបែបរិះរកតាមលំនាំ** 5E **ដោយបញ្ជ្រាប** GCED

I) **ដំណើរការបង្រៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| | **ជំហានទី១ លំនឹងថ្នាក់ (៣នាទី)** | |
| ○ គ្រូត្រួតពិនិត្យសណ្តាប់ធ្នាប់សិស្ស<br><br>○ ត្រួតពិនិត្យវត្តមាន<br>○ គ្រូលើកបញ្ហាសកលដូចជា សង្គ្រាមនៅអ៊ុយក្រែន និងផលប៉ះពាល់សេដ្ឋកិច្ចសកលលោក និងកម្ពុជា | ពង្រឹងរដ្ឋបាលថ្នាក់<br><br>GCED: ទាញចំណាប់អារម្មណ៍សិស្សអំពីបញ្ហាដែលបានប៉ះពាល់ទៅដល់អន្តរកម្ម និងទំនាក់ទំនងរបស់សហគមន៍នៅក្នុងកម្រិតមូលដ្ឋាន ជាតិ និងសកល | ▪ សិស្សអង្គុយតាមកន្លែងដោយស្ងៀមស្ងាត់<br>▪ សិស្សរាយការណ៍វត្តមាន<br>▪ សិស្សគិតអំពីបញ្ហាដែលកំពុងកើតឡើងក្នុងសកលលោក និងក្នុងប្រទេស កម្ពុជា |
| | **ជំហានទី២ រំលឹកមេរៀនចាស់ (៥នាទី)** | |
| ○ តើសិលាមានប៉ុន្មានប្រភេទ? អ្វីខ្លះ?<br><br>○ តើធរណីវិទូធ្វើចំណែកថ្នាក់ប្រភេទសិលាដោយផ្អែកលើអ្វីខ្លះ? | រំលឹកសិស្សអំពីចំណេះដឹងដែលមានរៀនកាលពីពេលមុន។ | ▪ សិលាមានបីប្រភេទធំៗគឺ សិលាកម្ទេចកំណ សិលាម៉ាក់ម៉ា សិលាប្រែកំណើត<br>▪ ធរណីវិទូធ្វើចំណែកថ្នាក់ប្រភេទសិលាដោយផ្អែកលើវាយភាព និងសមាសធាតុផ្សំ។ |
| | **ជំហានទី៣ មេរៀនថ្មី (៣៥នាទី)**<br><br>**ជំពូក2 មេរៀនទី4 ប្រភេទសិលា (ត)** | |
| (ទាញចំណាប់អារម្មណ៍)<br>○ បង្ហាញគម្រូសិលាកម្ទេចកំណមួយចំនួន រួចឱ្យសិស្សសង្កេត<br><br>○ បន្ទាប់មកសួរសំណួរគន្លឹះ |  | ▪ សិស្សសង្កេតគម្រូសិលា<br><br>▪ សិស្សអានសំណួរគន្លឹះ និងស្វែងយល់ |

**សំណួរគន្លឹះ**

ចូរកំណត់ឈ្មោះ និងប្រភេទគម្រូសិលាកម្ទេចកំណទាំងនេះ។

| | | |
|---|---|---|
| ○ គ្រូសួរអំពីប្រភេទសិលា និងឈ្មោះសិលាដែលសិស្សធ្លាប់ស្គាល់(ប្រភេទអ្វី ឈ្មោះអ្វីខ្លះ?) (**បង្កើតសម្មតិកម្ម**)<br><br>(**រុករក**)<br>○ ចែកសិស្សជា៦ក្រុម (<u>**ដោយគិតអំពី GCED៖ គោរពភាពចម្រុះភាពខុសគ្នា និងសមូហភាព**</u>) ហើយប្រគល់គម្រូសិលា និងសម្ភារសម្រាប់ធ្វើតេស្តសិលារួមមានមីក្រូទស្សន៍ កែវពង្រីក បន្ទាត់ក្រិត ទឹកខ្មេះ ក្រដាសជូត និងតារាងកំណត់លក្ខណៈរបស់សិលាកម្ទេចកំណតាមក្រុមនីមួយៗដើម្បីធ្វើការសង្កេត និងវិភាគអំពីឈ្មោះ និងប្រភេទនៃសិលាកម្ទេចកំណ<br><br>○ គ្រូចែកសន្លឹកកិច្ចការ និងណែនាំខ្លះៗអំពីរបៀបប្រើប្រាស់ និងកត់ត្រា<br><br>○ ឱ្យសិស្សចាប់ផ្តើមពិភាក្សាគ្នាដើម្បីកំណត់ប្រភេទ និងឈ្មោះគម្រូសិលា<br><br>(**ពន្យល់**) | <u>**៣. សិលាកម្ទេចកំណ**</u><br><br>សិលាកម្ទេចកំណកើតឡើងពីការបង្ហាំផ្សាភ្ជាប់គ្នានៃកម្ទេចកំណរាប់លានឆ្នាំ។ គេចែកសិលាកម្ទេចកំណបីប្រភេទគឺ សិលាកម្ទេចកំណក្លាស្ទិច សិលាកម្ទេចកំណគីមី និងសិលាកម្ទេចកំណសរីរាង្គ ដោយផ្អែកលើរបៀបនៃការកកើត។<br><br>➢ សិលាកម្ទេចកំណក្លាស្ទិច៖ សិលាកម្ទេចកំណក្លាស្ទិចកើតឡើងពីការបង្ហាំភ្ជាប់គ្នានៃបំណែកសិលា និងរ៉ែ។ អ្នកវិទ្យាសាស្ត្រកំណត់ឈ្មោះសិលាកម្ទេចកំណក្លាស្ទិចតាមរយៈទំហំភាគល្អិត។ ឧទាហរណ៍ ថ្មភក់(d < 0.004mm) ថ្មភាជន៍(0.06 mm< d < 0.004mm) សិលាក្រែ (2 mm < d < 0.06 mm) សិលាក្លាំង និងប្រេស្យា (d > 2mm)។<br>➢ សិលាកម្ទេចកំណគីមី៖ កើតឡើងពីកំណជាក្រោមនៃសូលុយស្យុងរ៉ែ។ ឧទាហរណ៍ | ▪ សិស្សទស្សន៍ទាយឈ្មោះ និងប្រភេទសិលាកម្ទេចកំណ។<br><br>▪ សិស្សផ្តុំគ្នាជាក្រុម ទទួលយកគម្រូសិលា(រូបភាព) និងសម្ភារសម្រាប់វិភាគប្រភេទ និងឈ្មោះសិលាកម្ទេចកំណ។<br><br>▪ សិស្សទទួលសន្លឹកកិច្ចការ និងស្តាប់ការណែនាំ |

<table>
<tr>
<td>
○ ហៅតំណាងក្រុមនីមួយៗឱ្យឡើងរាយការណ៍លទ្ធផល។<br><br>
○ គ្រូសម្របសម្រួលដើម្បីផ្ទៀងផ្ទាល់ចម្លើយសិស្ស<br>
(ពង្រីកគំនិត)<br>
(<u>ការបញ្ជ្រាប GCED: សហគមន៍មនុស្ស និងទំនាក់ទំនងក្នុងសហគមន៍ សកម្មភាពដែលអាចធ្វើដោយបុគ្គល និងសមូហភាព ឥរិយាបថទទួលខុសត្រូវប្រកបដោយសីលធម៌ ការចូលរួមសកម្មភាពនានារបស់សហគមន៍</u>)<br>
○ គ្រូឱ្យសិស្សពិភាក្សាសំណួរបន្តជាក្រុម៖<br>
Q1. តើសិលាទាំងនេះមានសារៈសំខាន់ដូចម្តេចខ្លះ?<br>
Q2. តើការធ្វើអាជីវកម្មសិលាផ្តល់ផលប៉ះពាល់ដូចម្តេចខ្លះ៖ ចំពោះបរិស្ថាន និងសហគមន៍ដែលនៅក្បែរអាជីវកម្មសិលា?
</td>
<td>
សិលាហាលីត កាល់ស៊ីត និងថ្មកំបោរគីមី<br>
➢ សិលាកម្ទេចកំណសរីរាង្គ៖ កើតពីការចាក់បង្គរនៃសាកសពសត្វ និងរុក្ខជាតិរាប់លានឆ្នាំ។ ឧទាហរណ៍ ថ្មកំបោរសរីរាង្គ និងធ្យូងថ្ម។
</td>
<td>
▪ សិស្សចាប់ផ្តើមធ្វើការពិភាក្សា<br><br>
▪ តំណាងក្រុមឡើងបកស្រាយអំពីឈ្មោះ និងប្រភេទសិលាកម្ទេចកំណ។<br>
<table>
<tr><th>សិលាកម្ទេចកំណក្លាស្ទិច</th><th>សិលាកម្ទេចកំណគីមី</th><th>សិលាកម្ទេចកំណសរីរាង្គ</th></tr>
<tr><td>ថ្មភាជន៍<br>ថ្មភក់<br>សិលាក្រែ<br>សិលាក្លាំង<br>ប្រេស្សា</td><td>ហាលីត<br>កាល់ស៊ីត</td><td>ថ្មកំបោរសរីរាង្គ<br>ធ្យូងថ្ម</td></tr>
</table>

<br>
▪ សិស្សស្តាប់ និងកែតម្រូវចម្លើយ<br><br>
▪ សិស្សពិភាក្សាគ្នា
</td>
</tr>
</table>

| | | |
|---|---|---|
| **Q3. តើយើងត្រូវធ្វើដូចម្ដេចដើម្បីរួមចំណែកកាត់បន្ថយផលប៉ះពាល់ និងប្រើប្រាស់សិលាឱ្យបានយូរអង្វែង?**<br>○ គ្រូហៅសិស្សឡើងបញ្ចេញយោបល់ | | ▪ សិស្សឡើងបញ្ចេញមតិ៖<br>A1. សារៈសំខាន់៖ រ៉ែ ការងារ អាជីវកម្ម ផលិតកម្ម ជម្រកសត្វព្រៃ ទេសចរណ៍ ........។<br>A2. ផលប៉ះពាល់ពីអាជីវកម្មសិលា៖ ប៉ះពាល់សុខភាពមនុស្ស បំផ្លាញជម្រកសត្វព្រៃ បំពុល...។<br>A3. កំណត់មូលហេតុនៃផលប៉ះពាល់ ចូលរួមអប់រំពលរដ្ឋដែលខ្វះការយល់ដឹង រិះរកវិធីការពារ ប្រើប្រាស់សិលាដោយសន្សំសំចៃ ទប់ស្កាត់អាជីវកម្មខុសច្បាប់..។ |
| | **ជំហានទី៤ ពង្រឹងពុទ្ធិ (៥នាទី)** | |
| (វាយតម្លៃ) | រំលឹកសិស្សនូវចំណុចសំខាន់ៗដែលបានរៀនថ្ងៃនេះ។ | |

| | | |
|---|---|---|
| ○ តើសិលាកម្ទេចកំណទាំង៣ ប្រភេទខុសគ្នាដូចម្ដេចខ្លះ? <br><br> ○ ចូរចាត់ថ្នាក់សិលាទាំងនេះ ទៅតាមប្រភេទទាំង៣នៃ សិលាកម្ទេចកំណ៖ សិលាក្រៃ កាល់ស៊ីត ថ្មកំបោរ សិលាក្លាំង ហាលីត ធ្យូងថ្ម។ <br><br> ○ តើសិលាក្រៃ និងថ្មកំបោរខុសគ្នាដូចម្ដេចខ្លះ? | | ▪ សិលាកម្ទេចកំណក្លាស្ទិច កើតឡើងពីការបង្ហាំភ្ជាប់គ្នា នៃបំណែកសិលា និងរ៉ែ។ សិលាកម្ទេចកំណគីមីកើត ឡើងពីកំណជាក្រាមនៃសូលុយស្យុងរ៉ែ។ សិលាកម្ទេចកំណសរីរាង្គកើតពី ការចាក់បង្គរនៃសាកសពសត្វ និងរុក្ខជាតិរាប់លានឆ្នាំ។ <br> ▪ សិលាក្រៃ និងសិលាក្លាំង ជាប្រភេទសិលាក្លាស្ទិច កាល់ស៊ីត និងហាលីតជា ប្រភេទសិលាកម្ទេចកំណ គីមី ថ្មកំបោរ និងធ្យូងថ្ម ជា សិលាកម្ទេចកំណសរីរាង្គ។ <br> ▪ សិលាក្រៃកើតពីគ្រាប់ខ្សាច់ រីឯថ្មកំបោរកើតពីសំណល់ សរីរាង្គ |
| **ជំហានទី៥ បណ្ដាំផ្ញើ ឬកិច្ចការផ្ទះ (២នាទី)** | | |
| ○ ចូររាប់ឈ្មោះសិលាកម្ទេចកំណផ្សេងទៀត និងចាត់ថ្នាក់ទៅតាមប្រភេទនៃសិលាកម្ទេចកំណ(សិលាក្លាស្ទិចចំនួន៥ សិលាសរីរាង្គចំនួន៥ និងសិលាគីមីចំនួន៥)។ | ដើម្បីពង្រីកចំណេះក្ដៅសាលា | ▪ សិស្សប្រមូលសិលានៅតាមមូលដ្ឋានដើម្បីកំណត់ឈ្មោះ និងប្រភេទសិលា។ |

## សន្លឹកកិច្ចការ

## សំណួរគន្លឹះ

ចូរកំណត់ឈ្មោះ និងប្រភេទរបស់គម្រូសិលាកម្ទេចកំណាទាំងនេះ!




**សម្មតិកម្ម៖**

....................................................................................................................................

....................................................................................................................................

....................................................................................................................................

**លទ្ធផល៖**

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

**សន្និដ្ឋាន៖**

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

## ព័ត៌មានអំពីសិលាកម្ទេចកំណា

❖ **ប្រភេទសិលា៖**

- សិលាកម្ទេចកំណក្លាស្ទិច៖ សិលាកម្ទេចកំណក្លាស្ទិចកើតឡើងពីការបង្ហាំភ្ជាប់គ្នានៃបំណែកសិលា និងរ៉ែ។ អ្នកវិទ្យាសាស្ត្រកំណត់ឈ្មោះសិលាកម្ទេចកំណក្លាស្ទិចតាម រយៈទំហំភាគល្អិត។ ឧទាហរណ៍ ថ្មភក់( d < 0.004mm ) ថ្មភាជន៍( 0.06 mm< d < 0.004mm ) សិលាក្រែ ( 2 mm < d < 0.06 mm ) សិលាក្លាំង និងប្រេស្យា ( d > 2mm )។
- សិលាកម្ទេចកំណគីមី៖ កើតឡើងពីកំណជាក្រាមនៃសូលុយស្យុងរ៉ែ។
- សិលាកម្ទេចកំណសរីរាង្គ៖ កើតពីការចាក់បង្គរនៃសាកសពសត្វ និងរុក្ខជាតិរាប់លានឆ្នាំ។

❖ **ឈ្មោះសិលា៖** ថ្មភក់ ( Shale ) ថ្មភាជន៍( Siltstone ) សិលាក្រែ( Sandstone ) សិលាក្លាំង ( Conglomerate ) ប្រេស្យា( Breccia ) ថ្មកំបោរសរីរាង្គ( Organic limestone ) ធ្យូងថ្ម( Coal ) ហាលីត( Halite ) និងកាល់ស៊ីត( Calcite )។

# ប្រធានបទ៖ ការត្រួតពិនិត្យលើការងារ និងអតិផរណា

ហេង វិបុល និង រុយ សុភលក្ខិណា
វិទ្យាស្ថានជាតិអប់រំ

កាលបរិច្ឆេទ៖ ថ្ងៃ................ ខែ................ ឆ្នាំ.....................ព.ស. ២៥៦........

ត្រូវនឹងថ្ងៃទី............... ខែ................ ឆ្នាំ.......................

មុខវិជ្ជា៖ សេដ្ឋកិច្ច

បង្រៀនរយៈពេល៖ (១ម៉ោង ០០នាទី)

**១. វត្ថុបំណងនៃមេរៀន**

**ក្រោយពីបញ្ចប់ការសិក្សាមេរៀននេះ បញ្ញាបខ្លឹមសារពលរដ្ឋសកលដល់អ្នកសិក្សាអំពី៖**

- **វិជ្ជាសម្បទា/ពុទ្ធិ៖** ពន្យល់អំពីមូលហេតុនៃភាពមានការងារ និងគ្មានការងារធ្វើ អត្រាអត់ការងារធ្វើ ទីផ្សារកម្លាំងពលកម្ម និងអត្រាចូលរួមកម្លាំងពលកម្ម។
- **បំណិនសម្បទា/ចិត្ត៖** បង្ហាញអំពីមូលហេតុនៃភាពមានការងារ និងភាពគ្មានការងារធ្វើ អត្រាអត់ការងារធ្វើ ទីផ្សារកម្លាំងពលកម្ម និងអត្រាចូលរួមកម្លាំងពលកម្ម។
- **ចរិយាសម្បទា/ឥរិយាបថ៖** បណ្ដុះស្មារតីយុវជនឲ្យស្វែងយល់អំពីទីផ្សារការងារ មានសិទ្ធិស្មើគ្នា និងសមធម៌ក្នុងការស្វែងរកចំណូល ដោយគិតអំពីបរិស្ថាន និងជួយដល់សង្គម។ (បញ្ញាប GCED)

**២. សម្ភារៈបង្រៀន**

- ឯកសារ ឬសៀវភៅពិគ្រោះ
- សៀវភៅសិក្សាគោល ហ្វឺត ក្ដារខៀន
- រូបភាព (ប្រភេទការងារ)
- កុំព្យូទ័រ LCD ឧបករណ៍បញ្ចាំស្លាយ
- វចនានុក្រម សេដ្ឋកិច្ច

**៣. វិធីសាស្ត្របង្រៀន**

- គោលវិធីសិស្សមជ្ឈមណ្ឌល
- វិធីសាស្ត្របង្រៀនបែបចម្រុះ 5Es

**៤. ដំណើរការបង្រៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារ** | **សកម្មភាពសិស្ស** |
|---|---|---|
| **ជំហានទី១ រដ្ឋបាលថ្នាក់រៀន** *(៣ នាទី)* | | |
| រដ្ឋបាលថ្នាក់រៀន | **ពង្រឹងថ្នាក់** | ក្រោកឈរ សៀមស្ងាត់ |

| ពិនិត្យវត្តមាន | | ប្រធានថ្នាក់រាយការណ៍ |
|---|---|---|
| **ជំហានទី២ រម្លឹកមេរៀនចាស់ និងសំនួរន្ទាប់ *(៧ នាទី)*** | | |
| Z សួរសំណួររម្លឹកមេរៀនចាស់<br>Z សំណួរបំផុសដើម្បីចូលមេរៀនថ្មី<br>តើប្អូនៗ ចង់ដឹងអំពីការងារទេ? តើនាអនាគត ប្អូនៗចង់ធ្វើការងារអ្វីដែល? | **រម្លឹកមេរៀនចាស់** | សិស្សឆ្លើយជាលក្ខណៈបុគ្គល |
| **ជំហានទី៣ មេរៀនថ្មី *(៣០ នាទី)*** | | |
| ❖ តើលក្ខណៈអ្វីខ្លះ ដែលកំណត់ថាអ្នកមានការងារធ្វើ | មេរៀនទី១<br>ការត្រួតពិនិត្យលើការងារ និងអតិផរណា<br>លក្ខណៈកំណត់ថា ជាជនមានការងារធ្វើ<br>១. មនុស្សទាំងអស់ដែលបានធ្វើការងារណាមួយ ដើម្បីប្រាក់ឈ្នួល ឬប្រាក់ចំណេញក្នុងអំឡុងពេលសប្តាហ៍យោងការស្ទង់មតិ។<br>២. មនុស្សទាំងអស់ដែលបានធ្វើការយ៉ាងតិច ១៥ ម៉ោងនៃការងារដែលមិនមានប្រាក់ខែនៅក្នុងសហគ្រាសដែលដំណើរការដោយគ្រួសារ។<br>៣. ជនទាំងអស់ដែលអវត្តមានពីការងារទៀងទាត់ជាបណ្តោះអាសន្ន ដោយសារជំងឺ។ វិស្សមកាល អាកាសធាតុមិនល្អ ជម្លោះឧស្សាហកម្ម ឬហេតុផលផ្ទាល់ខ្លួនផ្សេងៗ។<br><br>លក្ខណៈសំគាល់ថា ថាជាជនអត់ការងារធ្វើ?<br>១. មនុស្សទាំងអស់ដែលមិនមានការងារធ្វើបានខិតខំប្រឹងប្រែងយ៉ាងសកម្មជាក់លាក់ ដើម្បីស្វែងរកការងារក្នុងអំឡុងពេល បួនសប្តាហ៍មុន ហើយអាចរកបានសម្រាប់ការងារ។<br>២. មនុស្សទាំងអស់ដែលមិនធ្វើការ ហើយកំពុងរង់ចាំការហៅត្រឡប់ទៅការងារវិញនៅពេលពួកគេត្រូវបានបញ្ឈប់ជាបណ្តោះអាសន្ន។ | សិស្សស្តាប់និងឆ្លើយសំនួរ |

| | | |
|---|---|---|
| ❖ តើលក្ខណៈអ្វីខ្លះ ដែលកំណត់ថាជាជនអត់ការងារធ្វើ? | | សិស្សឆ្លើយ |
| បង្កើតសកម្មភាព<br>គ្រូបង្កើតការចាប់អារម្មណ៍<br>១. តើរូបភាពនេះ បង្ហាញអំពីអ្វីខ្លះ?<br><br>គ្រូបែងចែកសិស្សជាក្រុម<br>សំនួរពិភាក្សា និងឆ្លើយ<br>២. ហេតុផលអ្វីខ្លះដែលបង្កអោយក្លាយជាជនគ្មានការងារធ្វើ? | ១. Engagement( ទាញចំណាប់អារម្មណ៍ )<br><br><br>២. Exploration ( ការរុករក )<br>**ខ្លឹមសារពិភាក្សាក្រុម** ( ២០នាទី )<br>ហេតុផលផ្សេងៗ បង្កឲ្យក្លាយជាជនអត់ការងារធ្វើ។ | សិស្សឆ្លើយ<br><br>សិស្សពិភាក្សាក្រុម<br>សិស្សកត់ត្រា<br>សិស្សសួរខ្លួនឯង<br>សិស្សសួរសំនួរក្នុងក្រុម |

| | | |
|---|---|---|
| គ្រូសង្កេត ពិនិត្យការគិតរបស់សិស្ស<br>គ្រូបង្កើតសំនួរបំផុត<br><br>គ្រូជាអ្នកសម្របសម្រួល(មានភស្តុតាង និងអំណះអំណាងមានលក្ខណៈវិទ្យាសាស្ត្រ និងសមស្របជាមួយសង្គម)<br><br>គ្រូជាអ្នកចូលរួម ពន្យល់ វែកញែក និងផ្តល់សេចក្តីសន្និដ្ឋានចុងក្រោយ។<br><br>ការចោទជាសំនួរដោយបញ្ជ្រាប GCED<br>៣. តើភាពមានការងារធ្វើជួយដល់សេដ្ឋកិច្ច និងសង្គមដូចម្តេច?<br>គ្រូលើកទឹកចិត្តសិស្សបង្ហាញ<br>ភស្តុតាង ឯកសារអំណះអំណាង | ៣. Explanation ពន្យល់ (២៥នាទី)<br>១. Job Loser នេះជាមនុស្សម្នាក់ដែលត្រូវបានគេជួលក្នុងកម្លាំងពលកម្មស៊ីវិល ហើយក៏ជា បណ្តេញចេញ ឬបញ្ឈប់ពីការងារ។ អ្នកអត់ការងារធ្វើភាគច្រើនធ្លាក់ចូលក្នុងប្រភេទនេះ។<br>២. អ្នកលាឈប់ពីការងារ Job Leaver នេះជាបុគ្គលដែលបម្រើការងារក្នុងកម្លាំងពលកម្មស៊ីវិល ដែលឈប់ពីការងារ។ ជាឧទាហរណ៍ ប្រសិនបើ Jim លាឈប់ពីការងារជាមួយ<br>ក្រុមហ៊ុន X ហើយកំពុងស្វែងរកការងារល្អជាង។ បន្ទាប់មកគាត់ជាអ្នកឈប់ធ្វើការ។<br>៣. Reentrant ជាមនុស្សដែលធ្លាប់មានការងារធ្វើ មិនបានធ្វើខ្លះ<br>ហើយបច្ចុប្បន្នកំពុងចូលបម្រើការងារវិញ។<br>៤. New entrant. នេះជាមនុស្សដែលមិនធ្លាប់ធ្វើការងារពេញម៉ោងរយៈ ពេល២សប្តាហ៍ ឬ យូរជាងនេះ ហើយឥឡូវនេះគឺកំពុងស្វែងរកការងារធ្វើ។<br><br>៤. Elaboration ពង្រីកគំនិត (១៥នាទី)<br>✓ ខ្ញុំចង់បើហាងលក់ម្ហូបអាហារ ដែលគិតអំពីបរិស្ថាន<br>✓ បើបើកសាលា ឬក្រុមហ៊ុន ខ្ញុំនឹងធ្វើជំរលឡើងចុះសម្រាប់ជនពិការ | សិស្សសង្កេត គិតពិចារណា និងផ្តល់ចំលើយ<br><br>សិស្សតំណាងក្រុមឡើងពន្យល់ និងសន្និដ្ឋាន<br><br>សិស្សឆ្លើយ (គិត ដោះស្រាយបញ្ហា) |
| **ជំហានទី៤៖** ពង្រឹងពុទ្ធិ (៧នាទី) | | |

| | | |
|---|---|---|
| ❖ ហេតុផលអ្វីខ្លះដែលបង្កអោយក្លាយជាជនគ្មានការងារធ្វើ? | ៥. Evaluation (វាយតម្លៃ) | សិស្សឆ្លើយសំណួរជាលក្ខណៈបុគ្គល |
| **ជំហានទី៥៖** បណ្តាំផ្ញើ (៣នាទី) | | |
| ចូរប្អូនៗស្វែកយល់អំពីរបៀបសរសេរប្រវត្តិរូបសង្ខេប CV | កិច្ចការផ្ទះ | កិច្ចការយកនៅថ្ងៃស្អែក |

# ប្រធានបទ៖ វិធីធ្វើបង្អែមបបរត្នោត

ឆាយ បូនី, ហុង សុវណ្ណ

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

កាលបរិច្ឆេទ ៖ ថ្ងៃ ................. ខែ................. ឆ្នាំ.....................ពស. ២៥៦.....

ត្រូវនឹងថ្ងៃទី........... ខែ.... ឆ្នាំ២០២...

មុខវិជ្ជា ៖ គេហវិទ្យា

មេរៀនទី៦ ៖ វិធីធ្វើបង្អែម

អំពី ៖ បបរត្នោត

រយៈពេល ៖ ២ម៉ោងសិក្សា

ថ្នាក់ ៖ បឋមសិក្សា (១២+៤) ឆ្នាំទី២ ឆមាសទី២

## I. វត្ថុបំណង

- វិជ្ជាសម្បទា ៖គរុនិស្សិតប្រាប់បានពីរបៀបចម្អិនបបរត្នោតបានត្រឹមត្រូវ តាមរយៈសំណួរគន្លឹះ និងការស្រាវជ្រាវ។
- បំណិនសម្បទា ៖គរុនិស្សិតចម្អិនបបរត្នោតបានយ៉ាងឈ្លយឆ្ងាញ់តាមរយៈការអនុវត្តផ្ទាល់ជាក្រុម។
- ចរិយាសម្បទា ៖ឱ្យតម្លៃបង្អែមខ្មែរ និងមានទំនួលខុសត្រូវក្នុងការធ្វើបង្អែមប្រកបដោយអនាម័យ និងមានសុវត្ថិភាពដល់អ្នកទទួលទាន។ (GCED៖ អាកប្បកិរិយាទទួលខុសត្រូវប្រកបដោយសីលធម៌)

## II. ខ្លឹមសារមេរៀន

បង្អែមបបរត្នោត

ក. គ្រឿងផ្សំ

ខ. វិធីធ្វើ

## III. សម្ភារៈឧបទេស

- ចំពោះគ្រូ៖ ស្លាយមេរៀន LCD Projector

- ចំពោះសិស្ស៖ សម្ភារសម្រាប់ចម្អិន និងគ្រឿងផ្សំ( គ្រាប់ត្នោតខ្ចី អង្ករដំណើប ស្ករ ខ្ទិះដូង អំបិល )

## IV. វិធីសាស្ត្របង្រៀន

វិធីសាស្ត្របង្រៀនតាមបែបរិះរក

## V. ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពគរុនិស្សិត |
|---|---|---|
| | ជំហានទី១ រដ្ឋបាលថ្នាក់( ៣នាទី ) | |
| -ពិនិត្យអនាម័យនិងសណ្តាប់ធ្នាប់<br>-សួរនិងស្តាប់ប្រធានថ្នាក់រាយការណ៍វត្តមានសិស្ស | រដ្ឋបាលថ្នាក់ | -ក្រោកឈរស្វាគមន៍គ្រូ<br>-ប្រធានថ្នាក់ឡើងរាយការណ៍វត្តមាន |
| | ជំហានទី២ រំលឹកមេរៀនចាស់ ( ១០នាទី ) | |
| -តើគ្រឿងផ្សំសម្លការីមានអ្វីខ្លះ ? | **ជំហានទី២**<br>-សាច់មាន់ ១គីឡូក្រាម<br>-សាច់គោ ឬសាច់ជ្រូក( ឆ្អឹងជំនីរជ្រូកក៏បាន )៥ខាំ<br>-គ្រឿងការី.....<br>-គ្រឿងទេស( អំបិល ស្ករ ប៊ីចេង កាពិ... )<br>-បន្លែ( ខ្ទឹមបារាំង ១មើម ការ៉ុត ១មើម ដំឡូងបារាំង ១-២មើម ត្រប់ សណ្តែកកួរ( មិនដាក់ក៏បាន )<br>**ទំនាក់ទំនងមេរៀនថ្មី** | -សាច់មាន់ ១គីឡូក្រាម<br>-សាច់គោ ឬសាច់ជ្រូក( ឆ្អឹងជំនីរជ្រូកក៏បាន )៥ខាំ<br>-គ្រឿងការី.....<br>-គ្រឿងទេស( អំបិល ស្ករ ប៊ីចេង កាពិ... )<br>-បន្លែ( ខ្ទឹមបារាំង ១មើម ការ៉ុត ១មើម ដំឡូងបារាំង ១-២មើម ត្រប់ សណ្តែកកួរ( មិនដាក់ក៏បាន ) |

| | | |
|---|---|---|
| -បង្ហាញរូបភាព<br>-តើនេះជារូបភាពអ្វី?<br>-តើវាដុះនៅកន្លែងណាខ្លះ?<br>-តើត្នោតមានប្រយោជន៍អ្វីខ្លះ?<br>-តើផ្លែត្នោតមានសារៈសំខាន់អ្វីខ្លះ? | <br>-ខ្ចីធ្វើបង្អែម ញ៉ាំខ្ចី ទុំធ្វើនំ និងជាចំណីសត្វ គោផងដែរ។ | -សិស្សសង្កេតដោយយកចិត្តទុកដាក់<br>-ដើមត្នោត<br>-វាដុះនៅតាមព្រៃ ភ្លឺស្រែ តាមភូមិ<br>-ដើមត្នោតគេយកធ្វើផ្ទះ និងអុស ធាងត្នោតធ្វើ គ្រឿងប្រើប្រាស់ដូចជា សង្រែកជាដើម ស្លឹកយកដេរប្រក់ដំបូល ផ្សេងៗផ្លែធ្វើបង្អែមទាំង ខ្ចីនិងទុំ...។ល។<br>-ខ្ចីធ្វើបង្អែម ញ៉ាំខ្ចី ទុំធ្វើនំ និងជាចំណីសត្វ គោផងដែរ។ |
| ជំហានទី៣ មេរៀនថ្មី (៨៥នាទី) | | |
| -គ្រូបង្ហាញរូបភាពដើម្បីគរុនិស្សិតងាយបង្កើតសំណួរគន្លឹះ | **មេរៀនទី៦៖ វិធីធ្វើបង្អែមបបរត្នោត** | -សង្កេតដោយយកចិត្តទុកដាក់ |

| | | |
|---|---|---|
| -តើនេះជារូបភាពអ្វី?<br><br>-ឱ្យគរុនិស្សិតបង្កើតសំណួរគន្លឹះ<br><br>-បែងចែកសិស្សជាពីរក្រុម<br><br>-ឱ្យគរុនិស្សិតបង្កើតសម្មតិកម្មដោយសួរសំណួរគន្លឹះទៅកាន់គរុនិស្សិត<br><br>- តើបបរត្នោតដែលមានរសជាតិឈ្ងុយឆ្ងាញ់មានគ្រឿងផ្សំអ្វីខ្លះ?មានវិធីធ្វើយ៉ាងដូចម្ដេច?<br>-ឱ្យគរុនិស្សិតឡើងសរសេរចម្លើយដែលគេបានដឹងដាក់ក្ដារខៀន | <br><br>-បង្អែមបបរត្នោត<br><br>សំណួរគន្លឹះ<br><br>- **តើបបរត្នោតដែលមានរសជាតិឈ្ងុយឆ្ងាញ់មានគ្រឿងផ្សំអ្វីខ្លះ?មានវិធីធ្វើយ៉ាងដូចម្ដេច?**<br><br>សកម្មភាព<br><br>-បបរត្នោតគ្រឿងផ្សំដូចជា<br><br>គ្រាប់ត្នោតខ្ចី អង្ករដំណើប ស្ករត្នោត ទឹក/ខ្ទិះចុង អំបិល ខ្ទិះដូងដើម ម្សៅធា។<br><br>-វិធីធ្វើមានដូចជា៖មុនដំបូងត្រូវដាក់ទឹក ឬខ្ទិះដូងចុង និងអង្ករដំណើបក្នុងឆ្នាំងដាំជាមួយគ្នាឱ្យពុះ បន្ទាប់មកដាក់អំបិល និងស្ករចូល។<br><br>នៅពេលដែលអង្ករដំណើបឆ្អិនល្អហើយ ដាក់គ្រាប់ត្នោតចូល ទុកមួយពុះប្រហែលជា២ ទៅ៣នាទី ដាក់ខ្ទិះដើមចូលរួចយកម្សៅធា២ស្លាបព្រាកាហ្វេលាយទឹក១ស្លាបព្រាបាយកូរអោយរលាយ(មិនដាក់ក៏បាន) ចាក់ចូលកូរឱ្យឡើងខាប់ៗជាការស្រេច។ | -បង្អែមបបរត្នោត<br><br>-បង្កើតសំណួរគន្លឹះនិងអានដោយយកចិត្តទុកដាក់។<br><br>-គរុនិស្សិតចូលតាមក្រុម<br><br>-សិស្សសាកល្បងឆ្លើយសំណួរគន្លឹះ<br><br>-គរុនិស្សិតសរសេរចម្លើយដាក់លើក្ដារខៀន |

| | | |
|---|---|---|
| **-ក្រុមនីមួយៗសហការគ្នា** ចម្អិនទៅតាមសម្មតិកម្មដែលគេបានលើកឡើង)<br>-ឱ្យតំណាងក្រុមឡើងរាយការណ៍ពីលទ្ធផលក្រោយអនុវត្តជាក់ស្តែង<br>-គ្រូ និងគរុនិស្សិតភ្លក្សបង្អែមស្នាដៃទាំងពីរក្រុម និងវិភាគរួមគ្នាទៅលើចម្លើយទាំងពីរក្រុម<br>**GCED៖ ៩. ប្រសិទ្ធភាពនៃការធ្វើការងារក្រុម**<br>-គ្រូសម្របសម្រួលចម្លើយគរុនិស្សិត និងធ្វើសេចក្តីសន្និដ្ឋានរួម<br>-ឱ្យគរុនិស្សិតកត់មេរៀនដាក់ក្នុងសៀវភៅ | -ចម្អិនបង្អែមបបរត្នោតជាក្រុម<br>-គ្រឿងផ្សំ និងវិធីចម្អិនបបរត្នោត<br>- បង្អែមបបរត្នោតស្នាដៃទាំងពីរក្រុម<br>សេចក្តីសន្និដ្ឋាន<br>-បង្អែមបបរត្នោតមានគ្រឿងផ្សំដូចជា៖គ្រាប់ត្នោត២០គ្រាប់ ឬ៤៥០ក្រាម (សាច់ទន់) អង្ករដំណើប១០០ក្រាម ស្ករត្នោត១៥០ក្រាម ទឹក/ខ្ទិះចុង១លីត្រ អំបិល១/៤ស្លាបព្រាកាហ្វេ ខ្ទិះដូងដើម២៥០ក្រាម ម្សៅធា២ស្លាបព្រាកាហ្វេ+ទឹក១ស្លាបព្រាបាយ (មិនដាក់ក៏បាន)។<br>-វិធីធ្វើ៖មុនដំបូងត្រូវដាក់ទឹក ឬខ្ទិះដូងចុង និងអង្ករដំណើបក្នុងឆ្នាំងដាំជាមួយគ្នាឱ្យពុះ បន្ទាប់មកដាក់អំបិល និងស្ករចូល។<br>នៅពេលដែលអង្ករដំណើបឆ្អិនល្អហើយ ដាក់គ្រាប់ត្នោតចូល ទុកមួយពុះប្រហែលជា២ ទៅ៣នាទី ដាក់ខ្ទិះដើមចូលរួចយកម្សៅធា២ស្លាបព្រាកាហ្វេលាយទឹក១ស្លាបព្រាបាយកូរអោយរលាយ(មិនដាក់ក៏បាន) ចាក់ចូលកូរឱ្យឡើងខាប់ៗជាការស្រេច | -ចម្អិនដាក់ស្តែង<br>-តំណាងក្រុមរាយការណ៍<br>- ភ្លក្សបង្អែមស្នាដៃទាំងពីរក្រុម និងវិភាគរួមគ្នា<br>-គរុនិស្សិតស្តាប់<br>-កត់មេរៀនដាក់ក្នុងសៀវភៅ |
| ជំហានទី៤ ពង្រឹងចំណេះដឹង(៧នាទី) | | |

| | | |
|---|---|---|
| -តើប្អូនត្រូវចម្អិនបបរត្នោតយ៉ាងដូចម្តេចឱ្យមានរសជាតិឆ្ងាញ់? | -មុនដំបូងត្រូវដាក់ទឹក ឬខ្ទិះដូងចុង និងអង្ករដំណើបក្នុងឆ្នាំងដាំជាមួយគ្នាឱ្យពុះ បន្ទាប់មកដាក់អំបិល និងស្ករចូល។<br>នៅពេលដែលអង្ករដំណើបឆ្អិនល្អហើយ ដាក់គ្រាប់ត្នោតចូល ទុកមួយពុះប្រហែលជា២ ទៅ៣នាទី ដាក់ខ្ទិះដើមចូលរួចយកម្សៅឆា២ស្លាបព្រាកាហ្វេ(មិនដាក់ក៏បាន) ដាក់ទឹក១ស្លាបព្រាបាយកូរអោយរលាយ ចាក់ចូលកូរឱ្យឡើងខាប់ៗជាការស្រេច។ | -មុនដំបូងត្រូវដាក់ទឹក ឬខ្ទិះដូងចុង និងអង្ករដំណើបក្នុងឆ្នាំងដាំជាមួយគ្នាឱ្យពុះ បន្ទាប់មកដាក់អំបិល និងស្ករចូល។<br>នៅពេលដែលអង្ករដំណើបឆ្អិនល្អហើយ ដាក់គ្រាប់ត្នោតចូល ទុកមួយពុះប្រហែលជា២ ទៅ៣នាទី ដាក់ខ្ទិះដើមចូលរួចយកម្សៅឆា២ស្លាបព្រាកាហ្វេ(មិនដាក់ក៏បាន) ដាក់ទឹក១ស្លាបព្រាបាយកូរអោយរលាយ ចាក់ចូលកូរឱ្យឡើងខាប់ៗជាការស្រេច។ |
| -តើការចេះចម្អិនបង្អែមបបរត្នោតផ្តល់អត្ថប្រយោជន៍អ្វីខ្លះ? GCED | -អត្ថប្រយោជន៍នៃបង្អែមបបរត្នោតមានដូចជា៖ អាចចម្អិនសម្រាប់ញ៉ាំក្នុងគ្រួសារ បង្រៀនសិស្សបន្ត ទទួលភ្ញៀវ ចម្អិនលក់ដើម្បីរកប្រាក់ចំណូល សន្សំថវិកា អាចធ្វើដើម្បីបំបាត់ការអផ្សុក ជួយឱ្យអ្នកភូមិទាញប្រយោជន៍ពីដើមត្នោត<br>-អ្នកចម្អិនត្រូវគិតលើគ្រឿងផ្សំដែលមានគុណភាព ការរៀបចំ អនាម័យអំឡុងនិងក្រោយចម្អិន... | -អត្ថប្រយោជន៍នៃបង្អែមបបរត្នោតមានដូចជា៖ អាចចម្អិនសម្រាប់ញ៉ាំក្នុងគ្រួសារ បង្រៀនសិស្សបន្ត ទទួលភ្ញៀវ ចម្អិនលក់ដើម្បីរកប្រាក់ចំណូល សន្សំថវិកា អាចធ្វើដើម្បីបំបាត់ការអផ្សុក ជួយឱ្យអ្នកភូមិទាញប្រយោជន៍ពីដើមត្នោត<br>- អ្នកចម្អិនត្រូវគិតពីសុខភាព និងសុវត្ថិភាពអ្នកទទួលទាន ដោយប្រើគ្រឿងផ្សំមានគុណភាព និងសុវត្ថិភាព មានអនាម័យក្នុងការចម្អិន ទុកដាក់ឱ្យមាន |

| | | |
|---|---|---|
| - តើអ្នកចម្អិនបបរឆ្នោតត្រូវគិតពីសុខភាព និងសុវត្ថិភាពអ្នកទទួលទានយ៉ាងដូចម្ដេច? (GCED៖ អាកប្បកិរិយាទទួលខុសត្រូវប្រកបដោយសីលធម៌) | - អ្នកចម្អិនត្រូវគិតពីសុខភាព និងសុវត្ថិភាពអ្នកទទួលទាន ដោយប្រើគ្រឿងផ្សំមានគុណភាព និងសុវត្ថិភាព មានអនាម័យក្នុងការចម្អិន ទុកដាក់ឱ្យមានសុវត្ថិភាពនិង រយៈពេលសមស្រប...។ | សុវត្ថិភាពនិងរយៈពេលសមស្រប...។ |
| **ជំហានទី៥(១៥នាទី)** | | |
| -ចូរប្អូនស្រាវជ្រាវពីគ្រឿងផ្សំ និងរបៀបធ្វើចាហួយដូងឱ្យបានឈ្ងុយឆ្ងាញ់។<br><br>- រាល់ការចម្អិននិងការទទួលទានអាហារ ប្អូនៗត្រូវគិតពីសុខភាព និងសុវត្ថិភាពជាចម្បង។ (GCED៖ អាកប្បកិរិយាទទួលខុសត្រូវប្រកបដោយសីលធម៌) | កិច្ចការផ្ទះ<br><br>បណ្ដាំផ្ញើ | -កត់កិច្ចការផ្ទះចូលក្នុងសៀវភៅ<br><br>-ស្ដាប់តាមការណែនាំរបស់អ្នកគ្រូ។ |

# ប្រធានបទ៖ ព័ត៌មាន ទំនាក់ទំនង និងបច្ចេកវិទ្យា(ផ្នែកទី១១)

យាង ប៉េងលី
វិទ្យាស្ថានជាតិអប់រំ

កាលបរិច្ឆេទ ៖ថ្ងៃ................. ខែ................ ឆ្នាំ.............. ព.ស.២៥៦.......
ត្រូវនឹងថ្ងៃទី............ ខែ.................. ឆ្នាំ២០២......

**មុខវិជ្ជា** ៖បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍

**ប្រធានបទ** ៖ព័ត៌មាន ទំនាក់ទំនង និងបច្ចេកវិទ្យា(ផ្នែកទី១១)

**រយៈពេល** ៖៥០នាទី

I. **វត្ថុបំណង៖** ក្រោយពីបានសិក្សាមេរៀននេះចប់ គរុសិស្សនឹងទទួលបាន៖

1.**វិជ្ជាសម្បទា៖**

- ពណ៌នាមុខងារសំខាន់ៗរបស់សមាសធាតុកុំព្យូទ័របានត្រឹមត្រូវ តាមរយៈការអង្កេត
- បង្ហាញពីសារប្រយោជន៍នៃការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យា តាមរយៈការស្រាវជ្រាវ

2.**បំណិនសម្បទា៖**

- បកស្រាយពីសមាសធាតុកុំព្យូទ័របានត្រឹមត្រូវ តាមរយៈការអនុវត្តន៍
- វិភាគពីសារប្រយោជន៍នៃការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យា តាមរយៈការពិភាក្សាក្រុម

3. **ចរិយាសម្បទា៖**

- អនុវត្តការប្រើប្រាស់សមាសធាតុរបស់កុំព្យូទ័របានត្រឹមត្រូវ។
- ប្រាប់ពីសារប្រយោជន៍នៃការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាក្នុងការសិក្សាបានទូលំទូលាយ
- បណ្ដុះស្មារតីឲ្យសិស្សចូលរួមប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាក្នុងការសិក្សា និងការងារដើម្បីជួយ**កាត់បន្ថយផលប៉ះពាល់**ដល់ **បរិស្ថាន សេដ្ឋកិច្ច និងសង្គម**។ (GCED)

II. **សម្ភារៈឧបទេស៖**

- -កិច្ចតែងការបង្រៀន
- -សៀវភៅបច្ចេកវិទ្យាព័ត៌មាន និង សារគមនាគមន៍សម្រាប់ថ្នាក់ទី១១
- -ហ្វឺតពណ៌ខៀវ ឧបករណ៍លុបក្ដារខៀន
- -កុំព្យូទ័រសម្រាប់សិស្សអនុវត្ត និងឧបករណ៍បញ្ចាំងស្លាយ
- -ស្លាយសម្រាប់បង្រៀន

III. **វិធីសាស្ត្របង្រៀន** ៖គោលវិធីសិស្សមជ្ឈមណ្ឌល តាមបែបសហការ **ដោយបញ្ជ្រាប** GCED

## IV. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| **ជំហានទី១ ៖ លំនឹងថ្នាក់ (២នាទី)** | | |
| -ឱ្យប្រធានថ្នាក់រាយការណ៍ពីចំនួនសិស្សអវត្តមាន<br>-ពិនិត្យអនាម័យ សណ្តាប់ធ្នាប់និងឯកសណ្ឋានគរុសិស្ស<br>- សួរសុខទុកគ្នា និងចែករំលែកនូវព័ត៌មានទាក់ទងការងារសង្គមនិងការរស់នៅប្រចាំថ្ងៃ GCED | -ពិនិត្យអនាម័យថ្នាក់រៀន និងសណ្តាប់ធ្នាប់ថ្នាក់រៀន<br>-ពិនិត្យឯកសណ្ឋានសិស្ស<br>-ពិនិត្យអវត្តមានសិស្ស | -សិស្សឈរឱ្យគ្រូពិនិត្យឯកសណ្ឋាន និងចូលអង្គុយ តាមកន្លែងរៀងខ្លួន<br>-ប្រធានថ្នាក់រាយការណ៍ពីចំនួនសិស្សអវត្តមាន<br>- សិស្សស្តាប់ ត្រិះរិះពិចារណារាល់ព័ត៌មានទាំងនេះ GCED |
| **ជំហានទី២ ៖ រំលឹកមេរៀនចាស់ (៣នាទី)** | | |
| -តើការផ្តល់បរិបទមិនគ្រប់គ្រាន់ធ្វើឲ្យមានបញ្ហាអ្វីខ្លះនៅក្នុងទំនាក់ទំនង ? | -ធ្វើឲ្យអ្នកស្តាប់មិនយល់ពីកាលៈទេសៈនៃទំនាក់ទំនងដែលអ្នកផ្តល់ព័ត៌មានចង់បាន<br>-ធ្វើឲ្យអ្នកស្តាប់យល់ច្រឡំលើគំនិតរបស់អ្នកផ្តល់ព័ត៌មាន<br>-ធ្វើឲ្យការទំនាក់ទំនងមិនជោគជ័យដូចការចង់បាន។ | - សិស្សគិតស្វែងរកចម្លើយដែលគ្រូបានសួរ<br>- សិស្សឡើងឆ្លើយនូវចម្លើយដែលគាត់បានគិតឃើញ |
| **ជំហានទី៣៖ខ្លឹមសារមេរៀន(៤០នាទី)** | | |
| -ដូចម្តេចដែលហៅថាកុំព្យូទ័រ ? | -កុំព្យូទ័រគឺជាម៉ាស៊ីនអេឡិចត្រូនិកដែលអាចប្រើសម្រាប់ជំនួយក្នុងការប្រមូល រៀបចំ គណនា និងផ្តល់ព័ត៌មានយ៉ាងមានប្រសិទ្ធភាព ។<br>-វាជាច្រកចេញចូលសម្រាប់ព័ត៌មាននៅជុំវិញពិភពលោកតាមរយៈ | -សិស្សព្យាយាមឆ្លើយរៀងខ្លួន និងជាក្រុម តាមរយៈបទពិសោធន៍ផ្ទាល់ខ្លួនរបស់គេ។ |



| | | |
|---|---|---|
| | អ៊ីនធឺណិត។ | |
| -តើយើងអាចប្រើកុំព្យូទ័រសម្រាប់ធ្វើអ្វីខ្លះ? | -កុំព្យូទ័រប្រើសម្រាប់សម្រួលការងាររដ្ឋបាលដូចជា៖ រៀបចំអត្ថបទ ប្រមូលព័ត៌មាន វិភាគព័ត៌មាន គណនា ។ល។<br>-កុំព្យូទ័រប្រើប្រាស់សម្រាប់ទំនាក់ទំនងមនុស្សជុំវិញពិភពលោកដើម្បី កម្សាន្ត ទទួល និងចែករំលែកព័ត៌មាន ។<br>GCED<br> | -សិស្សព្យាយាមឆ្លើយរៀងខ្លួនតាមរយៈបទពិសោធន៍ផ្ទាល់ខ្លួនរបស់គេ។ |
| -ចូរប្អូននិយាយពីតួនាទីនៃផ្នែកនីមួយៗរបស់កុំព្យូទ័រ? | <br>-ធុងប្រព័ន្ធ ៖ជាប្រអប់ដែលផ្ទុកនូវរាល់គ្រឿងដំណើរការទាំងអស់របស់កុំព្យូទ័រ ។<br>-ម៉ូនីទ័រ ៖ជាឧបករណ៍ស្រដៀងគ្នានឹងទូរទស្សន៍ដែលមានអេក្រង់ប្រើសម្រាប់បង្ហាញព័ត៌មានដល់អ្នកប្រើ។<br>-ក្តារចុចៈជាឧបករណ៍សម្រាប់បញ្ចូលព័ត៌មាន ដូចជាការវាយ<br>អត្ថបទ ទៅក្នុងកុំព្យូទ័រ។ | -សិស្សព្យាយាមឆ្លើយរៀងខ្លួនតាមរយៈបទពិសោធន៍ផ្ទាល់ខ្លួនរបស់គេ។ |

| | | |
|---|---|---|
| | -កណ្ដុរៈជាឧបករណ៍សម្រាប់បញ្ជាព្រួញកណ្ដុរ ។ | |
| **<u>សំណួរពិភាក្សាក្រុម</u>**<br>- បែងចែកសិស្សជា៣ក្រុម ដោយឱ្យពិភាក្សាលើបរិស្ថាន សេដ្ឋកិច្ច និងសង្គម។<br>- តើការប្រើប្រាស់កុំព្យូទ័រផ្ដល់អត្ថប្រយោជន៍អ្វីខ្លះដល់បរិស្ថាន សេដ្ឋកិច្ច និងសង្គម? GCED | **បរិស្ថានៈ** GCED<br>-កាត់បន្ថយទីកន្លែងទុកឯកសារ និងការប្រើប្រាស់ក្រដាសក្នុងការងារប្រចាំថ្ងៃ។<br>**សេដ្ឋកិច្ចៈ** GCED<br>-ចំណេញពេលវេលាច្រើនក្នុងការប្រតិបត្តិការងារ<br>-សន្សំសំចៃថវិកាដោយសារការកាត់បន្ថយប្រើប្រាស់ក្រដាសច្រើនសន្ធឹកសន្ធាប់ពីមួយឆ្នាំទៅមួយឆ្នាំ<br>-ការងារទទួលបានលទ្ធផលល្អ ធ្វើឲ្យអាជីវកម្មរីកចម្រើន។<br>**សង្គមៈ** GCED<br>-ធ្វើឲ្យមានភាពងាយស្រួលក្នុងការទទួលបានព័ត៌មានទាន់ហេតុការណ៍<br>-សង្គមកាន់តែរីកចម្រើនឡើងថែមទៀត។ | - សិស្សធ្វើការពិភាក្សាជាក្រុម<br>- សិស្សគិតរកចម្លើយដែលគ្រូបានសួរ<br>- ដំណាងក្រុមឡើងបកស្រាយ |
| **ជំហានទី៤៖ ពង្រឹងពុទ្ធិ (៣នាទី)** | | |
| -តើយើងអាចប្រើកុំព្យូទ័រសម្រាប់ធ្វើអ្វីខ្លះ? | -កុំព្យូទ័រប្រើសម្រាប់សម្រួលការងាររដ្ឋបាលដូចជា៖ រៀបចំអត្ថបទ ប្រមូលព័ត៌មាន វិភាគព័ត៌មាន គណនា ។ល។<br>-កុំព្យូទ័រប្រើប្រាស់សម្រាប់ទំនាក់ទំនងមនុស្សជុំវិញពិភពលោកដើម្បី កម្សាន្ត ទទួល និងចែករំលែកព័ត៌មាន ។ GCED | -សិស្សព្យាយាមឆ្លើយរៀងៗខ្លួនតាមរយៈចំណេះដឹងពីមេរៀននិងការស្រាវជ្រាវ ដែលពួកគេបានសិក្សារួច។ |
| **ជំហានទី៥៖បណ្ដាំផ្ញើ(២នាទី)** | | |
| -ឲ្យសិស្សមើលមេរៀនដែលទើបនឹងបានរៀនហើយឡើងវិញ និងមើល | | -កត់មេរៀននូវចំណុចសំខាន់ៗសម្រាប់មើលឡើងវិញនិងមើលជា |

| | | |
|---|---|---|
| មេរៀនជាបន្តទៀតសម្រាប់ផ្នែកទី២ គឺបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT)។<br>-តើយើងអាចប្រើកុំព្យូទ័រសម្រាប់ធ្វើអ្វីខ្លះ?<br>-ផ្តាំផ្ញើឲ្យសស្សជួយធ្វើការងារឪពុកម្តាយពេលទំនេរពីការសិក្សា | | បន្ត<br>-ស្តាប់នូវការណែនាំរបស់គ្រូទាក់ទងនឹងការជួយការងារឪពុកម្តាយនៅផ្ទះ |

## ប្រធានបទ៖ ការប្រើប្រាស់អ៊ីនធឺណិត និងបង្កើតអ៊ីម៉ែល

សោ ភក្តី
វិទ្យាស្ថានគរុកោសល្យបាត់ដំបង

កាលបរិច្ឆេទ ៖ ថ្ងៃ.........................ខែ.....................ឆ្នាំ................ព.ស.២៥៦...
ត្រូវនឹងថ្ងៃទី.............ខែ...................ឆ្នាំ២០២....
មុខវិជ្ជា ៖ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍
ថ្នាក់ ៖ បឋម ឆមាស១ ឆ្នាំទី១
ប្រធានបទ ៖ មេរៀនទី៥ ការប្រើប្រាស់អ៊ីនធឺណិត និងបង្កើតអ៊ីម៉ែល
រយៈពេល ៖ ២ ម៉ោងសិក្សា

### I. វត្ថុបំណង

វិជ្ជាសម្បទា ៖ ពណ៌នាពីរបៀបបង្កើត ប្រើប្រាស់អ៊ីម៉ែល និងប្រភពដើមនៃអ៊ីនធឺណិត និងគេហទំព័របានត្រឹមត្រូវ តាមរយៈការពន្យល់ខ្លឹមសារមេរៀន

បំណិនសម្បទា ៖ ពន្យល់ពីរបៀបបង្កើត ប្រើប្រាស់អ៊ីម៉ែល និងការប្រើប្រាស់អ៊ីនធឺណិតបានត្រឹមត្រូវ តាមរយៈការអនុវត្តជាក់ស្តែងរៀងៗខ្លួន

ចរិយាសម្បទា ៖ ជំរុញឱ្យគរុនិស្សិតប្រើប្រាស់ និងចែករំលែកពីការប្រើប្រាស់អ៊ីនធឺណិត អ៊ីម៉ែលឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពចំពោះខ្លួនឯង និងអ្នកដទៃក្នុងសង្គម និងពិភពលោក(GCED)

### II. សម្ភារៈឧបទ្ទេស

- មេរៀនសម្រាប់គ្រូ និងស្លាយសម្រាប់បង្រៀន
- ហ្វឺត ប្រដាប់លុបក្តារខៀន
- កុំព្យូទ័រ និងឧបករណ៍បញ្ចាំងស្លាយ

### III. វិធីសាស្ត្របង្រៀន

- ពិភាក្សាសហការ
- អនុវត្តជាក់ស្តែង

## IV. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ជំហានទី ១៖ លំនឹងថ្នាក់ ( ១០នាទី ) | | |
| - ឱ្យប្រធានថ្នាក់រាយការណ៍ពីវត្តមាន និងអវត្តមានសិស្ស។<br>- ពិនិត្យអនាម័យសណ្តាប់ធ្នាប់ និង ឯកសណ្ឋានសិស្ស។ | - ពិនិត្យវត្តមាន និងអវត្តមានសិស្ស<br>- ពិនិត្យអនាម័យថ្នាក់រៀន<br>- ពិនិត្យឯកសណ្ឋានសិស្ស | - ប្រធានថ្នាក់ឡើងរាយការណ៍ពីវត្តមាន និងអវត្តមានសិស្ស។<br>- សិស្សឈរឱ្យគ្រូពិនិត្យឯកសណ្ឋាន និងចូលអង្គុយតាមកន្លែងរៀងៗខ្លួន។ |
| ជំហានទី ២៖ រំលឹកមេរៀនចាស់ ( ១៥នាទី ) | | |
| វាយអត្ថបទភាសាខ្មែរ | <br>មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនកម្ពុជា-ឥណ្ឌា Cambodia-India Entrepreneurship Development Centre<br>2. ប្រភេទនៃកុំព្យូទ័រ ( Types of Computer System )<br>សព្វថ្ងៃនៅលើពិភពលោកយើងនេះ កុំព្យូទ័រត្រូវបានគេចែកចេញជាប្រាំប្រភេទផ្សេងៗគ្នា៖<br>1. Super Computer: អាចធ្វើការគណនាបានចំនួនច្រើន វាត្រូវបានរក្សាទុកក្នុងបន្ទប់ពិសេស វាមានល្បឿនលឿនជាងMicrocomputer ប្រហែលជា 50 000ដង ហើយមានតំលៃប្រហែល 20 លានដុល្លា ។ យើងអាចជួបជាមួយវានៅក្នុងវិស័យយោធា សភាវុធ ឧត្តុនិយម ឬស្រាវជ្រាវ វិទ្យាសាស្ត្រនៅតាមសកលវិទ្យាល័យធំៗមួយចំនួន និងការគ្រប់គ្រងលើអវកាស ។<br>2. Mainframe Computer: គឺជាកុំព្យូទ័រធំមួយ ជាធម្មតាគេដាក់វានៅក្នុងមជ្ឈដ្ឋានមួយដែរមានសីតុណ្ហភាព និង សំណើមសមស្របដែលអាចផ្តល់នូវតំរូវការដំណើរការរាប់រយ និង អ្នកប្រើប្រាស់រាប់ពាន់ ។<br>3. Minicomputer: គឺជាប្រភេទម៉ាស៊ីនថ្នាក់កណ្តាល វាត្រូវបានគេប្រើប្រាស់ជាលក្ខណៈមួយៗដូចជា Workstations តែមួយឬ ក៏ដូចទៅនឹងប្រព័ន្ធមួយដែលភ្ជាប់ទៅដោយ Networks ទៅនឹង Terminals រាប់រយសំរាប់អ្នកប្រើប្រាស់រាប់រយនាក់ ។ វាត្រូវបានគេដាក់ប្រើប្រាស់ក្នុងក្រុមហ៊ុនធុនមធ្យម ឬអាគារធំៗជាទូទៅប្រើនៅក្នុង Accounting, Design និង Industry ។<br>4. Microcomputer/PC: គឺជាម៉ាស៊ីនកុំព្យូទ័រដែលត្រូវបានគេបង្កើតឡើងសំរាប់ប្រើប្រាស់ចំពោះមនុស្សម្នាក់ ក្នុងពេលតែមួយ ។ ខុសពី Super Computer, Mainframe និង Minicomputer ដែលបង្កើតឡើងសំរាប់ប្រើប្រាស់ដោយមនុស្សច្រើន ក្នុងពេលតែមួយដើម្បីដោះស្រាយរួមគ្នា ។<br>5. Laptop: ជាម៉ាស៊ីនកុំព្យូទ័រចល័ត មានទំហំតូច ស្រាល ប៉ុន្តែមានតំលៃថ្លៃជាង Microcomputer ។ | សិស្សអនុវត្តន៍១៥នាទី |
| ជំហានទី ៣៖ ខ្លឹមសារមេរៀន ( ៨៥នាទី ) | | |
| | | |
| ការណែនាំអំពីអ៊ីនធឺណិត និងគេហទំព័រ | *អ៊ីនធឺណិត<br>• បណ្តាញភ្ជាប់គ្នានៃកុំព្យូទ័រ និងខ្សែទិន្នន័យ<br>• ភ្ជាប់ទំនាក់ទំនងមនុស្សរាប់លាននាក់ក្នុងពិភពលោក និងអង្គភាព<br>• មូលដ្ឋានគ្រឹះនៃបដិវត្តន៍បណ្តាញឌីជីថល<br>*គេហទំព័រ<br>• ផ្តល់នូវចំណុចប្រទាក់ងាយស្រួលប្រើចំពោះធនធានអ៊ីនធឺណិត | - ស្តាប់គ្រូដោយយកចិត្តទុកដាក់ ហើយកត់ចំណាំលើសៀវភៅកត់ត្រា។<br>- បន្ទាប់ពីទទួលបានចំណេះដឹង សួរសំណួរណាមួយប្រសិនបើមាន |

| | | |
|---|---|---|
| | • ដើម្បីឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល<br>• ការយល់ដឹងរបស់អ្នកប្រើប្រាស់ចុងក្រោយអំពីធនធានដែលមាននៅលើអ៊ីនធឺណិត និងគេហទំព័រ | |
| ប្រវត្តអ៊ីនធឺណិត | អ៊ីនធឺណិត<br>• បណ្តាញសកលធំដែលភ្ជាប់បណ្តាញតូចៗជុំវិញពិភពលោក<br>• អ៊ីនធឺណែតបានបើកដំណើរការនៅឆ្នាំ 1969<br>- សហរដ្ឋអាមេរិកបានផ្តល់មូលនិធិដល់គម្រោងអភិវឌ្ឍន៍បណ្តាញកុំព្យូទ័រជាតិ<br>- ARPANET បណ្តាញទីភ្នាក់ងារគម្រោងស្រាវជ្រាវកម្រិតខ្ពស់( Advanced Research Project Agency Network )<br>• World Wide Web ឬ WWW ត្រូវបានណែនាំអោយប្រើប្រាស់ក្នុងឆ្នាំ 1991<br>• អ៊ីនធឺណិត និងគេហទំព័រមិនដូចគ្នាទេ<br>- អ៊ិនធឺណិតគឺជាបណ្តាញរាងកាយ<br>- គេហទំព័រគឺជាចំណុចប្រទាក់ពហុព័ត៌មាន ទៅនឹងធនធានដែលមាននៅលើអ៊ីនធឺណិត | -សិស្សស្វែងរកចម្លើយរៀងៗខ្លួនលើអ៊ីនធឺណិត៥នាទី |
| ការកែសម្រួលគេហទំព័រ និងមុខងារ | គេហទំព័រ<br>• គេហទំព័រ 1.0<br>- ផ្តោតអារម្មណ៍ជាមួយព័ត៌មាន<br>- កម្មវិធីស្វែងរកត្រូវបានបង្កើតឡើង<br>- ផ្តល់តំណភ្ជាប់ទៅកាន់គេហទំព័រជាមួយនឹងពាក្យ ឬឃ្លាជាក់លាក់<br>• គេហទំព័រ 2.0<br>- ការបង្កើតមាតិកាថាមវន្ត ឧ. Facebook<br>• គេហទំព័រ 3.0<br>- កំណត់ទំនាក់ទំនងរវាងទិន្នន័យ<br>- ការបង្កើតមាតិកាផ្ទាល់ខ្លួនសម្រាប់អ្នកប្រើប្រាស់ | - ស្តាប់គ្រូដោយយកចិត្តទុកដាក់ ហើយកត់ចំណាំលើសៀវភៅកត់ត្រា។ |

| | | |
|---|---|---|
| ការប្រើប្រាស់អ៊ីនធឺណិតទូទៅ | ការទំនាក់ទំនង តាមរយៈ៖ អ៊ីម៉ែល រូបថត វីដេអូ ការពិភាក្សា ការដើរទិញឥវ៉ាន់ កំពុងស្វែងរក(Searching) បណ្ណាល័យនិម្មិត ការអប់រំ ឬការសិក្សាតាមអេឡិចត្រូនិកការកំសាន្តតាមអ៊ីនធឺណិត | - ស្តាប់គ្រូដោយយកចិត្តទុកដាក់ ហើយកត់ចំណាំលើសៀវភៅកត់ត្រា។ |
| ការណែនាំអំពីកម្មវិធីរុករក | កម្មវិធីរុករក<br>• ផ្តល់នូវគេហទំព័រដែកមានធនធាន<br>• អនុញ្ញាតឱ្យអ្នករុករកលើគេហទំព័រ<br>- ភ្ជាប់ទៅកុំព្យូទ័រពីចម្ងាយ<br>- ចំណុចប្រទាក់មិនស្មុគស្មាញទៅអ៊ីនធឺណិត<br>- ការផ្ទេរឯកសារ<br>- បង្ហាញពហុព័ត៌មានជាច្រើនប្រភេទ<br>• កម្មវិធីរុករកបណ្តាញពេញនិយមរួមមាន:<br>- Mozilla Firefox<br>- Apple Safari<br>- ក្រុមហ៊ុន Microsoft Edge<br>- Google Chrome | - ស្តាប់គ្រូដោយយកចិត្តទុកដាក់ ហើយកត់ចំណាំលើសៀវភៅកត់ត្រា។<br>- បន្ទាប់ពីទទួលបានចំណេះដឹង សួរសំណួរណាមួយប្រសិនបើមាន |
| URLs | • អ្នកកំណត់ទីតាំងធនធានច្បាស់លាស់<br>- ទីតាំងឬអាសយដ្ឋាននៃធនធាន<br>- https គឺជារឿងធម្មតាបំផុតសម្រាប់ចរាចរណ៍គេហទំព័រ<br>• គេហទំព័រចែកចេញជាពីរផ្នែក<br>-Protocol៖ ច្បាប់សម្រាប់ការផ្លាស់ប្តូរទិន្នន័យ<br>- ឈ្មោះដែន៖ កន្លែងដែលធនធានស្ថិត<br> | -សិស្សស្វែងរកចម្លើយរៀងៗខ្លួនលើអ៊ីនធឺណិ ៥នាទី |
| អ៊ីម៉ែល និងជាតុរបស់អ៊ីម៉ែល | អ៊ីម៉ែល<br>• ការបញ្ជូនសារអេឡិចត្រូនិចតាមអ៊ីនធឺណិត<br>• ជាតុបី<br>- បឋមកថា៖ អាស័យដ្ឋាន ប្រធានបទ | -សិស្សស្វែងរកចម្លើយរៀងៗខ្លួនលើអ៊ីនធឺណិត៥នាទី |

| | | |
|---|---|---|
| | ឯកសារភ្ជាប់<br>- សារ<br>- ហត្ថលេខា<br> | |
| ប្រព័ន្ធអ៊ីម៉ែល | ប្រព័ន្ធអ៊ីម៉ែល<br>• Client-based<br>- អ៊ីម៉ែល ត្រូវតែដំឡើងនៅលើកុំព្យូទ័រ៖ Apple Mail or Microsoft Outlook<br>• Web-based<br>- Webmail client៖ មិនត្រូវការដំឡើង ឥតគិតថ្លៃ មានដូចជា Gmail របស់ Google Hotmail របស់ Microsoft និង Yahoo!mail<br>• សារឥតបានការ៖ សំបុត្រដែលមិនល្អ<br>• មេរោគកុំព្យូទ័រ៖ បំផ្លិចបំផ្លាញកម្មវិធី ភ្ជាប់ជាមួយអ៊ីម៉ែលដែលមិនបានស្នើសុំ<br>• ច្បាប់ CAN-SPAM បានបង្កើតដើម្បីប្រឆាំងសារឥតបានការសម្រាប់ការគ្រប់គ្រងរាល់អ៊ីម៉ែលដែលទាក់ទងនឹងទីផ្សារត្រូវតែជ្រើសរើសចេញ<br>• អ្នកទប់ស្កាត់សារឥតបានការ ឬ តម្រងសារឥតបានការ ដោយកំណត់អត្តសញ្ញាណ | -សិស្សស្វែងរកចម្លើយរៀងៗខ្លួនលើអ៊ីនធឺណិត៥នាទី |
| របៀបបង្កើតគណនី Gmail? | 1. ចូលទៅកាន់ www.gmail.com<br>2. ចុចបង្កើតគណនី<br>3. ទម្រង់ចុះឈ្មោះនឹងលេចឡើង<br>4. បន្ទាប់មក បញ្ចូលលេខទូរស័ព្ទរបស់អ្នកដើម្បីផ្ទៀងផ្ទាត់គណនីរបស់អ្នក<br>5. អ្នកនឹងទទួលបានសារជាអក្សរពី Google ជាមួយនឹងលេខកូដផ្ទៀងផ្ទាត់<br>6. បន្ទាប់មកមានទម្រង់មួយដើម្បីបញ្ចូលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ដូចជាឈ្មោះ និងថ្ងៃកំណើតរបស់អ្នក | -សិស្សស្វែងរកចម្លើយរៀងៗខ្លួនលើអ៊ីនធឺណិត៥នាទី និងអនុវត្តន៍ |

| | | |
|---|---|---|
| សំណួរពិភាក្សាក្រុម<br>- បែងចែកសិស្សជា៥ក្រុម<br>១. តើការប្រើប្រាស់អ៊ីនធឺណិតបានជួយប្អូនៗអ្វីខ្លះក្នុងការរៀនសូត្រ?<br><br>**២. ចូររៀបរាប់ពីគុណសម្បត្តិ និងគុណវិបត្តិនៃការប្រើប្រាស់អ៊ីនធឺណិតដល់អ្នកប្រើប្រាស់?**<br>(GCED) | ១. ការប្រើប្រាស់អ៊ីនធឺណិតបានជួយក្នុងការរៀនសូត្រ<br>- ព័ត៌មានថ្មី និងទាន់ហេតុការណ៍<br>- ការអប់រំតាមអ៊ីនធឺណិតតាមអ៊ីនធឺណិត<br>- អភិវឌ្ឍទំនាក់ទំនង និងការតភ្ជាប់គ្នា<br>- ផែនការអាជីព<br>- ប្រភពឯកសារដ៏មហាសាល<br>**២. គុណសម្បត្តិ និងគុណវិបត្តិនៃការប្រើប្រាស់អ៊ីនធឺណិតដល់អ្នកប្រើប្រាស់**<br>***គុណសម្បត្តិ**<br>**- ការតភ្ជាប់សកលតាមរយៈទំនាក់ទំនង**<br>**- ភាពសម្បូរបែបនៃព័ត៌មាន និងចំណេះដឹង**<br>**- ឱកាសការងារ និងការរៀនសូត្រនៅក្រៅប្រទេស**<br>**- បង្កើនមិត្តភាព និងកិច្ចសហប្រតិបត្តការ**<br>***គុណវិបត្តិ**<br>**- ផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ**<br>**- ការញៀនអ៊ីនធឺណិត និងការខ្ជះខ្ជាយពេលវេលា**<br>**- ការបាត់បង់ព័ត៌មានផ្ទាល់ខ្លួន**<br>**- បញ្ហាសុខភាពផ្លូវកាយ និងផ្លូវចិត្ត**<br>(GCED) | - សិស្សធ្វើការពិភាក្សាជាក្រុម<br>- សិស្សគិតរកចម្លើយដែលគ្រូបានសួរ<br>- ដំណាងក្រុមឡើងបកស្រាយ |
| **ជំហានទី ៤៖ ពង្រឹងពុទ្ធិ ( ១០នាទី )** | | |
| របៀបបង្កើតគណនី Gmail? | 1. ចូលទៅកាន់ www.gmail.com<br>2. ចុចបង្កើតគណនី<br>3. ទម្រង់ចុះឈ្មោះនឹងលេចឡើង<br>4. បន្ទាប់មក បញ្ចូលលេខទូរស័ព្ទរបស់អ្នកដើម្បីផ្ទៀងផ្ទាត់គណនីរបស់អ្នក<br>5. អ្នកនឹងទទួលបានសារជាអក្សរពី Google ជាមួយនឹងលេខកូដផ្ទៀងផ្ទាត់ | -សិស្សព្យាយាមឆ្លើយរៀងៗខ្លួនតាមរយៈចំណេះដឹងពីមេរៀននិងការស្រាវជ្រាវ ដែលពួកគេបានសិក្សារួច។ |

| | | |
|---|---|---|
| | 6. បន្ទាប់មក អ្នកនឹងឃើញទម្រង់មួយដើម្បីបញ្ចូលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ដូចជាឈ្មោះ និងថ្ងៃកំណើតរបស់អ្នក | |
| **ជំហានទី ៥៖ បណ្តាំផ្ញើ ( ១០នាទី )** | | |
| - កិច្ចការផ្ទះ | -កិច្ចការផ្ទះ<br>- https://edu.gcfglobal.org/en/gmail/setting-up-a-gmail-account/1/<br>-សូមសង្ខេបអត្ថបទចេញពីគេហទំព័រ ជាភាសាខ្មែរ ដោយប្រើកម្មវិធី Google Doc | - សួរសំណួរណាមួយប្រសិនបើមាន |
| **-សូមចែករំលែកនូវអ្វីដែលប្អូនបានចេះរបៀបបង្កើត និងប្រើប្រាស់អ៊ីម៉ែល ដល់អ្នករស់នៅជុំវិញខ្លួន(GCED)** | | -ស្តាប់ការណែនាំរបស់គ្រូ |

# ប្រធានបទ៖ រូបសាស្ត្រនៃដី

សោម សង្ហុក
វិទ្យាស្ថានជាតិអប់រំ

ថ្ងៃ.........................ខែ....................ឆ្នាំ...........................ព.ស. ២៥៦.......
ត្រូវនឹងថ្ងៃទី.............ខែ................ ឆ្នាំ២០២..........

មុខវិជ្ជា ៖ ក្សេត្រសាស្ត្រ
ប្រធានបទ ៖ រូបសាស្ត្រនៃដី
រយៈពេលបង្រៀន ៖ ៥០ នាទី

## I. **វត្ថុបំណង**

ក្រោយពីរៀនមេរៀនេះចប់សិស្សអាច

- **វិជ្ជាសម្បទា** ៖ រាប់ពីនិយមន័យនៃដី ការកកើតនៃដី សមាសធាតុនៃដី ប្រូហ្វីលដី និងវាយនភាពដី
- **បំណិនសម្បទា** ៖ ស្វែងយល់ពីការបែងចែកពីប្រូហ្វីលដី ឬចំណាត់ថ្នាក់ដី
- **ចរិយាសម្បទា** ៖ ចេះវិភាគអំពីវាយនភាពរបស់ដី និងយល់ពីសារៈសំខាន់ចំពោះការប្រើប្រាស់ដី

## II. **ខ្លឹមសារមេរៀន**

១. និយមន័យនៃដី
២. ការកកើតនៃដី
  ២.១ សិលាមេ
  ២.២ អាកាសធាតុ
  ២.៣ សារពាង្គកាយ
  ២.៤ ទីកន្លែង ឬសណ្ឋានដី
  ២.៥ ពេលវេលា
៣. សមាសធាតុនៃដី
៤. ប្រូហ្វីលដី
៥. វាយនភាពដី

## III. **សម្ភារៈឧបទេស**

- ឯកសារ និងសៀវភៅក្រៅពីសៀវភៅសិក្សាគោល
- សៀវភៅសិក្សាគោល (សម្រាប់ប្រើប្រាស់ផ្ទៃក្នុងរបស់វិទ្យាស្ថានអប់រំ)
- ក្រដាស A4 ហ្វឺត ស្កុត ក្រដាសកាតុង និងផ្ទាំងរូបភាពតុក្កតាគំនិតស្ដីពីរូបរូបសាស្ត្រនៃដី

## IV. **ដំណើរការនាំមេរៀន**

- វិធីសាស្ត្ររៀន-បង្រៀនតាមបែបរិះរក
- ការបញ្ជ្រាប GCED ៖ បញ្ជ្រាបតាមរយៈការកំណត់នូវ វត្ថុបំណងមេរៀន ការពិភាក្សាក្រុមធ្វើឱ្យសិស្សចេះធ្វើការងារក្រុម ដើម្បីចេះរកដំណោះស្រាយរួម ប្រើប្រាស់សំណួរពង្រីកគំនិត និងបញ្ចូលនូវគំនិតអប់រំភាពជាពលរដ្ឋសកល។

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| **ជំហានទី១ ៖ រដ្ឋបាលថ្នាក់រៀន** ( **៥ នាទី** ) | | |
| - ពិនិត្យអវត្តមាន អនាម័យ និងសណ្តាប់ធ្នាក់ក្នុងថ្នាក់<br>- សួរសុខទុក្ខ (ការបញ្ជ្រាប GCED) | - អវត្តមាន អនាម័យ និងសណ្តាប់ ធ្នាប់ក្នុងថ្នាក់រៀន | - សម្អាតថ្នាក់រៀន និងរាយការណ៍ពីអវត្តមាន<br>- ប្រធានថ្នាក់ឡើងរាយការណ៍ពីវត្តមាននិងអវត្ត មានសិស្សក្នុងថ្នាក់រៀន |
| **ជំហានទី២ ៖ រំលឹកមេរៀនចាស់** ( **៥ នាទី** ) | | |
| - និយាយអំពីមេរៀនរូបសាស្ត្រនៃដី<br>- តើរូបសាស្ត្រនៃដីផ្តល់ប្រយោជន៍ចំពោះមនុស្សជាតិអ្វីខ្លះ? (ការបញ្ជ្រាប GCED) | ពន្យល់អំពីចំណេះដឹងទូទៅទាក់ទងនឹងរូបសាស្ត្រនៃដីដែលមានសារៈប្រយោជន៍ចំពោះមនុស្សជាតិរួមមាន<br>- ជម្រករបស់មនុស្ស សត្វ និងរុក្ខជាតិ<br>- សម្រាប់ដាំដំណាំ)<br>- ជាសាជាតុចិញ្ចឹមរបស់ជីវចម្រុះក្នុងដី.. (GCED) | - សិស្សស្តាប់ |
| **ជំហានទី៣ ៖ ខ្លឹមសារមេរៀន** ( **៣០ នាទី** ) | | |
| - សរសេរចំណងជើងមេរៀនដាក់ក្តាខៀន | **មេរៀន**<br>**រូបសាស្ត្រនៃដី** | - សិស្សសរសេរចំណងជើងមេរៀនដាក់ក្នុងសៀវភៅមេរៀន<br>- បែងចែកសិស្សជាក្រុម |

| | | |
|---|---|---|
| - ឱ្យសិស្សអានមេរៀនបែងចែក សិស្សតាមចំណុចនីមួយៗ<br>- បង្ហាញរូបភាពដល់សិស្សរូបសាស្ត្រនៃដី<br>- បែងចែកសិស្សជា ២ ក្រុមធំ<br>- បង្ហាញរូបគំនូរតុក្កតាគំនិតដែលមានសរសេរខ្លឹមសារនៅក្នុងប្រអប់ ពុះនៅលើក្ដាខៀន។ | | - ឱ្យសិស្សចូលតាមក្រុម<br>- ប្រើប្រាស់និងសង្កេតពីរូបគំនូរតុក្កតាគំនិតនៅលើក្ដាខៀន |
| | **១. និយមន័យនៃដី**<br><u>សំណួរគន្លឹះ: ទី១</u><br>ដូចម្ដេចដែលហៅថាដី ?<br> | |
| - គ្រូត្រូវបានជួយសម្របសម្រួលក្នុង ការពិភាក្សា និងបំផុសគំនិតខ្លះ ក្នុងការពិភាក្សាតាមចំណុចដែលសិស្សមានចម្ងល់( ការបញ្ជ្រាប GCED ) | **ខ្លឹមសារលើរូបភាពតុក្កតាគំនិត៖**<br>១. ជាការប្រមូលផ្ដុំចូលគ្នានៃអង្គធាតុរឹងធម្មជាតិ ( សារធាតុខនិជ និងសារធាតុសរីរាង្គ ) អង្គធាតុរាវ និងឧស្ម័នស្ថិតនៅផ្នែកខាងលើបង្អួរនៃផែនដីដែលអាចចែកចេញស្រទាប់ដី ហើយមានលទ្ធភាពផ្គត់ផ្គង់ឱ្យរុក្ខជាតិដុះលូតលាស់ក្នុង បរិស្ថានធម្មជាតិបាន។ ( GCED ) | - សិស្សបង្ហាញពីមតិយោបល់របស់ខ្លួន<br>- សិស្សអាចសាកសួរពាក្យគន្លឹះខ្លះដែលទាក់ទង |
| | **២. ការកកើតនៃដី** | |
| - គ្រូត្រូវបានជួយសម្របសម្រួលក្នុង ការពិភាក្សា | | - សិស្សបង្ហាញពីមតិយោបល់របស់ខ្លួន |

| | | |
|---|---|---|
| និងបំផុសគំនិតខ្លះ ក្នុងការពិភាក្សាតាមចំណុចដែលសិស្សមានចម្ងល់<br>- តើដីកកើតនៃដីដោយកត្តាអ្វីខ្លះ? | <br>ខ្លឹមសារលើរូបភាពតុក្កតាគំនិត៖<br>មានកត្តា ៥ គឺ សិលាមេ អាកាសធាតុ សារពាង្គកាយ ទីកន្លែង ឬសណ្ឋានដី និងពេលវេលា។<br>**៣. សមាសធាតុនៃដី** | - សិស្សអាចសាកសួរពាក្យគន្លឹះខ្លះដែលទាក់ទង<br>**ការកកើតនៃដីមាន ៥ កត្តា**<br>១. សិលាមេ<br>២. អាកាសធាតុ<br>៣. សារពាង្គកាយ<br>៤. ទីកន្លែង ឬសណ្ឋានដី<br>៥. ពេលវេលា |
| - គ្រូត្រូវបានជួយសម្រប សម្រួលក្នុង ការពិភាក្សា និងបំផុសគំនិតខ្លះ ក្នុងការពិភាក្សាតាមចំណុចដែលសិស្សមានចម្ងល់<br>- តើសមាសធាតុនៃដីមានអ្វីខ្លះ? | <br>សមាសធាតុនៃដីមានដូចជា ៖<br>- សារធាតុខនិជពី ៤៥% - ៤៨% នៃមាឌដីសរុប។<br>- រន្ធដីផ្ទុកខ្យល់ ២៥% ផ្ទុកទឹក ២៥% ផ្ទុកទឹក និង ២៥% ផ្ទុកខ្យល់។<br>- សារធាតុសរីរាង្គប្រមាណ ២% -៥%។ | - សិស្សបង្ហាញពីមតិយោបល់របស់ខ្លួន<br>- សិស្សអាចសាកសួរពាក្យគន្លឹះខ្លះដែលទាក់ទង<br>- សមាសធាតុនៃដីមានដូចជា:<br>- សារធាតុខនិជ ៤៥% -៤៨%<br>- រន្ធដីផ្ទុកខ្យល់ ២៥% ផ្ទុកទឹក ២៥% សម្រាប់ផ្ទុកទឹក និង ២៥%សម្រាប់ផ្ទុកខ្យល់<br>- សារធាតុសរីរាង្គ ២% -៥% |

| | | |
|---|---|---|
| - គ្រូត្រូវបានជួយសម្របសម្រួលក្នុង ការពិភាក្សា និងបំផុសគំនិតខ្លះ ក្នុងការពិភាក្សាតាមចំណុចដែលសិស្សមានចម្ងល់ | **៤. ប្រូហ្វីលដី**<br><br> | - សិស្សបង្ហាញពីមតិយោបល់របស់ខ្លួន<br>- សិស្សអាចសាកសួរពាក្យគន្លឹះខ្លះដែលទាក់ទង |
| តើគេបែងចែកប្រូហ្វីលដីមានប៉ុន្មានស្រទាប់? | **គោលការណ៍នៃការកំណត់ស្រទាប់ដីកសិកម្មមានដូចខាងក្រោម ៖**<br>- ស្រទាប់ A ជាដីខនិជខាងលើ<br>- ស្រទាប់ B ជាស្រទាប់ដីបន្ទាប់<br>- ស្រទាប់ C ជាស្រទាប់ដែលមានភាគល្អិត និងបំណែកនៃថ្មមេ<br>- ស្រទាប់ R ជាថ្មមេដែលបង្កើតដីនោះ<br><br>**៥. វាយនភាពដី** | គោលការណ៍នៃការកំណត់ស្រទាប់ដីកសិកម្ម ៖<br>- ស្រទាប់ A ជាដីខនិជខាងលើ<br>- ស្រទាប់ B ជាស្រទាប់ដីបន្ទាប់<br>- ស្រទាប់ C ជាស្រទាប់មានភាគល្អិត និងបំណែកនៃថ្មមេ<br>- ស្រទាប់ R ជាថ្មមេដែលបង្កើតដីនោះ។ |

| | | |
|---|---|---|
| - គ្រូត្រូវបានជួយសម្របសម្រួលក្នុង ការពិភាក្សា និងបំផុសគំនិតខ្លះ ក្នុងការពិភាក្សាតាមចំណុចដែលសិស្សមានចម្ងល់ |  | - សិស្សបង្ហាញពីមតិយោបល់របស់ខ្លួន<br>- សិស្សអាចសាកសួរពាក្យគន្លឹះខ្លះដែលទាក់ង |
| - តើវាយនភាពដីចែកចេញជាប៉ុន្មាន ប្រភេទ ? | - **ខ្សាច់** ខ្សាច់នៅពេលត្រដុសនៅចន្លោះរវាងមេដៃ និងចង្អុលដៃមានអារម្មណ៍គ្រើម និងសង្កៀត។<br>- **ល្បប់** នៅពេលច្របាច់វាដោយ មេដៃ និងចង្អុលដៃ មានអារម្មណ៍រលោង និងមិនស្អិត ឬជាប់ដៃទេ ហើយមានស្នាមម្រាមដៃនៅជាប់លើដីនោះ។<br>- **ដីឥដ្ឋ** នៅពេលច្របាច់វាមានអារម្មណ៍រលោងហើយ មានលក្ខណៈដូចជាម្សៅនៅពេលស្ងួត និងមានលក្ខណៈស្អិតហើយអាចពត់ពែនលុញជាឃ្លី ឬសូន ជារូបបាននៅពេលដីសើម។(GCED) | - **ខ្សាច់** ខ្សាច់នៅពេលត្រដុសនៅចន្លោះរវាងមេដៃ និងចង្អុលដៃមានអារម្មណ៍គ្រើម និងសង្កៀត។<br>- **ល្បប់** នៅពេលច្របាច់វាដោយមេដៃ និងចង្អុលដៃ មានអារម្មណ៍រលោង និងមិនស្អិត ឬជាប់ដៃទេ ហើយមានស្នាមម្រាមដៃនៅជាប់ លើដី<br>- **ដីឥដ្ឋ** នៅពេលច្របាច់វាមានអារម្មណ៍រលោងហើយ មានលក្ខណៈដូចជាម្សៅនៅពេលស្ងួត និងមានលក្ខណៈស្អិតហើយអាចពត់ពែនលុញជាឃ្លី ឬសូន ជារូបបាន នៅពេលដីសើម។ |
| | **ជំហានទី ៤៖ ពង្រឹងពុទ្ធិ ( ៥ នាទី )** | |
| - តើដូចម្តេចដែលហៅថាដី ?<br>- ( សិស្សអាចឆ្លើយ ១ ឬ ៣ នាក់ ) | - ជាការប្រមូលផ្តុំចូលគ្នានៃអង្គធាតុរឹងធម្មជាតិអង្គធាតុរាវនិងឧស្ម័នស្ថិតនៅផ្នែកខាងលើបង្អស់នៃផែនដីដែលអាចចែកចេញស្រទាប់ដី ហើយមានលទ្ធភាពផ្គត់ផ្គង់ឱ្យរុក្ខជាតិដុះលូតលាស់ក្នុងបរិស្ថានធម្មជាតិបាន។ | - ជាការប្រមូលផ្តុំចូលគ្នានៃអង្គធាតុរឹងធម្មជាតិអង្គធាតុរាវនិងឧស្ម័នស្ថិតនៅផ្នែកខាងលើបង្អស់នៃផែនដីដែលអាចចែកចេស្រទាប់ |

| | | |
|---|---|---|
| | | ដី ហើយមានលទ្ធភាពផ្គត់ផ្គង់ឱ្យរុក្ខជាតិដុះលូតលាស់ក្នុងបរិស្ថានធម្មជាតិបាន។ |
| - តើវាយនភាពដីចែកចេញជាប៉ុន្មាន ប្រភេទ? | - **ខ្សាច់** ខ្សាច់នៅពេលត្រដុសនៅចន្លោះរវាងមេដៃ និងចង្អុលដៃមានអារម្មណ៍គ្រើម និងសង្អៀត។<br>- **ល្បាប់** នៅពេលច្របាច់វាដោយ មេដៃ និងចង្អុលដៃ មានអារម្មណ៍រលោង និងមិនស្អិត ឬជាប់ដៃទេ ហើយមានស្នាមម្រាមដៃនៅជាប់ លើដីនោះ។<br>- **ដីឥដ្ឋ** នៅពេលច្របាច់វាមានអារម្មណ៍រលោងហើយ មានលក្ខណៈដូចជាម្សៅនៅពេលស្ងួត និងមានលក្ខណៈស្អិតហើយអាចពត់ពែនលុញជាឃ្លី ឬសូន ជារូបបាន នៅពេលដីសើម។ | - **ខ្សាច់** ខ្សាច់នៅពេលត្រដុសនៅចន្លោះរវាងមេដៃ និងចង្អុលដៃមានអារម្មណ៍គ្រើម និងសង្អៀត។<br>- **ល្បាប់** នៅពេលច្របាច់វាដោយមេដៃ និងចង្អុលដៃមានអារម្មណ៍រលោង និងមិនស្អិត ឬជាប់ដៃទេហើយមានស្នាមម្រាមដៃនៅជាប់លើដី<br>- **ដីឥដ្ឋ** នៅពេលច្របាច់វាមានអារម្មណ៍រលោងហើយ មានលក្ខណៈដូចជាម្សៅនៅពេលស្ងួត និងមានលក្ខណៈស្អិតហើយអាចពត់ពែនលុញជាឃ្លី ឬសូន ជារូបបាន នៅពេលដីសើម។ |
| | **ជំហានទី ៥ ៖ បណ្ដាំផ្ញើ ( ៥ នាទី )** | |
| - ចូរប្អូនស្វែងយល់បន្ថែមទៀតដើម្បីឱ្យដឹងកាន់តែច្បាស់។<br>- សូមប្អូនៗអានមេរៀនឡើងវិញពេលត្រឡប់ទៅផ្ទះ។<br>- គោរពច្បាប់ចរាចរណ៍ ធ្វើកិច្ចការផ្ទះ និងជួយកិច្ចការងារផ្ទះ មករៀនឱ្យទៀងទាត់ពេល។(GCED) | | - សិស្សយកចិត្តទុកដាក់ស្ដាប់ និងអនុវត្តតាម |

# ប្រធានបទ៖ ភាពជាពលរដ្ឋសកលក្នុងវិស័យអេឡិចត្រូនិក

ទឹម រ័ត្ន
វិទ្យាស្ថានជាតិអប់រំ

មុខវិជ្ជា ៖ អេឡិចត្រូនិក
ជំពូក១/មេរៀនទី១ ៖មូលដ្ឋានគ្រឹះអេឡិចត្រូនិក
រយៈពេល ៖ ៩០នាទី

I. **វត្ថុបំណង៖** បញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនឹងការសិក្សាភាពជាពលរដ្ឋសកលក្នុងផ្នែកអេឡិចត្រូនិក ដោយតម្លើងគ្រឿងអេឡិចត្រូនិកគំរូ ក្នុងការជួយសន្សំសំចៃភ្លើងអគ្គិសនីក្នុងបរិបទពិភពលោក។

- វិជ្ជាសម្បទា៖ កំណត់ភាពជាពលរដ្ឋសកល និងពន្យល់ពីសារៈសំខាន់របស់វា។
  - កំណត់អត្តសញ្ញាណ និងស្រាវជ្រាវឧបករណ៍អេឡិចត្រូនិកដែលប្រប្រាស់ជុំវិញពិភពលោក ដើម្បីដោះស្រាយតម្រូវការសកល។
- បំណិនសម្បទា៖ អាចរចនា និងបង្កើតគំរូឧបករណ៍អេឡិចត្រូនិកដ៏សាមញ្ញមួយ ដែលឆ្លើយតបទៅនឹងតម្រូវការសកល។
- ចរិយាសម្បទា៖ ជំរុញការចាប់អារម្មណ៍ ក្នុងការបង្ហាញឧបករណ៍របស់ពួកគេដល់ថ្នាក់រៀន និងពិភាក្សាអំពីផលប៉ះពាល់ផ្នែកសីលធម៌ និងសង្គម។

II. **សម្ភារៈឧបទេស៖**
* ក្តារខៀន ឬម៉ាស៊ីនបញ្ចាំងស្លាយ
* ហ្វឺតឬប៊ិច high light
* ក្រដាស
* គ្រឿងអេឡិចត្រូនិក (ជម្រើស)
* ឧបករណ៍ប្រើប្រាស់ (ជម្រើស)

III. **វិធីសាស្ត្របង្រៀន៖** វិធីសាស្ត្រ PBL ដោយបញ្ជ្រាប ការសិក្សាភាពជាពលរដ្ឋសកល

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| **ជំហានទី១ (លំនឹងថ្នាក់ ៥នាទី)** | | |
| • គ្រួតពិនិត្យ<br>○ អនាម័យ<br>○ សណ្តាប់ធ្នាប់<br>○ អវត្តមាន | | • ប្រាកដថាមិនមានសំរាមក្នុងថ្នាក់និងមានខ្យល់អាកាសបរិបូរ |

| | | |
|---|---|---|
| | | • សិស្សអង្គុយតាមប្លង់តុ ដោយរក្សាភាពស្ងៀមស្ងាត់<br>• សម្លៀកបំពាក់សមរម្យ<br>• សក់ខ្លីសម្រាប់បុរស និងចងសក់សម្រាប់សិស្សស្រី<br>• មានស្មារតីត្រង់ត្រាប់ស្តាប់គ្រូនែនាំ |
| **ជំហានទី២ (រំលឹកមេរៀន ១០នាទី)** | | |
| • ភាពខុសគ្នារវាងការសិក្សាផ្នែកអគ្គិសនីនិងអេឡិចត្រូនិក<br>• ហេតុអ្វីបានជាបច្ចេកវិទ្យាពឹងផ្អែកសំខាន់លើផ្នែកអេឡិចត្រូនិក?<br><br>• រៀបរាប់គ្រឿងអេឡិចត្រូនិកដែលអ្នកបានដឹង | • ការសិក្សាផ្នែកអគ្គិសនីផ្តោតសំខាន់ធ្វើយ៉ាងណាឲមានលំហូរចរន្តអគ្គិសនីក្នុងសៀគ្វី តែអេឡិចត្រូនិកធ្វើយ៉ាងណា កុងត្រូលលំហូចរន្តក្នុងសៀគ្វី<br><br>• អេឡិចត្រូនិច និងវិស្វកម្មអេឡិចត្រូនិចបានជំរុញការច្នៃប្រឌិតនៅទូទាំងឧស្សាហកម្មធំៗ ហើយបានក្លាយជាកត្តាសំខាន់ក្នុងជីវិតប្រចាំថ្ងៃរបស់យើង។ នៅពេលដែលបច្ចេកវិទ្យាបន្តរីកចម្រើន អេឡិចត្រូនិកទំនងជានឹងនៅតែនាំមុខគេនៃការអភិវឌ្ឍន៍បច្ចេកវិទ្យា ដោយបង្កើតពិភពលោកមួយដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក។<br>• រេស៊ីស្តង់,LDR,LED,កុងដង់សាទ័រ,អាំងឌុចទ័រ, ឌីយ៉ូត,ត្រង់ស៊ីស្ទ័រ និង ICs | • សិស្សក្រោកឈរនិង ឆ្លើយតាមការយល់ឃើញ |
| **ជំហានទី៣ ( មេរៀនថ្មី ៦៥នាទី)** | | |

| | | |
|---|---|---|
| * ចាប់ផ្តើមដោយសួរសិស្សនូវអ្វីដែលពួកគេដឹងអំពីភាពជាពលរដ្ឋសកល។<br><br>បញ្ចាំងវិដេអូតាម youtube<br><br>សំណួរបំផុស: តើយើងត្រូវជួយសន្សំសំចៃភ្លើងអគ្គិសនីបានយ៉ាងដូចម្តេច ក្នុងបរិបទពិភពលោក?<br><br>គ្រូបែងចែកក្រុមដោយប្រើ Random list sheet | ភាពជាពលរដ្ឋសកលគឺអំពីការដឹង និងខ្វល់ខ្វាយអំពីពិភពលោកជុំវិញយើង ហើយចាត់វិធានការដើម្បីធ្វើឱ្យវាក្លាយជាកន្លែងប្រសើរជាងមុន។<br><br>https://www.youtube.com/watch?v=uLeREqPKR08<br><br>( Global Citizenship Education 1min 20sec)<br><br>https://www.youtube.com/watch?v=-RSrviqvAmY<br><br>( Global Energy Demand 4min )<br><br>• ស្រាវជ្រាវបច្ចេកវិទ្យាថ្មីៗដែលប្រើប្រាស់ថាមពលតិច<br>• បង្កើនការបញ្ញាបចំណេះដឹងពីហានិភ័យនៃការកើនឡើងកំណើនប្រជាជនសកលនិងការប្រើប្រាស់ថាមពល<br>• ថាមពលកកើតឡើងវិញ<br>• កែសម្រួលឡើងវិញនៅប្រព័ន្ធបញ្ជូនថាមពលទៅជាប្រព័ន្ធឆ្លាតវៃ<br><br>ការកាត់បន្ថយកាក់សំណល់អេឡិចត្រូនិក , ថាមពលកកើតឡើងវិញ,សន្សំសំចៃការប្រើប្រាស់ភ្លើងអគ្គិសនី (រំពឹងទុក)<br><br>* ពិភាក្សាអំពីសារៈសំខាន់នៃភាពជាពលរដ្ឋសកលនៅក្នុងផ្នែកអេឡិចត្រូនិក និង ឧបករណ៍អេឡិចត្រូនិកដែលអាចត្រូវបានគេប្រើប្រាស់ដើម្បីភ្ជាប់មនុស្ស | • សិស្សអង្គុយត្រងត្រាប់ស្តាប់និងឆ្លើយសំណួរ<br><br>• សិស្សទទួលបាន សិស្សទស្សនានិងកត់ត្រា<br><br>• សិស្សពិចារណា កត់ត្រា និងសាកល្បងឆ្លើយ<br><br>• សិស្សសញ្ជឹងគិតនិងពិភាក្សាជាក្រុម (ការកាត់បន្ថយកាក់សំណល់អេឡិចត្រូនិក , ថាមពលកកើតឡើងវិញ, សន្សំសំចៃការប្រើប្រាស់ភ្លើងអគ្គិសនី) (ភាគរយខ្ពស់ ក្នុងការគិតរបស់សិស្សដល់បញ្ហានេះ) |

| | | |
|---|---|---|
| | មកពីជុំវិញពិភពលោក និងដោះស្រាយបញ្ហាប្រឈមជាសកល។ | |

| | | |
|---|---|---|
| ណែនាំគម្រោងដល់ថ្នាក់ និងពន្យល់ថាសិស្សនឹងកំពុងរចនា និងបង្កើតគំរូដើមនៃឧបករណ៍អេឡិចត្រូនិកដ៏សាមញ្ញមួយ ដែលឆ្លើយតបទៅនឹងតម្រូវការសកល។<br><br>* *សង្កេតមើលសិស្សក្នុងអំឡុងពេលគម្រោងដើម្បីវាយតម្លៃការយល់ដឹងរបស់ពួកគេអំពីភាពជាពលរដ្ឋសកល និងសមត្ថភាពរបស់ពួកគេក្នុងការរចនា និងបង្កើតឧបករណ៍អេឡិចត្រូនិកសម្រាប់ភាពជាពលរដ្ឋសកល។*<br><br>ពន្យល់ពីតម្រូវការគម្រោង និងពេលវេលាកំណត់។ | **សេចក្តីផ្តើមគម្រោង (១០នាទី)**<br><br>គម្រោងងាយៗ ស្រួលរកគ្រឿងមកតម្លើង និងតម្លៃសមរម្យ<br><br>(ស្វែងរកតាមgoogle)<br><br> | • សិស្សស្តាប់និងកត់ត្រា<br><br>• សិស្សតាមក្រុមនីមួយៗពិភាក្សារកដំណោះស្រាយប្រឈមនិងស្វែងរកសៀគ្វីអេឡិចត្រូនិកសាកសមនិងគម្រោងងាយៗរបស់ពួកគេ (google) |

| | | |
|---|---|---|
| * ឱ្យសិស្សស្រាវជ្រាវឧបករណ៍អេឡិចត្រូនិកដែលប្រើសម្រាប់គម្រោងនេះ<br><br>* លើកទឹកចិត្តសិស្សឱ្យស្រាវជ្រាវឧបករណ៍មកពីinternet។<br><br>* ឱ្យសិស្សកំណត់ចំណុចខ្លាំង និងចំណុចខ្សោយរបស់ឧបករណ៍ដែលមានស្រាប់។ | ការស្រាវជ្រាវ (១០ នាទី)<br><br>Search Engine ដែលនិយមប្រើ គឺ Google search.<br><br>ស្វែងរកសៀគ្វីដែលអាចជួយសន្សំសំចៃថាមពលអគ្គិសនីដោយប្រើគ្រឿងអេឡិចត្រូនិកសម្រាប់បិទបើក<br><br>• សៀគ្វីដែលប្រើ LDR ពេញនិយមសម្រាប់បិទបើកចរន្តអគ្គិសនី(អំពូលភ្លើង)<br><br><br><br>• LDR មានការប្រែប្រួលតម្លៃអូម ទៅតាមពន្លឺ | • សិស្សពិភាក្សាក្រុម<br>• ឧទាហរណ៍៖សិស្សក្រុម១ សម្រេចជ្រើសរើសសៀគ្វីបិទបើកភ្លើងដោយពន្លឺ<br><br>• ស្រាវជ្រាវ កត់ត្រា |

| | | |
|---|---|---|
| ៦សិស្សចាប់ផ្ដើមរចនាឧបករណ៍អេឡិចត្រូនិក របស់ក្រុមពួកគេ ដើម្បីដោះស្រាយតម្រូវការសកលដែលពួកគេបានជ្រើសរើស។<br><br>-ទុកពេល១០នាទីសម្រាប់គូសសៀគ្វី | ការរចនា (១៥ នាទី)<br><br>លើកទឹកចិត្តសិស្សឱ្យមានភាពច្នៃប្រឌិត និងទទួលបានដំណោះស្រាយថ្មីៗ និងប្រកបដោយភាពច្នៃប្រឌិត។<br><br> | • សិស្សចាប់ផ្ដើមពិភាក្សា និងចាត់តាំងអ្នកគូសសៀគ្វី ដោយប្រើកម្មវិធីជំនួយ និងធ្វើតេស្តសាកល្បង Simulation ( Proteus) |

| | | |
|---|---|---|
| -ផ្តល់ឱ្យសិស្សនូវសិទ្ធិចូលប្រើប្រាស់គ្រឿងបន្លាស់ និងឧបករណ៍អេឡិចត្រូនិក ( ជាជម្រើស )។ | **ការតម្លើង ( ១៥ នាទី )**<br><br>1. Transistor BC547 -2<br>2. LDR ( Light Dependent Resistor )<br>3. Relay<br>4. Resistor 1k<br><br>5. 100k Potentiometer<br>6. Power Supply 12v -1<br>7. Connecting wires<br><br>8. Jumper wires<br>9. Screw terminal Block 2 pin or 3 pin<br>10. Bread Board or Perf Board<br>11. 1n4007 Diode<br>12. AC supply<br>13. AC Load or Bulb | • ក្រុមនីមួយៗចាប់ផ្តើមស្វែងរកគ្រឿងដើម្បីតម្លើងសៀគ្វីដែលមានក្នុង បន្ទប់ពិសោធន៍ |

| | | |
|---|---|---|
| ស្តាប់ការពន្យល់បកស្រាយរបស់ដំណាងក្រុមនីមួយៗយ៉ាងយកចិត្តទុកដាក់ កត់ត្រានៅចំណុចសំខាន់<br><br>ដឹកនាំការពិភាក្សាអំពីសំណួរខាងស្តាំដៃ៖ | **បទបង្ហាញ និងការពិភាក្សា (១០ នាទី)**<br><br>នៅពេលណាដែលពន្លឺប៉ះលើ LDR តម្លៃអូមរបស់វាថយចុះ ហើយត្រង់ស៊ីស្ទ័រ Q1 និងបើកឡើង ហើយជើងC ត្រង់ស៊ីស្ទ័រនេះចរន្តថយចុះ ហើយកត្តានេះធ្វើឱ្យត្រង់ស៊ីស្ទ័រទីពីរបិទដោយសារតែជើងB ទទួលបានចរន្តទាបនៅជើងBរបស់វា ដូច្នេះការបញ្ជូនតក៏នៅតែបិទផងដែរ ដោយសារត្រង់ស៊ីស្ទ័រទីពីរ .<br><br><br>នៅពេលណាដែល LDR ស្ថិតក្នុងស្ថានភាពងងឹត មានន័យថាគ្មានពន្លឺ នោះត្រង់ស៊ីស្ទ័រ Q1 បានបើកដោយសារតែការកើនឡើងនៅតម្លៃអូម របស់ LDR ដែលទទួលខុសត្រូវចំពោះការធ្លាក់ចុះតង់ស្យុងនៅជើងB Q1 ។ ដោយសារតែស៊ីញ៉ាល់ទាបនៅជើងB Q1, ត្រង់ស៊ីស្ទ័រ Q2 ទទួលបានស៊ីញ៉ាល់ HIGH ពីជើង C Q1 ហើយបើកដំណើរការ Relay ។ Relay បានបើកបន្ទុករបស់ AC ដែលភ្ជាប់ទៅRelay ។ ជើង 10K របស់រេស៊ីស្តង់ ប្រែប្រួល ក៏ត្រូវបានប្រើសម្រាប់ការកំណត់ភាពរនៃសៀគ្វី ។ | • តំណាងក្រុមចាប់ផ្តើម ឡើងបង្ហាញ និងពន្យល់ពីដំណើរការសៀគ្វីដែល ក្រុមគេបានធ្វើចប់សព្វគ្រប់ដល់សិស្សក្នុងថ្នាក់<br><br>• សិស្សកត់ត្រា និងត្រៀមសំណួរសម្រាប់សួរ<br><br>* តើឧបករណ៍នេះដោះស្រាយតម្រូវការសកលដោយរបៀបណា ?<br>ជួយច្រើនក្នុងការសន្សំសំចៃភ្លើងបានច្រើន បើគិតពីមនុស្សម្នាក់យ៉ាងហើយណាស់ ក៏អាចមានការធ្វេសប្រហេស ចំពោះការបិទភ្លើងបំភ្លឺ បើប្រើឧបករណ៍នេះ វាជួយបិទបើកដោយស្វ័យប្រវត្តិ<br>ចុះបើមនុស្សក្នុងពិភពលោកទាំងមូល អាចជួយសន្សំសំចៃបានប៉ុន្មានវិញ<br><br>* តើអ្វីជាផលប៉ះពាល់ខាងសីលធម៌ និងសង្គមនៃឧបករណ៍នេះ ?<br><br>* តើឧបករណ៍នេះអាចត្រូវបានធ្វើឱ្យមនុស្សជុំវិញពិភពលោកអាចចូលប្រើប្រាស់បានកាន់តែច្រើនដោយរបៀបណា ? |

| | | |
|---|---|---|
| * ប្រមូលការរចនា និងគំរូឧបករណ៍របស់សិស្ស ហើយ*វាយតម្លៃវាដោយផ្អែកលើលក្ខណៈវិនិច្ឆ័យខាងក្រោម ៖*<br>* *ភាពច្នៃប្រឌិត*<br>* *លទ្ធភាព*<br>* *ផលប៉ះពាល់ជាសកល*<br>* *ការពិចារណា* | សេចក្តីសន្និដ្ឋាន ( ៥ នាទី )<br>ការជ្រើសរើសយកគម្រោងនេះមកប្រើប្រាស់ពិតជាជួយសន្សំសំចៃថាមពលអគ្គិសនីដោយសារការច្នៃសប្រហេស ដែលកើតឡើងដោយចៃដន្យ ។សៀគ្វីនេះ បិទបើកកុងតាក់បំភ្លឺ ដោយសៀគ្វីងាយស្រួលចំណាយតិច ដូច្នេះ មនុស្សដែលចង់ដឹង ចង់សាកល្បងលើពិភពលោក អាចយកគំរូសៀគ្វីនេះ សាកល្បងតម្លើង និងតេស្តនៅទីតាំងរបស់ខ្លួនរៀងៗខ្លួន ដែលឈានទៅដល់ការជួយកាត់បន្ថយនៅកំហាតបង់ថាមពលជាសកល។ | • សិស្សស្តាប់និងកត់ត្រា |
| **ជំហានទី៤ ( ពង្រឹងពុទ្ធិ ៥នាទី )** | | |
| ឲ្យសិស្សគិតលើសំណួរខាងក្រោមនេះ ៖ | * តើខ្ញុំបានរៀនអ្វីខ្លះអំពីភាពជាពលរដ្ឋសកល ?<br>* តើខ្ញុំអាចប្រើប្រាស់ចំណេះដឹងផ្នែកអេឡិចត្រូនិចរបស់ខ្ញុំដោយរបៀបណា ដើម្បីក្លាយជាពលរដ្ឋសកលលោក ? | • សិស្សក្រោកឈរឆ្លើយដោយភ្លាហាន |
| **ជំហានទី៥ ( មតិផ្តាំផ្ញើរ ៥នាទី )** | | |
| ឱ្យសិស្សបង្កើតយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈអំពីឧបករណ៍អេឡិចត្រូនិក្នុងភាពជាពលរដ្ឋសកលរបស់ពួកគេ។ | • កិច្ចការផ្ទះ | • សិស្សស្តាប់និងកត់ត្រា |

| | | |
|---|---|---|
| | | |

# ប្រធានបទ៖ ទិវាទឹកស្អាតពិភពលោក

ផែន សារិត ( PHEN Sarith )
វិទ្យាស្ថានជាតិអប់រំ

**កាលបរិច្ឆេទ** ៖ ថ្ងៃ...........................ខែ...........................ឆ្នាំ...............ព.ស.២៥៦...
ត្រូវនឹងថ្ងៃទី................ខែ......................ឆ្នាំ២០២...
**មុខវិជ្ជា** ៖ ដីវវិទ្យា
**ប្រធានបទ** ៖ ទិវាទឹកសាបពិភពលោក
**រយៈពេល** ៖ ៥០ នាទី

## ១. វត្ថុបំណងនៃមេរៀន

### ១. ចំណេះដឹង៖

- ពន្យល់ពីសារប្រយោជន៍ទឹកសាបនៅលើផែនដីបានត្រឹមត្រូវតាមរយៈលទ្ធផលពិសោធ។
- ប្រាប់ពីរបៀបគណនាមាឌតំណក់ទឹកបានត្រឹមត្រូវតាមរយៈដំណើរការពិសោធ។

### ២. បំណិនសម្បទា៖

- វិភាគលើការខាតបង់សេដ្ឋកិច្ចគ្រួសារក្នុងករណីប្រើប្រាស់ទឹកសាប ដោយខ្ជះខ្ជាយបានសមហេតុផល តាមរយៈលទ្ធផលពិសោធ។

### ៣. ចរិយាសម្បទា៖

- មានបម្រុងប្រយ័ត្ននៅក្នុងការគ្រប់គ្រងការប្រើទឹកសាប (មិនខ្ជះខ្ជាយ) នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។
- ចូលរួមថែរក្សា និងការពារទឹកស្អាតសម្រាប់ជាប្រយោជន៍ទ្រទ្រង់ជីវិតរស់នៅក្នុងសហគមន៍ និងសកលលោក។

## ២. ខ្លឹមសារមេរៀន

សារៈសំខាន់ទឹកសាបនៅលើផែនដី

## ៣. សម្ភារៈឧបទេស

ទឹកសាប ដបជ័រ (ដបទឹកសុទ្ធដែលប្រើប្រាស់រួច) កាជន់ជ័រ ស៊ីឡាំងក្រិត ឬកែវក្រិត នាឡិកាកំណត់ពេល ឧបករណ៍ចុងស្រួច (ចុងកូនកាំបិត ឬចុងកន្ត្រៃ)។

## ៤. វិធីសាស្រ្តបង្រៀន ៖ វិធីសាស្រ្តបែបរិះរក (IBL)

## ៥. ដំណើរការមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|

| ជំហានទី១ រដ្ឋបាលថ្នាក់រៀន | | |
|---|---|---|
| -គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | ពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និងវិន័យ | ប្រធានថ្នាក់ឡើងរាយការណ៍ |
| **ជំហានទី២ រំលឹកមេរៀនចាស់** | | |
| – តើអាហារចែកជាប៉ុន្មានក្រុម? អ្វីខ្លះ?<br>– ក្រៅពីអាហារ តើសារពាង្គការត្រូវការអ្វីទៀត ដើម្បីលូតលាស់និងមានសុខភាពល្អ?<br>– ក្រៅពីតម្រូវការសារពាង្គកាយ តើទឹកមានសារសំខាន់យ៉ាងដូចម្តេចសម្រាប់មនុស្ស សត្វ និងរុក្ខជាតិនៅលើផែនដី? | **ក្រុមអាហារ** | – អាហារចែកជាបីក្រុមធំៗគឺៈ អាហារទ្រទ្រង់ អាហារថាមពល និងអាហារសាងសង់។<br>– ដើម្បីមាលូតលាស់ និងសុខភាពល្អ ក្រៅពីអាហារបីក្រុមខាងលើ សារពាង្គកាយត្រូវការសារជាតុរ៉ែ និងទឹក។<br>– ទឹកមានសារៈសំខាន់សម្រាប់ទ្រទ្រង់ជីវិត មនុស្ស សត្វ និងរុក្ខជាតិនៅលើផែនដីទាំងមូល។ |
| **ជំហានទី៣ មេរៀនប្រចាំថ្ងៃ** | | |
| –តើប្អូនៗដឹងទេថានៅលើផែនដីយើង ផ្ទៃទឹកមានប៉ុន្មានភាគរយនៃផ្ទៃដី?<br>–តើទឹកសាបនៅលើផែនដីមានប៉ុន្មានភាគរយបរិមាណទឹកសរុបនៅលើផែនដី?<br>–តើរបាយទឹកសាបនៅលើផែនដីយើងនេះមានរបាយស្មើគ្នាដែរឬទេ? ចូរលើកឧទាហរណ៍។ | *GCED-Integration*<br>*passion global issues* | –៧១% នៃផ្ទៃផែនដីសរុប<br>–២.៥%នៃបរិមាណទឹកសរុប<br>–ទឹកសាបនៅលើផែនដីមានរបាយមិនស្មើគ្នាទេ។ ឧទាហរណ៍ៈ បណ្តាប្រទេសនៅតំបន់អាស៊ីរួមទាំកម្ពុជាផងដែរ សម្បូរទឹកសាបសម្រាប់ប្រើប្រាស់ ប៉ុន្តែនៅបណ្តាប្រទេសមួយចំនួននៅតំបន់អាព្រិច និងវាលខ្សាច់សាហារាជាដើម ទឹកសាបសម្រាបប្រើប្រាស់មានកម្រិតតិចទួចបំផុត។ |

| | | |
|---|---|---|
| **១. បង្ហាញបាតុភូត**<br>– គ្រូបង្ហាញរូបភាពតំណក់ទឹកនៅលើស្លឹករុក្ខជាតិ និងរូបតំណក់ទឹកដែលតក់ចេញពីរ៉ូប៊ីនេទឹកក្នុងផ្ទះបាយ<br>– តើប្អូនៗធ្លាប់បានជួបបាតុភូតទាំងនេះនៅកន្លែងណាខ្លះ? | **ប្រធានបទ៖**<br>**ទិវាទឹកសាបពិភពលោក** | – សិស្សសង្កេតរូបភាពតំណក់ទឹកនៅលើស្លឹករុក្ខជាតិ និងរូបតំណក់ទឹកដែលតក់ចេញពីរ៉ូប៊ីនេទឹកក្នុងផ្ទះបាយ។<br>– នៅក្នុងផ្ទះបាយ ក្នុងព្រៃ ឬនៅជុំវិញផ្ទះ ក្នុងបរិវេនសាលារៀន និងក្នុងសួនច្បារជាដើម។<br>– ខ្លះសិស្សមិនដឹង ខ្លះដឹង |
| **- តើប្អូនៗដឹងទេថាទឹកមួយតំណក់ៗនេះមានមាឌប៉ុន្មានមីលីលីត្រ?** | *GCED-Reald world phenomena connection* | **- សិស្សខ្លះមិនដឹង ខ្លះដឹង** |
|   | | |
| **២. សំណួរគន្លឹះ៖**<br>តើទឹកមួយតំណក់ៗមានមាឌប៉ុន្មាន? | | |
| **៣. សម្មតិកម្ម**<br>– ឱ្យសិស្សធ្វើការព្យាករណ៍មាឌតំណក់ទឹក ដោយប្រើតារាងព្យាករណ៍ខាងក្រោម។<br>– ចូរគូសសញ្ញា ✓ នៅក្នុងតារាងខាងក្រោម៖ | | – ធ្វើការព្យាករណ៍ពីមាឌតំណក់ទឹកដោយគូសសញ្ញា ✓ នៅក្នុងតារាងខាងក្រោម។ |

| មាឌទឹក | តិចជាង 1ml | ស្មើ 1ml | ច្រើនជាង 1ml |
|---|---|---|---|
| មួយតំណក់ទឹក | | | |

| | | |
|---|---|---|
| ៤. សកម្មភាព<br>- បែងចែកសិស្សជាបួនក្រុម<br>- បែងចែកសម្ភារៈឱ្យសិស្សតាមក្រុមនីមួយៗ | GCED-Capacitation and connection students | - ចូលតាមក្រុមរៀងៗខ្លួន<br>- ទទួលបានសម្ភារៈតាមក្រុមរៀងៗខ្លួន |
| - តើធ្វើដូចម្ដេចដើម្បីវាស់មាឌតំណក់ទឹកមួយតំណក់បាន?<br>- បន្ទាប់មកឱ្យសិស្សតាមក្រុមនីមួយពីភាក្សារកវិធីវាស់មាឌតំណក់ទឹក។<br>- ផ្ដល់ឱកាសឱ្យសិស្សតាមក្រុមរិះរកវិធីផ្សេងៗគ្នាដើម្បីវាស់មាឌតំណក់ទឹក។ | | - សិស្សគិតរកវិធីវាស់មាឌតំណក់ទឹករៀងៗខ្លួន រួចសាកល្បងឆ្លើយជាបុគ្គល។<br>- បន្ទាប់មកពិភាក្សាក្នុងក្រុមដើម្បីរិះរកវិធីវាស់មាឌ តំណក់ទឹក |

## វិធីសាស្ត្រ

***សំណួរពិភាក្សាទី១៖*** *ចូររកវិធីគណនាមាឌទឹកមួយតំណក់។*

- ចុះដបទឹកសុទ្ធដោយប្រើឧបករណ៍ចុងស្រួច
- ធ្វើយ៉ាងណាឱ្យរន្ធដែលចោះនោះមិនធំពេក ដើម្បីបង្កើតបានជាតំណក់ទឹក
- ចាក់ទឹកចូលក្នុងដបដែលបានចោះរន្ធនោះឱ្យជិត ពេញ ឬបរិមាណណាមួយតាមស្ថានភាពជាក់ស្ដែង
- ដាក់ឱ្យតំណក់ទឹកចេញពីដបក្នុងល្បឿនណាមួយ (ប្រសិនបើតំណក់ទឹកតក់យឺតពេក ត្រូវពង្រីករន្ធបន្ថែមទៀត)
- យកស៊ីឡាំងក្រិត ឬកែវក្រិតត្រងតំណក់ទឹក
- រាប់ចំនួនតំណក់ទឹកក្នុងមួយនាទីម្ដង ដោយប្រើនាឡិកាកំណត់ពេល
- រាប់ចំនួនតំណក់ទឹកក្នុងមួយនាទីម្ដងឱ្យបាន៤ទៅ៥ដង
- កត់ត្រាចំនួនតំណក់ទឹកចូលក្នុងតារាងទិន្នន័យ

*ចំណាំសិស្សអាចធ្វើតាមវិធីផ្សេងៗទៀតក៏បានឱ្យតែបង្កើតបានជាតំណក់ទឹក*



*រូបទី១៖ សកម្មភាពពិសោធ*

តារាងទី១៖ កត់ត្រាទិន្នន័យ

| ក្រុម | ចំនួនតំណក់ទឹកក្នុងមួយនាទីៗ | | | | | |
|---|---|---|---|---|---|---|
| | នាទី១ | នាទី២ | នាទី៣ | នាទី៤ | មធ្យមភាគ | មាឌទឹកមួយតំណក់ (ml) |
| ក្រុមទី១ | | | | | | |
| ក្រុមទី២ | | | | | | |
| ក្រុមទី៣ | | | | | | |
| ក្រុមទី៤ | | | | | | |

**៥. វិភាគលទ្ធផល**

- ឱ្យសិស្សតាមក្រុមនីមួយៗគណនារកមធ្យមភាគចំនួនតំណក់ទឹកក្នុងមួយនាទីពីនាទីនីមួយខាងលើ
- បន្ទាប់មកឱ្យសិស្សគណនាមាឌតំណក់ទឹកមួយតំណក់គិតជាមីលីលីត្រ
- ឱ្យសិស្សគណនាបរិមាណទឹកដែលបានតក់ក្នុងរយៈពេលមួយម៉ោង មួយថ្ងៃ មួយសប្តាហ៍ និងមួយខែ ដោយប្រើតារាងខាងក្រោម៖

- គណនារកមធ្យមភាគចំនួនតំណក់ទឹកក្នុងមួយនាទីពីនាទីនីមួយៗខាងលើ
- គណនាមាឌទឹកមួយតំណក់គិតជាមីលីលីត្រ
- គណនាបរិមាណទឹកដែលបានតក់ក្នុងរយៈពេលមួយម៉ោង មួយថ្ងៃ មួយសប្តាហ៍ និងមួយខែ

***សំណួរពីភាគទី២៖***

*ចូរគណនាបរិមាណទឹកដែលបាត់បង់ក្នុងរយៈពេលមួយនាទី មួយម៉ោង មួយសប្តាហ៍ និងមួយខែ។*

តារាងទី២ បរិមាណទឹកដែលតក់ចោលក្នុងថេរវេលាមួយ

| ក្រុម | ១នាទី | ១ម៉ោង | ១សប្តាហ៍ | ១ខែ |
|---|---|---|---|---|
| ក្រុម១ | | | | |
| ក្រុម២ | | | | |
| ក្រុម៣ | | | | |
| ក្រុម៤ | | | | |

***សំណួរពិភាក្សាទី៣៖***

*ចូរគណនាពីការខាតបង់ថវិការពីការបាត់បង់ទឹកក្នុងរយៈពេលមួយនាទី មួយម៉ោង មួយសប្តាហ៍ និងមួយខែ។*

តារាងទី៣ តម្លៃទឹកដែលបានតក់ចោលក្នុងថេរវេលាមួយ

| ក្រុម | មួយនាទី | មួយម៉ោង | មួយសប្តាហ៍ | មួយខែ |
|---|---|---|---|---|
| ក្រុម១ | | | | |
| ក្រុម២ | | | | |
| ក្រុម៣ | | | | |
| ក្រុម៤ | | | | |

***សំណួរពិភាក្សាទី៤៖***

*ដោយប្រើតារាងទី៣ ចូរប្អូនៗសង់ក្រាបអំពីការខាតបង់ពីការដែលទឹកហូរតក់ចោលថេរវេលាមួយនាទី មួយម៉ោង មួយសប្តាហ៍ និងមួយខែ។*



<table>
<tr><td colspan="3"></td></tr>
<tr><td>- ឱ្យសិស្សផ្ទៀងផ្ទាត់សម្មតិកម្ម</td><td></td><td>- ផ្ទៀងផ្ទាត់សម្មតិកម្ម</td></tr>
<tr><td colspan="3">
<table>
<tr><td>មាឌទឹក</td><td>តិចជាង 1ml</td><td>ស្មើ 1ml</td><td>ច្រើនជាង 1ml</td></tr>
<tr><td>មួយតំណក់ទឹក</td><td></td><td></td><td></td></tr>
</table>
</td></tr>
<tr><td>- ឱ្យសិស្សតំណាងក្រុមឡើងបង្ហាញពីលទ្ធផល និងធ្វើសេចក្ដីសន្និដ្ឋានរបស់ក្រុម។</td><td></td><td>- សិស្សតំណាងក្រុមឡើងធ្វើបទបង្ហាញ លទ្ធផលរបស់ក្រុម</td></tr>
<tr><td colspan="3">៦. សន្និដ្ឋាន<br>- យើងប្រើវិធីសាស្ត្រផ្សេងៗ ឬខុសគ្នាដើម្បីវាស់ពីមាឌរបស់ទឹកមួយតំណក់។<br>- តំណក់ទឹកនីមួយៗមានមាឌខុសគ្នា ហើយតូចជាងមួយមីលីលីត្រនៃខ្នាតមាឌ។<br>- តាមរយៈក្រាបខាងលើបង្ហាញថា បើបាត់បង់ទឹកតែមួយតំណក់ ឬការដែលទឹកតក់ចោលក្នុងថេរវេលាខ្លី (មួយនាទី) នោះមិនមានការខាតបង់ថវិការច្រើននោះទេ។ ប៉ុន្តែប្រសិនបើយើងខ្វះការប្រុងប្រយ័ត្នដែលបណ្ដោយទុកឱ្យទឹកតក់ចោលរយៈពេលយូ នោះនាំឱ្យមានការខាតបង់ថវិការច្រើន។</td></tr>
<tr><td>- តើយើងត្រូវធ្វើដូចម្ដេច ក្នុងការប្រើប្រាស់ទឹកសាបនៅលើផែនដី?</td><td>GCED-Global responsibility</td><td>- ត្រូវប្រើទឹកសាបឱ្យមានការប្រុងប្រយ័ត្នខ្ពស់បំផុត និងសម្អាតបរិស្ថានឱ្យបានស្អាត។</td></tr>
<tr><td>- តើប្អូនៗត្រូវមានឥរិយាបថយ៉ាងដូចម្ដេច នៅក្នុងការចូលរួមថែរក្សា ទឹកសាបនៅលើផែនដី សម្រាប់ជាប្រយោជន៍ក្នុងសហគមន៍ និសកលលោកទាំងមូល?</td><td>GCED-Multiplication in Global Citizenship<br>▪ ទុកដាក់សំណល់ពុលឱ្យបានត្រឹមត្រូវ<br>▪ ប្រើប្រាស់ និងទុកដាក់សម្ភារៈដែលបង្កគ្រោះថ្នាក់ឱ្យបានត្រឹមត្រូវ (ហាមទុកដាក់នៅក្បែរប្រភពទឹកសាប)<br>▪ ចូលរួមនៅក្នុងសកម្មភាពសហគមន៍ក្នុងការសម្អាតបរិស្ថានឱ្យបានស្អាត</td><td>- យើងត្រូវ៖<br>▪ ទុកដាក់សំណល់ពុលឱ្យបានត្រឹមត្រូវ<br>▪ ប្រើប្រាស់ និងទុកដាក់សម្ភារៈដែលបង្កគ្រោះថ្នាក់ឱ្យបានត្រឹមត្រូវ (ហាមទុកដាក់នៅក្បែរប្រភពទឹកសាប)<br>▪ ចូលរួមនៅក្នុងសកម្មភាពសហគមន៍ក្នុងការសម្អាតបរិស្ថានឱ្យបានស្អាត<br>▪ ចូលរួមនៅក្នុងសកម្មភាពសម្អាតឆកនេរ ស្ទឹង ទន្លេង បឹងបួរ និង</td></tr>
</table>

| | | |
|---|---|---|
| - **តើប្អូនៗត្រូវចូលរួមដូចម្ដេចខ្លះដើម្បីជួយទៅដល់ពលរដ្ឋនៅតាមប្រទេសដែលខ្សត់ទឹកសាប (ប្រទេសនៅតំបន់អាព្រិច និងវាលខ្សាច់សាហារា)។** | ▪ ចូលរួមនៅក្នុងសកម្មភាពសម្អាតឆកនេរ ស្ទឹង ទន្លេង បឹងបួរ និងតំបន់ដីសើមផ្សេងៗទៀតឱ្យបានស្អាត<br>▪ ធ្វើបទបង្ហាញអំពីសារៈសំខាន់ និងការថែរក្សាទឹកស្អាតនៅក្នុងសាលារៀន សហគមន៍ និងនៅក្រៅប្រទេស។ | **តំបន់ដីសើមផ្សេងៗទៀតឱ្យបានស្អាត**<br>▪ **ធ្វើបទបង្ហាញអំពីសារៈសំខាន់ និងការថែរក្សាទឹកស្អាតនៅក្នុងសាលារៀន សហគមន៍ និងនៅក្រៅប្រទេស។**<br>- **យើងត្រូវ៖**<br>▪ **ប្រើទឹកសាបដោយមិនខ្ជះខ្ជាយ**<br>▪ **បង្កើតមូលនិធិសន្សំថវិកាដែលបានពីការសន្សំសំចៃទឹក យកទៅជួយដល់ការសិក្សាស្រាវជ្រាវលើបច្ចេកវិទ្យាផលិតទឹកសាបដល់ពលរដ្ឋនៅបណ្ដាប្រទេសដែលខ្សត់ទឹកសាបទាំងនោះ។**<br>▪ **ជៀសវាងការខួងយកទឹកសាបពីក្នុងដីខុសស្តង់ដាបច្ចេកទេស បណ្ដាលឱ្យប៉ះពាល់ដល់តំបន់ផ្សេងទៀត។** |
| **ជំហានទី៤ ពង្រឹងពុទ្ធិ** | | |
| - តើយើងត្រូវធ្វើដូចម្ដេចក្នុងការប្រើប្រាស់ទឹកសាបនៅលើផែនដី? | | - ត្រូវប្រើទឹកសាបឱ្យមានការប្រុងប្រយ័ត្នខ្ពស់បំផុត និងសម្អាតបរិស្ថានឱ្យបានស្អាត។ |
| **ជំហានទី៥ បណ្ដាំផ្ញើ** | | |
| ពេលប្អូនៗត្រឡប់ទៅផ្ទះវិញ សូមចូលរួមសម្អាតបរិស្ថានជាពិសេសទឹកសាបដែលយើងប្រើប្រាស់រាល់ថ្ងៃឱ្យបានស្អាតដោយចៀសវាងនូវការបោះចោលកាកសំណល់ផ្សេងៗទៅក្នុងទឹកសាបនៅក្នុងសហគមន៍រស់នៅរបស់ប្អូនៗ។ | | សិស្សស្ដាប់ការណែនាំ និងអនុវត្តនៅក្នុងសហគមន៍។ |

## សន្លឹកកិច្ចការ

## សេចក្តីផ្តើម

ទឹកគឺជាសមាសធាតុដែលមានសារសំខាន់ក្នុងការទ្រទ្រង់ជីវិតរស់នៅរបស់មនុស្ស សត្វ និងរុក្ខជាតិនៅលើផែនដី។ ភពផែនដីគ្របដណ្តប់ដោយផ្ទៃទឹកច្រើនជាងដីគោក ហើយនៅក្នុងចំណោមផ្ទៃទឹកទាំងអស់ ទឹកសាបមានចំនួនប្រហែល២.៥%ប៉ុណ្ណោះបូករួមទាំងទឹកកកនៅតំបន់ប៉ូល។ នៅក្នុងចំណោមទឹកសាប២.៥%នោះ ទឹកសាបដែលអាចប្រើប្រាស់សម្រាប់ទ្រង់ជីវិតរសនៅរបស់មនុស្សជាតិនៅលើផែនដី។ របាយទឹកសាបនៅលើផែនដីស្ថិតនៅជ្រៀតតាមចន្លោះប្រហោង ឬទំនាបនៃផ្ទៃទីបនានា។ របាយទឹកសាបមិនស្មើគ្នានេះធ្វើឱ្យពលរដ្ឋនៃតំបន់ខ្លះលើផែនដីជួបការខ្វះខាតទឹកសាបសម្រាប់ប្រើប្រាស់នៅក្នុងជីវភាពរស់នៅ សម្រាប់ឧស្សាហកម្ម និងសម្រាប់វិស័យកសិកម្មជាដើម។ ហេតុដូច្នេះការគ្រប់គ្រង និងការប្រើប្រាស់ទឹកសាបឱ្យមានប្រសិទ្ធិភាពគឺជាកតាព្វកិច្ចរបស់មនុស្សគ្រប់ៗនៅលើភពផែនដី។

### ១. បង្ហាញបាតុភូត

តើប្អូនៗតែងតែបានជួបបាតុភូតទាំងពីរខាងក្រោមនេះនៅកន្លែងណាខ្លះ ?





*តំណក់ទឹកចេញពីរ៉ូប៊ីនេនៅក្នុងផ្ទះបាយ ឬក្នុងបន្ទប់ទឹក* *តំណក់ទឹកធ្លាក់ពីស្លឹករុក្ខជាតិ*

### ២. សំណួរគន្លឹះ

តើទឹកមួយតំណក់ៗមានមាឌប៉ុន្មាន ?

### ៣. សម្មតិកម្ម

ចូរគូសសញ្ញា ✓ នៅក្នុងតារាងខាងក្រោម៖

| មាឌទឹក | តិចជាង 1ml | ស្មើ 1ml | ច្រើនជាង 1ml |
|---|---|---|---|
| មួយតំណក់ទឹក | | | |

## ៤. សកម្មភាព

**៤.១ សម្ភារៈ** ទឹកសាប ដបជ័រ (ដបទឹកសុទ្ធដែលប្រើប្រាស់រួច) កាជន់ជ័រ ស៊ីឡាំងក្រិត ឬកែវក្រិត នាឡិកាកំណត់ពេល ឧបករណ៍ចុងស្រួច (ចុងកូនកាំបិត ឬចុងកន្ត្រៃ)។

**៤.២ វិធីសាស្ត្រ**

***សំណួរពីភាក្យទី១៖*** *ចូររកវិធីគណនាមាឌទឹកមួយតំណក់។*

..........................................................................................................................................

..............................................................................................................................

..........................................................................................................................................

..............................................................................................................................

..........................................................................................................................................

..............................................................................................................................

..........................................................................................................................................

..............................................................................................................................

..........................................................................................................................................

..............................................................................................................................

តារាងទី១៖ កត់ត្រាទិន្នន័យ

| ក្រុម | ចំនួនតំណក់ទឹកក្នុងមួយនាទីៗ | | | | | |
|---|---|---|---|---|---|---|
| | នាទី១ | នាទី២ | នាទី៣ | នាទី៤ | ម.ភាគ | មាឌទឹកមួយតំណក់ (ml) |
| ក្រុមទី១ | | | | | | |
| ក្រុមទី២ | | | | | | |
| ក្រុមទី៣ | | | | | | |
| ក្រុមទី៤ | | | | | | |

ផ្ទៀងផ្ទាត់សម្មតិកម្ម

| មាឌទឹក | តិចជាង 1ml | ស្មើ 1ml | ច្រើនជាង 1ml |
|---|---|---|---|
| មួយតំណក់ទឹក | | | |

## ៥. វិភាគលទ្ធផល

***សំណួរពិភាក្សាទី២៖***

*ចូរគណនាបរិមាណទឹកដែលបាត់បង់ក្នុងរយៈពេលមួយនាទី មួយម៉ោង មួយសប្តាហ៍ និងមួយខែ។*

តារាងទី២ បរិមាណទឹកដែលតក់ចោលក្នុងថេរវេលាមួយ

| ក្រុម | ១នាទី | ១ម៉ោង | ១សប្តាហ៍ | ១ខែ |
|---|---|---|---|---|
| ក្រុម១ | | | | |
| ក្រុម២ | | | | |
| ក្រុម៣ | | | | |
| ក្រុម៤ | | | | |

***សំណួរពិភាក្សាទី៣៖***

*ចូរ[illegible] មួយម៉ោង មួយសប្តាហ៍ និងមួយខែ។*

តារាងទី៣ តម្លៃទឹកដែលបានតក់ចោលក្នុងថេរវេលាមួយ

| ក្រុម | មួយនាទី | មួយម៉ោង | មួយសប្តាហ៍ | មួយខែ |
|---|---|---|---|---|
| ក្រុម១ | | | | |
| ក្រុម២ | | | | |
| ក្រុម៣ | | | | |
| ក្រុម៤ | | | | |

## ៥.១ សង់ក្រាប

***សំណួរពិភាក្សាទី៤៖***

*ដោយប្រើតារាងទី៣ ចូរប្អូនៗសង់ក្រាបអំពីការខាតបង់ពីការដែលទឹកហូរតក់ចោលថេរវេលាមួយនាទី មួយម៉ោង មួយសប្តាហ៍ និងមួយខែ។*



## ៦. សន្និដ្ឋាន

ចូរប្អូនធ្វើការសន្និដ្ឋានដោយផ្អែកលើលទ្ធផលពិសោធខាងលើ។

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

..................................................................................................

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

.................................................................................................

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

..................................................................................................

......................................................................................................................................................

......................................................................................................................................................

..............................................................................................................

**Topic:** Funerals

Integrated GCED into a Reading Lesson Plan

Prepared by: Seng Sacha and Chan Thoeun

National Institute of Education

**Date:** ……………………………………………………….

**Subject:** English

**Topic:** English for Cambodia Book 6, **Chapter 7: Funerals**

**Time allowed:** 90 minutes

**I. Objectives**: By the end of the lesson students will be able to:

a. **Knowledge**:
   - skim the text to get general ideal about funerals
   - scan the text to get specific information that they want to know about funerals

b. **Skills**:
   - Use Inquiry Based Learning (KWLS) Chart to explain the learning process and get practice speaking about funerals.
   - Become self-directed learners as well as cooperate with others.
   - Develop their skills in surfing texts related to funerals of the other cultures.

c. **Attitude**
   - Mourning and nostalgic for the loss of other family members as well as other cultures.
   - Display a behave of seeking closure, attempting to find peace and acceptance after the loss.

**II. Teaching aids, materials, equipment**

English for Cambodia Book 6, Whiteboard, pictures of activities, flipcharts/ posters, markers, scotch, (Smartphone or Laptop to access the Internet)

**III. Methodology**

- Inquiry Based Learning (IBL) by integrated Global Citizenship Education (GCED) into a Reading Lesson Plan

# IV. Teaching Process

| Teacher's Activities | Contents | Students 'Activities |
|---|---|---|
| | Phase 1: Greetings ( 10 minutes ) | |
| ➢ **Greetings:** Good morning everybody. How are you ?<br>- **Check the attendance:** Who is absent today ?<br>- **Check the date:** What date is it today ?<br>➢ Small talk<br>Integrated GCED | - Greeting<br>- Attendance<br>- Classroom Hygiene<br>- Previous lesson<br>+ If you have attended funerals before and feel comfortable sharing your experiences. Briefly mention and share your experiences with your partners. | - Clean the classroom<br>- The class monitor reports<br>- Get ready for today's lesson<br>- Answer questions<br>- Asks students to work in pair to share ideas with partners before sharing as a whole class |
| | Phase 2: Revision Lesson ( 5 minutes ) | |
| **Revision Lesson**<br>How can you protect yourself from flood ? | Revise what students learnt in previous lesson about the Natural of Disaster | - Asks a few students to answers or tell the class what they have learnt. |
| | Phase 3: Start New Lesson ( 55 minutes ) | |
| **Start New Lesson**<br>❖ **Pre-Focusing / Asking Questions**<br>**( Uses KWLS chart )** | - Asks students to answer the questions and fill in the KWLS | - Some students answer the questions.<br>- Students work in groups of 4/6 using their background |

| | | |
|---|---|---|
| - Asks students to work in groups to fill in the first column of the KWLS chart all what they know about the funerals.<br>- Students can fill in all words, phrases and ideas related to funerals | - Have you ever attended a Funeral? When, Where, Who? | knowledge to complete the first column (K) of the KWLS chart. |

| KWLS Chart | | | |
|---|---|---|---|
| What do you **Know** about the funerals? | What do you **Want** to know about the funerals? | What have you **Learnt** about the funerals? | What do you want to **Search** more about the funerals? |
| ……………………….<br>……………………….<br>………………………. | …………………….<br>…………………….<br>……………………. | ……………………….<br>……………………….<br>………………………. | ……………………….<br>……………………….<br>………………………. |

| | | |
|---|---|---|
| ❖ **Processing /Investigating** into various situations<br>- Asks students to discuss in groups and brainstorm all their ideas of what they want to learn about funerals before filling in the column (W) of the KWLS chart | **Free discussion** | - Students discuss and brainstorm all their ideas before filling in the column (W) of the KWLS chart |
| ❖ **Creating / Conducting analyses and provide descriptions**<br>- Students discuss and put the most important information in the column | | - Students discuss to get the most important points and fill in the column (W) of the KWLS chart using their own words. |

| | | |
|---|---|---|
| ( W ) of the KWLS chart using their own words. | | |
| ❖ **Thinking about/ Discussing information and knowledge obtained**<br>- Asks each group to read the texts, discuss and fill in all what they have just learnt in the third column of the KWLS chart.<br>- Asks students to re-write what they cannot find the answer in 'S' column ( just in case ) | ➢ **Group Discussion**<br>**- English for Cambodia Book 6, Chapter 7 / Use internet to search for every point listed in the column L** | - Students discuss and fill in what they have just learnt about the funerals<br>- Students skim and scan the texts in the book and any related texts found online.<br>- Students discuss within groups and write in 'L' column. |
| ❖ **Reflecting / Sharing Information**<br>- Asks Students to form new groups and present their charts to their new groups.<br>- Asks each group if they can answer to the point in 'S' column | **Onion Grouping/**<br>**Cross Grouping/ Jigsaw/**<br>**Students present their chart to their new groups** | - Students tell the other friends in new groups about their charts<br>- Students search all what they want to learn more via Internet as their homework |
| **Phase 4: Strengthening The Lesson ( 15 minutes )** | | |
| **Strengthening**<br>➢ Integrated GCED<br>- Difference and perspective for diversity | ➢ Asks students to work groups or 3 or 4 ask and answers the questions.<br>+ How are funeral expenses typically managed in your country and the other countries you know ? | - Group work<br>- Whole class |

| | | |
|---|---|---|
| ➢ Reflection | + Are there any differences in the type and form of burial or cremation methods ?<br><br>+ Are there any specific rituals or ceremonies unique to funerals in each country ?<br><br>+ How do cultural beliefs and values shape the grieving process and mourning rituals after a funeral ?<br><br>+ What environmental considerations should be taken into account when organizing a sustainable funeral ceremony ?<br><br>➢ Students walk around and tell at least 2 friends about what they have just learnt. | - Students walk around and tell 2 friends all what they have just learnt |

| | | |
|---|---|---|
| | | - 2/3 students tell the class about what they have just learnt. |
| **Phase 5: Closing (3/5 minutes)** | | |
| **Closing**<br>**Homework**<br>- Asks Students to read the texts again and do all exercises<br>- Reminds students to search more to answer to the remained questions from each group (Homework) | - Tells students to read the texts again and search more at home and do exercises. | - Asks students to read the texts again and search more at home and do exercises. |

**Possible answers**

| What do you **know** about the funeral? | What do you **want** to know about the funeral? | What have you **learnt** about the funeral? | What do you want to **search** more about the funeral? |
|---|---|---|---|
| - Take place at their houses or the pagoda<br>- burn<br>- white flag<br>- cremate<br>- bitter grief | - Can describe the scene before, during and after the funeral.<br><br>- Can describe ideas about the Buddhist advise | **Students ideas of what they have just learnt.**<br>- All people will die<br>- Sharing sorrow to the family of the dead<br>- Keep as in the temples<br>- Death is not the end of one life | - Students search more what they want to know, for example: How do Muslim people celebrate when people die? |

| | | | |
|---|---|---|---|
| - ceremony<br>- mourner<br>- coffin<br>- sad<br>- crematorium<br>- bury<br>- condolence | - Can describe the feeling of the loss of their member. | - The monks have to calm the soul<br>- The coin is placed in the corpse´s mouth<br>- Why some people are so greedy to grab all the things for themselves | - I want to search why do our ancestors put the coin in the corpse´s mouth. |

**Au restaurant en mettant GCED**

NGUON Chanleakhena,
Institul National de l'Éducation

- **Date:** ………………………………………………
- **Public** : Étudiants-enseignants
- **Thème** : 3
- **Leçon 12** : Au restaurant
- **Séance du cours n⁰** : 2
- **Durée de la séance** : **1h30mn**
- **Objectif du cours** : Les étudiants sont capables de savoir et connaître les divers des gastronomie asiatiques et françaises et les vocabulaires
    a. **Savoir** : Comprendre les informations auprès de la gastronomie asiatiques et françaises
    b. **Savoir-faire/Compétences cognitive :** Être capable de comprendre les information sur la recette asiatiques et françaises et Avoir une bonne manière à table
    c. **Savoir-être et responsabilité (Compétence interpersonnelle et responsabilité) :** Aimer apprendre la langue française sur la gastronomie asiatique et français
- **Support** : Tous Ensemble II, page 96, (https://www.cuisineaz.com/recettes/pho-ga-soupe-vietnamienne-au-poulet.aspx, https://www.marmiton.org/recettes/recette_pad-thai-aux-crevettes.aspx)
- **Méthodologie directe et Enseignement apprentissage selon 5Es**

| **Déroulement** | | |
|---|---|---|
| **Enseignant** | **Contenus (support/matériels nécessaires, activités, correction, remarques, etc.)** | **Elève** |
| **1er pas : Prise de contact (3mn)** | | |
| - Dire bonjour aux élèves : *Bonjour, tout le monde. Comment allez-vous ? Je vais bien, merci.*<br>- Demander la date à un/une élève(e) : *Quel jour nous sommes ?*<br>- Ecrire la date au tableau<br><br>Demander le nombre d'absents et les noms des absents au major de la classe : aujourd'hui, il y a | **Salutation**<br><br>**Administration de la classe**<br>- Contrôler la classe<br>- L'hygiène,<br>- La propreté,<br>- La discipline,<br>- La présence<br>- Les matériels pédagogiques<br>- Les matériels numériques etc. | - Répondre : Bonjour, Madame. Nous allons bien, merci. Et vous ?<br><br>- Ecouter et respecter<br><br>- Répondre : Nous sommes….<br><br>- Ecrire la date au tableau et les autres regardent le tableau<br><br>- Répondre : aujourd'hui, il y a… |

| | | |
|---|---|---|
| combien d'absents ? et qui sont-ils ? | | |
| **2e pas : Amorce (7mn)** | | |
| + Demander aux élèves de corriger le devoir à la maison et ramasser.<br><br>+ Ramasser les devoirs à la maison.<br><br>+ Bon, maintenant on va corriger le devoir à la maison ensemble et féliciter à tous les élèves, qui ont fait les devoirs. | **Le corrigé d'exercice 3**<br><br>Tout d'abord nous ramassons le devoir et puis nous corrisons ensembrs<br><br>1. Bopha prend une salade en entrée pour l'entrée<br>2. Pour la boisson, elle prend l'eau<br>3. Jean prend une bouteille de vin rouge. | - Répondre<br>- Recopier<br><br>- Donner le devoir<br>- Noter la correction<br>- Poser sur le vocabulaire ce qui ne sait pas. |
| **3e pas : Leçon du jour (35mn)** | | |
| **Étape 1 : Présentation**<br><br>+ Annoncer la leçon du jour.<br><br>- Aujourd'hui, on va continuer la leçon 12 sur la civilisation.<br><br>- et webside www.les gastronomies asiatiques et françaises<br><br>+ Demander aux élèves d'ouvrir le livre à la page 96. | Activité 1 : Civilisation<br><br>Objectifs :<br><br>- Les élèves sont capables de connaitre les plats asiatiques ni les plats français et les vocabulaires des plats.<br><br>Support : Tous Ensemble II, page 96 et 97, et webside www.les gastronomies asiatiques et françaises | - Ecouter<br><br>- Ouvrir le livre<br><br>- Ouvrir le lien<br><br>- Écouter<br><br>- Consulter |

| | | |
|---|---|---|
| Puis, faire observer les photos.<br><br>À partir ce lien les étudiants peuvent consulter<br><br>Les receptes asiatique et français.<br><br>-Bon, ouvrez votre livre à la page 96/le lien. Puis, observez les photos.<br><br>- À partir ce lien les étudiants peuvent trouver les images puis les élèves peuvent discuter entre vous<br><br>+ Poser quelques questions concernant les photos.<br><br>- Faire la comparasion entre les plats asiatique et français.<br><br>-Qu’est-ce que vous voyez sur les photos ?<br><br><br><br> | - Annoncer l’activité du jour et faire ouvrir le livre et aussi cliquer sur le lien ce que le professeurs a donné<br><br>Leçon 12 : <u>Au Restaurant</u><br><br>+ Civilisation<br><br><br><br><br><br>- Attirer l’attention les élèves en regardant les photos dans la leçon et le lien ce qu’on a donné à consulter et puis poser les questions. | - Demander<br><br>- Répondre<br><br>- Lire la question<br><br>- Répondre<br><br>- Donner<br><br>- Argumenter<br><br>- Lire<br><br>- Regarder au tableau<br><br>- Regarder les photos<br><br>- Écouter<br><br>- Répondre |

| | | |
|---|---|---|
|  | <u>Questions et Réponses</u><br><br>1. Qu’est-ce que vous voyez l’image ?<br>=> Je vois les photos.<br>2. Il y a combien de photos ?<br>=> Il y a beaucoup des photos.<br>3. Les photos de quoi ?<br>=> Ce sont les photos de plats asiatiques et françaises.<br>4. Est-ce qu’il ya des plats français ?<br>=> Oui<br>5. Est-ce qu’il ya des plats asiatique ?<br>=> Oui<br>6. Quels sont les différences entre les plats asiatique et les françaises ?<br>=> Pour les plats asiatiques, ils sont plustôt sucrée et huit<br>=> Pour les plats français, ils sont plustôt salé et avec des bures et fromage aussi. | |
| **Étape 2 : Questions**<br><br>+ Demander aux élèves de lire les questions.<br>-Qui peut lire les question ? | -Il y a 2 questions. | - Répondre : Moi madame, …. |
| + Poser les questions :<br>-Il y a combien de question ? | <u>Questions et Réponses</u><br><br>1. Quel plat aimes-tu manger le matin ? le déjeuner ? le dîner ? | - Regarder au tableau |
| + Écrire les questions au tableau.<br>+ Expliquer les questions aux élèves. | 2. Quel est ton plat préféré ?<br><br>- Faire la correction ensemble. | - Recopier dans le cahier<br><br>- Ecouter |

| | | |
|---|---|---|
| + Laisser un peu de temps pour répondre les questions.<br><br>**Étape 3 : Correction**<br><br>+ Demander une volontaire de répondre la question 1.<br><br>-Qui peut répondre la question 1 et 2 ?<br><br>-On vas corriger ensemble.<br><br>+ Laisser quelques minutes aux élèves de recopier les réponses au tableau.<br><br>-Je vous laisse 2 minutes de recopier les réponses au tableau. | - Demander la volontaire pour répondre la question.<br>- Ecrire les réponses au tableau.<br>- Corriger tous ensemble.<br>- Laisser le temps pour recopier | - Recopier<br>- Regarder au tableau<br>- Travailler en groupe<br>- Parler |
| + Annoncer la 2ème activité du jour.<br><br>- Donc, maintenant on va continuer une autre activité, c'est Production orale sur le point Apprendre à parler.<br><br>+Ecrire les mots difficiles au tableau et les vocabulaires concernants les plats en expliquant et traduire en khmer.<br><br>+Ecrire le point Apprendre à parler au tableau en expliquant tous les points.<br><br>+Demander aux élèves de faire travailler en groupe et laisser le temps pour faire.<br><br>- Je vous laisse 5mn pour discuter ou travailler par | **Activité 2 : PO (30mn)**<br><br>Objectifs :<br>- Les élèves sont capables de présenter la manière de prendre et de commander les plats asiatiques et françaises dans une restaurent.<br><br>Support : Tous Ensemble II, page 97 et et webside [www.les plats asiatiques et françaises]() | - Jeu de rôle<br>- Discuter<br>- Consulter<br>- Trouver<br>- discussion<br>- Jeu de rôle |

| | | |
|---|---|---|
| groupe de 3 ou 4 personnes et après faire de jeu du rôle.<br><br>+Demander le groupe volontaire pour faire de jeu de rôle au tableau et les autres font écouter.<br><br>-Qui est volontaire de jeu de rôle ?<br><br>-Allez au tableau, s'il vous plait. | Annoncer la 2ème activité<br><br>- Ecrire les mots difficiles au tableau.<br>(de poulet et du canard, escargots, un filet de jus de citron, le foie gras, jambon/fromage/œuf etc…)<br><br>- Demander de faire travailler en groupe<br><br>- Demander le groupe volontaire de faire de jeu de rôle.<br><br>( la conversation dans une restaurante asitique ou français) | |
| **4e pas : Renforcement des acquis (10mn)** | | |
| +Poser quelques questions après le cours.<br><br>- Qu'est-ce qu'on a appris à tout à l'heure ?<br><br>-Quels sont les plats asiatiques ?<br><br>Quels sont les plats Françaises ? | Civilisation entre les pays asiatiques et les pays européennes<br><br>Les pluparts des gastronomies asiatiques et les gastronomies françaises.<br><br>Les recettes des plats asiatiques et les plats françaises<br><br>Les vocabulaires de la nurriture<br>Avoir une bonne manière à table<br><br>**Echanger les idées et les goût préférer** | - Répondre :<br><br>- On a appris sur la civilisation,<br><br>- Les plats asiatiques et français etc...<br><br>- Point Apprendre à parler et connaitre les ingraidiens des plats<br><br>- Du poulet du curry, des nems, des pâtes avec des … |
| **5e pas : Devoir à la maison et conseil (5mn)** | | |
| - Avant de finir notre cours, le professeur donne un devoir à faire en groupe de deux | | |

| | | |
|---|---|---|
| personnes à la maison sur les plats préférer en mettant les recettes , (faire un exposé en classe à la semaine prochaine) | **Exposé en classe de votre travail à la semaine prochaine !** | - Ecouter et noter |

# ប្រធានបទ៖ សុវត្ថិភាពការផ្សារអគ្គិសនី

សយ សិលា
វិទ្យាស្ថានជាតិអប់រំ

- កាលបរិច្ឆេទ ៖ ថ្ងៃ................ ខែ.............ឆ្នាំ.................ព.ស .........
  ត្រូវនឹងថ្ងៃទី.................ខែ...........................ឆ្នាំ....................
- មុខវិជ្ជា ៖ មេកានិក
- ថ្នាក់ ៖ ឆ្នាំទី១ (ថ្នាក់ទី១០)
- ជំពូកទី១ ៖ ការផ្សារ
- មេរៀនទី១ ៖ការផ្សារដោយចរន្តអគ្គីសនី
- រយៈពេល ៖ ៥០នាទី

## I. វត្ថុបំណងនៃមេរៀន

ក្រោយពីរៀនខ្លឹមសារនៃមេរៀននេះចប់សិស្ស៖

- **វិជ្ជាសម្បទា៖** រៀបរាប់ពីគ្រោះថ្នាក់ដែលបណ្តាលពីការផ្សារអគ្គីសនី វិធានការការពារនិងឧបករណ៍សុវត្ថិភាពសម្រាប់ការផ្សារអគ្គីសនី បានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម។
- **បំណិនសម្បទា៖** អនុវត្តការប្រើប្រាស់ឧបករណ៍សុវត្ថិភាពសម្រាប់ការផ្សារអគ្គិសនីបានត្រឹមត្រូវតាមរយៈការប្រត្តិបត្តិដាក់ស្តែង។
- **ចរិយាសម្បទា៖** មានទំនួលខុសត្រូវ និងប្រុងប្រយ័ត្នខ្ពស់ចំពោះការប្រើប្រាស់ឧបករណ៍សុវត្ថិភាព និងមានសណ្តាប់ធ្នាប់ល្អ។

## II. សំភារៈឧបទេស

សៀវភៅ ប៊ិច បន្ទាត់ ក្តាខៀន គុ ហ្វឺត រូបភាព LCD Projector
ឧបករណ៍សុវត្ថិភាពសម្រាប់ផ្សារអគ្គិសនី...

## III. វិធីសាស្ត្របង្រៀន

គោលវិធីសិស្សមជ្ឈមណ្ឌលតាមបែបសហការដោយបញ្ញាប GCED

## IV. ដំណើរការបង្រៀន និងរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| **ជំហានទី១ ៖ លំនឹងថ្នាក់ ឬរដ្ឋបាលថ្នាក់ (៣នាទី)** | | |
| – ត្រួតពិនិត្យអនាម័យ<br>– អវត្តមានសិស្ស<br>– សណ្តាប់ធ្នាប់។ | ការរៀបចំការបង្រៀន<br><br>បញ្ញាប GCED | – ប្រធានថ្នាក់ឡើងរាយការណ៍អវត្តមាន<br>– សិស្សអង្គុយតាមកន្លែង |

| | | |
|---|---|---|
| **ជំហានទី២ ៖ រំលឹកមេរៀនចាស់ ( ៥នាទី )** | | |
| - យើងបានសិក្សារួចមកហើយ ពីនិយមន័យនៃការផ្សារ បញ្ហា និង ការថែទាំជុសជុល<br>- គោលការណ៍នៃដំណើរការផ្សារអគ្គិសនី។<br>- ចូរឲនិយមន័យ ការផ្សារអគ្គិសនី។<br>- ចូរនិយាយរៀបរាប់អំពីដំណើរការផ្សារដោយចរន្តអគ្គិសនី | - ចំណេះដឹងមូលដ្ឋានសម្រាប់ការផ្សារដោយអគ្គិសនី និងដំណើរផ្សារដោយចរន្តអគ្គិសនី។ | - សិស្សឆ្លើយសំណួរ៖<br>- ការផ្សារអគ្គិសនី គឺជាការបម្លែងថាមពលអគ្គិសនីអោយទៅជាថាមពលកម្តៅ ដើម្បីអោយរលាយចូលគ្នាជាសាច់តែមួយរវាងដុំការងារនិងធូបផ្សារ។<br>- សិស្សនិយាយរៀបរាប់អំពីដំណើរការផ្សារដោយចរន្តអគ្គិសនី |
| **ជំហានទី៣ ៖ ខ្លឹមសារមេរៀនថ្មី ( ៣០នាទី )** | | |
| មេរៀនទី១ការផ្សារដោយចរន្តអគ្គិសនី<br><br>ចូរប្អូនមើលរូបភាព៖<br><br><br><br>➢ចែកសិស្សជាពីរក្រុម៖<br>ក្រុមទី១<br>ក្រុមទី២ | មេរៀនទី១ ការផ្សារដោយចរន្តអគ្គិសនី<br>១.៧ សុវត្ថិភាពការងារផ្សារអគ្គីសនី និងអនាម័យ<br><br>១.៧.១គ្រោះថ្នាក់ដែលបណ្ដាលពីការផ្សារអគ្គិសនី<br><br>ក.ផ្សែងដែលភាយចេញពីលោហៈធាតុនៅពេលកំពុងផ្សារអគ្គិសនី | - សិស្សសង្កេត៖<br><br>- សិស្សឆ្លើយ.................<br><br>- សិស្សចូលតាមក្រុម៖ |

| | | |
|---|---|---|
| សំណួរពិភាក្សាក្រុមៈ<br>➢ តើគ្រោះថ្នាក់ដែលបណ្តាលពីការផ្សារអគ្គិសនីមានអ្វីខ្លះ ?<br>➢ តើយើងមានវិធានការអ្វីដើម្បីការពារគ្រោះថ្នាក់បណ្តាលពីការផ្សារអគ្គិសនី ប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព ?<br>(បញ្ជ្រាប GCED ) | <br>ផ្សែងដែលភាយចេញពីលោហៈធាតុនៅពេលឆេះមានគ្រោះថ្នាក់ដល់សុខភាពដូចជាពពួកលោហៈ Zn, Al ,Fe,Cr, Cu, Pb, S វាធ្វើអោយយើងពិបាកដកដង្ហើម វិលមុខ ឈឺក្បាល តឹងទ្រូង ធ្លល់ពោះ ក្អក ចង់ក្អួត ទល់លាមក ឈឺភ្នែក ជាពិសេសប៉ះពាល់ដល់សសៃប្រសាទ និងបរិស្ថាន។<br>ខ.កាំរស្មីដែលកើតឡើងនៅពេលកំពុងផ្សារអគ្គិសនី<br><br>កាំរស្មីដែលកើតឡើងនៅពេលផ្សារមានគ្រោះថ្នាក់ដូចជា៖<br>- កាំរស្មីនេះបង្ករអោយគ្រោះថ្នាក់បំផុតដល់សារពាង្គកាយយើង កាលណាវាចាំងមក ប៉ះខ្លួន | - សិស្សពិភាក្សាតាមក្រុម.........<br>- សិស្សយកឧបករណ៍សុវត្ថិភាពដាក់លើតុតាមក្រុមនីមួយៗបានយ៉ាងត្រឹមត្រូវប្រកបដោយទំនួលខុសត្រូវ និងការសហការខ្ពស់<br>- សិស្សយកឧបករណ៍សុវត្ថិភាព និងរៀបរាប់ពីការប្រើប្រាស់ឧបករណ៍សុវត្ថិភាពសម្រាប់ការផ្សារអគ្គិសនី |

| | | |
|---|---|---|
| គ្រូសម្របសម្រួលចម្លើយរបស់សិស្ស<br><br>២. ឧបករណ៍សុវត្ថិភាព និងការប្រើប្រាស់សម្រាប់ការផ្សារអគ្គិសនី | ប្រាណយើងធ្វើអោយស្បែករបក ស្បែកស្ងួតឡើងជាំខ្មៅ ។<br>- ពេលចាំងប៉ះមុខ ភ្នែកស្រវាំងភ្នែកនិងរលាកប្រស្រីភ្នែក ។<br><br>គ.គ្រោះថ្នាក់ទូទៅដែលកើតឡើងនៅពេលអនុវត្តន៍ការផ្សារអគ្គិសនី<br><br>- ភ្លើងឆក់នៅពេលកំពង់ផ្សារនៅកន្លែងសើម រឺនៅពេលមានភ្លៀងធ្លាក់ ។<br>- រលាក ដៃ ជើង ក្បាល ខ្លួនប្រាណ ពេលកំពង់ផ្សារ ដោយគ្មានប្រដាប់ការពារ កំទេចដែកក្ដៅ លោតខ្ទាតចូលភ្នែកពេលគោកញ៉ឹមមិនពាក់វែនតា ។<br>- ធ្លាក់ពីលើអាគារ រឺជណ្ដើរដែលបណ្ដាលមកមិនប្រើខ្សែក្រវាត់ពាក់ការពារ ។ | សិស្សឡើងបកស្រាយចម្លើយ....<br><br>សិស្សស្ដាប់គ្រូពន្យល់និងកត់មេរៀន |

| | | |
|---|---|---|
| ក.ស្រោមមុខ ឬរបាំងមុខសុវត្ថិភាព<br><br>ខ.ស្រោមដៃសុវត្ថិភាព<br><br>គ.សម្លៀកបំពាក់សុវត្ថិភាព<br><br>ឃ.ស្បែកជើងសុវត្ថិភាព<br><br>ង.វ៉ែនតាសុវត្ថិភាព និងម៉ាស | ២. ឧបករណ៍សុវត្ថិភាព និងការប្រើប្រាស់សម្រាប់ការផ្សារអគ្គិសនី<br><br>ការអនុវត្តន៍ការផ្សារដែក គឺជាការងារមួយដែលងាយមានគ្រោះថ្នាក់បំផុត វាអាចបង្កអោយរលាកសរីរាង្គកាយ រលាកភ្នែក ឬអាចឆក់យកជីវិត។ ដូចនេះមុននឹងអនុវត្តន៍ការងារផ្សារ យើងត្រូវតែប្រើឧបករណ៍ការពារសុវត្ថិភាព ជាចាំបាច់ ដែលមានដូចជា ស្រោមមុខ ឬរបាំងមុខសុវត្ថិភាព ស្រោមដៃសុវត្ថិភាព សម្លៀកបំពាក់សុវត្ថិភាព ស្បែកជើងសុវត្ថិភាព និងវ៉ែនតាសុវត្ថិភាព និងម៉ាស។<br><br>ក.ស្រោមមុខ ឬរបាំងមុខសុវត្ថិភាព<br><br>ស្រោមមុខ ឬរបាំងមុខសុវត្ថិភាព គឺជាឧបករណ៍ប្រើប្រាស់ពេលអនុវត្តន៍ការងារផ្សារ ដើម្បីការពារប្រឆាំងនឹងពន្លឺកាំរស្មីដោយផ្ទផ្សារ និងការពារការជះនូវកំទិចកំទីមកលើផ្ទៃមុខរបស់យើង ពេលប្រតិបត្តិការងារផ្សារ។ ប្រសិនបើយើងមិនមានឧបករណ៍នេះទេ យើងត្រូវមានយ៉ាងហោចណាស់កញ្ចក់ខ្មៅមួយសម្រាប់ការពារកាំពន្លឺកុំអោយចាំងចូលភ្នែក ដែលនាំអោយរលាកភ្នែក។ | |

| | | |
|---|---|---|
| | <br>ខ.ស្រោមដៃសុវត្ថិភាព<br>ដើម្បីធានាបាននូវការការពារ ពីការរលាកដោយកម្ដៅ ការមុតដោយកំទិចកំទី និងការចាប់កាន់ខ្សែចម្លងចរន្តអគ្គិសនីដោយដៃរបស់យើង យើងត្រូវប្រើប្រាស់ស្រោមដៃសុវត្ថិភាព អោយបានគ្រប់ពេលអនុវត្តន៍ការងារផ្សារ។<br> <br>គ.សម្លៀកបំពាក់សុវត្ថិភាព<br>សម្លៀកបំពាក់ដែលប្រើពេលអនុវត្តិការងារផ្សារ មានលក្ខណៈក្រាស់គ្មានហោប៉ៅ ពេលប្រើហាមរមួលជើង និងមិនអោយមានស្នាមរហែក។ យើងប្រើវាដើម្បីការងារ ការរលាក និងខ្ទាតកំទិចកំទីមកប៉ះរាងកាយរបស់យើងពេលអនុវត្តន៍ការងារផ្សារ។ | |



### ឃ.ស្បែកជើងសុវត្ថិភាព

ស្បែកជើងសុវត្ថិភាព គឺជាឧបករណ៍ការងារមួយដ៏ចាំបាច់សម្រាប់អ្នកអនុវត្តន៍ការងារផ្សារ។ អ្នកអនុវត្តន៍ការងារផ្សារប្រើប្រាស់ស្បែកជើងសុវត្ថិភាព ដើម្បីការងារជើង ពីការធ្លាក់ដុំដែកលើជើង ការពារការមុត ការរលាក និងការឆក់ដោយចរន្តអគ្គិសនីជាដើម។



### ង.វ៉ែនតាសុវត្ថិភាព និងម៉ាស

ជាទូទៅគេមិនសូវប្រើវ៉ែនតាសុវត្ថិភាពទេ ពីព្រោះវាការពារមិនបានល្អដូចរបាំងមុខសុវត្ថិភាព។ វ៉ែនតាសុវត្ថិភាព ត្រូវបានអ្នកអនុវត្តន៍ការងារផ្សារមួយចំនួនយកមកប្រើជំនួសរបាំងមុខសុវត្ថិភាព ដើម្បីប្រើការពារភ្នែកកុំអោយកាំរស្មីពន្លឺចាំងចូលភ្នែក ដែលបណ្តាលអោយភ្នែកឡើងក្រហម រលាក និងបង្កជាមហារីកគ្រាប់ភ្នែក។ ដើម្បីធានាបាននូវសុវត្ថិភាពលើផ្ទៃមុខពេល

| | | |
|---|---|---|
| | អនុវត្តន៍ការងារផ្សារ យើងត្រូវប្រើរបាំងមុខសុវត្ថិភាពដើម្បីការពារផ្ទៃមុខបានល្អ។<br> <br><br>**៣.វិធានការការពារគ្រោះថ្នាក់ពីការផ្សារដែកដោយប្រើចរន្តអគ្គិសនី**<br>ដើម្បីកាត់បន្ថយគ្រោះថ្នាក់ និងហានិភ័យសម្រាប់អ្នកអនុវត្តន៍ការងារផ្សារ យើងត្រូវមានវិធានការការពារដូចជា៖<br>**ក.វិធានការការពារគ្រោះថ្នាក់ដែលបង្ករដោយផ្សែងពុលដែលកើតមានពេលកំពុងផ្សារ**<br>ការការពារមួយដែលមានប្រសិទ្ធភាពក្នុងការប្រឆាំងនឹងគ្រោះថ្នាក់ដោយសារផ្សែងពុល គឺការរៀបចំប្រព័ន្ធខ្យល់ក្នុងបរិវេនអនុវត្តន៍ការងារផ្សារនិងពាក់ម៉ាសអោយបានត្រឹមត្រូវ។ ជាពិសេស ត្រូវរៀបចំកន្លែងផ្សារអោយមានលក្ខណៈធំទូលាយ មានខ្យល់អាកាសធម្មជាតិចេញចូលគ្រប់គ្រាន់។ | |

<table>
<tr>
<td>

**៣.វិធានការការពារគ្រោះថ្នាក់ពីការផ្សារដែកដោយប្រើចរន្តអគ្គិសនី**




</td>
<td>



**ខ.វិធានការការពារគ្រោះថ្នាក់ដែលបង្ករដោយកាំរស្មីពន្លឺដែលកើតមានពេលកំពុងផ្សារ**

ដើម្បីការពារកាំរស្មីពន្លឺដែលជះទៅលើផ្ទៃមុខ និងស្បែកពេលអនុវត្តន៍ការងារផ្សារ យើងចាំបាច់ត្រូវតែប្រើប្រាស់ឧបករណ៍ការពារសុវត្ថិភាព ដូចជា របាំងមុខសុវត្ថិភាពសម្លៀកបំពាក់សុវត្ថិភាព និងស្បែកជើងសុវត្ថិភាពអោយបានត្រឹមត្រូវជានិច្ច។

**គ.វិធានការការពារគ្រោះថ្នាក់ដែលបង្ករដោយចរន្តអគ្គិសនី**

ដើម្បីការពារការប៉ះដោយផ្ទាល់ជាមួយខ្សែចម្លងចរន្តអគ្គិសនីយើងគម្បីប្រើប្រាស់អ៊ីសូឡង់ដើម្បីការពារការឆក់ដោយចរន្តអគ្គិសនី។ ជាពិសេស ត្រូវត្រួតពិនិត្យមើលលើប៉ុស្តិ៍ផ្សារ កុងតាក់និងមុខតំណរខ្សែចម្លងចរន្តអគ្គិសនីអោយបានត្រឹមត្រូវមុនពេលអនុវត្តន៍ការងារផ្សារ។

</td>
<td>

- សម្អាតនិងរៀបចំទុកដាក់ឧបករណ៍សុវត្ថិភាពសម្រាប់ការផ្សារអគ្គិសនី ក្នុងរោងជាងត្រូវកន្លែងដើម



</td>
</tr>
</table>

<table>
<tr><td></td><td></td><td></td></tr>
<tr><td colspan="3">ជំហានទី៤ ៖ ពង្រឹងពុទ្ធិ ( ១០នាទី )</td></tr>
<tr><td>➢ តើយើងគួធ្វើដូចម្តេចដើម្បីអនុវត្តន៍ការផ្សារអគ្គីសនីប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព ?<br>( បញ្ជ្រាប GCED )<br><br>➢ តើមានឧបករណ៍សុវត្ថិភាពអ្វីខ្លះដែលប្រើពេលកំពុងផ្សារអគ្គិសនី ?<br><br>- គ្រូឲសិស្សអនុវត្តន៍ការប្រើប្រាស់ឧបករណ៍សុវត្ថិភាពសម្រាប់ការផ្សារអគ្គិសនី។</td><td>➢ ដើម្បីអនុវត្តន៍ការផ្សារអគ្គីសនី ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព យើងត្រូវ៖<br>- ប្រើប្រាស់ឧបករណ៍សុវត្ថិភាពឲបានត្រឹមត្រូវ<br>- យកចិត្តទុកដាក់ប្រកបដោយស្មារតីប្រុងប្រយ័ត្ននិងទំនួលខុសត្រូវខ្ពស់<br>- ការចូលរួមសហការ (ថែរក្សា ការពារ ចំនេញពេលវេលា និងបរិស្ថានស្អាត)។<br><br>- អនុវត្តន៍ការប្រើប្រាស់ឧបករណ៍សុវត្ថិភាពសម្រាប់ការផ្សារអគ្គិសនី</td><td>- សិស្សឆ្លើយ....<br><br>- សិស្សទាំងអស់គ្នាបានយល់ដឹងពីខ្លឹមសារនីមួយៗនៃគ្រោះថ្នាក់ដែលបណ្តាលពីការផ្សារអគ្គិសនី និងវិធានការការពារ<br><br>- សិស្សអនុវត្តការប្រើប្រាស់ឧបករណ៍សុវត្ថិភាពសម្រាប់ការផ្សារអគ្គិសនី</td></tr>
</table>

| | | |
|---|---|---|
| | |  - រៀបចំឧបករណ៍សុវត្ថិភាព សម្រាប់ការផ្សារអេគ្គិសនីមាន សណ្តាប់ធ្នាប់ល្អ អនាម័យ និង ទំនួលខុសត្រូវខ្ពស់  |
| **ជំហានទី៥ ៖ បណ្តាំផ្ញើនិងកិច្ចការផ្ទះ (២នាទី)** | | |
| សិស្សទាំងអស់គ្នាត្រូវអានមេរៀន ឡើងវិញ និងមេរៀនបន្ទាប់ ។<br>- គ្រូបញ្ជាប និងណែនាំ សិលធ៌ម វិជ្ជាជីវៈទៅលើការអនុវត្តជាក់ស្តែង<br>- ចែករំលែកចំណេះដឹងដែលទទួលបាន ទៅកាន់មនុស្សជុំវិញខ្លួន | | បាទ/ចាស<br>សិស្សស្តាប់ការណែនាំ និងធ្វើតាមគ្រូ ប្រកបដោយ សិលធ៌ម វិជ្ជាជីវៈ ទៅលើការអនុវត្តជាក់ស្តែង ដោយប្រើចំណេះដឹងដែលទទួលបាន |

# ប្រធានបទ៖ សំណុំ

ចាន់ រ៉ាដា, ស៊ឹម វិសុទ្ធ
វិទ្យាស្ថានជាតិអប់រំ

**កាលបរិច្ឆេទ៖** ថ្ងៃ.........ខែ ......... ឆ្នាំ..................ព.ស. ២៥៦........
ត្រូវនឹងថ្ងៃទី...... ខែ......... ឆ្នាំ២០២........

**មុខវិជ្ជា** ៖ គណិតវិទ្យា

**ថ្នាក់ទី** ៖ ១០ (ភាគ១)

**ជំពូក១** ៖ តក្កវិទ្យា សំណុំ និងចំនួន

**មេរៀនទី២** ៖ **សំណុំ**

២.១. សញ្ញាណនៃសំណុំ

ក. សំណុំកំណត់តាមការរៀបរាប់ឈ្មោះធាតុ

**រយៈពេល** ៖ ៥០នាទី

I. **វត្ថុបំណង** ៖ ក្រោយពីបញ្ចប់ខ្លឹមសារនៃមេរៀននេះ

- **វិជ្ជាសម្បទា៖** សិស្សកំណត់ពីសញ្ញាណសំណុំបានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម និងការសម្រប សម្រួលរបស់គ្រូ
- **បំណិនសម្បទា(ជំនាញនៃការគិត, លេខនព្វន្ត បច្ចេកវិទ្យា និងទំនាក់ទំនង)៖** សិស្សសរសេរសំណុំ តាមការរៀបរាប់ឈ្មោះធាតុ និងលក្ខណៈរួមនៃធាតុបានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម និងការ សម្របសម្រួលរបស់គ្រូ
- **ចរិយាសម្បទា (ជំនាញចិត្តចលករ, អន្តរបុគ្គល និងទំនួលខុសត្រូវ)៖** សិស្សមានសាមគ្គីភាពក្នុង ក្រុម និងពិភាក្សាដោះស្រាយបញ្ហាដោយបញ្ជ្រាប GCED

II. **សម្ភារឧបទេស**

-សៀវភៅសិក្សាគោល និងសៀវភៅគ្រូទំព័រ១៦-១៨ -ហ្វឺត និងបន្ទាត់

III. **វិធីសាស្ត្របង្រៀន៖** វិធីបង្រៀនតាមលំនាំគំរូ 5E (បញ្ជ្រាប GCED)

IV. **ដំណើរការបង្រៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| **ជំហានទី១៖ រដ្ឋបាលថ្នាក់រៀន ឬលំនឹងថ្នាក់** | | |
| -គ្រូពិនិត្យវត្តមាន អនាម័យ និងសណ្តាប់ធ្នាប់ក្នុងថ្នាក់រៀន | សិស្សរៀបចំបរិស្ថានថ្នាក់រៀន | -គោរពគ្រូពេលគ្រូដើរចូលថ្នាក់GCED |

| | | |
|---|---|---|
| | | -រៀបចំសណ្ដាប់ធ្នាប់ |
| **ជំហានទី២៖ រំលឹកមេរៀន** | | |
| -សិស្សតម្រូវឱ្យលេងល្បែងគណិតវិទ្យាមួយដែលគ្រូជាអ្នកសម្របសម្រួល | **ល្បែងលេខវេទមន្ត**<br>ចូរសរសេរលេខបួនខ្ទង់ផ្សេងៗគ្នា រួចប៉ាន់ចម្លើយនៃផលបូកលេខរួមដែលត្រូវសរសេរបន្តទៀត<br>ឧទាហរណ៍៖<br>១២៥៦ ចម្លើយ ២១២៥៤<br>៣៤៧៨( សិស្សសរសេរ )<br>៦៥២១ ( គ្រូសរសេរ )<br>៣៤៥៦ ( សិស្សសរសេរ )<br>៦៥៤៣ ( គ្រូសរសេរ )<br>បូកចូលគ្នា<br>១២៦៥ ចម្លើយ ២[illegible]៣៥៤<br>៣៤៧៨( សិស្សសរសេរ[illegible]២៦៣<br>៦៥២១ ( គ្រូសរសេរ )<br>៣៤៥៦ ( សិស្សសរសេរ )<br>៦៥៤៣ ( គ្រូសរសេរ )<br>បូកចូលគ្នា | សិស្សលេងល្បែងតាមការណែនាំរបស់គ្រូ |
| -ចូររកចំនួនគត់ដែលជាតួចែកនៃ 12<br>-ចូររកចំនួនគត់ដែលជាពហុគុណនៃ 5 ហើយតូចជាង 30 ។ | -តួចែក<br>-ពហុគុណ | -ចំនួនគត់ដែលជាតួចែកនៃ12 គឺ $\{1,2,3,4,6,12\}$ ។<br>-ចំនួនដែលជាពហុគុណនៃ 5 ហើយតូចជាង30គឺ $\{5,10,15,25\}$ |
| **ជំហានទី៣៖ ខ្លឹមសារមេរៀនថ្មី** | | |
| **១. ការចូលរួម**<br><br>បែងចែកសិស្សជាក្រុមដែលមានសមាជិក 5 នាក់ ដើម្បីសង្កេតលើសកម្មភាពសិក្សា<br><br>**២. ការរុករក**<br>ជួយក្រុមនីមួយៗធ្វើការពិភាក្សាលើសកម្មភាពសិក្សារបស់ខ្លួន | **សកម្មភាពទី១៖ ការកំណត់សញ្ញាណ**<br>ចូរជ្រើសរើសចំនួនគត់ចេញពីបញ្ជីប្រាក់ចំនួនពី 1$ ដល់100$ចូលក្នុងក្រុមខាងក្រោម<br>ក. ប្រាក់ដុល្លារជាចំនួនគត់សេស<br>ខ. ប្រាក់ដុល្លារជាចំនួនគត់គូ<br>គ. ប្រាក់ដុល្លារជាចំនួនបឋម<br>ឃ. ប្រាក់ដុល្លារជាតួចែកនៃ 60 ។<br>**ជំពូក១ តក្កវិទ្យា សំណុំ និងចំនួន**<br>**មេរៀនទី២ សំណុំ**<br>**២.១. សញ្ញាណសំណុំ**<br>**សំណុំកំណត់តាមការរៀបរាប់ឈ្មោះធាតុ**<br>ក. ប្រាក់ដុល្លារជាចំនួនគត់សេស<br>{1, 5}<br>ខ. ប្រាក់ដុល្លារជាចំនួនគត់គូ | **១. ការចូលរួម**<br><br>-ក្រុមទី១ ៖ ក. $ជាចំនួនគត់សេស<br>-ក្រុមទី២ ៖ ខ. $ជាចំនួនគត់គូ<br>-ក្រុមទី៣ ៖ គ. $ជាចំនួនបឋម<br>-ក្រុមទី៤ ៖ ឃ. $ជាតួចែកនៃ 60<br><br>**២. ការរុករក**<br>-ក្រុមទី១ ៖<br>ក. ប្រាក់ដុល្លារជាចំនួនគត់សេស<br>{1, 5} ឬ<br>$\{x \mid x$ ជាចំនួនគត់សេសតូចជាង $100\}$<br>-ក្រុមទី២ ៖<br>ខ. ប្រាក់ដុល្លារជាចំនួនគត់គូ<br>{2, 10, 20, 50, 100} ឬ |

| | | |
|---|---|---|
| **៣. ការពន្យល់**<br>ស្តាប់សិស្សពន្យល់ចម្លើយតាមក្រុមនីមួយៗនិងឱ្យសិស្សបង្ហាញអំពីមូលហេតុដែលចាំបាច់ ។<br><br>**៤. បញ្ជាក់លម្អិត**<br>គ្រូបញ្ជាក់បន្ថែម<br>- តើបណ្តុំនៃប្រាក់ដុល្លារជាចំនួន {1, 5}, {2, 10, 20, 50, 100}, {2, 5}, {1, 2, 5, 10, 20} ហៅថាអ្វី?<br>-ផ្តល់ការពន្យល់បន្ថែម<br>-តាមរយៈសកម្មភាពសិក្សា ចូរប្អូនឱ្យនិយមន័យសំណុំ ។<br>-តើសំណុំដែលគ្មានធាតុគេហៅថាជាអ្វី? | {2, 10, 20, 50, 100}<br>គ. ប្រាក់ដុល្លារជាចំនួនបឋម<br>{2, 5}<br>ឃ. ប្រាក់ដុល្លារជាតួចែកនៃ 60<br>{1, 2, 5, 10, 20}<br><br>-បណ្តុំនៃប្រាក់ដុល្លារជាចំនួនទាំងនេះ {1, 5}, {2, 10, 20, 50, 100}, {2, 5}, {1, 2, 5, 10, 20} **ហៅថាសំណុំ** ។<br><br>-សំណុំគឺជាបណ្តុំវត្ថុដែលកំណត់ដោយលក្ខខណ្ឌជាក់លាក់ ។ ចំនួនធាតុនៃសំណុំ $A$ គេកំណត់សរសេរដោយ $n(A)$ ។<br>-សំណុំទទេ តាងដោយ $\varnothing$ ឬ $\{\}$។ | $\{x \mid x$ ជាចំនួនគត់គូតូចជាងឬស្មើ $100\}$<br>-ក្រុមទី៣ ៖<br>គ. ប្រាក់ដុល្លារជាចំនួនបឋម<br>{2, 5} ឬ<br>$\{x \mid x$ ជាចំនួនបឋមតូចជាង$100\}$<br>-ក្រុមទី៤ ៖<br>ឃ. ប្រាក់ដុល្លារជាតួចែកនៃ 60<br>{1, 2, 5, 10, 20} ឬ<br>$\{x \mid x$ ជាតួចែកនៃ 60 តូចជាងឬស្មើ $60\}$<br>**៣. ការពន្យល់**<br>តំណាងក្រុមនីមួយៗពន្យល់ពីការរកឃើញរបស់ពួកគេ(សម្រាប់សំណួរនីមួយៗ) ទៅកាន់គ្រូនិងកែលម្អចម្លើយរបស់គេបើមើលឃើញថាជាការចាំបាច់<br><br>**៤. បញ្ជាក់លម្អិត**<br>-បណ្តុំនៃប្រាក់ដុល្លារជាចំនួនទាំងអស់ហៅថាសំណុំ ។<br><br>- សំណុំគឺជាបណ្តុំវត្ថុដែលកំណត់ដោយលក្ខខណ្ឌជាក់លាក់ ។ ចំនួនធាតុនៃសំណុំ $A$ គេកំណត់សរសេរដោយ $n(A)$។<br>-សំណុំទទេ |
| **ជំហានទី៤៖ ពង្រឹងចំណេះដឹង** | | |
| **៥. ការវាយតម្លៃ**<br>-ចែកលំហាត់ឱ្យសិស្សដោះស្រាយជាក្រុម<br>-ហៅសិស្សដំណាងក្រុមឡើងដោះស្រាយលើក្តារខៀន | **សកម្មភាពទី២៖ដោះស្រាយការបញ្ជ្រាប** GCED | **៥. ការវាយតម្លៃ**<br>សមាជិកក្រុមនីមួយៗឡើយដោះស្រាយប្រឡងប្រណាំង<br>Cambodia<br>Annual GDP 2022={$29,599M} |

<table>
<tr>
<td>-ចូរកំណត់សំណុំខាងក្រោមតាមការរៀបរាប់ឈ្មោះGDP រវាងប្រទេសកម្ពុជា និងប្រទេសឡាវ នៃក្រាហ្វិកខាងលើ។<br>-ចូរប្រៀបធៀបរវាងប្រទេសកម្ពុជា និងប្រទេសឡាវ។</td>
<td>
<br>-ចូរកំណត់សំណុំខាងក្រោមតាមការរៀបរាប់ឈ្មោះGDP រវាង ប្រទេសកម្ពុជា និងប្រទេសឡាវ នៃក្រាហ្វិកខាងលើ។<br>-ចូរប្រៀបធៀបរវាងប្រទេសកម្ពុជា និងប្រទេសឡាវ។</td>
<td>GDP per capital<br>2022={$1,765M}<br>Laos<br>Annual GDP 2022={$15,724M}<br>GDP per capital<br>2022={$2,118M}<br><br>តាមក្រាហ្វខាងលើ យើងឃើញថា GDP ប្រចាំឆ្នាំ ២០២២ របស់ប្រទេសកម្ពុជាមានចំនួន $29,599M ច្រើនជាងប្រទេសឡាវដែលមានចំនួន $15,724M និង GDP per capital ឆ្នាំ ២០២២ មានចំនួន $1,765M តិចជាង GDP per capital ឆ្នាំ ២០២២ ប្រទេសឡាវមានចំនួន $2,118M។</td>
</tr>
<tr>
<td colspan="3">ជំហានទី៥៖ កិច្ចការផ្ទះ និងបណ្តាំផ្ញើ</td>
</tr>
<tr>
<td>-ដាក់លំហាត់ទី១ទំព័រទី៣៣<br>-ចូរប្រៀបធៀប GDP រវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម<br>ឱ្យសិស្សធ្វើនៅផ្ទះនិងណែនាំសិស្សគោរពវិន័យនិងច្បាប់ចរាចរណ៍</td>
<td>-លំហាត់ទី១ ទំព័រទី៣៣<br>-ចូរប្រៀបធៀប GDP រវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម</td>
<td>-សិស្សគូសចំណាំលើលំហាត់និងលេខទំព័រ ស្តាប់ដំបូន្មានគ្រូ</td>
</tr>
</table>

# ប្រធានបទ៖ ការប្រើអនុគមន៍ដើម្បីដោះស្រាយបញ្ហា

ឈាន ហាង
វិទ្យស្ថានគរុកោសល្យបាត់ដំបង

កាលបរិច្ឆេទ៖ ថ្ងៃ............................ខែ........................ឆ្នាំ.......................ព.ស ២៥៦.....
ត្រូវនឹងថ្ងៃទី.................ខែ..................ឆ្នាំ ២០២..........
មុខវិជ្ជា៖ គណិតវិទ្យា
មេរៀន៖ ការប្រើអនុគមន៍ដើម្បីដោះស្រាយបញ្ហា
រយៈពេល៖ ០១ ម៉ោង

I. **វត្ថុបំណង៖** បន្ទាប់ពីសិក្សាមេរៀននេះចប់គរុនិស្សិតនឹង៖

- វិជ្ជាសម្បទា៖ ប្រាប់បានពីការជ្រើសរើសនៃការប្រើប្រាស់សេវាអិនធើណែតដោយផ្អែកលើទំនាក់ទំនងអនុគមន៍បានត្រឹមត្រូវតាមរយៈការគិតជាបុគ្គល និងពិភាក្សាក្រុម។
- បំណិនសម្បទា៖ ដោះស្រាយបញ្ហាការប្រើប្រាស់សេវាអិនធើណែតដោយផ្អែកលើទំនាក់ទំនងអនុគមន៍បានត្រឹមត្រូវតាមរយៈការគិតជាបុគ្គល និងពិភាក្សាក្រុម។
- ចរិយាសម្បទា៖ បណ្តុះស្មារតី ក្នុងការធ្វើការងារជាក្រុម ឬ ការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព ការទទួលខុសត្រូវនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ (GCED)

II. **សម្ភារៈបង្រៀន**

- ឯកសារ៖សៀវភៅ Gateway for the future MATH 2ទំព័រ74-77
- សម្ភារៈឧបទេស៖ បន្ទាត់ សន្លឹកកិច្ចការ

III. **វិធីសាស្ត្របង្រៀន**

- គោលវិធីសិស្សមជ្ឈមណ្ឌល
- វិធីសាស្ត្របង្រៀនបែបរិះរក ( IBL )ដោយបញ្ជ្រាបGCED
- ក្រុមពិភាក្សា បទបង្ហាញ

IV. **ដំណើរការបង្រៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| ជំហានទី១៖ រដ្ឋបាលថ្នាក់ ( ៣នាទី ) | | |

| | | |
|---|---|---|
| ១. ស្វាគមន៍ថ្នាក់ទាំងមូលៈ<br>- សួស្តីអ្នកទាំងអស់គ្នា!<br><br>២.ពិនិត្យមើលវត្តមានគរុនិស្សិតប្រុស និង ស្រី<br>- តើថ្ងៃនេះមានគរុនិស្សិតប្រុស ស្រីប៉ុន្មាននាក់?<br><br>៣. ពិនិត្យអនាម័យនៅក្នុងថ្នាក់ និងណែនាំជួយសម្អាតអនាម័យបរិស្ថាននៅក្នុងសង្គមរស់នៅ។(GCED) | - ស្វាគមន៍<br><br>- កំណត់ត្រាវត្តមានស្រី ប្រុស<br><br>- ប្រធានថ្នាក់រាយការណ៍ | ១.គរុនិស្សិតក្រោកឈរថ្នាក់ទាំងមូលឈរនិងទទួលស្វាគមន៍ៈ<br>- ជម្រាបសួរ!<br><br>២. ប្រធានថ្នាក់ឡើងរាយការណ៍ពីវត្តមានគរុនិស្សិតប្រុស ស្រីដែលអវត្តមានថ្ងៃនេះ។<br>៣-ត្រួតពិនិត្យបុគ្គល / ប្រធានថ្នាក់រាយការណ៍ក្រុមដែលទទួលបន្ទុកសម្អាតថ្នាក់រៀនថ្ងៃនេះដើម្បីចូលរួមចំណែកក្នុងការថែរក្សាអនាម័យបរិស្ថានសង្គម |
| ជំហានទី២ៈ រំឭកមេរៀន (៧នាទី) | | |
| ចូរដោះស្រាយបញ្ហាខាងក្រោមៈ<br>បើ $y$ ជាអនុគមន៍លីនេអ៊ែរនៃ $x$ ។ ក្រាបនៃអនុគមន៍ជាបន្ទាត់ប៉ះត្រង់ចំណុច $(-1,-4)$ និងកាត់ត្រង់ចំណុច $(3,8)$ ។ ចូររកអនុគមន៍លីនេអ៊ែរ។ | $y=3x-1$ | គរុនិស្សិតប្រុស ស្រី ឆ្លើយ $y=3x-1$ |
| ជំហានទី៣ៈ មេរៀនថ្មី (៣៥នាទី) | | |
| | មេរៀនៈការប្រើអនុគមន៍ដើម្បីដោះស្រាយបញ្ហា<br>**[សំណួរគន្លឹះ១]** | |

<table>
<tr>
<td rowspan="2">

**[សកម្មភាពទី១]**

[SP1] ក្រុមហ៊ុនទូរស័ព្ទបានផ្តល់ជូននូវគម្រោងនៃអត្រាដូចខាងក្រោម៖

<table>
<tr><th></th><th>ថ្លៃសេវ៉ាប្រចាំខែ</th><th>អត្រាប្រើនាទីដំបូង</th></tr>
<tr><td>គម្រោង A</td><td>3500 យ៉េន</td><td>30 យ៉េន</td></tr>
<tr><td>គម្រោង B</td><td>2000 យ៉េន</td><td>40 យ៉េន</td></tr>
</table>

គម្រោងប្រចាំខែ=ថ្លៃសេវ៉ាប្រចាំខែ+(អត្រាប្រើនាទីដំបូង× រយៈពេលខល)

តើរយៈពេលប៉ុន្មាននាទីនៃការហៅទូរស័ព្ទក្នុងមួយខែដែលនឹងធ្វើឱ្យ

គម្រោង A មានតម្លៃថោកជាងគម្រោង $B$ ?

</td>
<td>

តើប្អូនអាចជ្រើសរើសគម្រោងតម្លៃ(សេវ៉ាInternet)តាមគោលបំណងនៃការប្រើប្រាស់បានទេ?

</td>
<td rowspan="2">

-ដំបូងគិតជាលក្ខណៈបុគ្គល ហើយសរសេរចម្លើយដោយខ្លួនឯងនៅលើសៀវភៅកត់ត្រា។

-បន្ទាប់មកធ្វើការជាក្រុម

-ជាចុងបញ្ចប់ចែករំលែកយោបល់គ្នាទៅវិញទៅមក។ស្តាប់យោបល់របស់គ្រូហើយកត់ត្រាចូលក្នុងសៀវភៅ។

</td>
</tr>
<tr>
<td>

**[សកម្មភាពទី១]**

+វិធីសាស្ត្រ៖

តាង $y$ ជាប្រាក់យ៉េនជាការចំណាយប្រចាំខែ

$x$ ជានាទីនៃការហៅទូរស័ព្ទ

យើងប្រើអនុគមន៍លីនេអ៊ែរដើម្បីបង្ហាញពីទំនាក់ទំនងរវាង $x$ និង $y$ សម្រាប់គម្រោងនីមួយៗ បន្ទាប់មកយើងគូរក្រាហ្វ។

ដំណោះស្រាយ៖

តាង $y$ ប្រាក់យ៉េនជាថ្លៃដើមប្រចាំខែជាមួយនឹងពេលវេលានៃការហៅទូរស័ព្ទ។

យើងអាចបង្ហាញពីទំនាក់ទំនងរវាង $x$ និង $y$ ដូចនេះយើងបាន៖

គម្រោង $A$៖

$y=30x+3500\ (x\ge 0)\ (1)$

គម្រោង $B$៖

$y=40x+2000\ (x\ge 0)\ (2)$

ក្រាហ្វនៃអនុគមន៍និងត្រូវបានបង្ហាញខាងក្រោម៖

</td>
</tr>
</table>

**[សកម្មភាពទី២]**

គេបន្ថែមគម្រោង $C$ ជាអត្រាប្រែប្រួលនៃគម្រោងដូចខាងក្រោម៖

SP1.

| | ថ្លៃសេវា ប្រចាំខែ | អត្រាប្រើនាទីដំបូង |
|---|---|---|
| គម្រោង C | 9500 យ៉េន | 0 យ៉េន |




ក្រាហ្វបង្ហាញថាថ្លៃសេវាកម្មប្រចាំខែនៃគម្រោង $A$ មានតម្លៃថោកជាងគម្រោង $B$ បន្ទាប់ពីរយៈពេលនៃការហៅទូរស័ព្ទរយៈពេល ១៥០ នាទី។

**[សកម្មភាពទី២]**

ចំនួននាទីនៃការហៅទូរស័ព្ទក្នុងមួយខែដែលពួកគេនឹងធ្វើឱ្យគម្រោង C មានជម្រើសថោកបំផុតគឺ៖

ចំពោះគម្រោងC៖ $y = 9500$ yen

ប៉ុន្តែតាម (1) $y = 30x + 3500$

$\Rightarrow 9500 = 30x + 3500$

$\Rightarrow x = 200$ នាទី

ចំពោះ (2) $y = 40x + 2000$

$\Rightarrow 9500 = 40x + 2000$

$\Rightarrow x = 187.5$ នាទី

**[សកម្មភាពទី៣]**

+តារាងចំពោះគម្រោង A, B និង C

-ដំបូងគិតជាលក្ខណៈបុគ្គល ហើយសរសេរចម្លើយដោយខ្លួនឯងនៅលើសៀវភៅកត់ត្រា។

-បន្ទាប់មកធ្វើការជាក្រុម

-ជាចុងបញ្ចប់ចែករំលែកយោបល់គ្នាទៅវិញទៅមក។ស្តាប់យោបល់របស់គ្រូហើយកត់ត្រាចូលក្នុងសៀវភៅ។

-ដំបូងគិតជាលក្ខណៈបុគ្គល ហើយសរសេរ

តើរយៈពេលប៉ុន្មាននាទីនៃការហៅទូរស័ព្ទក្នុងមួយខែនឹងធ្វើឱ្យគម្រោង C ក្លាយជាជម្រើសថោកបំផុត?

**[សកម្មភាពទី៣]**

ចំពោះគម្រោង (A, B, C) ចូរសង់តារាង និងក្រាហ្វនៃការហៅចេញ និងប្រើតម្លៃនេះដើម្បីបង្កើតជាអនុគមន៍ បន្ទាប់មកសូមគិតអំពីវិធីពន្យល់ដល់អតិថិជនអំពីគម្រោងគ្រប់ប្រភេទ។

| | ថ្លៃសេវាប្រចាំខែ | អត្រាប្រើនាទីដំបូង |
|---|---|---|
| គម្រោង A | 3500 យ៉េន | 30 យ៉េន |
| គម្រោង B | 2000 យ៉េន | 40 យ៉េន |
| គម្រោង C | 9500 យ៉េន | 0 យ៉េន |

+ក្រាហ្វចំពោះនសគម្រោង A, B និង C




ផ្អែកលើក្រាហ្វបានបង្ហាញថា៖

+ គម្រោង*A*៖ ចំនួននៃការហៅទូរស័ព្ទនាទីប្រើតិចជាងថ្លៃសេវាប្រចាំខែ។

+ គម្រោង*B*៖ ចំនួននៃការហៅទូរស័ព្ទប្រើនាទីពី 200 នាទីថ្លៃប្រចាំខែតិចជាងគម្រោង*A*។

+ គម្រោង*C*៖ បើយើងប្រៀបធៀបគម្រោង *C* រវាងគម្រោង *A* និង *B* យើងឃើញថាគម្រោង *C* គឺថោកជាងគម្រោង *A* និង *B* ។

ចម្លើយដោយខ្លួនឯងនៅលើសៀវភៅកត់ត្រា។

-បន្ទាប់មកធ្វើការជាក្រុម

-ជាចុងបញ្ចប់ចែករំលែកយោបល់គ្នាទៅវិញទៅមក។ស្តាប់យោបល់របស់គ្រូហើយកត់ត្រាចូលក្នុងសៀវភៅ។

| | | |
|---|---|---|
| • ក្រោយពីសិក្សាអនុគមន៍លីនេអ៊ែរខាងលើតើប្អូនចូលរួមចំណែកក្នុងការណែនាំដល់សិស្ស មិត្តភក្តិ បងប្អូនយ៉ាងដូចម្តេចក្នុងការជ្រើសរើសសៅ៉អិនធើណេតក្នុងការប្រើប្រចាំថ្ងៃ? **(GCED)** | • ឱ្យគិតពីការចំណាយតិច ឬច្រើនក្នុងសេវ៉ាអិនធើណែត<br>• ជៀសវាងការជ្រើសរើសសេវ៉ាប្រព័ន្ធអិនធើណែតខុស<br>• | • គរុនិស្សិតពិភាក្សាគ្នារួចឆ្លើយ<br>• .......... |
| ជំហានទី៤៖ ពង្រឹងពុទ្ធិ (១០នាទី) | | |
| 1.តើអ្វីជាអនុគមន៍លីនេអ៊ែរ? | 1-អនុគមន៍លីនេអ៊ែរជាប្រភេទនៃកន្សោមដែលមានទម្រង់៖ $y=ax+b$ ដែល $a$ និង $b$ ជាចំនួនថេរ<br><br>2.គេប្រើអនុគមន៍លីនេអ៊ែរដើម្បី៖<br>-កាត់បន្ថយចំណាយលើការប្រើប្រាស់សេវ៉ាអិនធើណែត | - ធ្វើរៀងៗខ្លួន<br>- ស្តាប់ការពន្យល់របស់គ្រូ និងចែក រំលែកគំនិតសំខាន់ៗ។<br>- កត់ត្រាទុកចូលក្នុងសៀវភៅនូវ គំនិតសំខាន់ៗទាំងនោះ។ |

| | | |
|---|---|---|
| **2.តើគេប្រើអនុគមន៍លីនេអ៊ែរដើម្បីជួយជាប្រយោជន៍អ្វីខ្លះដល់ប្រជាជនក្នុងការជ្រើសរើសប្រព័ន្ធអិនធើណែត? (GCED)** | -ការសម្រេចចិត្តក្នុងជ្រើសរើសប្រើប្រព័ន្ធទូរស័ព្ទ<br>-សារៈប្រយោជន៍នៃការប្រើប្រាស់អនុគមន៍<br>-... | |
| ជំហានទី៥៖ បណ្ដាំផ្ញើ (៥នាទី) | | |
| - ចូរប្អូនទៅផ្ទះវិញធ្វើលំហាត់ទំព័រ៨០<br>-តើក្រៅពីការប្រើប្រាស់ប្រព័ន្ធអិនធើណែតគេអាចយកទៅអនុវត្តអ្វីខ្លះដើម្បីជាប្រយោជន៍ប្រជាជន? | | - ស្ដាប់ដោយយកចិត្តទុកដាក់ និងកត់ត្រា<br>-ជំរាបលា! |

## សន្លឹកកិច្ចការ

### អនុគមន៍៖ ការដោះស្រាយបញ្ហាដោយប្រើអនុគមន៍

[**សំណួរគន្លឹះ**]

តើអ្នកអាចជ្រើសរើសគម្រោងតម្លៃសេវាអិនធើណែតតាមគោលបំណងនៃការប្រើប្រាស់បានទេ?

[**ប្រធានបទថ្ងៃនេះ**]

⊕ បញ្ហាជាមួយនឹងការគិតថ្លៃតាមទូរស័ព្ទ

**រំឭកមេរៀន៖** $y$ ជាអនុគមន៍លីនេអ៊ែរនៃ $x$ ។ ក្រាបនៃអនុគមន៍ជាបន្ទាត់ប៉ះត្រង់ចំណុច $(-1,-4)$ និងកាត់ត្រង់ចំណុច $(3,8)$ ។ ចូររកអនុគមន៍លីនេអ៊ែរ។

[សកម្មភាពទី១]

SP1 ក្រុមហ៊ុនទូរស័ព្ទផ្ដល់ជូននូវគម្រោងនៃអត្រាដូចខាងក្រោម៖

| | ថ្លៃសេវាប្រចាំខែ | អត្រាប្រើនាទីដំបូង |
|---|---|---|
| គម្រោង A | 3500 យ៉េន | 30 យ៉េន |

| | | |
|---|---|---|
| គម្រោង B | 2000 យ៉េន | 40 យ៉េន |

គម្រោងប្រចាំខែ=ថ្លៃសេវាប្រចាំខែ+(អត្រាប្រើនាទីដំបូង× រយៈពេលខល)

តើរយៈពេលប៉ុន្មាននាទីនៃការហៅទូរស័ព្ទក្នុងមួយខែដែលនឹងធ្វើឱ្យគម្រោងAមានតម្លៃថោកជាងគម្រោង $B$ ?

**[សកម្មភាពទី២] គេបន្ថែមគម្រោង $C$ ជាអត្រាប្រែប្រួលនៃគម្រោងដូចខាងក្រោម៖**

SP1.

| | ថ្លៃសេវាប្រចាំខែ | អត្រាប្រើនាទីដំបូង |
|---|---|---|
| គម្រោង C | 9500 យ៉េន | 0 យ៉េន |

តើរយៈពេលប៉ុន្មាននាទីនៃការហៅទូរស័ព្ទក្នុងមួយខែនឹងធ្វើឱ្យគម្រោង C ក្លាយជាជម្រើសថោកបំផុត?

**[សកម្មភាពទី៣]**

ចំពោះគម្រោង (A, B, C) ចូរសង់តារាង និងក្រាហ្វនៃការហៅចេញ និងតម្លៃនៃការប្រើដើម្បីបង្កើតជាអនុគមន៍ បន្ទាប់មកសូមគិតអំពីវិធីក្នុងពន្យល់ដល់អតិថិជនអំពីគម្រោងការគ្រប់ប្រភេទ។

# ប្រធានបទៈ កត្តាជះឥទ្ធិពលលើល្បឿនប្រតិកម្ម

ប៉ែន សំភា
វិទ្យាស្ថានជាតិអប់រំ

កាលបរិច្ឆេទ ៖ ថ្ងៃ.........ខែ........ឆ្នាំ.......ព.ស ២៥៦.........
ត្រូវនឹងថ្ងៃទី ..........ខែ.......ឆ្នាំ២០២...........

**ជំពូក១** **៖ ស៊ីនេទិចគីមី**
**មេរៀនទី២** ៖ កត្តាជះឥទ្ធិពលលើល្បឿនប្រតិកម្ម
១. ទំហំភាគល្អិត
**រយៈពេល** ៖ ៥០ នាទី

## ១. លទ្ធផលរំពឹងទុក

ក្រោយរៀនចប់ចំណុចខាងលើ សិស្សមានសមត្ថភាព

- **វិជ្ជាសម្បទា** : ពន្យល់បានច្បាស់លាស់ ពីការប្រែប្រួលផ្ទៃប៉ះរបស់ភាគល្អិត នៅពេលគេវាយបំបែកពីទំហំធំទៅទំហំតូច។
- **បំណិនសម្បទា** : ប្រៀបធៀបល្បឿនប្រតិកម្មអាស្រ័យនឹងទំហំភាគល្អិតបានត្រឹមត្រូវតាមរយៈសំណួរបំផុស។
- **ចរិយាសម្បទា** : សហការណ៍គ្នា ពិភាក្សាតាមការចាត់តាំងរបស់គ្រូ និងចែករំលែកចំណេះដឹងទទួលបាន យកទៅអនុវត្តក្នុងជីវភាពប្រចាំថ្ងៃ។

## ២. សម្ភារឧបទេស

- សន្លឹកកិច្ចការ "ឥទ្ធិពលទំហំភាគល្អិតអង្គធាតុប្រតិករលើល្បឿនប្រតិកម្ម"
- សីរ៉ាំង ធ្នុកកៅស៊ូ កែវអេកឡែន កែវបេស៊ែ ស៊ីឡាំងក្រិត នាឡិកាក្រិត
- សូលុយស្យុងអាស៊ីត HCl : 0.5 M មាឌ 100 mL
- សំបកលៀសដុំធំ និងសំបកលៀសដុំតូចៗ
- សៀវភៅគោលបោះពុម្ពឆ្នាំ ២០១៣ ទំព័រ ៨ ដល់ ១០
- សៀវភៅគ្រូ បោះពុម្ពឆ្នាំ ២០១១ ទំព័រ ៨ ដល់ ១០

## ៣. វិធីសាស្ត្របង្រៀនៈ

វិធីបង្រៀន និងរៀនតាមបែបរិះរក ដោយបញ្ជ្រាប GCED

## ៤. ដំណើរនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|

| | | |
|---|---|---|
| - សួរសុខទុក្ខ(GCED)<br>- ពិនិត្យសណ្តាប់ធ្នាប់<br>- វត្តមាន អវត្តមាន<br>- អនាម័យ | **ជំហានទី១**<br>រដ្ឋបាលថ្នាក់ (២នាទី) | - ក្រោកឈរ<br>- អង្គុយចុះដោយមាន សណ្តាប់ធ្នាប់ |
| - លើកយកសំណួរទាក់ទងបាតុភូតក្នុងជីវភាពប្រចាំថ្ងៃមកឱ្យសិស្សទាំងអស់គ្នាគិត។<br>នៅពេលយើងយកថ្នាំវីតាមីន C មកដាក់ក្នុងទឹក យើងសង្កេតឃើញគ្រាប់ថ្នាំរលាយក្នុងទឹក និងឃើញមានពពុះកើតឡើង យើងនាំគ្នានិយាយថា លំនាំបែបនេះជាប្រតិកម្មគីមី។<br>សំណួរ<br>១. តើអ្វីទៅជា ប្រតិកម្មគីមី?<br>គ្រូបន្ថែម៖ តើការដាក់វត្ថុពីរឱ្យ ប៉ះទង្គិចគ្នា សុទ្ធតែមានប្រតិកម្មកើតឡើងឬ? គេតែង និយាយថា ទង្គិចមានពីរ គឺទង្គិចឥតបានការ និងទង្គិចប្រសិទ្ធ។ | **ជំហានទី២**<br>**រំឭកមេរៀនចាស់ (៧ នាទី)**<br>១. **ប្រតិកម្មគីមី** ជាការបំលែងពីអង្គធាតុមួយ ទៅជាអង្គធាតុថ្មីមួយផ្សេងទៀត។ ឬជាការប៉ះទង្គិចរវាងភាគល្អិតពីរ ឬច្រើន ដែលនាំឱ្យមានការបែកបាក់<br>សម្ព័ន្ធគីមីចាស់ និងបង្កើតសម្ព័ន្ធគីមីថ្មី | -សិស្សគិតរក ចម្លើយ |

| | | |
|---|---|---|
| ២. ក្នុងប្រតិកម្មគីមីមួយ តើអ្វីទៅជាទង្គិចប្រសិទ្ធ ?<br><br>- សំណួរភ្ជាប់ខ្លឹមសារមេរៀនថ្មី ៖ តើដើម្បីឱ្យប្រតិកម្មមួយ កាន់តែលឿន ឬកាន់តែយឺត យើងគួរធ្វើរបៀបណា ? ថ្ងៃនេះយើងនឹងសិក្សាកត្តាមួយដែល មានឥទ្ធិពលលើល្បឿនប្រតិកម្ម។ | ២. **ទង្គិចប្រសិទ្ធ** គឺជាការប៉ះទង្គិចណាដែលមានកម្លាំងទង្គិចខ្លាំងគ្រប់គ្រាន់<br>បណ្ដាលឱ្យមានប្រតិកម្មកើតឡើង។ | |
| .គ្រូចែកសន្លឹកកិច្ចការ " ឥទ្ធិពលទំហំភាគល្អិតអង្គធាតុប្រតិករលើល្បឿនប្រតិកម្ម" ដល់សិស្ស ដើម្បីពិភាក្សា<br>តាមក្រុម។<br>. បែងចែកក្រុមពិភាក្សា ១ក្រុម មានគ្នា ៤ នាក់។<br>(សកម្មភាពនេះ គ្រូបញ្ជ្រាបភាពជាពលរដ្ឋសកល តាមរយៈការណែនាំសិស្សធ្វើការជាក្រុម ការចេះស្ដាប់យោបល់សមាជិកក្រុម ការចេះធ្វើការងារតាមការចាត់តាំងរបស់ប្រធានក្រុម GCED) | **ជំហានទី៣**<br>មេរៀនប្រចាំថ្ងៃ (៣៥ នាទី)<br>**មេរៀនទី២: កត្តាជះឥទ្ធិពលលើល្បឿនប្រតិកម្ម**<br>១. ទំហំភាគល្អិត<br>**សន្លឹកកិច្ចការ**<br>**" ឥទ្ធិពលទំហំភាគល្អិតអង្គធាតុប្រតិករលើល្បឿនប្រតិកម្ម"**<br><br> | . សិស្សទទួលយកសន្លឹកកិច្ចការ និងបែងចែក ជា ក្រុម ២ ទៅ៣ នាក់ដើម្បី ពិភាក្សា លើសំណួរក្នុងសន្លឹកកិច្ចការ។ |

| | | |
|---|---|---|
| .គ្រូបំផុសសំណួរម្ដងមួយៗ<br>**សង្កេត** ៖ គេមានដុំសាប៊ូ A មួយរាងគូប មានជ្រុងប្រវែង 1cm ។<br>ក. ចូរគណនាផ្ទៃមុខសរុបរបស់សាប៊ូ(រាងគូប)។<br><br>ខ. ប្រសិនបើគេកាត់សាប៊ូជាពីរចំណែកស្មើគ្នា គេបានដុំសាប៊ូ $A_1$ និង $A_2$ ។ ចូរគណនាផ្ទៃមុខសរុបរបស់សាប៊ូទាំងពីរដុំ។<br><br>.គ្រូលើកឡើងពីសំណួរគន្លឹះ | ក. ផ្ទៃមុខសរុបរបស់សាប៊ូ<br>1 ផ្ទៃមុខ = 1 $cm^2$<br>សរុបទាំងអស់ 6 ផ្ទៃមុខ = 1 $cm^2$ x 6<br>= 6 $cm^2$<br>ខ. ប្រសិនបើគេកាត់សាប៊ូជាពីរចំណែកស្មើគ្នា គេបានដុំសាប៊ូ $A_1$ និង $A_2$ ។<br>យើងសង្កេតឃើញថា ស្នាមកាត់ថ្មី បង្កើតផ្ទៃមុខ ឬផ្ទៃប៉ះថ្មី ដែលនៅ ដុំ $A_1$ មានទំហំផ្ទៃប៉ះថ្មី 1$cm^2$ និងនៅដុំ $A_2$ ក៏មានទំហំផ្ទៃប៉ះថ្មី 1$cm^2$ ដែរ។<br>ផ្ទៃប៉ះសរុបរបស់ = ផ្ទៃប៉ះចាស់ + ផ្ទៃប៉ះថ្មី<br>= 6 $cm^2$ + 2 $cm^2$<br>= 8 $cm^2$<br>១. **សំណួរគន្លឹះ** "តើក្នុងករណីម៉ាសស្មើគ្នា អង្គធាតុប្រតិករមានទំហំភាគល្អិតខុសគ្នា ធ្វើប្រតិកម្មក្នុងល្បឿនដូចគ្នាដែរឬទេ?" | . សិស្សពិភាក្សាគ្នាតាមក្រុម និងគណនារកផ្ទៃមុខ ឬផ្ទៃប៉ះ<br><br>. សិស្សសាកល្បងឆ្លើយ |

| | | |
|---|---|---|
| . បន្ទាប់មក ទុកពេលឱ្យសិក្ខាកាមសាកល្បងឆ្លើយ ទៅលើសំណួរគន្លឹះ (ការបង្កើតសម្មតិកម្ម)<br><br>. គ្រូទុកពេលឱ្យសិស្ស រៀបចំផែនការពិសោធ ដោយ គិតទៅលើ សម្ភារៈចាំបាច់ និងសមស្របសម្រាប់ពិសោធ និង ដំណើរការពិសោធ។<br><br>. គ្រូសម្របសម្រួល ផែនការពិសោធ របស់ក្រុមនីមួយៗ<br>និងបន្ទាប់មករៀបចំឱ្យសិស្សធ្វើពិសោធ។ | **២. ការបង្កើតសម្មតិកម្ម** :<br>- ក្នុងករណីម៉ាសស្មើគ្នា អង្គធាតុប្រតិករមានទំហំតូច ចូលរួមប្រតិកម្ម ក្នុងល្បឿនលឿនជាងអង្គធាតុប្រតិករមានទំហំធំ។<br>- ក្នុងករណីម៉ាសស្មើគ្នា អង្គធាតុប្រតិករមានទំហំតូច ចូលរួមប្រតិកម្ម ក្នុងល្បឿនយឺតជាងអង្គធាតុប្រតិករមានទំហំធំ។<br>- ក្នុងករណីម៉ាសស្មើគ្នា អង្គធាតុប្រតិករមានទំហំតូច ចូលរួមប្រតិកម្ម ក្នុងល្បឿនស្មើគ្នា ធៀបអង្គធាតុប្រតិករមានទំហំធំ។<br><br>**៣ .ផែនការពិសោធ** (ដើម្បីបញ្ជាក់ថា សម្មតិកម្ម ឬចម្លើយសាកល្បង ដែលបានបង្កើត ត្រូវឬ ខុស តើយើងគួរធ្វើពិសោធបែបណាដើម្បីរកការពិត?)<br>សម្ភារ (ឧបករណ៍ និង សារធាតុគីមី)<br> | . សិស្សលើកឡើងនូវសំណួរផ្សេងទៀត<br><br>. សិស្សពិភាក្សាគ្នា រកមើល<br>សម្ភារៈ និងសារធាតុគីមីដែលសមស្របសម្រាប់ធ្វើពិសោធ។<br>. គូសរូប ប្លង់ពិសោធ ទៅតាមគំនិតតាមក្រុម<br><br>. សិស្ស រៀបចំសម្ភារៈ និង ស្តាប់ការណែនាំ របស់គ្រូ |

| | | |
|---|---|---|
| | - សូលុយស្យុងអាស៊ីត HCl : 0.5 M<br>- សំបកលៀសដុំធំ និង សំបកលៀសដុំតូចៗ<br><br>ដំណើរការ<br>1. យកសីរ៉ាំងញាត់ចូលរន្ធឆ្នុកជ័រឱ្យជាប់មាំ<br>2 .ប្រើស៊ីឡាំងក្រិត វាល់សូលុយស្យុងអាស៊ីត 30mL ដាក់ចូលក្នុងកែវអែឡិន<br>3 .យកសំបកលៀសដុំតូច 3.0g រួច ត្រៀមនាឡិកាក្រិតដើម្បីផ្តើមប្រតិកម្ម<br>4 .ដាក់សំកលៀសដុំតូច ចូលក្នុងកែវអែឡិន រួចយកឆ្នុកដែលមានភ្ជាប់សីរ៉ាំងចុកភ្លាម (ព្រមទាំងចាប់ផ្តើមចុចនាឡិកាក្រិតភ្លាម)<br>5 .កត់ត្រាមាឌឧស្ម័ន ដែលទទួលបានក្នុងរយៈពេល ២ នាទី។<br>6. ធ្វើដូចដំណាក់កាលទី 2 ដល់ទី 5. ដែរចំពោះសំបកលៀសដុំធំ។<br><br>**៤. ការសង្កេត និងលទ្ធផល** | . សិស្សអនុវត្តពិសោធ សង្កេត និងកត់ត្រាលទ្ធផល |

| | |
|---|---|
| មាឌឧស្ម័នបានពីប្រតិកម្មទី១ (សំបកលៀសដុំតូច) | 70 $cm^3$ |
| មាឌឧស្ម័នបានពីប្រតិកម្មទី២ (សំបកលៀសដុំធំ) | 16 $cm^3$ |

| | | |
|---|---|---|
| | **៥. សំណួរពិភាក្សា និងសេចក្តីសន្និដ្ឋាន** | |

| | | |
|---|---|---|
| | *ក. ចូរគណនាល្បឿនមធ្យមកំណើ $CO_2$ ក្នុង ចន្លោះពេល $t_1 = 0\ min$ និង $t_2 = 2\ min$ គិតជា $cm^3/s$*<br><br>(i) ក្នុងប្រតិកម្មទី១ (សំបកលៀសដុំតូច)<br>$V_m(CO_2)_{t1,t2} = \frac{\Delta(V_{CO_2})}{\Delta t} = \frac{70cm^3}{2min} = 35cm^3/min$<br><br>(ii) ក្នុងប្រតិកម្មទី២ (សំបកលៀសដុំធំ) :<br>$V_m(CO_2)_{t1,t2} = \frac{\Delta(V_{CO_2})}{\Delta t} = \frac{16cm^3}{2min} = 8cm^3/min$<br><br>ខ. *តាមរយៈលទ្ធផលនៃការពិសោធ តើយើងអាចឆ្លើយទៅនឹង សំណួរគន្លឹះខាងលើបានយ៉ាងដូចម្ដេច?*<br>ក្នុងករណីម៉ាសស្មើគ្នា អង្គធាតុប្រតិករមានទំហំភាគល្អិតតូច មានប្រតិកម្មក្នុងល្បឿនលឿនជាងអង្គធាតុប្រតិករដែលមានទំហំភាគល្អិតធំជាង។<br><br>គ. *ក្នុងករណីអង្គធាតុរឹងពីរ* មានម៉ាសស្មើគ្នា *អង្គធាតុរឹងដែលមានទំហំតូចជាង មានផ្ទៃប៉ះ* .ធំជាង.*(តូចជាង/ធំជាង)អង្គធាតុរឹងដែលមានទំហំធំ។ កាលណាអង្គធាតុរឹងមានផ្ទៃប៉ះធំជាង នោះមានចំនួនង្គិចប្រសិទ្ធ*<br>..ច្រើនជាង..*(តិចជាង/ច្រើនជាង)។ ប្រតិកម្មមួយដែលមានចំនួនទង្គិច*<br>*ប្រសិទ្ធច្រើនជាង នោះប្រតិកម្មមានល្បឿន* ..លឿន...*(យឺត/លឿន)ជាង។* | . សិស្សពិភាក្សាក្នុងក្រុម ឆ្លើយសំណួរ និងធ្វើការសន្និដ្ឋាន |

| | | |
|---|---|---|
| | **ជំហានទី៤**<br>ពង្រឹងពុទ្ធិ ( ៨ នាទី ) | |
| គ្រូលើកឧទាហរណ៍ ប្រតិកម្មពីរ មកសួរសិស្ស៖<br>តើខ្សែកោងខាងក្រោមមួយណា ត្រូវនឹងប្រតិកម្មក្នុងកែវ A? និង មួយណាត្រូវនឹងប្រតិកម្ម ក្នុងកែវ B? | - គេមានប្រតិកម្មពីរ គឺក្នុងកែវ A និងកែវ B | សិស្សគិតរកចម្លើយ ទាក់ទងនឹងប្រតិកម្ម។ |










| | | |
|---|---|---|
| **( សំណួរទាក់ទងភាពជាពលរដ្ឋសកល គឺចែករំលែកចំណេះដឹងទទួលបាន ទៅអនុវត្តក្នុងជីវភាពរស់នៅ GCED )**<br>- ក្នុងជីវភាពរស់នៅ ក៏ដូចជាក្នុងឧស្សាហកម្ម តើមានលំនាំណាខ្លះដែលយើងអនុវត្តដោយប្រើប្រាស់ | - ល្បឿនប្រតិកម្មក្នុងកែវA ត្រូវនឹងខ្សែកោងលេខ (2) និងល្បឿនប្រតិកម្មក្នុងកែវ B ត្រូវនឹងខ្សែកោងលេខ (1)។<br>- ការកិនថ្នាំឱ្យម៉ដ្ឋមុននឹងឱ្យកូនក្មេងញ៉ាំ | |

| | | |
|---|---|---|
| ចំណេះដឹងទាក់ទងនឹងទំហំភាគល្អិត? | - ការប្រើប្រាស់អំបិលម៉ដ្ឋ ជាជាងប្រើអំបិលគ្រួសក្នុងការប្រឡាក់សាច់។<br>- ក្នុងឧស្សាហកម្មគីមី អគ្គិសនីវិភាគ គេប្រើបន្ទះតូចៗឆ្លាស់គ្នាច្រើនបន្ទះដើម្បីបង្កើនផ្ទៃប៉ះ ឱ្យប្រតិកម្មប្រព្រឹត្តទៅលឿនចំណេញពេល។ | សិស្សគិតរកចម្លើយ ទាក់ទងនឹងសកម្មភាពប្រចាំថ្ងៃ ដែលអនុវត្តដោយគិតទៅលើទំហំភាគល្អិត។ |
| ដាក់សំណួរឱ្យសិស្សយកទៅគិតឆ្លើយនៅផ្ទះ | **ជំហានទី៥**<br>**កិច្ចការផ្ទះ ( ៣នាទី )**<br>សំណួរៈ យើងបានសិក្សារួចមកហើយថា ទំហំភាគល្អិតរបស់អង្គធាតុប្រតិករ អាចមានឥទ្ធិពលលើល្បឿនប្រតិកម្ម។ តើមានកត្តាអ្វីខ្លះទៀតដែលមានឥទ្ធិពលដល់ល្បឿនប្រតិកម្ម? | សិស្សកត់ត្រាសំណួរយកទៅដោះស្រាយរកចម្លើយ នៅផ្ទះ។ |

## សន្លឹកកិច្ចការ

### " ឥទ្ធិពលទំហំភាគល្អិតអង្គធាតុប្រតិករលើល្បឿនប្រតិកម្ម"

**សង្កេត ៖** គេមានដុំសាប៊ូ A មួយរាងគូប មានជ្រុងប្រវែង 1cm ។




ក. ចូរគណនាផ្ទៃមុខសរុបរបស់សាប៊ូ ។ ……………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

ខ. ប្រសិនបើគេកាត់សាប៊ូជាពីរចំណែកស្មើគ្នា គេបានដុំសាប៊ូ $A_1$ និង $A_2$ ។
ចូរគណនាផ្ទៃមុខសរុបរបស់សាប៊ូទាំងពីរដុំ ។

……………………………………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

គ.ទាក់ទងនឹងប្រតិកម្មគីមី បើគេយកអង្គធាតុ A ឱ្យមានប្រតិកម្មជាមួយសូលុយស្យុង S និងមួយទៀត គេយកអង្គធាតុ $A_1 + A_2$ ឱ្យមានប្រតិកម្មជាមួយសូលុយស្យុង S ដែរ តើល្បឿនប្រតិកម្មប្រព្រឹត្តទៅដូចគ្នាដែរឬទេ ?

១. **សំណួរគន្លឹះ:** "តើក្នុងករណីម៉ាសស្មើគ្នា អង្គធាតុប្រតិករមានទំហំភាគល្អិតខុសគ្នា ធ្វើប្រតិកម្មក្នុងល្បឿនដូចគ្នាដែរឬទេ ?"

២. **ការបង្កើតសម្មតិកម្ម** : ( ចូរសាកល្បងឆ្លើយសំណួរគន្លឹះខាងលើ )

……………………………………………………………………………………………

……………………………………………………………………

……………………………………………………………………………………………

……………………………………………………………………

……………………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………

៣. ផែនការពិសោធ (ដើម្បីបញ្ជាក់ថាសម្មតិកម្ម ឬចម្លើយសាកល្បង ដែលបានបង្កើត ត្រូវឬ ខុស តើយើងគួរធ្វើពិសោធបែបណាដើម្បីរកការពិត?)

សម្ភារ (ឧបករណ៍ និង សារធាតុគីមី)

……………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………………………………………

…………………………………………………………………….

ដំណើរការ

……………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………………………………………

…………………………………………………………………………………………………………………

## ៤. ការសង្កេត និងលទ្ធផល

……………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

…………………………………

## ៥. សំណួរពិភាក្សា និងសេចក្តីសន្និដ្ឋាន

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………… ។

# ប្រធានបទ៖ ថ្មពិលអេឡិចត្រូគីមី

ផេង សារ៉ាយ
វិទ្យាស្ថានគរុកោសល្យបាត់ដំបង

កាលបរិច្ឆេទ៖ ថ្ងៃ..........................ខែ....................ឆ្នាំ....................ព.ស.២៥៦...
ត្រូវនឹងថ្ងៃ........................ខែ....................ឆ្នាំ២០២...

មុខវិជ្ជា គីមីវិទ្យា
រយៈពេល ៦០នាទី
ជំពូកទី៣ អុកស៊ីតកម្ម រេដុកម្ម និងអេឡិចត្រូគីមី
មេរៀនទី៤ ថ្មពិលអេឡិចត្រូគីមី

៣. អាគុយ

៣. ១ អាគុយសំណ

ទំព័រ៖ ៩៧-៩៨

## I. វត្ថុបំណង

- **វិជ្ជាសម្បទា(ចំណេះដឹង)៖** ពណ៌នាអំពីជាតុបង្គុ ព្រមទាំងដំណើរការពេលអាគុយសំណាផ្ទេរ និងផ្ទុកបានត្រឹមត្រូវ តាមរយៈ រូបភាពដែលគ្រូបង្ហាញ និងការពិភាក្សាក្រុម។
- **បំណិនសម្បទា៖** បកស្រាយប្រតិកម្មគីមីដែលកើតមាននៅលើផ្លាកទាំងពីរនៃអាគុយសំណនៅពេលវាផ្ទេរ និងផ្ទុកតាមរយៈការពិភាក្សាក្រុម។
- **ចរិយាសម្បទា៖** បណ្ដុះស្មារតីឱ្យសិស្សមានការបម្រុងប្រយ័ត្ននៅពេលប្រើប្រាស់ នឹងថែរក្សាអាគុយដើម្បីឱ្យប្រើប្រាស់បានយូរព្រមទាំងយល់ដឹងពីផលប៉ះពាល់ដល់បរិស្ថាននិងសុខភាពសាធារណៈ។

## II. ខ្លឹមសារមេរៀន

### ៣. អាគុយ

### ៣.១. អាគុយសំណ (សៀវភៅគីមីថ្នាក់ទី១១ទំព័រទី ៩៧ ដល់ ៩៨)

#### ក. ពណ៌នា

អាគុយសំណមានគូរេដុកអាណូត (-) $Pb^{2+}/Pb$ កាតូត(+) $PbO_2/Pb^{2+}$ ដែលមានអេឡិចត្រូលីត សូលុយស្យុង $H_2SO_4$ កំហាប់ 6mol/L។






## ខ. ដំណើរការជាជនិតា ឬបន្ទេរអាគុយ




ពេលអាគុយដំណើរការជាជនិតា ឬអាគុយផ្ទេរ គឺជាប្រតិកម្មអុកស៊ីដូរេដុកម្មស្របវិធានកាម៉ាក្នុងមជ្ឈដ្ឋានអាស៊ីត ដែលបំលែងថាមពលគីមីទៅជាថាមពលអគ្គិសនី។

ផ្លាកវិជ្ជមាន(+)៖ $PbO_2 + 4H^+ + 2e^- \rightarrow Pb^{2+} + 2H_2O$

ផ្លាកអវិជ្ជមាន(-)៖ $Pb \rightarrow Pb^{2+} + 2e^-$

សមីការតុល្យការ៖ $PbO_2 + 4H^+ + Pb \rightarrow 2Pb^{2+} + 2H_2O$

គណនាកម្លាំងអគ្គិសនីចលករ

$$E^0_{Cell} = E^0_{PbO_2/Pb^{2+}} - E^0_{Pb^{2+}/Pb} = 1.69V - (-0.36V) = 2.05V$$

ចំណាំ៖ ពេលអាគុយចាប់ផ្ដើមដំណើរការជាជនិតាកំហាប់អាស៊ីតស៊ុលផួរិចចាប់ផ្ដើមថយចុះ និងផ្លាកអាគុយរុំព័ទ្ធដោយ $PbSO_4$ (ស្នឹមអាគុយ)។

### គ. ដំណើរការជាគ្រឿងទទួល ឬបន្ទុកអាគុយ

ពេលអាគុយផ្ទុក ឬគ្រឿងទទួលជាប្រតិកម្មអុកស៊ីដូរេដុកម្មច្រាសវិធានកាម៉ាដែលបំលែងថាមពលអគ្គិសនីទៅជាថាមពលគីមី។ គេសាក ឬផ្ទុកអាគុយដោយប្រើជនិតាចរន្តជាប់ដែលមានកម្លាំងអគ្គិសនីចលករខ្ពស់ជាង 12V។




*រូបទី4.9 : ការផ្ទុកអាគុយ*

ផ្លាកវិជ្ជមាន(+)៖ $Pb^{2+} + 2H_2O \rightarrow PbO_2 + 4H^+ + 2e^-$

ផ្លាកអវិជ្ជមាន(-)៖ $Pb^{2+} + 2e^- \rightarrow Pb$

---

សមីការតុល្យការ៖ $2Pb^{2+} + 2H_2O \rightarrow PbO_2 + 4H^+ + Pb$

## III. វិធីសាស្ត្របង្រៀន

- គោលវិធីសិស្សមជ្ឈមណ្ឌល
  វិធីសាស្ត្របង្រៀនតាមបែបសហការ(ក្រុមតូច)

## IV. សម្ភារឧបទេស៖

- ផ្ទាំងរូបភាពជាតុបង្ករបស់អាគុយសំណ
- ក្រដាស $A_0$ សម្រាប់ពិភាក្សាក្រុម
- ហ្វឺត បន្ទាត់ ប៊ិច
- សៀវភៅសិក្សាគោលគីមីវិទ្យាទំព័រទី ៩៧ ដល់ ៩៨។

## V. ដំណើការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| | ជំហានទី១ រដ្ឋបាលថ្នាក់រៀន (5min) | |

| | | |
|---|---|---|
| – ពិនិត្យឯកសណ្ឋាន<br>– អនាម័យ<br>– ពង្រឹងសណ្តាប់ធ្នាប់ | រដ្ឋបាលថ្នាក់រៀន | – ប្រធានថ្នាក់ឡើងរាយការណ៍<br>– អង្គុយតាមកន្លែងរៀងខ្លួន |
| ជំហានទី២ រំឮកមេរៀនចាស់ (5min) | | |
| គ្រូសួរសំណួរទៅកាន់សិស្ស<br>1. ដូចម្តេចដែលហៅថា អាណូត និងកាតូត។<br>2. តើសម្ភារៈណាខ្លះដែលជាប្រភពផ្តល់ថាមពលអគ្គិសនី?<br>3. តើប្រភពថាមពលអគ្គិសនីទាំងនេះមានផលប៉ះពាល់ដល់បរិស្ថានយ៉ាងដូចម្តេចខ្លះ? | 1. អាណូតជាកន្លែងដែលដែលរងអុកស៊ីតកម្ម(លំនាំបោះបង់ $e^-$) ចំណែកកាតូតជាកន្លែងដែលរងរេដុកម្ម (លំនាំចាប់យក $e^-$)<br>2. សម្ភារៈដែលជាប្រភពថាមពលអគ្គិសនីមានដូចជាៈថ្មពិល អាគុយ ផ្ទាំងសូឡា ម៉ាស៊ីនភ្លើង វារីអគ្គិសនី រ៉េអាកទ័រនុយក្លេអែរ......។<br>3. ប្រភពផលិតថាមពលអគ្គិសនី ដូចជាម៉ាស៊ីនភ្លើងដែលប្រើប្រេងឥន្ទនៈអាចបង្កើតបានជាឧស្ម័នកាបូនិច ($CO_2$) ដែលជាឧស្ម័នផ្ទះកញ្ចក់ | សិស្សឡើងឆ្លើយដែលគ្រូបានសួរ |
| ជំហានទី៣ ខ្លឹមសារមេរៀនថ្មី (30min) | | |
| គ្រូបែងចែកសិស្សជាក្រុមតូច (**ដោយតម្រូវឱ្យក្រុមនិមួយៗ ត្រូវមានសមភាព ហ្សែនឌ័រ និងភាពចម្រុះនៃសាសនា និងវប្បធម៌** | ជំពូកទី៣<br>អុកស៊ីតកម្ម រេដុកម្ម និងអេឡិចត្រូគីមី<br>មេរៀនទី៤ ថ្មពិលអេឡិចត្រូគីមី<br>៣. អាគុយ<br>៣.១ អាគុយសំណ<br> | ចូលអង្គុយតាមក្រុម ទទួលសន្លឹកកិច្ចការពីគ្រូ និងពិភាក្សារកចម្លើយ។ |

| | | |
|---|---|---|
| **ដោយគ្មានភាពរើសអើង ពូជសាសន៍ និងនិន្នាការនយោបាយ**) បន្ទាប់មកចែករូបភាព និងសន្លឹកកិច្ចការឱ្យសិស្ស។<br><br>1. ចូរពណ៌នាធាតុបង្ករបស់អាគុយសំណ។<br><br>2. សរសេរសមីការតុល្យការដែលកើតមាននៅលើផ្លាកទាំងពីរបស់អាគុយពេលអាគុយផ្ទេរ។<br>3. សរសេរសមីការតុល្យការដែលកើតមាននៅលើផ្លាកទាំងពីរបស់អាគុយពេលអាគុយផ្ទុក។ | <br><br>1. ធាតុបង្ករបស់ថ្មពិលមានដូចជា៖ ផ្លាកវិជ្ជមានជាសំណាញ់ធ្វើសំណឌីអុកស៊ីត $PbO_2$ ផ្លាកអវិជ្ជមានធ្វើពីសំណាញ់សំណស្ពាត $Pb$ ផ្លាកទាំងពីររបស់អាគុយតម្រៀបឆ្លាស់គ្នាត្រាំក្នុងអេឡិចត្រូលីតជាអាស៊ីតស៊ុលផួរិច $H_2SO_4$ ដែលមានកំហាប់ 6M ។<br>2. សមីការតុល្យការពេលអាគុយផ្ទេរ<br><br>ផ្លាកវិជ្ជមាន(+)៖ $PbO_2 + 4H^+ + 2e^- \rightarrow Pb^{2+} + 2H_2O$<br>ផ្លាកអវិជ្ជមាន(-)៖ $Pb \rightarrow Pb^{2+} + 2e^-$<br>សមីការតុល្យការ៖ $PbO_2 + 4H^+ + Pb \rightarrow 2Pb^{2+} + 2H_2O$<br><br>3. សមីការតុល្យការពេលអាគុយផ្ទុក<br>ផ្លាកវិជ្ជមាន(+)៖ $Pb^{2+} + 2H_2O \rightarrow PbO_2 + 4H^+ + 2e^-$<br>ផ្លាកអវិជ្ជមាន(-)៖ $Pb^{2+} + 2e^- \rightarrow Pb$<br>សមីការតុល្យការ៖ $2Pb^{2+} + 2H_2O \rightarrow PbO_2 + 4H^+ + Pb$<br><br>**បញ្ច្រាបភាពជាពលរដ្ឋសាកល (សេដ្ឋកិច្ច ភាពមិនខ្ជះខ្ជាយលើការផលិតកាកសំណល់គីមី ដែលអាចបង្កផលអាក្រក់ទៅលើបរិស្ថាន ថែរក្សាធនធានធម្មជាតិដែលជាសម្បត្តិពិភពលោក)**<br>4. ការប្រើប្រាស់អាគុយឱ្យបានយូរ<br>– លើកទុកដាក់ថ្នមៗ ពេលដឹកជញ្ជូន<br>– ផ្លាស់ប្ដូរអាស៊ីតរៀងរាល់៣ខែ ទៅ៦ខែម្ដង<br>– កុំប្រើប្រាស់អាគុយឱ្យអស់ថាមពលខ្លាំងពេករហូតរលត់ឧបករណ៍អេឡិចត្រូលីត។<br>**ដើម្បីកុំឱ្យប៉ះពាល់ដល់បរិស្ថានយើងត្រូវ** | |

| | | |
|---|---|---|
| (បញ្ញាប GCED រូបភាព)<br>4. តើប្អូនត្រូវធ្វើដូចម្តេចដើម្បីឱ្យអាគុយប្រើប្រាស់បានយូរ ព្រមទាំងមិនប៉ះពាល់ដល់បរិស្ថាន និងសុខភាពសាធារណៈ?<br><br>ឱ្យសិស្សឡើងធ្វើបទបង្ហាញគ្រូសម្របសម្រួល | – នៅពេលផ្លាស់ប្តូរអាស៊ីតយើង មុននឹងបោះចោលយើងអាចពង្រាវ ឬបន្សាបដោយប្រើម៉ៅស្ងួជាជាដើម។<br>– មិនត្រូវបោះចោលអាគុយចាស់ៗផ្តេសផ្តាស (សុខភាពបុគ្គល និងមនុស្សក្នុងសហគមន៍) ដើម្បីកុំឱ្យប៉ះពាល់សុខភាពសាធារណៈ<br>– ប្រើប្រាស់អាគុយដោយប្រុងប្រយ័ត្នកុំឱ្យមានការកំពប់ ឬបែកបាក់ខ្ទាត់សារធាតុគីមីចេញក្រៅ។<br>សំយោគចម្លើយសិស្ស | ឡើងធ្វើបទបង្ហាញទៅកាន់មិត្តភក្តិរួមថ្នាក់ |
| ជំហានទី៤ ពង្រឹងពុទ្ធិ (5min) | | |
| 1. គណនាកម្លាំងអគ្គិសនីចលករបស់អាគុយសំណនៅពេលវាដើរតួជាជនិតាអគ្គិសនី។<br>2. ប្រសិនបើនៅជិតផ្ទះប្អូនមានអ្នកជួសជុលអាគុយ ឬអ្នកសាកអាគុយតើប្អូនអាចែករំលែកចំណេះដឹងពីការគ្រប់គ្រងកាកសំណល់អាគុយទៅគាត់យ៉ាងដូចម្តេចដើម្បីកុំឱ្យប៉ះ | 1. គណនាកម្លាំងអគ្គិសនីចលករ<br>$E^0_{Cell} = E^0_{PbO_2/Pb^{2+}} - E^0_{Pb^{2+}/Pb} = 1.69V - (-0.36V) = 2.05V$<br><br>2. ប្រតិកម្មអុកស៊ីដូរេដុកម្ម។ ក្នុងមជ្ឈដ្ឋានអាស៊ីត។ | សិស្សឆ្លើយសំណួរគ្រូ |

| | | |
|---|---|---|
| ពាល់បរិស្ថាន និងសុខភាពសារធារណៈ | | |
| ជំហានទី៥ កិច្ចការផ្ទះ (5min) | | |
| គ្រូដាក់កិច្ចការផ្ទះ | ១. តើការប្រើប្រាស់អាគុយមានគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះសម្រាប់អ្នក និងអ្នកនៅជុំវិញអ្នក?<br>២. តើអ្វីទៅជាអេឡិចត្រូលីត?<br>៣. និមិត្តសញ្ញាអាគុយសំណ<br>$(-)Pb\|PbSO_4\|\|H_2SO_4\|\| PbSO_4\|PbO_2(+)$<br>ក. សរសេរកន្លះសមីការអេឡិចត្រុងតាងប្រតិកម្មដែលកើតមាននៅលើផ្លាកវិជ្ជមាន និងផ្លាកអវិជ្ជមាននៅពេល<br>អាគុយផ្ទេរ។<br>ខ. សរសេរសមីការតុល្យការពេលអាគុយផ្ទុក។ | កត់ត្រាមេរៀន |

VI. **ការវាយតម្លៃ**

១.តើការប្រើប្រាស់អាសគុយ ឬថ្មពិលដែលខូចអាចផលប៉ះពាល់អ្វីខ្លះដល់មនុស្ស និងបរិស្ថាន?ចូររៀបរាប់។

……………………………………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

២.ក្នុងនាមអ្នកជាពលរដ្ឋតើអ្នកនឹងចូលរួមចំណែកក្នុងការចាត់ចែងកាកសំណល់អាគុយ ឬថ្មពិលដែលខូចគុណភាពក្នុងសហគនម៍អ្នកយ៉ាងដូចម្ដេច?

……………………………………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

## សន្លឹកកិច្ចការពិសោធ

ពិសោធន៍៖ ញែកសម្គាល់សូលុយស្យុងអាស៊ីត-បាស

## បង្ហាញបាតុភូត



---------------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------------

## សំណួរគន្លឹះ

តើយើងអាចញែកសម្គាល់ភាពខ្លាំង ឬខ្សោយរបស់អាស៊ីត-បាសដូចម្តេច?

## សម្មតិកម្ម

| សូលុយស្យុង | អាស៊ីត-បាសខ្លាំង ឬខ្សោយ | អំណះអំណាង |
|---|---|---|
| A | ...................................... | ........................ |
| B | ...................................... | ........................ |
| C | ...................................... | ........................ |
| D | ...................................... | ........................ |
| E | ...................................... | ........................ |

## តេស្តសម្មតិកម្ម

- សម្ភារៈ និងសារធាតុគីមី



សូ. A B C D E






ក្រដាស pH ពីប៉ែតបន្តក់ អំពូល+ខ្សែចម្លង ថ្មពិល 9V

- ដំណើការពិសោធ

----------------------------------------------------------------------------------------------------------------
----------------------------------------------------------------------------------------------------------------
----------------------------------------------------------------------------------------------------------------
----------------------------------------------------------------------------------------------------------------
----------------------------------------------------------------------------------------------------------------
----------------------------------------------------------------------------------------------------------------
----------------------------------------------------------------------------------------------------------------
----------------------------------------------------------------------------------------------------------------

## លទ្ធផល

| សូ. | ភាពភ្លឺនៃអំពូល | ក្រដាសpH | តម្លៃ pH ប្រហែល |
|---|---|---|---|
| A | ………………………………. | ………………………………. | ………………………………. |
| B | ………………………………. | ………………………………. | ………………………………. |
| C | ………………………………. | ………………………………. | ………………………………. |
| D | ………………………………. | ………………………………. | ………………………………. |
| E | ………………………………. | ………………………………. | ………………………………. |

## ពិភាក្សា និងសន្និដ្ឋាន

1. ហេតុអ្វីបានជាសូលុយខ្លះធ្វើឱ្យអំពូលភ្លឺខ្លាំង និងភ្លឺខ្សោយ?

   ----------------------------------------------------------------------------------------------------
   ----------------------------------------------------------------------------------------------------

2. តើសូលុយស្យុងណាខ្លះជាសូលុយលុយស្យុងអាស៊ីតខ្លាំង ឬបាសខ្លាំង? ហេតុអ្វី?

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

3. តើសូលុយស្យុងណាខ្លះជាសូលុយលុយស្យុងអាស៊ីតខ្សោយ ឬបាសខ្សោយ? ហេតុអ្វី?

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

4. ចូរសរសេរមីការតាងប្រតិកម្មរវាងអាស៊ីតខ្សោយ(តាងដោយ $BH^+$) និងអាស៊ីតខ្លាំង(តាងដោយ HA) ក្នុងទឹក។

------------------------------------------------------------

------------------------------------------------------------

5. ចូរសរសេរមីការតាងប្រតិកម្មរវាងបាសខ្សោយ(តាងដោយ B) និងបាសខ្លាំង(តាងដោយ $A^-$) ក្នុងទឹក។

------------------------------------------------------------

------------------------------------------------------------

6. តើលោហៈធ្ងន់ដូចជាសំណរ បារត អាចប៉ះពាល់អ្វីខ្លះដល់សុខភាពមនុស្ស?

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

7. ប្រសិនបើមានកាកសំណល់ដូចជាអាស៊ីតស៊ុលផួរិចច្រើនក្នុងបរិស្ថានតើវាប៉ះពាល់អ្វីខ្លះដល់ជីវិតមនុស្ស សត្វ និងរុក្ខជាតិ?

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

សន្និដ្ឋានៈ

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

# ប្រធានបទៈ ការថែរក្សាអាហារដោយប្រើប្រាស់ Nitrite និង Nitrate

គឿក សុខនី
វិទ្យាស្ថានជាតិអប់រំ

**កាលបរិច្ឆេទ** ៖ ថ្ងៃ................ ខែ............... ឆ្នាំ.............. បញ្ចស័ក ព.ស.២៥៦.....
ត្រូវនឹងថ្ងៃទី........... ខែ................. ឆ្នាំ២០២............

**មុខវិជ្ជា** ៖ កែច្នៃអាហារ

**ជំពូកទី២** ៖ វិធីសាស្ត្រថែរក្សាអាហារ

**មេរៀនទី១** ៖ ការថែរក្សាអាហារដោយប្រើប្រាស់ Nitrite និង Nitrate

**រយៈពេល** ៖ ៥០នាទី

## I. **វត្ថុបំណង**

ក្រោយពីបានសិក្សាមេរៀននេះចប់ គរុសិស្សនឹងទទួលបាន៖

### ១. **វិជ្ជាសម្បទា**

- ពិពណ៌នាអំពីមុខងារ និងកត្តាដែលជះឥទ្ធិពលដល់ប្រសិទ្ធភាពរបស់ Nitrite និង Nitrate ក្នុងការថែរក្សាអាហារ
- ពន្យល់អំពីហានិភ័យ និងកង្វល់នៃ Nitrite និង Nitrate នៅក្នុងផលិតផលសាច់កែច្នៃចំពោះសុខភាព។

### ២. **បំណិនសម្បទា**

- ជ្រើសរើសលក្ខណ្ឌដំណើរការកែច្នៃអាហារសមស្របដើម្បីជម្រុញប្រសិទ្ធិភាពរបស់ Nitrite និង Nitrate និងកាត់បន្ថយការកើតមានសារជាតុដែលបង្កហានិភ័យចំពោះសុខភាព
- ប្រើប្រាស់ Nitrite និង Nitrate នៅក្នុងការថែរក្សាអាហារសមស្របតាមលក្ខណៈផលិតផលដែលចង់បាន។

### ៣. **ចរិយាសម្បទា**

- ប្រើប្រាស់ Nitrite និង Nitrate ក្នុងការថែរក្សាអាហារប្រកបដោយទំនួលខុសត្រូវសីលធម៌វិជ្ជាជីវៈ និងសង្គម(**បញ្ជ្រាប** GCED)។

## II. **សម្ភារៈឧបទេស**

- សៀវភៅសិក្សាគោល
- ហ្វឺតពណ៌ខៀវ ឧបករណ៍លុបក្តារខៀន
- ស្លាយសម្រាប់បង្រៀន

## III. វិធីសាស្រ្តបង្រៀន

គោលវិធីសិស្សមជ្ឈមណ្ឌល តាមបែបសហការ **ដោយបញ្ជ្រាប** GCED ។

## IV. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| **ជំហានទី១ ៖ លំនឹងថ្នាក់ (២នាទី)** | | |
| -ឱ្យប្រធានថ្នាក់រាយការណ៍ពីចំនួនសិស្សអវត្តមាន<br>-ពិនិត្យអនាម័យ សណ្ដាប់ធ្នាប់និងឯកសណ្ឋានគរុសិស្ស | -ពិនិត្យអនាម័យថ្នាក់រៀន និងណ្ដាប់ធ្នាប់ថ្នាក់រៀន<br>-ពិនិត្យឯកសណ្ឋានសិស្ស<br>-ពិនិត្យអវត្តមានសិស្ស | -សិស្សឈរឱ្យគ្រូពិនិត្យឯកសណ្ឋាន និងចូលអង្គុយតាមកន្លែងរៀងខ្លួន<br>-ប្រធានថ្នាក់រាយការណ៍ពីចំនួនសិស្សអវត្តមាន |
| **ជំហានទី២ ៖ រំលឹកមេរៀនចាស់ (៣នាទី)** | | |
| ១.តើការខូចគុណភាពរបស់អាហារអាចត្រូវបានកំណត់តាមវិធីអ្វីខ្លះ? | ១. ការខូចគុណភាពរបស់អាហារអាចត្រូវបានកំណត់តាមវិធីៈ<br>- អាហារមិនអាចទទួលយកបានសម្រាប់អ្នកប្រើប្រាស់ដោយ សារតែការផ្លាស់ប្ដូរលក្ខណៈញ្ញាណ<br>- អាហារអាចត្រូវបានគេនិយាយថាបានខូចនៅពេលដែលចំនួន និង/ឬសកម្មភាពរបស់អតិសុខុមប្រាណធ្វើឱ្យវាមិនមានសុវត្ថិភាពសម្រាប់បរិភោគ<br>- អាហារត្រូវបានខូចនៅពេលដែលសារធាតុចិញ្ចឹមមួយ ឬច្រើនខូចគុណភាព មានន័យថាវាគ្មានតម្លៃអាហារូបត្ថម្ភ។ | - សិស្សគិតរកចម្លើយដែលគ្រូបានសួរ<br>- សិស្សឡើងឆ្លើយនូវចម្លើយដែលគាត់បានគិតឃើញ |
| **ជំហានទី៣ៈខ្លឹមសារមេរៀន(៤០នាទី)** | | |

| | | |
|---|---|---|
| ១.តើសារជាតុថែរក្សាអាហារជាអ្វី? | ១.សារជាតុថែរក្សាគឺជាសមាសជាតុដែលប្រើដើម្បីពន្យារ ឬការពារការខូចរបស់អាហារដោយគីមី និងអតិសុខុមប្រាណ (ឧ. បាក់តេរី ផ្សិត)។ | -សិស្សឆ្លើយសំណួរ |
| ២.តើសារជាតុគីមី ឬសារជាតុបន្ថែមដែលត្រូវបានប្រើប្រាស់ក្នុងការថែរក្សាអាហារមានតួនាទីអ្វីខ្លះនៅក្នុងអាហារ? | ២. សារជាតុគីមីផ្សេងៗជាច្រើន ឬសារជាតុបន្ថែមត្រូវបានប្រើប្រាស់ក្នុងការថែរក្សាអាហារដើម្បីគ្រប់គ្រង pH សារជាតុប្រឆាំងអុកស៊ីតកម្ម និងប្រឆាំងអតិសុខុមប្រាណ ។ | -សិស្សឆ្លើយសំណួរ |
| ៣.តើការប្រើប្រាស់ Nitrite និង Nitrate នៅក្នុងផលិតផលសាច់កែច្នៃផ្តល់សារៈសំខាន់អ្វីខ្លះ? | ៣. Nitrite និង Nitrate ត្រូវបានប្រើប្រាស់នៅក្នុងផលិតផលសាច់កែច្នៃជាសមាសជាតុសំខាន់ដែលផ្តល់ឱ្យសាច់នូវលក្ខណៈពិសេសដូចជា៖<br>- ពណ៌ផ្កាឈូក៖ Nitrite ត្រូវបានបំប្លែងទៅជា Nitric oxide (NO) ផ្សំជាមួយនឹងដែកនៃ myoglobin ($Fe^{2+}$) និង metmyoglobin ($Fe^{3+}$) ដើម្បីបង្កើតជាពណ៌ផ្កាឈូក។<br>- Flavor៖ Nitrite នាំឱ្យមានការផលិត Strecker aldehydes នៅពេលដែលអាស៊ីតអាមីណូត្រូវបានខូចដោយ dicarbonyl ដែលផលិតតាមរយៈប្រតិកម្ម Maillard<br>- រារាំងអុកស៊ីតកម្មនៃខ្លាញ់៖ nitric oxide (NO) អាចរារាំងអុកស៊ីតកម្មលីពីតដោយភ្ជាប់ជាមួយរ៉ាឌីកាល់ lipid peroxyl និងបង្កើតម៉ូលេគុលដែលមិនមែនរ៉ាឌីកាល់។<br>- រារាំងការដុះលូតលាស់នៃអតិសុខុមប្រាណបង្កជំងឺ៖ Nitrite | -សិស្សឆ្លើយសំណួរ |

| | | |
|---|---|---|
| | វាយប្រហារបាក់តេរីនៅកន្លែងជាច្រើនដោយរារាំងអង់ស៊ីមមេតាបូលីស និងបញ្ឈប់ការស្រូបយកអុកស៊ីសែន។ | |
| ៤. តើកត្តាអ្វីខ្លះដែលជះឥទ្ធិពលដល់ប្រសិទ្ធភាពរបស់ Nitrite និង Nitrate ? | ៤.កត្តាដែលជះឥទ្ធិពលដល់ប្រសិទ្ធភាពរបស់ Nitrite និង Nitrate ៖<br>- pH៖ សកម្មភាពរារាំង Nitrite និង Nitrate លើប្រភេទបាក់តេរីជាច្រើនត្រូវបានបង្ហាញថាកើនឡើងជាមួយនឹងការថយចុះ pH ជាពិសេសនៅ pH 6.0 និងក្រោមនេះ។<br>- អុកស៊ីសែន៖ Nitrite រារាំងកាន់តែប្រសើរនៅក្រោមលក្ខខណ្ឌគ្មានអុកស៊ីសែន។<br>- សមាសធាតុអាហារ៖ ឧ.កំហាប់អំបិល( សូដ្យូមក្លរួតែឯងនៅកំហាប់ 9.0%–10.5% អាចរារាំងការលូតលាស់ និងការផលិតជាតិពុលដោយ *C. botulinum* ។ នៅពេលដែល nitrite ត្រូវបានបន្ថែមកំហាប់ 75 និង 150 ppm កម្រិតសូដ្យូមក្លរួ 5.8% និង 4.9% ត្រូវតម្រូវដើម្បីរារាំងការបង្កើតជាតិពុល ) ។<br>- កម្តៅ៖ ឧ.ឥទ្ធិពលនៃ sodium nitrite ដែលមិនត្រូវកំដៅគឺអាស្រ័យលើ pH ហើយ 200-400 ppm sodium nitrite គឺចាំបាច់ដើម្បីរារាំងការលូតលាស់របស់ *C. sporogenes* នៅ pH ក្បែណឺត។ ក្នុងបរិមាណតិចតួច 3-5 ppm sodium nitrite | -សិស្សឆ្លើយសំណួរ |

| | | |
|---|---|---|
| | កំដៅរយៈពេល 20 នាទីនៅ 105-115 ◦C អាចរារាំងការលូតលាស់ ហើយការរារាំងនេះពឹងផ្អែកតិចតួចលើ pH ។ | |
| <u>**សំណួរពិភាក្សាក្រុម**</u><br>- បែងចែកសិស្សជា៤ក្រុម ដោយធ្វើការពិភាក្សាទៅលើហានិភ័យ និងកង្វល់ក្នុងការប្រើប្រាស់ Nitrite និង Nitrate លើសពីបរិមាណដែនកំណត់(បទបញ្ញត្តិសុវត្ថិភាពអាហារ) នៅក្នុងផលិតផលសាច់កែច្នៃចំពោះសុខភាព (**បញ្ជ្រាប** GCED) ។ | ហានិភ័យ និងកង្វល់ក្នុងការប្រើប្រាស់ Nitrite និង Nitrate លើសពីបរិមាណដែនកំណត់ នៅក្នុងផលិតផលសាច់កែច្នៃចំពោះសុខភាព ៖ ការប្រើប្រាស់ Nitrate លើសពីបរិមាណដែនកំណត់ វាអាចត្រូវបានបំប្លែងទៅជា Nitrite ដែលអាចប្រតិកម្មជាមួយ amines និង amides ដើម្បីផលិតសមាសធាតុ nitrosamine ដែលមានហានិភ័យបង្កជាជំងឺមហារីក។ Nitrate មានជាតិពុលខ្លាំងព្រោះវារួមផ្សំជាមួយ hemoglobin និងបង្កើត methemoglobin ដែលរំខានដល់ការដឹកជញ្ជូនអុកស៊ីសែនទៅជាលិកា។ | - សិស្សធ្វើការពិភាក្សាជាក្រុម<br>- សិស្សគិតរកចម្លើយដែលគ្រូបានសួរ<br>- ដំណាងក្រុមឡើងបកស្រាយ |
| **ជំហានទី៤៖ ពង្រឹងពុទ្ធិ (៣នាទី)** | | |
| ១.តើការប្រើប្រាស់ Nitrite នៅក្នុងផលិតផលសាច់កែច្នៃផ្តល់សារៈសំខាន់អ្វីខ្លះ?<br><br>២.តើការប្រើប្រាស់ Nitrite និង Nitrate ក្នុងផលិតផលសាច់កែច្នៃបង្កហានិភ័យ និងកង្វល់ដូចម្តេចខ្លះ? | ១. Nitrite ត្រូវបានប្រើប្រាស់នៅក្នុងផលិតផលសាច់កែច្នៃជាសមាសធាតុសំខាន់ដោយផ្តល់ឱ្យសាច់នូវលក្ខណៈពិសេសដូចជា ពណ៌ផ្កាឈូក Flavor រារាំងអុកស៊ីតកម្មនៃខ្លាញ់ និងរារាំងការដុះលូតលាស់របស់អតិសុខុមប្រាណបង្កជំងឺ។<br>២.ការប្រើប្រាស់នីប្រាស់ Nitrite និង Nitrate ក្នុងផលិតផលសាច់កែច្នៃលើសបរិមាណកំណត់បង្កើនហានិភ័យ និងកង្វល់ដូចជា បង្កជាជំងឺមហារីក និងរំខានដល់ការដឹកជញ្ជូន | -សិស្សព្យាយាមឆ្លើយរៀងៗខ្លួនតាមរយៈចំណេះដឹងពីមេរៀននិងការស្រាវជ្រាវដែលពួកគេបានសិក្សារួច។ |

| | | |
|---|---|---|
| | អុកស៊ីសែនទៅជាលិកា។ | |
| **ជំហានទី៥៖បណ្ដាំផ្ញើ(២នាទី)** | | |
| (បញ្ជ្រាប GCED)<br>- ណែនាំឱ្យសិស្សអនុវត្តតាមបទបញ្ញត្តិសុវត្ថិភាពអាហារ (ប្រកបដោយទំនួលខុសត្រូវ សីលធម៌វិជ្ជាជីវៈ និងសង្គម)នៅក្នុងការប្រើប្រាស់ Nitrite និង Nitrate សម្រាប់ការថែរក្សាអាហារដើម្បីការពារផលប៉ះពាល់ចំពោះសុខភាព។ | | - ស្ដាប់ការណែនាំរបស់គ្រូ និងកត់ត្រាចំណុចសំខាន់ៗ |

# ប្រធានបទ៖ ការជ្រើសរើសប្រធានបទ និង ការដាក់សំណើស្រាវជ្រាវ

សាំង សុចិន្ដា, ចេង ចុន, លុយ អោក
វិទ្យាស្ថានជាតិអប់រំ

**រយៈពេល៖ ១ម៉ោង**

**១. វត្ថុបំណង៖** ក្រោយពីសិក្សាមេរៀននេះចប់សិស្សមានសមត្ថភាព៖

- វិជ្ជាសម្បទា ៖ រៀបរាប់ពីបញ្ហាស្រាវជ្រាវ និង សំណើស្រាវជ្រាវបានត្រឹមត្រូវ។
- បំណិនសម្បទា ៖ បកស្រាយពីបញ្ហាស្រាវជ្រាវ ដែលជ្រើសរើសជាបញ្ហាបានមកធ្វើការស្រាវជ្រាវ បានដាក់លាក់។
- ចរិយាសម្បទា ៖បណ្ដុះទម្លាប់ស្រឡាញ់ការស្រាវជ្រាវ ដើម្បីធ្វើការអភិវឌ្ឍវិស័យអប់រំ និងប្រទេសជាតិ ។

**២. សម្ភារៈបង្រៀន៖**

- ក្រដាសA4 ហ្វឺត ស្កុត ក្រដាសកាតុង។
- ផែនទីគំនិតស្ដីពីដំណើរជ្រើសរើសប្រធានបទ។
- គម្រូសំណើស្រាវជ្រាវ។

**៣. វិធីសាស្ត្របង្រៀន៖** វិធីសាស្ត្ររៀន-បង្រៀនតាមបែបរិះរក (IBL) តាមរយៈយុទ្ធវិធី **5Es**។

**៤. ដំណើកនាំមេរៀន៖**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| **ជំហានទី១ ៖ រដ្ឋបាលថ្នាក់រៀន(៣នាទី)** | | |
| • ពិនិត្យអវត្តមាន<br>• អនាម័យ<br>• និងសណ្ដាប់ធ្នាប់ក្នុងថ្នាក់រៀន | អវត្តមាន អនាម័យ និង<br>សណ្ដាប់ធ្នាប់ក្នុងថ្នាក់រៀន | • សម្អាតថ្នាក់រៀន<br>• ប្រធានថ្នាក់រាយការណ៍អវត្តមាន<br>• ត្រៀមខ្លួនសម្រាប់រៀនមេរៀនថ្ងៃនេះ |
| **ជំហានទី២ ៖ រំលឹកមេរៀនចាស់ (៧នាទី)** | | |
| • សួរសំណួររំលឹកមេរៀន<br>. ដើម្បីទទួលបានព័ត៌មានណាមួយ តើមនុស្សអាចទទួលបានតាមរបៀបណាខ្លះ? | **ការទទួលបាន និងវិភាគព័ត៌មាន** | • សិស្សស្ដាប់ គិត និងឆ្លើយសំណួរ<br>. តាមរយៈ ការអាន ការស្ដាប់អ្នកដទៃនិយាយរៀបរាប់ ការមើលទូរទស្សន៍ និងការស្រាវជ្រាវនៅតាមបណ្ណាល័យ និង អ៊ីនធឺណែត។ |

| | | |
|---|---|---|
| . តើគេអាចដឹងថា ព័ត៌មានដែលគេទទួលបាននោះពិត ឬមិនពិត កម្រិតណា តាមវិធីណា? | | . ដោយការ ប្រៀបធៀបទៅនិងបទពិសោធន៍ផ្ទាល់របស់ខ្លួន<br>. ដោយការពិចារណាតាមរយៈការគិតរបស់ខ្លួន |
| .តើគេប្រមូលព័ត៌មានក្នុងគោលបំណងអ្វី? | | .ដើម្បីស្វែងយល់ពីបញ្ហាដែលកំពុងកើតមាន<br>.ដើម្បីធ្វើផែនការ និងការអភិវឌ្ឍ<br>.ដើម្បីធ្វើសេចក្តីសម្រេចចិត្តលើបញ្ហាណាមួយ |
| **ជំហានទី៣ ៖ មេរៀនប្រចាំថ្ងៃ** (**៣០នាទី**) | | |
| **១-ទាញចំណាប់អារម្មណ៍**(Engage) | | |
| • ណែនាំឱ្យសិស្សជ្រើសរើសប្រធានបទម្នាក់មួយប្រធានបទដែលអ្នកគិតថាជាបញ្ហាត្រូវលើកមកស្រាវជ្រាវ ឧទាហរណ៍៖សីលធម៌យុវជនខ្មែរធ្លាក់ចុះ<br>• ពិនិត្យនិងប្រៀបធៀបប្រធានបទរបស់សិស្សម្នាក់ៗ | **ការជ្រើសរើសប្រធានបទ និង ការដាក់សំណើស្រាវជ្រាវ**<br>**តើកត្តាអ្វី បណ្តាលឱ្យសីលធម៌យុវជនខ្មែរស្រុតចុះ?** | • សិស្សជ្រើសរើសប្រធានបទតាមការយល់ឃើញផ្សេងៗគ្នា<br>• សិស្សអានប្រធានបទរបស់ខ្លួន<br>• មានកត្តាជាច្រើនបណ្តាលឱ្យសីលធម៌ស្រុតចុះ ដូចជាសាកលភាវូបនីយកម្ម |
| . តើប្រធានបទណាខ្លះដែលមានលក្ខណៈប្រសើរ? ប្រធានបទណាខ្លះដែលមិនប្រសើរសម្រាប់ធ្វើការស្រាវជ្រាវ? ហេតុអ្វី? | | .ប្រធានបទដែលល្អ មានខ្លឹមសារគ្រប់គ្រាន់ ច្បាស់លាស់ មានភាពទាក់ទាញ<br>.មានដែនកំណត់ច្បាស់លាស់ មិនទូលាយពេក មិនចង្អៀតពេក |

**សំណួរគន្លឹះ:**

តើលក្ខណៈពិសេសនៃប្រធានបទដែលល្អសម្រាប់ធ្វើការស្រាវជ្រាវមានអ្វីខ្លះ?

| | | |
|---|---|---|
| . ណែនាំឱ្យសិស្សពិនិត្យមើលលើចំណុចខ្វះខាតប្រធានបទរបស់សិស្សដទៃ។ | | .សិស្សសង្កេត និងកត់ត្រា<br>.សិស្សបង្កើតសំណួរតាមការឆ្លល់ ផ្សេងៗគ្នា។ |
| **២-ស្វែងរក( Explore )** | | |
| • ណែនាំឱ្យសិស្សបង្កើតសម្មតិកម្មអំពីលក្ខណៈពិសេសនៃកត្តាបណ្តាលឱ្យសីលធម៌យុវជនធ្លាក់ចុះ មានផលប៉ះពាល់ដល់សីលធម៌សកលលោកដូចម្តេច?<br>• ហៅសិស្សឱ្យបង្ហាញសម្មតិកម្មនៅលើក្តាខៀន។ | **បង្កើតសម្មតិកម្ម**<br>សម្មតិកម្មមានលក្ខណៈ<br>SMART៖<br>.S= Specific, Source and Supportive<br>.M=Meaningful, Money<br>.A=Acceptable, Accessible<br>.R=Resource, Response<br>.T=Timing | • សិស្សបង្កើត/ជ្រើសរើសសម្មតិកម្ម<br>• សិស្សបង្ហាញសម្មតិកម្ម ឬការព្យាករណ៍អនាគត ពីសីលធម៌យុវជនកម្ពុជា និងសកលលោក។ |
| • បែងចែកសិស្សជា៣ក្រុមតូចៗ ដើម្បីពិភាក្សាតាមសម្មតិកម្មដែលបានជ្រើសរើស។<br>• ផ្តល់ប្រធានបទគម្រូសម្រាប់សិស្ស (គ្រូបង្ហាញប្រធានបទដែលមានលក្ខណៈតាម SMART ឱ្យសិស្ស) | **ពិភាក្សាក្រុមរើសរកប្រធានបទ**<br>**តើកត្តាអ្វី ដែលបណ្តាលឱ្យសីលធម៌យុវជនស្រុតចុះ?** | • ចូលតាមក្រុម ពិភាក្សា |
| • សម្របសម្រួលការពិភាក្សាតាមក្រុមនីមួយៗ | • **ក្រុមA៖** សិក្សាអំពីកត្តាដែលបណ្តាលឱ្យសីលធម៌ស្រុតចុះ | • ពិភាក្សាក្រុម<br>ក្រុម១៖ ផ្នែកលក្ខណៈSMART៖ |

| | | |
|---|---|---|
| | | .S= Specific, Source and Supportive<br>.M=Meaningful, Money<br>.A=Acceptable, Accessible<br>.R=Resource, Response<br>.T=Timing |
| • ឱ្យក្រុមនីមួយៗសរសេរចម្លើយ និងពន្យល់នៅលើក្ដាខៀនដោយតំណាងក្រុមម្នាក់។ | • **ក្រុមB៖ បញ្ហាប្រឈម សិស្សគេចមិនចូលរៀននៅវិទ្យាល័យ** ក្នុងប្រទេសកម្ពុជា។ | • ពិភាក្សាក្រុម<br>ក្រុម១៖ ផែកលក្ខណៈSMART៖<br>.S= Specific, Source and Supportive<br>.M=Meaningful, Money<br>.A=Acceptable, Accessible<br>.R=Resource, Response<br>.T=Timing |
| | • **ក្រុមC៖ ឥទ្ធិពលនៃសាកលភាវូបនីយកម្មលើសីលធម៌របស់យុវជន ។** | • ពិភាក្សាក្រុម<br>ក្រុម១៖ ផែកលក្ខណៈSMART៖<br>.S= Specific, Source and Supportive<br>.M=Meaningful, Money<br>.A=Acceptable, Accessible<br>.R=Resource, Response<br>.T=Timing |
| **៣-ពន្យល់( Explain )** | | |
| • គ្រូឱ្យសិស្សឡើងបង្ហាញតាមក្រុម | | • សិស្សឡើងបង្ហាញតាមក្រុម |

| | | |
|---|---|---|
| • សម្របសម្រួលចម្លើយតាមក្រុមនីមួយៗនៅលើក្តាខៀន។ | | |
| • ចូរប្អូនសន្និដ្ឋានពីការដែលប្អូនអាចចាត់ទុកថា ប្រធានបទដែលប្អូនបានជ្រើសរើស ពិតជាធ្វើបានជោគជ័យ ។ | **សន្និដ្ឋាន**<br>➢ មូលហេតុដែលនាំឱ្យប្រធានបទធ្វើការស្រាវជ្រាវបានជោគជ័យគឺ ស្របតាមគោលការណ៍ SMART៖<br>✓ មានន័យគ្រប់គ្រាន់ មិនទូលំទូលាយពេក មិនតូចពេក<br>✓ មានប្រភពឯកសារ និងប្រភពទិន្នន័យគ្រប់គ្រាន់ដើម្បីស្រាវជ្រាវនិងប្រមូលបាន<br>✓ មានថវិកាគ្រប់គ្រាន់សម្រាប់ធ្វើការស្រាវជ្រាវលើប្រធានបទ<br>✓ ឆ្លើយតបទៅនឹងបញ្ហាជាក់ស្តែង ដែលនឹងនាំឱ្យថ្នាក់ដឹកនាំអនុញ្ញាតឱ្យធ្វើការស្រាវជ្រាវបាន<br>✓ មានទំហំនិងដែនកំណត់នៃការស្រាវជ្រាវច្បាស់លាស់។ (GCED) | • សិស្សធ្វើការសន្និដ្ឋានអំពីលក្ខណៈពិសេសដែលនាំឱ្យការស្រាវជ្រាវខ្លួនអាចសម្រេចទៅបាន |
| • ឱ្យសិស្សកត់ត្រាចម្លើយដែលត្រឹមត្រូវចូលក្នុងសៀវភៅរៀងខ្លួនៗ។ | | • កត់ត្រាចម្លើយដែលត្រឹមត្រូវចូលក្នុងសៀវភៅ។ |
| | **៤-ពង្រីកគំនិត** (Elaborate) | |
| • ឱ្យសិស្សពិភាក្សាជាក្រុមអំពីការដាក់សំណើស្រាវជ្រាវបន្ទាប់ពីខ្លួនរើសប្រធានបទរួច | **ចំណុចនានាដែលត្រូវដាក់ក្នុងសំណើស្រាវជ្រាវ** | • សិស្សពិភាក្សាគ្នា .ថាតើសំណើស្រាវជ្រាវ ត្រូវមានបញ្ចូលចំណុចអ្វីខ្លះ? |
| | **ជំហានទី៤ ៖ ពង្រឹងពុទ្ធិ** (**៧នាទី**) | |
| | **៥-វាយតម្លៃ** (Evaluate) | • **ប្រយោជន៍ដែលកើតមាន** |

| | | |
|---|---|---|
| • តើការស្រាវជ្រាវអប់រំ មានប្រយោជន៍អ្វីខ្លះដល់ ការដោះស្រាយបញ្ហាចំពោះមុខក្នុង វិស័យអប់រំ និងសង្គមជាតិ? (GCED) | | . ស្រាវជ្រាវ ដើម្បីអភិវឌ្ឍ<br>. ស្រាវជ្រាវដើម្បីស្វែងយល់ពីអតីតកាល<br>. ព្យាករណ៍នូវបាតុភូតអសកម្មនានាក្នុងវិស័យអប់រំ<br>. បណ្តុះទម្លាប់នៃការអាន និងស្រាវជ្រាវ ដើម្បីឈានដល់ការបង្កើតថ្មី<br>.អភិវឌ្ឍខ្លួនឱ្យឆ្លើយតបទៅនឹង ការវិវត្តនៃយុគសម័យឌីជីថល សង្គមពុទ្ធិ និង វិបុលភាព<br>. យល់កាន់តែច្បាស់ពីទំនាក់ទំនងសេដ្ឋកិច្ច អប់រំ នយោបាយ |
| **ជំហានទី៥ ៖ កិច្ចការផ្ទះ និង បណ្តាំផ្ញើ** | | |
| • ចូរប្អូនជ្រើសរើសប្រធានបទ«ការលើកកម្ពស់គុណភាពបង្រៀននិងរៀន»ដោយមានសំណើស្រាវជ្រាវមកបង្ហាញជាមួយផង(GCED) | **កិច្ចការផ្ទះ** | • សិស្សកត់ត្រាកិច្ចការផ្ទះ |
| • សូមប្អូនៗអានមេរៀនឡើងវិញពេលត្រឡប់ទៅផ្ទះ និងសាកល្បងធ្វើការស្រាវជ្រាវលើប្រធានបទដែលគ្រូបានដាក់ជូន។ | បណ្តាំផ្ញើ<br>ចូរអ្នកសិក្សាស្រាវជ្រាវលើប្រធានបទ ទាក់ទងទៅនឹង«ការអប់រំប្រកបដោយសមធម៌ សមភាព និងការអប់រំបរិយាបន្ន»(GCED) | • អនុវត្តន៍នៅផ្ទះ(កិច្ចការផ្ទះ) |

# មេរៀនៈ កំលាំងកកិត

ស្រ៊ន់ តៃស្រ៊ីម (Srorn Tay Srim)

**វិទ្យាស្ថានជាតិអប់រំ**

កាលបរិច្ឆេទៈ ថ្ងៃ..........................ខែ..........................ឆ្នាំ...............ព.ស.២៥៦...

ត្រូវនឹងថ្ងៃទី................ខែ.....................ឆ្នាំ២០២...

**មុខវិជ្ជាៈ** រូបវិទ្យា

**មេរៀនៈ** កំលាំងកកិត

**រយៈពេលៈ** ៥០ នាទី

## ១. វត្ថុបំណងនៃមេរៀន

### ១. ចំណេះដឹងៈ

- ចាប់បាននូវបញ្ញត្តិកម្លាំងកកិតតាមរយៈការបង្ហាញបាតុភូតងាយៗ។

### ២. បំណិនសម្បទាៈ

- កំណត់កត្តាដែលមានឥទ្ធិពលលើកម្លាំងកកិតបានយ៉ាងត្រឹមត្រូវតាមរយៈពិសោធន៍។

### ៣. ចរិយាសម្បទាៈ

- បណ្តុះគំនិតឱ្យសិស្សមានបម្រុងប្រយ័ត្នខ្ពស់ក្នុងការអនុវត្តកកិតទៅក្នុងជីវភាពប្រចាំថ្ងៃ។

## ២. ខ្លឹមសារមេរៀន

កំលាំងកកិត

## ៣. សម្ភារៈឧបទេស

កូនរទេះ គូបលោហៈ ដំឈើ បន្ទះក្តាឬប្លង់រាប ចំរៀកក្រណាត់ ស្កុតមុខពីរ ជញ្ជីង កៅវប្លាស្ទិច រ៉ក ខ្សែអំបោះ និងទឹក។

## ៤. វិធីសាស្ត្របង្រៀន ៈ

÷ គោលវិធីស្វែម

÷ វិធីសាស្ត្របែបរិះរក (IBL)

## ៥. ដំណើតនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| **ជំហានទី១ៈ រដ្ឋបាលថ្នាក់** | | |

| | | |
|---|---|---|
| ពិនិត្យវត្តមានសិស្ស<br>អនាម័យថ្នាក់ វិន័យ | | អង្គុយស្ងៀមស្ងាត់ តាម<br>កន្លែងរៀងៗខ្លួន |
| **ជំហានទី២៖ រំលឹកមេរៀន** | | |
| -ដូចម្តេចដែលហៅថា<br>កម្លាំង?<br><br>-តើអ្វីជាកម្លាំងពីចម្ងាយ?<br><br>-តើអ្វីជាកម្លាំងប៉ះ? | -កម្លាំងជាបុព្វហេតុធ្វើឱ្យអង្គធាតុផ្លាស់ទី ឈប់ ឬប្តូរទិសដៅចលនា<br><br>-កម្លាំងពីចម្ងាយជាកម្លាំងដែលមានអំពើលើអង្គធាតុពីចម្ងាយដោយមិនប៉ះអង្គធាតុ<br><br>-កម្លាំងប៉ះជាកម្លាំងដែលមានអំពើលើអង្គធាតុដោយប៉ះផ្ទាល់(ឬប៉ះដោយប្រយោល) នឹងអង្គធាតុ | -កម្លាំងជាបុព្វហេតុធ្វើឱ្យអង្គធាតុផ្លាស់ទី ឈប់ ឬប្តូរទិសដៅចលនា<br><br>-កម្លាំងពីចម្ងាយជាកម្លាំងដែលមានអំពើលើអង្គធាតុពីចម្ងាយដោយមិនប៉ះអង្គធាតុ<br><br>-កម្លាំងប៉ះជាកម្លាំងដែលមានអំពើលើអង្គធាតុដោយប៉ះផ្ទាល់(ឬប៉ះដោយប្រយោល) នឹងអង្គធាតុ |
| **ជំហានទី៣៖ មេរៀនថ្មី** | | |
| **១. បន្ទាញបាតុភូត**<br><br>**គ្រូបន្ទាញបាតុភូតទី១៖**<br><br>-ដាក់កូនរទេះ(កូនឡានជ័រ) លើតុ<br><br>-តើយើងធ្វើដូចម្តេច ដើម្បីឱ្យរទេះនេះផ្លាស់ទីបាន?<br><br>-បើកូនរទេះកំពុងផ្លាស់ទី តើយើងធ្វើដូចម្តេច ដើម្បីបញ្ឈប់វាបាន? | **កំលាំងកកិត**<br><br>*GCED-Real world phenomena connection-1*<br><br> | -ទាញ ឬរុញ<br><br>-ទាញ ឬទប់ ឬចាប់ ដោយកម្លាំង (មានទិសដៅផ្ទុយពីចលនា)<br><br>-ទិសដៅផ្ទុយពីបំលាស់ទី |

| | | |
|---|---|---|
| –តើកម្លាំងនោះមានទិសដៅដូចម្ដេច?<br>**–អ្នកកំពុងជិះកង់ដោយល្បឿនណាមួយ បន្ទាប់មកជើងរបស់អ្នកឈប់ធ្វើចលនា (ឈប់ធាក់) ហើយមិនចាប់ប្រាំងទេ។ មួយរយៈពេលក្រោយមក តើមានអ្វីកើតឡើងចំពោះអ្នក និងកង់? (បើសិស្សមិនយល់ គ្រូអាចសួរបន្ថែមថា តើវាឈប់ឬមានចលនា)**<br>**– តើហេតុអ្វីបានជាឈប់?**<br>–តើកម្លាំងកកិតនេះមានទិសដៅដូចម្ដេច? | <br>**រូបទី២**<br>កម្លាំងកកិតមានទិសដៅផ្ទុញពីទិសដៅបម្លាស់ទី ធ្វើឱ្យកង់របស់អ្នកឈប់។ | –កង់នឹងឈប់ដោយសាមានកកិត<br>–ដោយសាមានកកិត<br>–ទិសដៅផ្ទុយពីបំលាស់ទី |
| **គ្រូបង្ហាញបាតុភូតទី២៖**<br>–យកបន្ទះក្ដាដាក់លើតុរួច ដាក់កូនរទេះលើបន្ទះក្ដានោះ បន្ទាប់មកលើកចុងម្ខាងនៃបន្ទះក្ដាឡើង<br>–តើអ្នកសង្កេតឃើញដូចម្ដេច? | *GCED-Real world phenomena connection-2*<br> | –សង្កេត<br>–រទេះផ្លាស់ទី<br>–ទម្ងន់របស់វា |

| | | |
|---|---|---|
| –តើកម្លាំងអ្វីដែលធ្វើឱ្យ រទេះផ្លាស់ទី ? | | |
| –ក្នុងករណីនេះរទេះមានកកិត ឬអត់ ? | | –មាន |
| –ដាក់ដុំគូបលោហៈមួយ លើប្លង់ទេនោះ |  | –សង្កេត |
| –តើដុំគូបផ្លាស់ទីឬទេ ? ហេតុអ្វី ? | | –ទេ។ វានៅស្ងៀមដោយកម្លាំងកកិត។ |
| –ដាក់ពីរដុំទៀតដែលមានទំហំខុសគ្នាលើបន្ទះក្តាដដែលនោះ រួចលើកចុងម្ខាងបន្ថែមបន្តិចម្តងៗ រហូតវត្ថុណាមួយចាប់ផ្តើមផ្លាស់ទី |  | |
| –តើអ្នកសង្កេតឃើញដូចម្តេចចំពោះដុំលោហៈទាំងបី ? ហេតុអ្វី ? | កម្លាំងកកិតទប់អង្គធាតុទាំងបីមិនឱ្យផ្លាស់ទី។ | |
| –តើកម្លាំងកកិតនៃដុំគូបទាំងបីដូចគ្នាដែរឬទេ ? | | –ខ្លះផ្លាស់ទី ខ្លះនៅស្ងៀមដដែល។ ព្រោះកកិត។ |
| –លើបន្ទះក្តាបន្តិចម្តងៗរហូតដល់ដុំគូបរអិលធ្លាក់ម្តងមួយៗ | | –ដូចគ្នា<br>–មិនដូចគ្នា |

| | | |
|---|---|---|
| -ហេតុអ្វីចាំបាច់រអិលនៅពេលផ្សេងគ្នា?<br>-ហេតុអ្វីបានយល់ថាខុសគ្នា? | -កម្លាំងកកិតនៃអង្គធាតុនីមួយៗមិនដូចគ្នាទេ។ | -ដុំគូបទាំងបីមានកម្លាំងកកិតខុសៗគ្នា។<br>-ម៉ាស ផ្ទៃ ទំហំ......ខុសគ្នា |
| **២. សំណួរគន្លឹះ៖**<br>តើកត្តាអ្វីខ្លះមានឥទ្ធិពលលើកម្លាំងកកិត? | | |
| **៣. សមត្ថិកម្ម៖**<br>-ឱ្យសិស្សពិភាក្សាតាមក្រុមដើម្បីឆ្លើយសំណួរគន្លឹះ<br>-តើកម្លាំងកកិតអាស្រ័យនឹងកត្តាអ្វីខ្លះ?<br>ឲ្យសិស្សសរសេរចម្លើយស្មានទុកក្នុងសន្លឹកកិច្ចការ | | ក. ម៉ាស(ទម្ងន់)៖ ម៉ាសកើនកម្លាំងកកិតកើន<br>ខ. ភាពគ្រើមនៃផ្ទៃ៖ ផ្ទៃកាន់តែគ្រើមកម្លាំងកកិតកាន់តែធំ<br>គ. ទំហំផ្ទៃ៖ ផ្ទៃកាន់តែធំកម្លាំងកកិតកាន់តែធំ |
| **៤. សកម្មភាព**<br>**-ដឹកនាំសិស្សពិភាក្សាតាមក្រុមដើម្បីបង្កើតប្លង់ពិសោធន៍**<br>**-ក្រុមនីមួយៗបង្ហាញពីប្លង់ពិសោធន៍ដែលគេបានពិភាក្សា**<br>-គ្រូជ្រើសរើសប្លង់ពិសោធន៍ណាមួយដែលល្អជាងគេ<br>-គ្រូណែនាំពីដំណើរការពិសោធន៍ | *GCED-Capacitation and connection students*<br>**ប្លង់ពិសោធន៍** | -ពិភាក្សាតាមក្រុម |

-ប្រគល់សម្ភារៈពិសោធន៍ និងសន្លឹកកិច្ចការ( គូបលោហៈពីរដុំ ឈើ១ បន្ទះក្តាឬប្លង់រាប១ ចំរៀកក្រណាត់៣ ស្កុតមុខពីរ ជញ្ជីង១ កែវប្លាស្ទិច១ រ៉ក១ ខ្សែអំបោះ និងទឹក)

**ពិសោធន៍ទី១៖**

១. យកស្កុតមុខពីរបិទលើដុំឈើលើផ្ទៃ $A_1$ រួចយកក្រណាត់ $C_1$ មកបិទភ្ជាប់ $A_1$ ។ដាក់ផ្ទៃដែលបានបិទក្រណាត់លើផ្ទៃរាប រួចភ្ជាប់ទៅនឹងកែងទឹកដោយខ្សែអំបោះដោយឆ្លងកាត់រ៉កដូចរូបទី១។ គូសបន្ទាត់ជុំវិញដុំឈើដើម្បីចំណាំកន្លែងដែលបានដាក់ដុំឈើដើម្បីសម្គាល់ទីតាំង។

២. ឱ្យសិស្សម្នាក់កាន់រ៉កយ៉ាងណាឱ្យស្ថិតទិសដេកស្មើ។ សិស្សម្នាក់ទៀតចាក់ទឹកចូលក្នុងកែវបន្តិចម្តងៗ រហូតដុំឈើចាប់ផ្តើមផ្លាស់ទី។ នៅពេលដុំឈើចាប់ផ្តើមផ្លាស់ទីឈប់ចាក់ទឹក រួចយកកែវដែលមានទឹកទៅថ្លឹង។ ធ្វើដូចនេះបីដង ទៀត។ រួចគណនាតម្លៃមធ្យម







-ទទួលសម្ភារៈ និងសន្លឹក កិច្ចការ

-អានសន្លឹកកិច្ចការដើម្បីធ្វើពិសោធន៍ទី១។

| $A_1$ | ម៉ាស (kg) | | | |
|---|---|---|---|---|
| $M_1$ | 1 | 2 | 3 | មធ្យម |
| $C_1$ | | | | |
| $C_2$ | | | | |

កម្លាំងកកិត $f = w = mg$

$C_1$ : $f_1$=........

<table>
<tr>
<td>៣. ធ្វើលេខ១ឡើងវិញដោយប្តូរក្រណាត់ $C_1$ ទៅ $C_2$ វិញ។ បន្ទាប់ធ្វើលេខ២<br><br>ពិសោធន៍ទី២៖<br>ធ្វើដូចលេខ១ ក្នុងពិសោធ ទី១ដោយបន្ថែមម៉ាសទៅលើដុំឈើដូចរូបទី២ រួចធ្វើដូចលេខ២។<br><br>ពិសោធន៍ទី៣៖<br>ធ្វើដូចលេខ១ ក្នុងពិសោធ ទី១ដោយប្តូរ $A_1$ ទៅ $A_2$ និង $A_3$ ដូចរូបទី៣។ រួចធ្វើដូចលេខ២</td>
<td><br><br>**រូបទី១**</td>
<td>$C_2$ : $f_2$=………<br><br>–ប្តូរក្រណាត់ធ្វើឱ្យតម្លៃកម្លាំងកកិតប្រែប្រួល<br><br><table><tr><td>$A_1$</td><td colspan="4">ម៉ាស (kg)</td></tr><tr><td>$C_1$</td><td>1</td><td>2</td><td>3</td><td>មធ្យម</td></tr><tr><td>$M_1$</td><td></td><td></td><td></td><td></td></tr><tr><td>$M_2$</td><td></td><td></td><td></td><td></td></tr></table></td>
</tr>
</table>




រូបទី២

| | | | | |
|---|---|---|---|---|
| M3 | | | | |

កម្លាំងកកិត f=mg

$M_1$ : $f_1$ =……

$M_2$ : $f_2$ =……

$M_3$ : $f_3$ =……

ម៉ាសកាន់តែធំ កម្លាំងកកិតកាន់តែធំ។




រូបទី៣

| M1 | ម៉ាស (kg) | | | |
|---|---|---|---|---|
| C1 | 1 | 2 | 3 | មធ្យម |
| A1 | | | | |
| A2 | | | | |
| A3 | | | | |

កម្លាំងកកិត f=mg

$A_1$ : $f_1$ =……

$A_2$ : $f_2$ =……

$A_3$ : $f_3$ =……

– ផ្ទៃប្រែប្រួល កម្លាំងកកិតមិនប្រែប្រួល

## ៩. វិភាគទិន្នន័យ និង សន្និដ្ឋាន

ពិសោធន៍ទី១៖

| | កម្លាំងកកិត (N) |
|---|---|

<table>
<tr>
<td>
– គូសតារាងលទ្ធផលដាក់លើក្ដាខៀន សម្រាប់ក្រុមនីមួយៗ<br><br>
– តាមរយៈលទ្ធផលពិសោធន៍ អ្នកអាចឆ្លើយសំណួរគន្លឹះបានទេ ?
</td>
<td>
<table>
<tr><td>ក្រណាត់</td><td>ក្រុម១</td><td>ក្រុម២</td><td>ក្រុម៣</td></tr>
<tr><td>$C_1$</td><td></td><td></td><td></td></tr>
<tr><td>$C_2$</td><td></td><td></td><td></td></tr>
<tr><td>$C_3$</td><td></td><td></td><td></td></tr>
</table>
ក្រណាត់ខុសគ្នា ភាពគ្រើមខុសគ្នា កម្លាំងកកិតខុសគ្នា។ ផ្ទៃកាន់តែគ្រើមកកិតកាត់តែធំ។<br><br>
ពិសោធន៍ទី២៖
<table>
<tr><td></td><td colspan="3">កម្លាំងកកិត(N)</td></tr>
<tr><td>ម៉ាស</td><td>ក្រុម១</td><td>ក្រុម២</td><td>ក្រុម៣</td></tr>
<tr><td>$M_1$</td><td></td><td></td><td></td></tr>
<tr><td>$M_2$</td><td></td><td></td><td></td></tr>
<tr><td>$M_3$</td><td></td><td></td><td></td></tr>
</table>
ម៉ាសកាន់តែធំ កម្លាំងកកិតកាន់តែធំ។<br><br>
ពិសោធន៍ទី៣៖
<table>
<tr><td></td><td colspan="3">កម្លាំងកកិត(N)</td></tr>
<tr><td>ផ្ទៃ</td><td>ក្រុម១</td><td>ក្រុម២</td><td>ក្រុម៣</td></tr>
<tr><td>$A_1$</td><td></td><td></td><td></td></tr>
<tr><td>$A_2$</td><td></td><td></td><td></td></tr>
<tr><td>$A_3$</td><td></td><td></td><td></td></tr>
</table>
ផ្ទៃប្រែប្រួល កម្លាំងកកិតមិនប្រែប្រួលទេ។
</td>
<td>
–តំណាងក្រុមនីមួយៗសរសេរលទ្ធផលពិសោធន៍ដាក់ក្នុងតារាង<br><br>
–ភាពគ្រើមរបស់ផ្ទៃនៃអង្គធាតុមានឥទ្ធិពលលើកម្លាំងកកិត។ ផ្ទៃកាន់តែគ្រើម កម្លាំងកកិតកាន់តែធំ។<br><br>
–ម៉ាសក៏មានឥទ្ធិពលលើកម្លាំងកកិតដែរ។ ម៉ាសកាន់តែធំ កម្លាំងកកកិតកាន់តែធំ។<br><br>
–ទំហំផ្ទៃរបស់អង្គធាតុ គ្មានឥទ្ធិពលលើកម្លាំងកកិតទេ។
</td>
</tr>
</table>

| | | |
|---|---|---|
| សន្និដ្ឋាន<br>-ជំរុញឱ្យសិស្សធ្វើសេចក្ដីសន្និដ្ឋានដោយខ្លួនឯង<br><br>-ផ្អែកលើសេចក្ដីសន្និដ្ឋានរបស់ប្អូនខាងលើ បើប្អូនប្រើយានយន្តលើផ្លូវរអិល តើប្អូនប្រើប្រភេទក្រលាកង់យានយន្តដូចម្ដេច(ក្រលាតូច ក្រលាធំ) | កត្តាដែលមានឥទ្ធិពលលើកម្លាំងកកិតមាន ម៉ាស និងភាពគ្រើមរបស់ផ្ទៃនៃអង្គធាតុ | -កត្តាដែលមានឥទ្ធិពលលើកម្លាំងកកិតមាន ម៉ាស និងភាពគ្រើមនៃផ្ទៃរបស់អង្គធាតុ។ |
| **ជំហានទី៤៖ ពង្រឹងពុទ្ធិ** | | |
| -ហេតុអ្វីបានជាគេប្រើប្រេងម៉ាស៊ីនក្នុងយានយន្ត និងគ្រប់ម៉ាស៊ីន។<br>(បើសិស្សឆ្លើយមិនចំ គ្រូសម្របសម្រួល ឱ្យសិស្សឆ្លើយសំដៅទៅលើ ESD) | -កកិតអាចធ្វើឱ្យសឹករិចរិលដែលបណ្ដាលឱ្យខាតបង់ថវិការ និងបង្កើតកម្ដៅដែលជាផ្នែកមួយធ្វើឱ្យកំណើន កម្ដៅក្នុងបរិយាកាស។ ហើយកំណើតកម្ដៅនេះវាផ្តល់ផលអវិជ្ជមានជាច្រើនដល់ការរស់នៅរបស់មនុស្សលើភពផែនដី។ | -ឱ្យរអិល<br>-កាត់បន្ថយកកិត<br>ព្រោះ<br>(សេដ្ឋកិច្ច)ប្រេងម៉ាស៊ីនមានភាពរអិលដែលកាត់បន្ថយការសឹករិចរិលចំណេញថវិការ<br>(បរិស្ថាន)កាត់បន្ថយការបញ្ចេញកម្ដៅទៅក្នុងបរិយាកាស<br>(សង្គម) ធ្វើឱ្យមនុស្សរស់នៅបានស្រួល។ |

| | | |
|---|---|---|
| -តើយានជំនិះគ្រប់ប្រភេទអាចផ្លាស់ទីបានដោយសារអ្វី?<br>-បើកង់មិនប៉ះដី ឬផ្លូវទេ តើវាអាចទៅមុខបានដែរឬទេ?<br>-បើអញ្ចឹងមានប្អូនណាអាចនិយាយបានយ៉ាងម៉ិច<br>-នៅពេលកំពុងបើកបរ ប្រសិនបើមានឧបសគ្គ តើអ្នកបញ្ជាយានយន្ត ត្រូវធ្វើដូចម្តេច?<br>-ករណីប្រាំងមិនស៊ី តើនឹងមានអ្វីកើតឡើង?<br>-តើអ្នកត្រូវធ្វើដូចម្តេច ដើម្បីជៀសវៀងឧបទ្ទហេតុនេះ?<br>-តើគ្រោះថ្នាក់ចរាចរណ៍ធ្វើឱ្យប៉ះពាល់អ្វីខ្លះដល់សង្គម សេដ្ឋកិច្ច ក៏ដូចជាបរិស្ថាន? | | -កង់រិល ម៉ាស៊ីន(ម៉ូតូ ឡាន ...) កកិត<br>-អត់ទេ (អត់កកិត)<br>-កកិតអាចធ្វើឱ្យអង្គធាតុផ្លាស់ទី<br>-ជាន់ប្រាំងឱ្យឈប់<br>-បង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍<br>-ពិនិត្យប្រព័ន្ធប្រាំង មុនចេញដំណើរ សំបកកង់<br>-គ្រោះថ្នាក់ចរាចរណ៍ធ្វើឱ្យ<br>(សង្គម) មនុស្សមានរបួស បាក់ដៃជើង ពិការ ឬរហូតដល់បាត់បង់ជីវិតក៏មាន។<br>កកស្ទះចរាចរណ៍លើដងផ្លូវប៉ះពាល់ការធ្វើដំណើររបស់អ្នកដ៏ទៃ។ |

| | | |
|---|---|---|
| | | (សេដ្ឋកិច្ច) ខាតបង់ពេលវេលាទទួលទាន និងថវិការដើម្បីព្យាបាល ក៏ដូចជាជួសជុលយានយន្ត និងសម្បត្តិសាធារណៈ<br>(បរិស្ថាន) បង្កើននូវកាកសំណល់រឹងលើផែនដី<br>(វប្បធម៌)<br>បណ្ដុះវប្បធម៌សន្តិភាពចរាចរណ៍ ដោយមានបម្រុងប្រយ័ត្នពេលបើកបរ គោរពច្បាប់ចរាចរណ៍ ត្រួតពិនិត្យប្រព័ន្ធសុវត្ថភាព មិនបើកបរពិសេសប្រព័ន្ធប្រាំង និងកង់។ |
| **ជំហានទី៥៖ បណ្ដាំផ្ញើ** | | |
| -ទៅផ្ទះពិសោធន៍លើក្ដាផ្សេងៗទៀត<br>-មិនពេលធ្វើដំណើរត្រួតពិនិត្យប្រព័ន្ធប្រាំងរបស់យានយន្តដើម្បីសុវត្ថភាព | | -ស្ដាប់ និងកត់ត្រា |

## សន្លឹកកិច្ចការ

**សំណួរគន្លឹះ៖** តើកត្តាអ្វីខ្លះដែលមានឥទ្ធិពលលើកម្លាំងកកិត?

**សមត្ថិភាព្ទះ**

..................................................................................................................

..................................................................................................................

..................................................................................................................

$A_1$ $A_2$ ផ្ទៃ  $C_1$ $C_2$ ក្រណាត់  និង  $M_1$  $M_2$ ម៉ាស

**ពិសោធន៍ទី១៖** ប្រើ $A_1$ និង $M_1$




១. យកស្កុតមុខពីរបិទលើដុំឈើលើផ្ទៃ $A_1$ រួចយកក្រណាត់ $C_1$ មកបិទភ្ជាប់ $A_1$ ។ដាក់ផ្ទៃដែលបានបិទក្រណាត់លើផ្ទៃរាប រួចភ្ជាប់ទៅនឹងកែងទឹកដោយខ្សែអំបោះដោយឆ្លងកាត់រ៉កដូចរូបទី១។គូសបន្ទាត់ជុំវិញដុំឈើដើម្បីចំណាំកន្លែងដែលបានដាក់ដុំឈើដើម្បីសម្គាល់ទីតាំង។

២. ឱ្យសិស្សម្នាក់កាន់រ៉កយ៉ាងណាឱ្យស្ថិតទិសដេកស្មើ។ សិស្សម្នាក់ទៀតចាក់ទឹកចូលក្នុងកែវបន្តិចម្តងៗ ហូតដុំឈើចាប់ផ្តើមផ្លាស់ទី។ នៅពេលដុំឈើចាប់ផ្តើមផ្លាស់ទីឈប់ចាក់ទឹក រួចយកកែវដែលមានទឹកទៅថ្លឹង។ ធ្វើដូចនេះបីដង ទៀត។ រួចគណនាតម្លៃមធ្យម និងគណនាតម្លៃកម្លាំងកកិត $f=w=mg$

៣. ធ្វើលេខ១ឡើងវិញដោយប្តូរក្រណាត់ $C_1$ ទៅ $C_2$ វិញ។ បន្ទាប់ធ្វើលេខ២ឡើងវិញ

| $A_1$ $M_1$ | ម៉ាសកែវមានទឹក(kg) | | | | កម្លាំង(N) |
|---|---|---|---|---|---|
| | 1 | 2 | 3 | មធ្យម | |
| $C_1$ | | | | | |
| $C_2$ | | | | | |
| $C_3$ | | | | | |

## អ្វីដែលរកឃើញពីពិសោធន៍

.................................

**ពិសោធន៍ទី២៖ ប្រើ $A_1$ និង $C_1$**

ធ្វើដូចលេខ១ ក្នុងពិសោធ ទី១ដោយបន្ថែមម៉ាសទៅលើដុំឈើដូចរូបទី២ រួចធ្វើដូចលេខ២។




| $A_1$ $C_1$ | ម៉ាសកែវមានទឹក(kg) | | | | កម្លាំង(N) |
|---|---|---|---|---|---|
| | 1 | 2 | 3 | មធ្យម | |
| $M_1$ | | | | | |
| $M_2$ | | | | | |
| $M_3$ | | | | | |

## ពិសោធន៍ទី២៖ ប្រើ $M_1$ និង $C_1$

ធ្វើដូចលេខ១ ក្នុងពិសោធ ទី១ដោយប្តូរ $A_1$ ទៅ $A_2$ និង $A_3$ ដូចរូបទី ៣។ រួចធ្វើដូចលេខ២




| $A_1$ $M_1$ | ម៉ាសកែវមានទឹក(kg) | | | | កម្លាំង(N) |
|---|---|---|---|---|---|
| | 1 | 2 | 3 | មធ្យម | |
| $A_1$ | | | | | |
| $A_2$ | | | | | |
| $A_3$ | | | | | |

## អ្វីដែលរកឃើញពីពិសោធន៍

.........................................

**សន្និដ្ឋាន៖**

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៦៦៦៨ អយក.ទីក

# លិខិតឧទ្ទេសនាម

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**យោង៖** - សេចក្តីសម្រេចលេខ០៥ អយក.សសរ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការតែងតាំងសមាសភាព គណៈកម្មការបច្ចេកទេស និងលេខាធិការដ្ឋាននៃមជ្ឈមណ្ឌលសហប្រតិបត្តិការនៃការអប់រំភាពជាពលរដ្ឋសកល (ម.ស.អ.ស)។

- កិច្ចព្រមព្រៀងសហប្រតិបត្តិការ (Cooperation Agreement) សម្រាប់អនុវត្តគម្រោងសហប្រតិបត្តិការនៃការអប់រំភាពជាពលរដ្ឋសកលឆ្នាំ២០២៣។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងឱ្យចូលរួមវគ្គសិក្ខាសាលាស្តីពី "ការអប់រំភាពជាពលរដ្ឋសកលសម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន" ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី០៦ ដល់ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២៣ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម ខេត្តកំពង់ចាម៖

### I. គណៈកម្មការគ្រប់គ្រងទូទៅ

| | |
|---|---|
| ១. ឯកឧត្តម **ពុត សាមិត្ត** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ២. ឯកឧត្តម **អ៊ុង ជិនណា** | អគ្គនាយក នៃអគ្គនាយកដ្ឋានអប់រំ |
| ៣. ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** | នាយកវិទ្យាស្ថានជាតិអប់រំ |

### II. គ្រូឧទ្ទេស

| | |
|---|---|
| ១. លោក **ឌី បុណ្ណា** | នាយករង វិទ្យាស្ថានជាតិអប់រំ |
| ២. លោកបណ្ឌិត **នូវ វីរ៉ា** | នាយករង វិទ្យាស្ថានជាតិអប់រំ |
| ៣. លោកស្រី **ប៊ុន សុផានី** | នាយិការង វិទ្យាស្ថានជាតិអប់រំ |
| ៤. លោក **ថៃ ហេង** | នាយករង វិទ្យាស្ថានជាតិអប់រំ |
| ៥. លោក **ម៉ៅ សារឿន** | ប្រធានដេប៉ាតឺម៉ង់ វិទ្យាស្ថានជាតិអប់រំ |
| ៦. លោក **ម៉ន មុនិន្ទ** | ប្រធានដេប៉ាតឺម៉ង់ វិទ្យាស្ថានជាតិអប់រំ |
| ៧. លោកបណ្ឌិត **ម៉ម ចាន់សៀន** | អនុប្រធានដេប៉ាតឺម៉ង់ វិទ្យាស្ថានជាតិអប់រំ |
| ៨. លោក **ចាប រតនា** | អនុប្រធានដេប៉ាតឺម៉ង់ វិទ្យាស្ថានជាតិអប់រំ |
| ៩. លោក **ប៉ូ ប៊ុន្នួន** | អនុប្រធានការិយាល័យ វិទ្យាស្ថានជាតិអប់រំ |
| ១០. លោកស្រី **នូ ចន្ទី** | គ្រូឧទ្ទេស វិទ្យាស្ថានជាតិអប់រំ |
| ១១. លោក **ឡុច ចាន់ថន** | គ្រូឧទ្ទេស វិទ្យាស្ថានជាតិអប់រំ |

១២. លោក ប្រាក់ ពៅ | គ្រូឧទ្ទេស វិទ្យាស្ថានជាតិអប់រំ
១៣. លោក ចាន់ វ៉ាដា | មន្ត្រីការិយាល័យ វិទ្យាស្ថានជាតិអប់រំ
១៤. លោកបណ្ឌិត អ៊ុំ ចាន់ចំណាន | គ្រូឧទ្ទេស វិទ្យាស្ថានជាតិអប់រំ

II. អ្នកចូលរួម

១. លោក ងួន លក្ខណា | ប្រធានលេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋានអប់រំ
២. លោក ឡេង បូរី | ប្រធានការិយាល័យ វិទ្យាស្ថានជាតិអប់រំ
៣. លោក លុយ អោក | ប្រធានការិយាល័យ វិទ្យាស្ថានជាតិអប់រំ
៤. លោកស្រី ហង់ ស្រីម៉ាច | ប្រធានការិយល័យ វិទ្យាស្ថានជាតិអប់រំ
៥. លោកបណ្ឌិត នី វង្ឍា | ប្រធានការិយាល័យ វិទ្យាស្ថានជាតិអប់រំ
៦. លោកស្រី ស៊ាំង សុចិន្តា | ប្រធានការិយាល័យ វិទ្យាស្ថានជាតិអប់រំ
៧. លោក ចេង ថុន | អនុប្រធានដេប៉ាតឺម៉ង់ វិទ្យាស្ថានជាតិអប់រំ
៨. លោក ឡាច ប៊ុនហ៊ាន | គ្រូឧទ្ទេសមុខវិជ្ជាចិត្តគរុកោសល្យ វ.ជ.អ
៩. លោកបណ្ឌិត គួយ សូគាន | គ្រូឧទ្ទេសមុខវិជ្ជាអក្សរសាស្ត្រ វ.ជ.អ
១០. លោកស្រី ជា កល្យាណ | គ្រូឧទ្ទេសមុខវិជ្ជាប្រវត្តិវិទ្យា វ.ជ.អ
១១. លោក ទី សុផល | គ្រូឧទ្ទេសមុខវិជ្ជាប្រវត្តិវិទ្យា វ.ជ.អ
១២. លោកស្រី ពន់ ជា | គ្រូឧទ្ទេសមុខវិជ្ជាភូមិវិទ្យា វ.ជ.អ
១៣. លោក ផ្លុង តូន | គ្រូឧទ្ទេសមុខវិជ្ជាសីលធម៌ពលរដ្ឋ វ.ជ.អ
១៤. លោកស្រី រុយ សុកលក្ខិណា | គ្រូឧទ្ទេសមុខវិជ្ជាសេដ្ឋកិច្ច វ.ជ.អ
១៥. លោក ស៊ឹម វិសុទ្ធ | គ្រូឧទ្ទេសមុខវិជ្ជាគណិតវិទ្យា វ.ជ.អ
១៦. លោក ទឹម វ៉ត្ត | គ្រូឧទ្ទេសមុខវិជ្ជាអេឡិចត្រូនិច និងអគ្គិសនី វ.ជ.អ
១៧. លោក សយ សីលា | គ្រូឧទ្ទេសមុខវិជ្ជាមេកានិច វ.ជ.អ
១៨.លោក ស្រ៊ន់ តៃស្រ៊ីម | គ្រូឧទ្ទេសមុខវិជ្ជារូបវិទ្យា វ.ជ.អ
១៩. លោក ប៉ែន សំភា | គ្រូឧទ្ទេសមុខវិជ្ជាគីមីវិទ្យា វ.ជ.អ
២០. លោក ផែន សារិត | គ្រូឧទ្ទេសមុខវិជ្ជាជីវវិទ្យា វ.ជ.អ
២១. លោក នី សុពុទ្ធី | គ្រូឧទ្ទេសមុខវិជ្ជាផែនដីវិទ្យា វ.ជ.អ
២២. លោកស្រី សេង សច្ចា | គ្រូឧទ្ទេសមុខវិជ្ជាភាសាអង់គ្លេស វ.ជ.អ
២៣. លោកស្រី ងួន ច័ន្ទលក្ខិណា | គ្រូឧទ្ទេសមុខវិជ្ជាភាសាបារាំង វ.ជ.អ
២៤. លោកស្រី វ៉ា ចំណាន | គ្រូឧទ្ទេសមុខវិជ្ជាសិល្បៈ វ.ជ.អ
២៥. លោក យ៉ាង ប៉េងលី | គ្រូឧទ្ទេសមុខវិជ្ជាព័ត៌មានវិទ្យា វ.ជ.អ
២៦. លោក សោម សង្ហុក | គ្រូឧទ្ទេសមុខវិជ្ជាកេ្បតសាស្ត្រ វ.ជ.អ
២៧. កញ្ញា ភឿក សុខនី | គ្រូឧទ្ទេសមុខវិជ្ជាកែច្នៃអាហារ វ.ជ.អ
២៨. លោក ចាន់ ធឿន | មន្ត្រីដេប៉ាតឺម៉ង់ វ.ជ.អ
២៩. លោកបណ្ឌិត សាំង មាសសួន | ព្រឹទ្ធបុរសរង វិទ្យាស្ថានគរុកោសល្យ ភ.ព
៣០. លោក សោភ័ណ សុភ័ក្រ | ព្រឹទ្ធបុរសរង វិទ្យាស្ថានគរុកោសល្យ ភ.ព

| | |
|---|---|
| ៣១. លោក **ហុង សុវណ្ណ** | ប្រធានដេប៉ាតឺម៉ង់ វិទ្យាស្ថានគរុកោសល្យ ភ.ព |
| ៣២. លោកស្រី **ធុំ តន្នី** | អនុប្រធានដេប៉ាតឺម៉ង់ វិទ្យាស្ថានគរុកោសល្យ ភ.ព |
| ៣៣. លោក **សឿ វណ្ណា** | អនុប្រធានដេប៉ាតឺម៉ង់ វិទ្យាស្ថានគរុកោសល្យ ភ.ព |
| ៣៤. លោកស្រី **ផេង ចុននី** | អនុប្រធានដេប៉ាតឺម៉ង់ វិទ្យាស្ថានគរុកោសល្យ ភ.ព |
| ៣៥. លោក **គង់ វលក្ខណ៍** | អនុប្រធានដេប៉ាតឺម៉ង់ វិទ្យាស្ថានគរុកោសល្យ ភ.ព |
| ៣៦. លោកស្រី **ឆាយ បូនី** | អនុប្រធានដេប៉ាតឺម៉ង់ វិទ្យាស្ថានគរុកោសល្យ ភ.ព |
| ៣៧. លោក **អ៊ូ ម៉ារិន** | គ្រូឧទ្ទេស វិទ្យាស្ថានគរុកោសល្យ ភ.ព |
| ៣៨. លោក **ធី សោភ័ណ្ឌ** | គ្រូឧទ្ទេស វិទ្យាស្ថានគរុកោសល្យ ភ.ព |
| ៣៩. លោក **ឈិត លៀងអៀង** | នាយករង វិទ្យាស្ថានគរុកោសល្យ ប.ប |
| ៤០. លោក **ហ៊ិត ស៊ីនួន** | នាយករង វិទ្យាស្ថានគរុកោសល្យ ប.ប |
| ៤១. លោក **ហោ ស៊ីណា** | ព្រឹទ្ធបុរសរង វិទ្យាស្ថានគរុកោសល្យ ប.ប |
| ៤២. លោក **ហ៊ុន រ៉ាវី** | ព្រឹទ្ធបុរសរង វិទ្យាស្ថានគរុកោសល្យ ប.ប |
| ៤៣. លោក **ថ្លាង សន្ត** | ព្រឹទ្ធបុរសរង វិទ្យាស្ថានគរុកោសល្យ ប.ប |
| ៤៤. លោកស្រី **ឡាំ ប៊ុនមករា** | ប្រធានដេប៉ាតឺម៉ង់ វិទ្យាស្ថានគរុកោសល្យ ប.ប |
| ៤៥. លោក **វ៉ែត សៀងហៃ** | អនុប្រធានដេប៉ាតឺម៉ង់ វិទ្យាស្ថានគរុកោសល្យ ប.ប |
| ៤៦. លោក **ខៀវ ចំរើន** | គ្រូឧទ្ទេស វិទ្យាស្ថានគរុកោសល្យ ប.ប |
| ៤៧. លោក **ហ៊ឹង ជីវយ៉ាន់** | គ្រូឧទ្ទេស វិទ្យាស្ថានគរុកោសល្យ ប.ប |
| ៤៨. លោក **សំអុល វិចិត្រ** | គ្រូឧទ្ទេស វិទ្យាស្ថានគរុកោសល្យ ប.ប |

- កាលបរិច្ឆេទចេញដំណើរ ៖ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៣
- កាលបរិច្ឆេទត្រឡប់មកវិញ ៖ ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២៣
- មធ្យោបាយធ្វើដំណើរ ៖ រថយន្តរដ្ឋ ១៦ ២-០៥៩៣ បើកបរដោយ លោក អុន ភិរុំ
  រថយន្តរដ្ឋ១៦ ២-០៦១៩ បើកបរដោយ លោក ឡុង រ៉ាវី
  រថយន្តរដ្ឋ ១៦ ២-០៦៤០ បើកបរដោយ លោក គក់ សំនៀង
  រថយន្តឈ្នួល

❖ រាល់ការចំណាយនៅក្នុងសិក្ខាសាលានេះ ប្រើប្រាស់ថវិកាព្រមព្រៀងប្រចាំឆ្នាំ២០២៣ របស់អង្គការ APCEIU។

ថ្ងៃ អង្គារ ៥កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០២៣

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**រដ្ឋលេខាធិការ**

**អ៊ុង_បូរាត**

**កន្លែងទទួល៖**

-រដ្ឋបាលខេត្តកំពង់ចាម
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
-មន្ទីរអេ.យ.ក ខេត្តកំពង់ចាម "ដើម្បីសហការ"
-សាមីជន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារ អគ្គនាយកដ្ឋានអប់រំ